អេស៊ីលីដា
ACLEDA BANK

របាយការណ៍ប្រចាំឆ្នាំ
២០២១

ACLEDA mobile

Available on the App Store
Google Play
EXPLORE IT ON AppGallery

ទស្សនៈ

ធនាគារ អេស៊ីលីដា ភីអិលស៊ី ជាធនាគារពាណិជ្ជនាំមុខក្នុងប្រទេសកម្ពុជា ក្នុងការផ្តល់សេវាកម្ម ហិរញ្ញវត្ថុល្អបំផុត ជូនដល់សាធារណជនគ្រប់មជ្ឈដ្ឋានក្នុងសហគមន៍ ។

បេសកកម្ម

បេសកកម្មរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី គឺផ្តល់ជូនសហគ្រិនខ្នាតតូចបំផុត ខ្នាតតូច ខ្នាតមធ្យម និងសាធារណជន នូវមធ្យោបាយក្នុងការគ្រប់គ្រង ចាត់ចែងធនធានហិរញ្ញវត្ថុឱ្យមានប្រសិទ្ធភាពខ្ពស់ ដើម្បីលើកស្ទួយជីវភាពរស់នៅឱ្យប្រសើរឡើង ដោយអនុវត្តឱ្យបាននូវនិរន្តរភាព និងបង្កើននូវអត្ថប្រយោជន៍ជូនដល់ភាគហ៊ុនិក កម្មករនិយោជិត ព្រមទាំងសហគមន៍ទាំងអស់ ។ យើងប្រកាន់ខ្ជាប់ជានិច្ចនូវគោលការណ៍សីលធម៌ វិជ្ជាជីវៈ សង្គម ច្បាប់ និងបរិស្ថាន ប្រកបដោយកម្រិតខ្ពស់បំផុត ។

គតិពេចន៍

ប្រជាធនាគារដែលលោកអ្នកជឿទុកចិត្ត ។

របាយការណ៍នេះរៀបចំ និងចេញផ្សាយដោយ ធនាគារ អេស៊ីលីដា ភីអិលស៊ី ។ សម្រាប់ព័ត៌មានបន្ថែម និងចម្ងល់ផ្សេងៗ សូមទាក់ទងមក ៖

ការិយាល័យកណ្តាល ៖

អគារលេខ៦១ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក
ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ។
ប្រអប់សំបុត្រលេខ ៖ ១១៨៩
ទូរស័ព្ទ ៖ ០២៣ ៩៩៨ ៧៧៧ / ៤៣០ ៩៩៩
ទូរសារ ៖ ០២៣ ៤៣០ ៥៥៥
អ៊ីម៉ែល ៖ acledabank@acledabank.com.kh
វេបសាយ ៖ www.acledabank.com.kh
SWIFT Code: ACLBKHPP

ការិយាល័យទំនាក់ទំនងអតិថិជន
(បម្រើ ២៤ម៉ោង ក្នុងមួយថ្ងៃ និង៧ថ្ងៃ ក្នុងមួយសប្តាហ៍) ៖

ទូរស័ព្ទ ៖ ០២៣ ៩៩៤ ៤៤៤, ០១៥ ៩៩៩ ២៣៣
អ៊ីម៉ែល ៖ inquiry@acledabank.com.kh

ទិន្នន័យហិរញ្ញវត្ថុសង្ខេប

ឯកតាគិតជាខ្នង់ពាន់ដុល្លារអាមេរិក	៣១/១២/២១ បានធ្វើសវនកម្ម	៣១/១២/២០ បានធ្វើសវនកម្ម	៣១/១២/១៩ បានធ្វើសវនកម្ម	៣១/១២/១៨ បានធ្វើសវនកម្ម	៣១/១២/១៧ បានធ្វើសវនកម្ម	បម្រែបម្រួល (%) [១]
ទិន្នន័យហិរញ្ញវត្ថុសង្ខេបរួម (ស.រ.ហ.អ.ក)						
ទ្រព្យសកម្ម	៧.៨៥៥.២៥២	៦.៥៥១.៨៩៨	៦.១៧៥.១៦២	៥.៦៨៣.៥៧៨	៥.២៨៧.០៩៨	១៩,៩០%
តណទាន និងបុរេប្រទាន (សុទ្ធ)	៥.៣៩៣.៩៥៨	៤.៨៧១.៣០១	៣.៨៨៦.០២១	៣.៥៩៤.៣៥៩	៣.១១៨.៥៧៧	២០,៦៨%
បំណុល	៦.៦៥០.២១៧	៥.៨៦១.៨៦៨	៥.២១០.៧០០	៤.៨៣០.៧៣៨	៤.៨៩៦.៨៧១	២១,៧៦%
ប្រាក់បញ្ញើ	៥.៧១៦.០២០	៥.៦១១.២៩៦	៤.៣៦៧.៨៩៨	៣.៨៦៤.៤៥៥	៣.៣៥៨.៩៦៨	២៣,៩៦%
ដើមទុន	៤៣៣.១៦៣	៤៣៣.១៦៣	៤២៨.៨១៨	៣៩៥.២២៨	៣៥៨.៥៤៥	០,០០%
មូលនិធិម្ចាស់ហ៊ុន [២]	១.១៩៩.០៤២	១.០៨៩.៦២៦	៩៦៨.៤៦២	៨៥២.៨៤០	៧៤៥.៦៦១	១០,០៤%
ចំណូលដុល	៦៣៦.៦៩៨	៥៧៩.២២១	៥៥០.១២៨	៥១០.៦៥៥	៤៩៣.៨៧៩	៩,៩២%
ប្រាក់ចំណេញមុនដកពន្ធ	២០៤.៧៥៣	១៨០.០៣៥	១៥៣.៥២៣	១៥០.៨៣២	១០៨.៩២៤	១៣,៧៣%
ប្រាក់ចំណេញសុទ្ធក្រោយដកពន្ធ	១៦៦.៦៧៨	១៤១.៤៩៣	១២០.៨៦០	១១៩.៣១៤	៨៦.៧៦៦	១៧,៨០%
ចំណេញក្នុងមួយភាគហ៊ុន	០,៣៩$	០,៣៣$	០,២៩$	០,៣០$	០,២៤$	១៨,១៨%
ភាគលាភ [៣]	០,១៣៨៩$	០,០៩៨១$	០,០៧៦៣$	០,១០៦៣$	០,១២៧៨$	៣៧,៥១%
ទិន្នន័យហិរញ្ញវត្ថុសង្ខេបដាច់ដោយឡែក (ស.រ.ហ.អ.ក)						
ទ្រព្យសកម្ម	៧.៦៩៥.១៦៣	៦.៣៧៩.៨៨៨	៦.០១៧.៣០៣	៥.៥៦៧.៥៩៥	៥.១២៣.៨២៨	២០,៦២%
តណទាន និងបុរេប្រទាន (សុទ្ធ)	៥.២៣២.០៥៩	៨.២៩២.៦៨៩	៣.៦៨៦.៥៧៩	៣.៨៥៩.៥៦៦	២.៩៧០.៩៦៧	២១,៨៨%
បំណុល	៦.៨៨៦.០៧១	៥.២៨៥.៨៥៨	៥.០៨៥.០២៥	៨.៧០៨.៦៨៩	៨.៣៧០.៦០៨	២២,៧២%
ប្រាក់បញ្ញើ	៥.៥៨២.៥៣៨	៨.៨៧៧.០៣៣	៨.២៥៦.៨២៨	៣.៧៨០.២៧៨	៣.២៧៧.៥៧៧	២៨,៦៩%
ដើមទុន [៤]	៤៣៣.១៦៣	៤៣៣.១៦៣	៤២៨.៨១៨	៣៩៥.២២៨	៣៥៨.៥៤៥	០,០០%
មូលនិធិម្ចាស់ហ៊ុន [៥]	១.២០៩.០៩២	១.០៩៨.០២៦	៩៧២.២៧៩	៨៦២.៩៨៦	៧៥២.៨២៨	១០,៥២%
ចំណូលដុល	៥៩៨.៦២៥	៥៣៧.៧៥៦	៥១៨.៩៣៣	៨៨២.៣១៧	៨៦២.៨៦៥	១០,៥៨%
ប្រាក់ចំណេញមុនដកពន្ធ	២០១.៦៦២	១៧២.១៥៨	១៨៨.២២៦	១៨៦.៥៦៥	៩៩.៧៨៨	១៧,១៨%
ប្រាក់ចំណេញសុទ្ធក្រោយដកពន្ធ	១៦២.០៨៥	១៣៨.៣៨២	១១៧.៨៨៧	១១៦.៩៩១	៧៩.៩២៨	១៧,១៦%

ចំណុចសំខាន់ៗក្នុងឆ្នាំ២០២១ (សម្ព័ន្ធធនាគារ)

- ទ្រព្យសកម្ម កើនឡើង ១៩,៩០% រហូតដល់ ៧.៨៥៥,២៥ លានដុល្លារអាមេរិក ។
- សមតុល្យតណទាន (សុទ្ធ) កើនឡើង ២០,៦៨% រហូតដល់ ៥.៣៩៣,៩៥ លានដុល្លារអាមេរិក ។
- តណទានមិនដំណើរការធៀបនឹងតណទានសរុប មានចំនួន ២,៣៣% ។
- សេរាបញ្ញើ-សន្សំ កើនឡើង ២៣,៩៦% រហូតដល់ ៥.៧១៦,០២ លានដុល្លារអាមេរិក ។
- មូលនិធិម្ចាស់ហ៊ុន កើនឡើង ១០,០៤% ពី ១.០៨៩,៦៣ លានដុល្លារអាមេរិក ដល់ ១.១៩៩,០៤ លានដុល្លារអាមេរិក ។
- ប្រាក់ចំណេញសុទ្ធក្រោយដកពន្ធ មានចំនួន ១៦៦,៦៧ លានដុល្លារអាមេរិក ។
- ផលលើមូលធន មានចំនួន ១៣,៩០% ។
- ធនាគារ អេស៊ីលីដា ភីអិលស៊ី មានបណ្តាញប្រតិបត្តិការចំនួន ៣១៩សាខា នៅក្នុងព្រះរាជាណាចក្រកម្ពុជា, សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ, និងសាធារណរដ្ឋសហភាពមីយ៉ាន់ម៉ា ។

---

១ បម្រែបម្រួលពី ឆ្នាំ២០២០ ដល់ ឆ្នាំ២០២១ ។

២ មិនគិតបញ្ចូលអប្បភាគភាគកម្ម និងបំណុលបន្ទាប់បន្សំ ។

៣ ការបែងចែកភាគលាភពីឆ្នាំ២០១៦ ដល់ឆ្នាំ២០១៨ ត្រូវបានបែងចែក ២០% ជាសាច់ប្រាក់ និង ៨០% ជាភាគហ៊ុន។ សម្រាប់ឆ្នាំ២០១៩ និង ឆ្នាំ២០២១ ភាគលាភ ១០០% ត្រូវបានបែងចែកជាសាច់ប្រាក់ ។

៤ ដើមទុនរបស់ អេស៊ីលីដា ហ្វាយណាន់ហ្សល់ ត្រាស់ និងអេ អេស អេ មានបង្ហាញដូចខាងក្រោម៖

បរិយាយ	២០២១	២០២០	២០១៩	២០១៨	២០១៧
ភាគហ៊ុន អេស៊ីលីដា ហ្វាយណាន់ហ្សល់ ត្រាស់ (%)	២៥,៧៣៩២%	២៥,៧៣៩២%	២៦,០០០០%	២៦,០០០០%	២៦,០០០០%
ចំនួនភាគហ៊ុន អេស៊ីលីដា ហ្វាយណាន់ហ្សល់ ត្រាស់	១១១.៤៩២.៧១៩	១១១.៤៩២.៧១៩	១១១.៤៩២.៧១៩	១០២.៧៥៨.២៦៧	៩៣.២២១.៦៨៩
ភាគហ៊ុនដែលបានធ្វើនិយ័តកម្ម ពី អេ អេស អេ (%)	២០,៧៤៩២%	២៤,៧៤៩២%	២៥,០០០០%	២៥,០០០០%	២៥,០០០០%
ចំនួនភាគហ៊ុនដែលបានធ្វើនិយ័តកម្ម ពី អេ អេស អេ	៨៩.៨៧៨.០២៦	១០៧.២០៤.៥៤៧	១០៧.២០៤.៥៤៧	៩៨.៨០៦.០៣៨	៨៩.៦៣៦.២៤៦

៥ មិនគិតបញ្ចូលបំណុលបន្ទាប់បន្សំ ។

ផលិតផល-សេវាកម្មនៅតាមបញ្ជូរ និងឌីជីថល

ប្រភេទប្រតិបត្តិការ	២០២១	២០២០	២០១៩	២០១៨	២០១៧
នៅតាមបញ្ជូរធនាគារ					
ចំនួនប្រតិបត្តិការ	៨.០៣៩.៥៧៩	៩.២៣០.៩៦៨	១០.៥៧៣.៨០០	១០.៧៣៩.៤២២	១១.៦៧៩.១០៧
ទំហំទឹកប្រាក់សរុប (លានរៀល)	៨៩.២០៩.៥០៩.៨៨៩	៨៥.៥៥៩.៧២៦.៥៥៩	៥០.៦១៨.៣៥៧.៦៩២	៨៦.៨៣៧.៣៥៦.១៨១	៨០.៧៩៨.៥១៧.២៦៧
សេវាកម្មឌីជីថល					
ចំនួនប្រតិបត្តិការ	១០២.១៣៩.៩០៨	៧៣.៩០៦.១៦០	៥០.៨៨៩.៥២៨	៣៣.៥៨២.០១៩	១៩.២៩៧.៣៨៧
ទំហំទឹកប្រាក់សរុប (លានរៀល)	៣៥.២៥៣.៥២៥.៨៨៨	២០.០៩៦.៨៨៧.៥០៧	១៣.០១៨.៥៣៣.៣៣៨	៥.៥៣០.៥៩៩.៩៧៧	៣.០៦៦.១១៨.១៥៨

របាយការណ៍បង់ពន្ធ

នៅក្នុងនាមជាធនាគារដែលមានតម្លាភាពមួយ យើងខ្ញុំសូមផ្សព្វផ្សាយជូនលោកអ្នកនូវរបាយការណ៍ពន្ធដែលបានបង់ ដូចមានបង្ហាញជូននៅក្នុងតារាងខាងក្រោម ៖

គិតជាដុល្លារអាមេរិក	២០១៧	២០១៨	២០១៩	២០២០	២០២១	សរុប*
ពន្ធប៉ាតង់	១៩. ៣០៩	២០.៩៣៦	១៩.១៣០	១៩.៥៧៦	១៨.៩៤២	២១០.០៦៥
ពន្ធលើស្លាកសញ្ញា	៣៦.៩៨៣	៥៧.៦៩៥	៦៨.០៩៦	៨៣.៥៦២	៤៩.៩៦៥	៨៤៩.៦១៦
ពន្ធលើមធ្យោបាយដឹកជញ្ជូន	៣៩.២៦៩	៣៧.២៤២	៣៣.៦៤៣	២០.៧៥៣	៤៣.១៣៤	៣៩៥.០៨៧
ពន្ធលើអចលនទ្រព្យ	២២.៩៦៤	២៣.០៩៤	៧.៦៧៣	៧.៦៣៦	៧.៦៨៣	១២៧.៤១០
អាករលើតម្លៃបន្ថែម	-	១.២៦៦	៥.៧៤៩	២២.១៨១	១៩៥.៥៧៤	២៣៣.០៦០
ប្រាក់រំលោះពន្ធលើប្រាក់ចំណេញ	៤.៦៨១.៧៣៣	៤.៦៨២.៤២៣	៥.១២២.៨៣៣	៥.២៩៨.១៩៩	-	៤២.២៦៨.៧៦៣
ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ	៣៥.១២០.៥៤៧	២២.៣៨០.៣៣០	១១.៩២៣.៤៦៤	២៨.៦៤៥.១៧១	២៦.៦៧៣.៦០០	២៣៥.៤៣៨.៩៤០
ពន្ធលើប្រាក់ហ៊ៀវត្សរ៍	៤.០៩២.៩៦៩	៩.៣៩៤.៦៥៥	៥.១៦៣.២១២	៦.៤៩៧.១៩៩	៧.២២៣.៣១៣	៦០.១៥១.៤៦១
ពន្ធកាត់ទុកលើប្រាក់បញ្ញើសន្សំ	២៥៦.៣៦៧	២២៥.៤៥១	១៦៩.៦៦៧	១៦០.៤១៧	២០០.៣២៤	២.៥៣៥.៨១៥
ពន្ធកាត់ទុកលើប្រាក់បញ្ញើមានកាលកំណត់	៤.៤១០.៨១៩	៤.២០៨.៣២០	៤.៧៥៨.៤៤២	៥.១២៩.០៩៦	៦.៣១០.៧៣៧	៤២.២០៩.៤០២
ពន្ធកាត់ទុកលើថ្លៃជួលអចលនទ្រព្យ	៩៣៣.៩៩៦	៩៧៦.៧១៩	១.០៤៩.៥០៤	១.០៣៦.៥៣០	១.១៤០.៩៣២	១១.៤៤៤.៤៧៩
ពន្ធកាត់ទុកលើថ្លៃសេវាក្នុងប្រទេស	៣៨៤.៤៩៥	៣២៧.៣៩០	៣៣៥.១៩៣	២៩៨.០៣៣	២៥៦.៣៧៦	៤.៣៣៤.៦៩០
ពន្ធកាត់ទុកលើថ្លៃសេវាក្រៅប្រទេស	៦.០៤៩.៧១៣	៦.៣៩១.៣៦៣	៥.៨៦៥.២០២	៦.៥១៩.០៧២	២.៩៣៧.៦៩៤	៤៨.២៨២.៤៦៥
សរុប	៥៦.០០៩.១៦៤	៤៨.៦៨៦.៨៨៥	៣៤.៥១៧.៨០៩	៥៣.៧៣៧.៤២៣	៤៥.០៥៨.២៧៥	៤៤៨.៤៨១.២៥១
សរុបយោង* (មកដល់បច្ចុប្បន្ន)	២៦៦.៤៨០.៨៦០	៣១៥.១៦៧.៧៤៥	៣៤៩.៦៨៥.៥៥៤	៤០៣.៤២២.៩៧៧	៤៤៨.៤៨១.២៥១	

* សរុប និងសរុបយោង គិតចាប់ពីឆ្នាំ២០០០ មក ។

លទ្ធផលសម្រេចបាន



ទ្រព្យសកម្មសរុប (គិតជាលានដុល្លារអាមេរិក)



សមតុល្យឥណទាន (គិតជាលានដុល្លារអាមេរិក)



ប្រាក់បញ្ញើ-សន្សំ (គិតជាលានដុល្លារអាមេរិក)



ចំនួនម៉ាស៊ីនអេធីអឹម



មាតិកា

៦ សូចនាករសេដ្ឋកិច្ចសំខាន់ៗនៅប្រទេសកម្ពុជា
៧ របាយការណ៍ប្រធានក្រុមប្រឹក្សាភិបាល
៨ របាយការណ៍ប្រធាននាយកប្រតិបត្តិ
១១ អង្គការលេខ
១២ បណ្តាញប្រតិបត្តិការ

១៣ អភិបាលកិច្ចសាជីវកម្ម
១៣ កិច្ចប្រជុំភាគហ៊ុនិក
១៣ ភាគហ៊ុនិក

១៥ ក្រុមប្រឹក្សាភិបាល
២០ គណៈកម្មាធិការប្រតិបត្តិ
៣០ សវនករផ្ទៃក្នុង
៣១ ក្រមសីលធម៌
៣២ របាយការណ៍ក្រុមប្រឹក្សាភិបាល
៣២ របាយការណ៍គណៈកម្មាធិការរបស់ក្រុមប្រឹក្សាភិបាល
៣៣ គណៈកម្មាធិការសវនកម្ម
៣៤ គណៈកម្មាធិការតែងតាំង និងលាភការ
៣៦ គណៈកម្មាធិការគ្រប់គ្រងហានិភ័យ និងព័ត៌មានវិទ្យា

៣៩ របាយការណ៍ស្តីពីនិរន្តរភាពបរិស្ថាន និងសង្គម
៤៣ ការផ្តល់ចំណាត់ថ្នាក់
៤៤ សាខាធនាគារ អេស៊ីលីដា ភីអិលស៊ី និងបុត្រសម្ព័ន្ធ
៤៥ ធនាគារដៃគូ

ឧបសម្ព័ន្ធ៖ **របាយការណ៍ហិរញ្ញវត្ថុដែលធ្វើសវនកម្ម ដោយសវនករឯករាជ្យ**

សូចនាករសេដ្ឋកិច្ចសំខាន់ៗនៅប្រទេសកម្ពុជា

	២០១៧	២០១៨	២០១៩	២០២០	២០២១e	២០២២f
១. ផលិតផលសរុបក្នុងស្រុក (GDP)						
បម្រែបម្រួលផលិតផលសរុបក្នុងស្រុក (គិតជាភាគរយ)	៧	៧,៥	៧,១	-៣,១	២,៤	៤,៨
ចំណូលក្នុងម្នាក់ (គិតជាដុល្លារអាមេរិក)	១.៤២៧	១.៥៦៣	១.៧០៦	១.៦៥៣	១.៧៣០	១.៨៤២
២. អតិផរណា						
អតិផរណា (មធ្យមប្រចាំឆ្នាំ)	២,៩	២,៥	១,៩	២,៩	២,៩	២,៨
(ចុងឆ្នាំ)	២,២	១,៦	៣,១	២,៩	៣,៧	-
៣. ថវិការបស់រដ្ឋាភិបាល (គិតជាភាគរយនៃផលិតផលសរុបក្នុងស្រុក)						
ចំណូល	២០,២	២២,៣	២៥,៣	២១,៦៨	១៨,៤២	១៩,៥៦
ចំណាយ	២៣,៥	២៤,៦	២៦,១	១៧,២៥	១៦,២៨	១៦,៧៩
៤. រូបិយវត្ថុ និងឥណទាន (បម្រែបម្រួលជាភាគរយក្នុង ១២ខែ)						
រូបិយវត្ថុទូទៅ (M2)	២៣,១	២៦,៦	១៨,២	១៥,៣	១៦,៤	-
ប្រាក់បញ្ញើសរុបនៅក្នុងប្រព័ន្ធធនាគារ	២៥,១	២៧,៩	១៥,១	១៨	១៧	-
ឥណទានសរុបនៅក្នុងប្រព័ន្ធធនាគារ	១៧,២	២៤,៣	២៣,៩	២៣,៤	៣០,២	-
ឥណទានធៀបនឹងប្រាក់បញ្ញើ (គិតជាភាគរយ)	៩៥,៣	៩២,២	៩៩	១០៣,៥	១១៥,១	-
ឥណទានវិស័យឯកជន	១៨,៥	២០,១	២៦,៣	១៧,៧	២៣,២	-
ប្រាក់បញ្ញើធៀបនឹងផលិតផលសរុបក្នុងស្រុក	៨៥,៦	៩១,១	៩៣,៣	១១០,៩	១២៣,៨	-
ឥណទានធៀបនឹងផលិតផលសរុបក្នុងស្រុក	៨០,៧	៨៣,៥	៩២	១១៤,៨	១៤២,៥	-
៥. ជញ្ជីងទូទាត់ (គិតជាលានដុល្លារអាមេរិក)						
ការនាំចេញ	១០.៧៧៧	១១.២១៤	១៤.៥៣០	១៧.២១០	១៩.៤៦៩	-
ការនាំចូល	១៣.០១៩	១៣.៧៧១	២២.១៩០	១៨.៥៩០	៣០.៩២៦	-
ជញ្ជីងពាណិជ្ជកម្ម	-២.២៤២	-២.៥៥៧	-៧.៦៦០	-១.៣៨០	-១១.៤៥៧	-
គណនីចរន្ត (មិនរាប់បញ្ចូលការផ្ទេរជាផ្លូវការ)	-២.១៤០,៥	-២.១៨០,១	-២.៦៣២,៥	-២.៥២៥,៥	-២.៦៦៣,៣	-
ផលិតផលសរុបក្នុងស្រុកជាមធ្យម (គិតជាពាន់លានដុល្លារអាមេរិក)	២២,១៦	២៤,៦១	២៧,២២	២៦,៧៣	២៨,៣៨	៣០,៥៤
អត្រាប្តូរប្រាក់ (រៀលក្នុងមួយដុល្លារ នៅចុងគ្រា)	៤.០៤៥	៤.០៣៧	៤.០៥៥	៤.០៨០	៤.០៦៥	៤.០៦៥

ប្រភព ៖ សមាគមធនាគារនៅកម្ពុជា, ធនាគារជាតិនៃកម្ពុជា, ធនាគារពិភពលោក, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, និង https://www.b2b-cambodia.com/articles/cambodias-economy-2020-summary-and-2021-predictions/

e: ប៉ាន់ប្រមាណ និង f: ព្យាករណ៍ ។

របាយការណ៍ប្រធានក្រុមប្រឹក្សាភិបាល

លោក ឆាយ សឿន

ប្រធានក្រុមប្រឹក្សាភិបាល

តាងនាមឱ្យធនាគារ អេស៊ីលីដា និងក្រុមប្រឹក្សាភិបាល ខ្ញុំបាទមានកិត្តិយស និងសេចក្តីសោមនស្សរីករាយ សូមធ្វើការបង្ហាញជូននូវរបាយការណ៍ហិរញ្ញវត្ថុ ប្រចាំឆ្នាំ២០២១ របស់ធនាគារ។

ការអូសបន្លាយពេលនៃវិបត្តិរីករាលដាលជំងឺកូវីដ-១៩ នៅតែជាក្តីព្រួយបារម្ភរបស់រាជរដ្ឋាភិបាល និងប្រជាជនកម្ពុជា នៅក្នុងកំលុងឆ្នាំ២០២១។ ទោះបីជាយ៉ាងណា រាជរដ្ឋាភិបាលមានផែនការយ៉ាងជាក់លាក់ ដើម្បីស្តារស្ថានភាពទាំងនេះឡើងវិញ ដោយបានដាក់ចេញនូវវិធានការគាំពារសង្គម និងសេដ្ឋកិច្ច ជាមួយនឹងការបង្កើននៃការចាក់វ៉ាក់សាំងយ៉ាងឆាប់រហ័ស ក៏ដូចជាការពង្រឹងវិធានការការពារយ៉ាងម៉ឹងម៉ាត់។ ដោយសារការអនុវត្តវិធានការការពារ និងការសម្រេចបានការចាក់វ៉ាក់សាំងកូវីដ-១៩ ប្រកបដោយជោគជ័យជូនប្រជាជនប្រមាណ៩០% នៃប្រជាជនសរុបនោះ រដ្ឋាភិបាលក៏បានបន្ធូរបន្ថយវិធានការរឹតបន្តឹង និងបើកប្រទេសឡើងវិញចាប់ពីថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០២១។ ការស្តារសកម្មភាពសេដ្ឋកិច្ចក្នុងស្រុក ស្របជាមួយអំណោយផលនៃកំណើនសេដ្ឋកិច្ចពិភពលោក គឺជាកម្លាំងចលករដ៏សំខាន់ ក្នុងការជួយជំរុញដល់កំណើនសេដ្ឋកិច្ចកម្ពុជា។ ទន្ទឹមនឹងនេះ ធនាគារជាតិ នៃ កម្ពុជា បានដាក់ចេញនូវវិធានការប្រុងប្រយ័ត្នផ្សេងៗ ដើម្បីបន្ធូរបន្ថយក្នុងការអនុវត្តអនុបាតប្រុងប្រយ័ត្នមួយចំនួន មានជាអាទិ៍ ១) រក្សាទ្រនាប់ដើមទុនខនស៊ើវេសិនក្នុងអត្រា១,២៥%, ២) កាត់បន្ថយអត្រាប្រាក់បម្រុងកាតព្វកិច្ចមកនៅត្រឹម៧%, ៣) អនុញ្ញាតឱ្យធនាគារ និងស្ថាប័នហិរញ្ញវត្ថុរៀបចំឥណទានឡើងវិញ ។ល។ ដើម្បីគាំទ្រដល់ប្រតិបត្តិការធនាគារ និងហិរញ្ញវត្ថុ ក្នុងការជួយសម្រាលបន្ទុកជូនអតិថិជន ដែលប្រឈមនឹងបញ្ហាហិរញ្ញវត្ថុនៅកំលុងពេលវិបត្តិនៃការរីករាលដាលជំងឺឆ្លង។ តាមរយៈវិធានដ៏មានប្រសិទ្ធភាពទាំងនេះ ធនាគារ និងស្ថាប័នហិរញ្ញវត្ថុអាចផ្តល់កម្ចីបន្ថែមដល់សហគ្រាសខ្នាតតូច និងមធ្យម ដើម្បីចូលរួមចំណែកក្នុងការពន្លឿនដល់កំណើនសេដ្ឋកិច្ច។ កំណើនសេដ្ឋកិច្ចកម្ពុជាត្រូវបានប៉ាន់ស្មានថាកើនឡើងក្នុងរង្វង់អត្រា៣% សម្រាប់ឆ្នាំ២០២១ និងរំពឹងថានឹងកើនឡើងក្នុងអត្រាប្រមាណ៥% នៅឆ្នាំ២០២២ ដោយផ្អែកទៅតាមរបាយការណ៍ស្តីពី "វឌ្ឍនភាពម៉ាក្រូសេដ្ឋកិច្ច និងវិស័យធនាគារឆ្នាំ២០២១ និងទស្សនវិស័យឆ្នាំ២០២២" ដែលចេញដោយធនាគារជាតិ នៃ កម្ពុជា នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១។ ទោះបីជាប្រទេសកម្ពុជាទទួលរងផលប៉ះពាល់ពីជំងឺរាតត្បាតជាសាកលនេះក្តី ក៏ប្រទេសកម្ពុជានៅតែរក្សាបាននូវកំណើនសេដ្ឋកិច្ចជាវិជ្ជមាននៅឆ្នាំ២០២១ ខណៈដែលអត្រាអតិផរណារក្សាបាននៅកម្រិតទាបក្នុងអត្រា២,៩០%។

កំលុងឆ្នាំ២០២១ ធនាគារបានធ្វើការផ្លាស់ប្តូររូបរាងស្លាកសញ្ញាថ្មី កែប្រែរូបរាង និងបន្ថែមមុខងារថ្មីៗ របស់អេស៊ីលីដាម៉ូបាល ព្រមទាំងបានពង្រីកសេវាកម្មធនាគារស្វ័យប្រវត្តិ ធ្វើនវានុវត្តន៍បច្ចេកវិទ្យា និងបង្កើនសមត្ថភាពប្រព័ន្ធធនាគារស្នូល ដើម្បីកម្លាយខ្លួនជាធនាគារឌីជីថលឈានមុខមួយនៅប្រទេសកម្ពុជាក្នុងបរិបទជំងឺកូវីដ-១៩ ដើម្បីឆ្លើយតបនឹងតម្រូវការរបស់អតិថិជន។ ការផ្លាស់ប្តូររូបរាងស្លាកសញ្ញាថ្មីនេះ គឺដើម្បីរក្សានូវនិមិត្តរូប អត្តសញ្ញាណ និងអត្ថន័យ ដែលធនាគារបានកសាងជាង២៩ឆ្នាំកន្លងមក។ ការធ្វើទំនើបកម្មស្លាកសញ្ញា ដើម្បីឆ្លើយតបនឹងទស្សនៈ បេសកកម្ម យុទ្ធសាស្ត្រ និងវឌ្ឍនភាពបច្ចេកវិទ្យាហិរញ្ញវត្ថុ ក៏ដូចជាធ្វើឱ្យកាន់តែទាន់សម័យ មានប្រជាប្រិយភាព និងកាន់តែមានភាពទាក់ទាញ។ ទន្ទឹមនឹងនេះ សេវាកម្មធនាគារស្វ័យប្រវត្តិជាង៥០កន្លែងនៅទូទាំងប្រទេស ត្រូវបានបង្កើតឡើងដោយបំពាក់នូវម៉ាស៊ីនដ៏ទំនើប ដែលមានបច្ចេកវិទ្យាចុងក្រោយ និងសុវត្ថិភាពខ្ពស់ ដើម្បីបង្កលក្ខណៈងាយស្រួលជូនដល់អតិថិជនក្នុងការធ្វើស្វ័យប្រតិបត្តិការសេវាកម្មធនាគារបានគ្រប់ពេលវេលា (២៤/៧) ដែលមានដូចជា ដាក់ប្រាក់ ដកប្រាក់ ផ្ទេរប្រាក់ ប្តូរប្រាក់ បង់រំកិយបត្រ បោះពុម្ពប័ណ្ណអេធីអឹម ផ្លាស់ប្តូរព័ត៌មានគណនី ដាក់ប្រាក់បញ្ញើមានកាលកំណត់ បោះពុម្ពវិញ្ញាបនបត្រប្រាក់បញ្ញើ និងសេវាស្វ័យប្រវត្តិជាច្រើនទៀត។ ធនាគារបានបង្កើនសមត្ថភាពប្រព័ន្ធធនាគារស្នូល ដើម្បីគាំទ្រដល់ប្រតិបត្តិការធនាគារទាំងអស់ឱ្យដំណើរការកាន់តែរលូន ប្រកបដោយសុវត្ថិភាព និងប្រសិទ្ធភាពខ្ពស់។ ដើម្បីធ្វើឱ្យប្រព័ន្ធដំណើរការយ៉ាងសកម្មក្នុងកិច្ចគាំទ្រសេវាកម្មឌីជីថល និងប្រតិបត្តិការធនាគារស្នូលរបស់ខ្លួនឱ្យមានប្រសិទ្ធភាពខ្ពស់ និងធានាបាននូវសុវត្ថិភាព ប្រកបដោយនិរន្តរភាពនោះ ធនាគារបានកសាងមជ្ឈមណ្ឌលសុវត្ថិភាពគ្រប់គ្រងទិន្នន័យព័ត៌មានវិជ្ជានៅស្រុកមុខកំពូល ខេត្តកណ្តាល។

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ ប្រាក់បញ្ញើសរុបបានកើនឡើងចំនួន ១.១០៤,៧២លានដុល្លារអាមេរិក សមតុល្យឥណទានសរុបបានកើនឡើងចំនួន ៩២១,៩៣លានដុល្លារអាមេរិក បើធៀបនឹងដំណាច់ឆ្នាំ២០២០។ បើធៀបលទ្ធផលប្រចាំឆ្នាំ២០២១ទៅនឹងលទ្ធផលឆ្នាំ២០២០ សម្ព័ន្ធធនាគារទទួលបានប្រាក់ចំណេញចំនួន១៦៦,៩១លានដុល្លារអាមេរិក កើនឡើង១៧,៩៧% ស្មើនឹង២៥,៤២លានដុល្លារអាមេរិក។ ជាលទ្ធផល អនុបាតចំណេញធៀបនឹងទ្រព្យសកម្មមធ្យម២,៣២% កើនឡើង០,០៩% និងអនុបាតចំណេញធៀបនឹងមូលធនមធ្យម១៤,៦១% កើនឡើង ០,៧៨% ខណៈដែលអនុបាតប្រសិទ្ធភាពប្រតិបត្តិការ៣៨,៦៦% ថយចុះ០,៦៤% បើធៀបនឹងដំណាច់ឆ្នាំ២០២០។

យើងខ្ញុំសូមថ្លែងអំណរគុណ និងសំដែងនូវការដឹងគុណយ៉ាងជ្រាលជ្រៅចំពោះភាគហ៊ុនិក អតិថិជន និយោជិត និងជាពិសេសអាជ្ញាធរពាក់ព័ន្ធទាំងអស់ដែលតែងតែផ្តល់ការគាំទ្រចំពោះធនាគារដើម្បីបានសម្រេចនូវលទ្ធផលស្របតាមផែនការជាពិសេសក្នុងឆ្នាំ២០២១។

លោក ឆាយ សឿន

ប្រធានក្រុមប្រឹក្សាភិបាល

ថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២

របាយការណ៍ប្រធាននាយកប្រតិបត្តិ

បណ្ឌិត អ៊ុន ចាន់នី

ប្រធាននាយកប្រតិបត្តិ

ការលើកកម្ពស់គុណភាព និងសុវត្ថិភាពសេវាកម្ម គឺជាអាទិភាពចម្បងរបស់ធនាគារ ហើយធនាគារនៅតែបន្តស្វែងរកដំណោះស្រាយល្អបំផុត ដើម្បីគាំទ្រ និងឆ្លើយតបនឹងតម្រូវការអតិថិជន។ មជ្ឈមណ្ឌលផ្ទុកទិន្នន័យបច្ចុប្បន្នរបស់ធនាគារបានរួមចំណែកយ៉ាងធំធេងក្នុងការរីកចម្រើនយ៉ាងឆាប់រហ័សរបស់ធនាគារនៅអំឡុងពេល៣០ឆ្នាំកន្លងមកនេះ។ ជាលទ្ធផល ធនាគារបានក្លាយជាធនាគារឈានមុខគេនៅក្នុងវិស័យធនាគារ និងហិរញ្ញវត្ថុក្នុងប្រទេសកម្ពុជា។ ធនាគារតែងតែខិតខំធ្វើឱ្យបានល្អបំផុត ជាជាងគ្រាន់តែធ្វើឱ្យបានល្អ។ ធនាគារកំពុងស្វែងរកជាបន្តបន្ទាប់នូវមធ្យោបាយ ឬដំណោះស្រាយថ្មីៗ ដើម្បីផ្តល់ជូនអតិថិជនឱ្យកាន់តែប្រសើរជាងមុន។ បច្ចុប្បន្ន ធនាគារក៏កំពុងតែស្វែងរកនូវសក្តានុពលនៃការបង្រួមនូវទិន្នន័យតូចៗដែលនៅដាច់ដោយឡែកពីគ្នា (Silo Data Domains) ដ៏ច្រើនរបស់ខ្លួន ទៅក្នុងបណ្តាញទិន្នន័យដ៏ធំ (Big Data Mesh) សម្រាប់ការវិភាគ និងការអភិវឌ្ឍម៉ាស៊ីន AI ស្របតាមគោលដៅ ដើម្បីសម្រេចបាននូវទីផ្សារឆ្លាតវៃ ការអភិវឌ្ឍផលិតផលជោគជ័យ ការរកឃើញនូវសញ្ញាណដំបូងនៃការក្លែងបន្លំ និងការផ្តល់ជូនសេវាកម្មដ៏ល្អបំផុតជូនអតិថិជន។

សមិទ្ធផលសម្រេចបានក្នុងឆ្នាំ២០២១

ស្ថានភាពប្រកួតប្រជែង

ដំណោះស្រាយឌីជីថលកំពុងមានការរីកចម្រើន និងក្លាយជាជម្រើសចម្បង សម្រាប់ធនាគារ និងស្ថាប័នហិរញ្ញវត្ថុ ក្នុងការផ្តល់សេវាកម្មជូនអតិថិជនរបស់ខ្លួន ក្នុងកំលុងពេល និងក្រោយពេលនៃការរីករាលដាលជំងឺកូវីដ-១៩។ ជាមួយនឹងអត្រាខ្ពស់ នៃការចាក់វ៉ាក់សាំង កម្ពុជាបានបើកប្រទេសឡើងវិញលើគ្រប់វិស័យ ចាប់ពីថ្ងៃទី១ ខែវិច្ឆិកា ដែលអាចជួយស្តារសកម្មភាពសេដ្ឋកិច្ច-សង្គមឡើងវិញ។ បច្ចេកវិទ្យាឌីជីថលក៏ត្រូវបានជឿជាក់ថា ជាឧបករណ៍ដ៏មានប្រសិទ្ធភាពបំផុតមួយ ដើម្បីប្រកួតប្រជែងក្នុងស្ថានភាពទីផ្សារបច្ចុប្បន្ន ក្នុងចំណោមស្ថាប័នហិរញ្ញវត្ថុ។ ធនាគារតែងតែពង្រឹងគុណភាពបម្រើសេវាកម្មហិរញ្ញវត្ថុដល់អតិថិជនគ្រប់មជ្ឈដ្ឋាន ដើម្បីទទួលបានការរីកចម្រើនជាមួយគ្នា ទាំងនៅក្នុងប្រទេសកម្ពុជា និងក្រៅប្រទេសផងដែរ តាមរយៈការទូទាត់ឆ្លងដែនតាមឃ្យូអរកូដ (QR Code)។

ចំណុចសំខាន់ៗនៃប្រតិបត្តិការក្នុងឆ្នាំ២០២១

- សមតុល្យឥណទានសរុបនៅដំណាច់ឆ្នាំ២០២១មានចំនួន៥.៤២៨,៥៧លានដុល្លារអាមេរិក ក្នុងនោះឥណទានចំនួន១.១០១,៥៤លានដុល្លារអាមេរិក ស្មើនឹង២០,២៩% បានផ្តល់ទៅឱ្យវិស័យកសិកម្ម។ ក្នុងឆ្នាំ២០២០ ការផ្តល់ឥណទានក្នុងវិស័យកសិកម្មមានចំនួន៨៩៤,៦៥លានដុល្លារអាមេរិក។ គិតត្រឹមដំណាច់ខែធ្នូ ឆ្នាំ២០២១ ចំនួនអតិថិជនឥណទានអាជីវកម្មខ្នាតតូចរបស់សម្ព័ន្ធធនាគារបានកើនដល់៤២៣.៣៧៨នាក់។
- ឥណទានមិនដំណើរការស្ថិតក្នុងអត្រា២,៣៣% ដែលជាអត្រាអាចគ្រប់គ្រងបាននៅក្នុងកំលុងពេលនៃវិបត្តិកូវីដ-១៩នេះ។
- ប្រាក់បញ្ញើ-សន្សំមានចំនួន៥.៧១៦,០២លានដុល្លារអាមេរិក ដែលមានគណនីសកម្មចំនួន៣.២៩៨.៣៨២។
- សម្ព័ន្ធធនាគារទទួលបានប្រាក់ចំណេញដែលផ្តល់ជូនភាគហ៊ុនិករបស់ធនាគារចំនួន១៦៦,៩១លានដុល្លារអាមេរិក។
- ធនាគារនៅតែបន្តកាត់បន្ថយចំណាយ និងត្រួតពិនិត្យហានិភ័យជាប្រចាំ ដើម្បីទទួលបានប្រាក់ចំណេញខ្ពស់បំផុត។
- សេវាធនាគារបច្ចេកវិទ្យាហិរញ្ញវត្ថុ (FinTech) បានបញ្ចូលជាមួយនឹងហេដ្ឋារចនាសម្ព័ន្ធធនាគារអេឡិចត្រូនិកផ្សេងទៀតរបស់ធនាគារ ដើម្បីផ្តល់ជម្រើសជាច្រើនជូនអតិថិជន ក្នុងការគ្រប់គ្រងធនធានហិរញ្ញវត្ថុរបស់ពួកគេ។

សេវាលក់រាយ និងអាជីវកម្មខ្នាតតូច

ឥណទានខ្នាតតូចបានកើនឡើង១០,៩៩% ឬស្មើនឹង២៨៣,១១លានដុល្លារអាមេរិក និងឥណទានសម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួន និងផ្សេងៗ បានកើនឡើង២៧,៩៥% ឬស្មើនឹង៤៤,២៤លានដុល្លារអាមេរិក។ ចំណែកឥណទានគេហដ្ឋានមានចំនួន១៦០,៥៣លានដុល្លារអាមេរិក។ សមតុល្យឥណទានសរុបមានចំនួន៥.៤២៨,៥៧លានដុល្លារអាមេរិកនៅដំណាច់ឆ្នាំ២០២១។

សម្ព័ន្ធធនាគារ មានសមតុល្យប្រាក់បញ្ញើ-សន្សំសរុបចំនួន៥.៧១៦,០២លានដុល្លារអាមេរិក (កើនឡើង២៣,៩៦% ឬស្មើនឹង១.១០៤,៧២លានដុល្លារអាមេរិក) និងមានគណនីសរុបជាង៣.២៩៨.៣៨២គណនី។ វិស័យលក់រាយគឺជាផ្នែកដែលធំជាងគេបំផុតនៃកំណើនប្រាក់បញ្ញើសរុប ដែលភាគច្រើនបានមកពីអតិថិជនដាក់ប្រាក់បញ្ញើដំបូង ដូចជាកម្មករនិយោជិត តាមរយៈសេវាបើកប្រាក់បៀវត្ស និងអតិថិជននៅតាមជនបទ ដែលពួកគាត់បានប្រើប្រាស់គណនីវ៉ាលឡេត របស់អេស៊ីលីដាម៉ូបាល ដែលជាផលិតផល និងសេវាកម្មហិរញ្ញវត្ថុ តាមរយៈបច្ចេកវិទ្យាហិរញ្ញវត្ថុ បានចូលរួមចំណែកធ្វើឱ្យមានកំណើនយ៉ាងខ្លាំងក្លា។

សម្ព័ន្ធធនាគារ កំពុងតែអភិវឌ្ឍនូវហេដ្ឋារចនាសម្ព័ន្ធឱ្យកាន់តែទូលំទូលាយ សម្រាប់ជាជម្រើសដ៏សម្បូរបែបជាមួយនឹងសាខាទាំង៣១៧ទីតាំង (ឬការិយាល័យ) និងមជ្ឈមណ្ឌលស្វ័យប្រតិបត្តិការចំនួន៧៣ទីតាំង ព្រមទាំងមានម៉ាស៊ីនអេធីអឹម ចំនួន៩៦៦គ្រឿង និងម៉ាស៊ីនឆូតកាតចំនួន៤.៤៦២គ្រឿង។ ចំណុចគួរជាទីមោទកភាពគឺសម្ព័ន្ធធនាគារ បានបោះពុម្ពប័ណ្ណឥណពន្ធចំនួន១,៥៩លានប័ណ្ណជូនដល់អតិថិជន។ បន្ថែមលើនេះ អេស៊ីលីដាម៉ូបាល (ACLEDA mobile) បានទទួលប្រជាប្រិយភាពយ៉ាងខ្លាំង ដែលមានអ្នកចុះឈ្មោះប្រើប្រាស់ច្រើនជាង២,២៨លាននាក់ នៅដំណាច់ឆ្នាំ២០២១នេះ។

ឥណទានខ្នាតមធ្យម និងសាជីវកម្ម

ក្នុងឆ្នាំ២០២១ សេវាចាត់ចែងសាច់ប្រាក់បានកើនឡើងយ៉ាងខ្លាំង តាមរយៈការចាប់ដៃគូជាមួយនឹងវិស័យសាធារណៈ ជាពិសេស បេឡាជាតិសន្តិសុខសង្គម សេវាបើកប្រាក់បៀវត្សសម្រាប់មន្ត្រីរាជការ សេវាប្រមូលពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានជំនិះគ្រប់ប្រភេទ។ តម្រូវការប្រើប្រាស់សេវាបើកប្រាក់បៀវត្សបានកើនឡើងខ្លាំងនៅក្នុងឆ្នាំ២០២១ ដោយមានស្ថាប័នរដ្ឋាភិបាល ព្រមទាំងក្រុមហ៊ុនធំៗ ក្នុងស្រុក និងក្រៅប្រទេស រួមទាំងស្ថាប័ននានា បានចូលរួមប្រើប្រាស់ ដែលជាឱកាសដ៏ល្អ សម្រាប់ការលក់ផលិតផលផ្សេងៗទៀត។

បន្ថែមលើនេះ ការផ្តល់ជូនសេវាកម្មដ៏ល្អបំផុតតាមរយៈបណ្តាញប្រតិបត្តិការទូទាំងប្រទេសរបស់ធនាគារ បានទាក់ទាញ និងជំរុញក្រុមហ៊ុនអាជីវកម្មខ្នាតមធ្យម និងសាជីវកម្មយ៉ាងខ្លាំង ក្នុងការជ្រើសរើសធនាគារជាអ្នកសម្របសម្រួលអាទិភាពទីមួយ សម្រាប់ការចាត់ចែង និងប្រភពហិរញ្ញវត្ថុ សម្រាប់ គាំទ្រការទូទាត់និងប្រតិបត្តិអាជីវកម្មរបស់ពួកគាត់។ សេវាកម្មចម្រុះសម្បូរបែបទាំងនេះបានផ្តល់ផលវិជ្ជមានដ៏សំខាន់លើលំហូរសាច់ប្រាក់ជារូបិយវត្ថុជាតិរបស់ធនាគារ និងបានធ្វើឱ្យធនាគារមានលទ្ធភាពប្រមូលនូវប្រភពធនធានហិរញ្ញវត្ថុជារូបិយវត្ថុរៀល ដើម្បីពង្រឹង និងពង្រីកការផ្តល់ឥណទានជាប្រាក់រៀលបានកាន់តែច្រើនផងដែរ។ ទន្ទឹមនឹងនេះ ឥណទានខ្នាតមធ្យម និងសាជីវកម្ម បានកើនឡើង៣៤,៦១% បើធៀបនឹងឆ្នាំ២០២០ ដែលមានចំនួនស្មើនឹង៣៩,១៨% នៃសមតុល្យឥណទានសរុប។

លើសពីនេះទៅទៀត ធនាគារ និងក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ខ្លួន នៅតែបន្តកិច្ចសហប្រតិបត្តិការជាមួយដៃគូយុទ្ធសាស្ត្ររយៈពេលវែង ដែលមានបទពិសោធន៍ដ៏សម្បូរបែប ដែលអាចជួយដល់អតិថិជនក្នុងការគ្រប់គ្រងធនធានហិរញ្ញវត្ថុរបស់ពួកគាត់ប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល។ ទន្ទឹមនឹងនេះ ភាពជាដៃគូទាំងនេះបានរួមចំណែកយ៉ាងសំខាន់ក្នុងការផ្តល់ប្រភពមូលនិធិរយៈពេលវែងដល់ធនាគារ និងជាប្រភពនៃប្រាក់ចំណូលក្រៅតារាងតុល្យការ។ ម្យ៉ាងវិញទៀត ភាពជាដៃគូនេះ បានចែករំលែកនូវជំនាញ និងបទពិសោធន៍អន្តរជាតិដល់ថ្នាក់គ្រប់គ្រង និងបុគ្គលិករបស់ធនាគារ។

រតនាភិបាល និងអន្តរជាតិ

ចំណូលពីសេវាប្តូរប្រាក់បន្តកើនឡើង និងចូលរួមបង្កើនចំណូលមិនមែនការប្រាក់របស់ធនាគារ។ ដោយយោងលើគោលការណ៍គ្រប់គ្រងហានិភ័យ ធនាគារបម្រើសេវាប្តូរប្រាក់សម្រាប់តែគាំទ្រដល់អាជីវកម្មរបស់អតិថិជនប៉ុណ្ណោះ។ សេវានេះផ្តល់ប្រភពចំណូលដែលមានហានិភ័យទាប និងមានស្ថិរភាព ហើយមានកំណើនជាលំដាប់ និងរក្សាទំនាក់ទំនងយូរអង្វែងជាមួយអតិថិជន។

តាមរយៈការគ្រប់គ្រងស្ថានភាពរូបិយប័ណ្ណចំហបានល្អប្រសើរដែលធ្វើឲ្យមានការកើនឡើងយ៉ាងខ្លាំងនូវលំហូរចូលនៃប្រាក់បញ្ញើដែលបានធ្វើឱ្យតារាងតុល្យការរបស់ធនាគារកាន់តែរឹងមាំថែមទៀត និងបានធ្វើឱ្យអនុបាតឥណទានធៀបនឹងប្រាក់បញ្ញើមានភាពល្អប្រសើរ និងជួយទ្រទ្រង់ដល់ការរីកចម្រើននៅលើទីផ្សារ។

ធនាគារបានចូលរួមចំណែកលើកស្ទួយការប្រើប្រាស់ប្រាក់រៀល តាមរយៈការផ្តល់ឥណទានជាប្រាក់រៀលដល់អតិថិជន ដែលមានចំនួនច្រើនជាង១៤% នៃទំហំឥណទានសរុប ដែលលើសពីបញ្ញត្តិតម្រូវត្រឹមតែ១០%ប៉ុណ្ណោះ។ ធនាគារក៏បានចូលរួមយ៉ាងសកម្មនៅក្នុងប្រតិបត្តិការផ្តល់សន្ធនីយភាពដោយមានការធានា (LPCO) ដើម្បីទុកជាប្រភពទុនបន្ថែមជាប្រភេទរូបិយវត្ថុក្នុងស្រុក។

បន្ថែមពីនេះទៀត ធនាគារបានរក្សាទំនាក់ទំនងល្អជាមួយនឹងដៃគូយុទ្ធសាស្ត្រទូទាំងសកលលោក ជាពិសេស នៅអឺរ៉ុប សហរដ្ឋអាមេរិក និងអាស៊ី ដើម្បីគាំទ្រដល់ធនាគារ ក្នុងការធ្វើពិពិធកម្មមូលនិធি និងផ្តល់ប្រភពមូលនិធិរយៈពេលវែង។

ធនាគារនៅតែបន្តពង្រឹងទំនាក់ទំនងជាមួយស្ថាប័នហិរញ្ញវត្ថុជាច្រើន និងបានបង្កើនធនាគារដៃគូក្រៅប្រទេសថ្មីៗ ជាច្រើនបន្ថែមទៀត ដើម្បីពង្រីកបណ្តាញប្រតិបត្តិការរបស់ខ្លួន។ នាដំណាច់ឆ្នាំ២០២១ ធនាគារមានធនាគារដៃគូចំនួន២៧០ នៅក្នុងចំណោម៤៤ប្រទេស។ លើសពីនេះទៀត ធនាគារមានចំណែកទីផ្សារលើសលុប ក្នុងការគ្រប់គ្រងគណនីរបស់ធនាគារ និងស្ថាប័នហិរញ្ញវត្ថុក្នុងស្រុក ព្រមទាំងផ្តល់សេវាផ្ទេរប្រាក់ដល់ស្ថាប័នទាំងនោះនៅទូទាំងប្រទេស។

ធនាគារក៏បានរៀបចំ និងអនុវត្តបានទាំងស្រុងតាមគោលការណ៍គ្រប់គ្រងហានិភ័យផ្ទៃក្នុង តម្រូវការបទប្បញ្ញត្តិ និងកិច្ចព្រមព្រៀងជាមួយនឹងម្ចាស់បំណុលនានា។

យុទ្ធសាស្ត្រអាទិភាពសម្រាប់ឆ្នាំ២០២២

១. ផ្តល់អាទិភាពសេវាធនាគារតាមទូរស័ព្ទ និងធ្វើឌីជីថលភារូបនីយកម្មក្នុងកម្រិតអតិបរមា រួមទាំងប្រព័ន្ធទូទាត់ជាតិ (NPH), ដៃគូ និងសមាហរណកម្មបណ្តាញទូទាត់អាស៊ាន និងកិច្ចសហប្រតិបត្តិការជាសកល។
២. អភិវឌ្ឍធនធានមនុស្សស្របតាមយុគសម័យឌីជីថល។
៣. បន្តកែទម្រង់ការិយាល័យសាខា ដើម្បីបម្រើសេវាជាធនាគារឌីជីថល និងយុទ្ធសាស្ត្រកសាងម៉ាកយីហោ ដើម្បីផ្តល់ភាពជឿជាក់ដល់អតិថិជន និងដៃគូសហការទាំងអស់។
៤. បន្តអភិវឌ្ឍមុខងារបច្ចេកវិទ្យាហិរញ្ញវត្ថុ និងធ្វើឱ្យអតិថិជនកាន់តែមានភាពងាយស្រួលក្នុងការប្រើប្រាស់។
៥. កសាងភាពជាដៃគូជាមួយស្ថាប័នដែលមានកេរ្តិ៍ឈ្មោះល្អ ដើម្បីគាំទ្រកំណើនអាជីវកម្ម។
៦. ពង្រឹងជំហរជាក្រុមហ៊ុនចុះបញ្ជីនៅផ្សារមូលបត្រកម្ពុជា ទាំងមូលបត្រកម្មសិទ្ធិ និងមូលបត្របំណុល។
៧. ធានាធ្វើឱ្យក្រុមហ៊ុនបុត្រសម្ព័ន្ធទាំងអស់របស់ធនាគារ អេស៊ីលីដា បង្កើតជាផ្នែកសំខាន់មួយនៃធនាគារឌីជីថល និងសេវាកម្មរបស់ពួកគេ។
៨. កាត់បន្ថយលំហូរការងារដោយប្រើប្រាស់កម្មវិធីឌីជីថលក្នុងការបញ្ជូន និងការរក្សាទុកឯកសារសម្រាប់ផលិតផល-សេវាកម្មហិរញ្ញវត្ថុទាំងអស់។
៩. បង្កើតសេវាកម្មបច្ចេកវិទ្យាព័ត៌មានលំដាប់ទីមួយ ដើម្បីគាំទ្រដល់យុទ្ធសាស្ត្រអាជីវកម្មធនាគារ ខណៈពេលដែលទ្រព្យសកម្មព័ត៌មាន ត្រូវបានការពារដោយប្រើប្រាស់បច្ចេកវិទ្យាដ៏ល្អបំផុត និងចុងក្រោយបង្អស់។
១០. បង្កើនការជំរុញលក់ និងការលក់ចម្រុះរួមបញ្ចូលគ្នាតែមួយ (Cross-Up Selling All-in-one) និងទីផ្សារឌីជីថល ដើម្បីកំណើនប្រកបដោយនិរន្តរភាព។

បញ្ហាចម្បងក្នុងឆ្នាំ២០២២

ធនាគារជាក្រុមហ៊ុនចុះបញ្ជីមួយ ដែលអនុលោមតាមបទប្បញ្ញត្តិរបស់ធនាគារជាតិ នៃ កម្ពុជា និង ន.ម.ក. ហើយនេះក៏ជាទំនួលខុសត្រូវរបស់ធនាគារចំពោះសាធារណជន និងវិនិយោគិនផងដែរ។ ក្នុងប្រវត្តិជាច្រើនឆ្នាំរបស់ខ្លួន ធនាគារបានបង្កើតទំនុកចិត្តដល់សាធារណជន តាមរយៈអភិបាលកិច្ចសាជីវកម្មល្អ គណៈគ្រប់គ្រងដែលមានបទពិសោធន៍យូរឆ្នាំ ព្រមទាំងមានវប្បធម៌ការងារប្រកបដោយតម្លាភាព។

ហេដ្ឋារចនាសម្ព័ន្ធឌីជីថល និងផលិតផលបច្ចេកវិទ្យាធ្វើឲ្យអតិថិជន និងសាធារណៈកាន់តែងាយស្រួលក្នុងការប្រើប្រាស់សេវាកម្មហិរញ្ញវត្ថុដែលមានភាពសម្បូរបែប។ តាមរយៈនេះ វាបានជួយលុបបំបាត់គម្លាតរបស់អតិថិជនក្នុងទីផ្សារហិរញ្ញវត្ថុ ព្រមទាំងញ៉ាំងឱ្យអតិថិជនមានជម្រើសក្នុងចំណោមធនាគារ និងស្ថាប័នហិរញ្ញវត្ថុ ដោយលែងខ្វល់អំពីតំបន់រស់នៅរបស់ពួកគេទៀត។ សេវាបច្ចេកវិទ្យាក៏ជួយជំរុញដល់ការប្រកួតប្រជែងខ្លាំងក្លា ទាំងគុណភាព និងតម្លៃនៃសេវាកម្ម។ អេស៊ីលីដាម៉ូបាលបានបំពាក់បច្ចេកវិទ្យាជំនាន់ចុងក្រោយបំផុត ដែលមានរូបភាពទាន់សម័យគួរឱ្យទាក់ទាញ។ វាត្រូវបានបង្កើតឡើងជាមួយនឹងបទពិសោធន៍របស់អតិថិជន ដើម្បីឲ្យមានភាពងាយស្រួល និងសមស្របទៅនឹងមនុស្សគ្រប់វ័យ។ លើសពីនេះ វាមានសុវត្ថិភាពខ្ពស់ និងអាចទាញយកដោយខ្លួនឯងនៅកន្លែងណា ដែលមាន WiFi ឬអ៊ីនធើណេត ហើយវាក៏ជាដំណោះស្រាយមួយដែរ ដើម្បីជួយឱ្យធនាគារឈានមុខក្នុងការប្រកួតប្រជែង។

កម្ពុជាបើកប្រទេសឡើងវិញលើគ្រប់វិស័យជាមួយនឹងអត្រាខ្ពស់នៃការចាក់វ៉ាក់សាំង និងលើកទឹកចិត្តប្រជាជនឱ្យបន្តអនុវត្តវិធានការ ៣កុំ ៣ការពារ។ ទោះជាយ៉ាងណាក៏ដោយ ការអូសបន្លាយនៃជំងឺរាតត្បាតកូវីដ-១៩ នៅតាមបណ្តាប្រទេសមួយចំនួនក្នុងពិភពលោក នៅតែបង្កភាពភ័យខ្លាចដល់សាធារណជន និងម្យ៉ាងវិញទៀតអាចនឹងនៅតែបន្តប៉ះពាល់ដល់ការរីកចម្រើនសេដ្ឋកិច្ចជាសកល រួមទាំងកម្ពុជាក្នុងរយៈពេលខ្លី ឬមធ្យម។

ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះការគាំទ្ររបស់អតិថិជន ក្រុមប្រឹក្សាភិបាល ថ្នាក់គ្រប់គ្រង និងបុគ្គលិក ជាពិសេសរាជរដ្ឋាភិបាល ធនាគារជាតិ នៃ កម្ពុជា និងនិយ័តករមូលបត្រកម្ពុជា ក្នុងឆ្នាំ២០២១ និងការចូលរួមប្រកបដោយសោមនស្ស និងឧត្តុង្គឧត្តមក្នុងឆ្នាំ២០២២។

បណ្ឌិត អ៊ុន ចាន់នី

ប្រធាននាយកប្រតិបត្តិ

ថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២២

រចនាសម្ព័ន្ធ



* បានតែងតាំងនៅថ្ងៃទី០១ ខែមីនា ឆ្នាំ២០២២

បណ្តាញប្រតិបត្តិការ



អភិបាលកិច្ចសាជីវកម្ម

ធនាគារ អេស៊ីលីដា ភីអិលស៊ី ទទួលស្គាល់នូវសារសំខាន់ នៃអភិបាលកិច្ចសាជីវកម្ម ដើម្បីគាំទ្រការរីកចម្រើនប្រកបដោយនិរន្តរភាពរបស់ធនាគារ បង្កើនប្រសិទ្ធភាពការងារ បង្កើនតម្លៃរបស់ភាគហ៊ុនិក និងជំនឿទុកចិត្តដល់ភាគហ៊ុនិក អតិថិជន បុគ្គលិក ព្រមទាំងសាធារណជនទូទៅ។ ក្រុមប្រឹក្សាភិបាលគាំទ្រ និងលើកទឹកចិត្តឲ្យអនុវត្តគោលការណ៍អភិបាលកិច្ចសាជីវកម្មល្អ រួមទាំងក្រមសីលធម៌។

កិច្ចប្រជុំភាគហ៊ុនិក

ធនាគារ អេស៊ីលីដា បើកកិច្ចប្រជុំប្រចាំឆ្នាំរបស់ភាគហ៊ុនិក ដោយអនុលោមទៅតាមច្បាប់ និងបទប្បញ្ញត្តិផ្សេងៗ ដែលពាក់ព័ន្ធ និងលក្ខន្តិកៈរបស់ធនាគារ។ ក្នុងឆ្នាំ២០២១ កិច្ចប្រជុំប្រចាំឆ្នាំរបស់ភាគហ៊ុនិកបានប្រព្រឹត្តិទៅនាថ្ងៃទី២២ ខែមេសា ឆ្នាំ២០២១ និងកិច្ចប្រជុំវិសាមញ្ញរបស់ភាគហ៊ុនិក២ផ្សេងទៀតត្រូវបានប្រារព្ធឡើងនៅថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២១ និងថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០២១ ជាបន្តបន្ទាប់នៅការិយាល័យកណ្តាលរបស់ធនាគារ អេស៊ីលីដា។ ធនាគារបានប្រតិបត្តិដូចខាងក្រោម៖

មុនបើកកិច្ចប្រជុំ

សេចក្តីជូនដំណឹងអំពីកិច្ចប្រជុំ រួមមាន របៀបវារៈលម្អិត តួលេខសំខាន់ៗ សេចក្តីសម្រេច និងអនុសាសន៍របស់ក្រុមប្រឹក្សាភិបាល ឯកសារគាំទ្ររបៀបវារៈនីមួយៗ និងរបាយការណ៍ហិរញ្ញវត្ថុឆ្នាំ២០២០ ដែលបានរៀបចំដោយសវនករខាងក្រៅ។ សេចក្តីជូនដំណឹង និងឯកសារគាំទ្ររបៀបវារៈនីមួយៗ ត្រូវបានរៀបចំឡើងជាភាសាអង់គ្លេស និងបានផ្ញើជូនភាគហ៊ុនិកទាំងអស់ មុនពេលបើកកិច្ចប្រជុំប្រចាំឆ្នាំរបស់ភាគហ៊ុនិក និងកិច្ចប្រជុំវិសាមញ្ញរបស់ភាគហ៊ុនិក។

អំឡុងពេលប្រជុំ

កិច្ចប្រជុំភាគហ៊ុនិកសាមញ្ញ និងវិសាមញ្ញប្រចាំឆ្នាំ២០២១ បានដឹកនាំដោយប្រធានក្រុមប្រឹក្សាភិបាល។ ប្រធានអង្គប្រជុំបានអនុញ្ញាតិឲ្យភាគហ៊ុនិកទាំងអស់មានឱកាសគ្រប់គ្រាន់ ដើម្បីសាកសួរ និងផ្តល់អនុសាសន៍ ព្រមទាំងអាចស្នើសុំពន្យល់ ឬបញ្ជាក់បញ្ហាផ្សេងៗ ពីថ្នាក់គ្រប់គ្រង។ ថ្នាក់គ្រប់គ្រងក៏បានបញ្ជាក់ និងឆ្លើយសំណួរទាក់ទងនឹងបញ្ហាដែលពាក់ព័ន្ធនានា។ កំណត់ហេតុប្រជុំ និងមតិអនុម័តដោយការបោះឆ្នោតតាមរបៀបវារៈនីមួយៗ ត្រូវបានកត់ត្រាដោយលេខាធិការក្រុមហ៊ុនរបស់ធនាគារ។

ចំណុចចម្បងៗ ដែលបានអនុម័ត ក្នុងកិច្ចប្រជុំប្រចាំឆ្នាំ២០២១ មាន៖

១ ការអនុម័តលើការដំឡើងកម្រៃសេវារបស់ក្រុមប្រឹក្សាភិបាល ធនាគារ អេស៊ីលីដា ស្របតាមអត្រាអតិផរណាចំនួន២.៩០%។

២ ការអនុម័តលើការបែងចែកភាគលាភ (ដោយមានការអនុម័តពីនិយតករ) និងផ្ទេរសមតុល្យដែលនៅសល់ នៃប្រាក់ចំណេញក្រោយដកពន្ធ ទៅជាទុនបម្រុងទូទៅ។

៣ ការអនុម័តលើគោលការណ៍បែងចែកភាគលាភ។

៤ ការអនុម័តលើគោលការណ៍ស្តីពីការតែងតាំង និងលាភការរបស់ធនាគារ។

៥ ការអនុម័តលើការតែងតាំង Mr. Stéphane MANGIAVACCA, Mr. Albertus BRUGGINK, and Drs. Pieter KOOI ជាសមាជិកក្រុមប្រឹក្សាភិបាល សម្រាប់អាណត្តិថ្មី រយៈពេល៣ឆ្នាំបន្ថែមទៀត។

៦ ការទទួលយករបាយការណ៍ហិរញ្ញវត្ថុរួម និងរបាយការណ៍ហិរញ្ញវត្ថុដាច់ដោយឡែក សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០។

៧ ការទទួលយករបាយការណ៍ប្រធានក្រុមប្រឹក្សាភិបាលសម្រាប់ឆ្នាំ២០២០ និងស្ថានភាពសេដ្ឋកិច្ចប្រទេសកម្ពុជា។

៨ ការទទួលយករបាយការណ៍ប្រធាននាយកប្រតិបត្តិសម្រាប់ឆ្នាំ២០២០ និងផែនការយុទ្ធសាស្ត្រ សម្រាប់ ធនាគារ អេស៊ីលីដា និងក្រុមហ៊ុនបុត្រសម្ព័ន្ធ។

៩ ការអនុម័តលើការតែងតាំងលោកស្រី Ms. Phurik Ratana ជាអភិបាលឯករាជ្យ ជំនួសលោក Mr. Ian S. Lydall។

១០ ការអនុម័តលើការតែងតាំង Mr. Kyosuke Hattori មកពី SMBC ជាអភិបាលជំនួសលោក Mr. Kenichiro Mori។

១១ ការអនុម័តលើការការិនិយោគនៅវិទ្យាស្ថានធនាគារ និងហិរញ្ញវត្ថុ (IBF)។

១២ ការអនុម័តលើការផ្ទេរភាគហ៊ុនចំនួន៣,៥០% (បីកណ្តាក់សញ្ញាហាសិបភាគរយ) នៅធនាគារ អេស៊ីលីដា ពី Triodos (TMF, TFSF, and TSFF) ទៅ North Haven Thai Private Equity Rumdul Company (Hong Kong) Limited។

១៣ ការអនុម័តលើការទទួលស្គាល់ North Haven Thai Private Equity Rumdul Company (Hong Kong) Limited ជាភាគហ៊ុនិកថ្មីរបស់ធនាគារ អេស៊ីលីដា។

១៤ ការអនុម័តលើការទទួលស្គាល់ Mr. Ong Ling Wei មកពី North Haven Thai Private Equity Rumdul Company (Hong Kong) Limited ជាតំណាងភាគហ៊ុនិកថ្មីរបស់ធនាគារ អេស៊ីលីដា។

១៥ ការអនុម័តលើការកែប្រែលក្ខន្តិកៈរបស់ធនាគារ អេស៊ីលីដា។

១៦ ការអនុម័តលើការជ្រើសរើសក្រុមហ៊ុន Grant Thornton ជាសវនករឯករាជ្យប្រចាំធនាគារ សម្រាប់ឆ្នាំ២០២២។

បន្ទាប់ពីប្រជុំ

កំណត់ហេតុកិច្ចប្រជុំភាគហ៊ុនិកប្រចាំឆ្នាំ២០២១ និងកិច្ចប្រជុំភាគហ៊ុនិកវិសាមញ្ញ ត្រូវផ្ញើជូនគ្រប់ភាគហ៊ុនិកទាំងអស់ ដើម្បីពិនិត្យ មុននឹងអនុម័តនៅកិច្ចប្រជុំប្រចាំឆ្នាំបន្ទាប់។

ភាគហ៊ុនិក

ភាគហ៊ុនិកគឺជាម្ចាស់របស់ធនាគារ។ ភាគហ៊ុនិកមានសិទ្ធិអនុម័តលើកិច្ចការយុទ្ធសាស្ត្រនានា ក៏ប៉ុន្តែពុំមានសិទ្ធិអំណាចគ្រប់គ្រងផ្ទាល់លើកិច្ចការរបស់ធនាគារនោះទេ ដោយភាគហ៊ុនិកបានផ្ទេរការទទួលបន្ទុកទាំងនេះទៅឲ្យក្រុមប្រឹក្សាភិបាលតាមរយៈលក្ខន្តិកៈរបស់ធនាគារ។

អេស៊ីលីដា ហ្វាយណាន់ហ្សល់ ត្រាស់

AFT ជាអ្នកបន្តវេនពី អង្គការ អេស៊ីលីដា ដោយអនុលោមតាមអនុក្រឹត្យ លេខ: ៨៧៦ អនក្រ-បក ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៣ របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ស្តីពីបរធនបាលកិច្ចហិរញ្ញវត្ថុ និងប្រកាសលេខ: ១០៤១ សហវ-ប្រក ចុះថ្ងៃទី២៦ ខែកញ្ញា ឆ្នាំ២០១៤ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការគ្រប់គ្រង និងការត្រួតពិនិត្យបរធនបាលកិច្ចហិរញ្ញវត្ថុ។ AFT បានទទួលវិញ្ញាបនបត្រចុះបញ្ជីបរធនបាលកិច្ចហិរញ្ញវត្ថុ លេខ: ២៦៩ សហវ.អឧហ ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលមានការិយាល័យចុះបញ្ជីនៅ អគារលេខ៦១ មហាវិថីមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

AFT មានគោលបំណង និងតួនាទី ដូចខាងក្រោម៖

- បង្កើននូវកាលានុវត្តភាពការងារ និងផ្តល់ប្រភពចំណូល ដើម្បីចូលរួមអភិវឌ្ឍសេដ្ឋកិច្ចនៃព្រះរាជាណាចក្រកម្ពុជា។
- ជួយលើកស្ទួយ និងជួយគាំទ្រដល់ការរីកចម្រើននៃវិទ្យាសាស្ត្រពាក់ព័ន្ធនឹងការអភិវឌ្ឍវិស័យសេដ្ឋកិច្ច រួមមាន វិស័យធនាគារ និងហិរញ្ញវត្ថុ និងផ្តោតសំខាន់ទៅលើបរិយាប័ន្នហិរញ្ញវត្ថុ និងចំណេះដឹងផ្នែកហិរញ្ញវត្ថុ។
- លើកស្ទួយកាលានុវត្តភាពសេដ្ឋកិច្ច និងអប់រំដល់យុវជន និងប្រជាពលរដ្ឋ ដែលមានចំណូលទាប។
- ចូលរួមចំណែកការធ្វើឲ្យប្រសើរឡើងនូវសេវាកម្មហិរញ្ញវត្ថុ តាមរយៈ ធនាគារ អេស៊ីលីដា និងក្រុមហ៊ុនបុត្រសម្ព័ន្ធ ដើម្បីជំរុញការអភិវឌ្ឍសេដ្ឋកិច្ចក្នុងស្រុក។

AFT ជាភាគហ៊ុនិកមួយរបស់ធនាគារ អេស៊ីលីដា ដែលបានបង្កើតឡើង អនុលោមតាមច្បាប់នៃរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា មានគោលដៅលើកទឹកចិត្តដល់ធនាគារ អេស៊ីលីដា ឲ្យប្រកាន់ខ្ជាប់នូវគោលបំណងដើម ដើម្បីគាំទ្រដល់សហគ្រាសខ្នាតតូចបំផុត ខ្នាតតូច និងខ្នាតមធ្យម និងរក្សានូវសញ្ញាតិជាក្រុមហ៊ុនខ្មែរ របស់ធនាគារ អេស៊ីលីដា។ AFT ត្រូវបន្តអនុវត្តដោយផ្ទាល់ និងដាច់ដោយឡែកនូវគោលបំណងមិនរកប្រាក់ចំណេញ ដូចបានរៀបរាប់ខាងលើ។ AFT ធ្វើសកម្មភាពជាប្រយោជន៍ដល់ជនទូទៅ និងមិនអនុវត្តគោលបំណងចម្បង ដើម្បីផលប្រយោជន៍ពាណិជ្ជកម្មឯកជនផ្ទាល់ខ្លួនឡើយ។ AFT មិនមែនជាស្ថាប័ននយោបាយ និងមិនចំណុះឲ្យបក្សនយោបាយណាមួយឡើយ។ AFT អាចប្រើប្រាស់មធ្យោបាយហិរញ្ញវត្ថុដូចបានកំណត់នៅក្នុងលក្ខន្តិកៈនេះតែប៉ុណ្ណោះ។ គ្មានបុគ្គលណាមួយទទួលបានអត្ថប្រយោជន៍ពីការផ្តល់តម្លៃការខ្ពស់ដោយវិសមាមាត្រ ឬទទួលបានពីការចំណាយដែលផ្ទុយទៅនឹងគោលបំណងនៃ AFT ឡើយ។

ភាគហ៊ុនិកដែលធ្វើនិយ័តកម្មពីក្រុមហ៊ុន អេ អេស អេ ភីអិលស៊ី

ជាភាគហ៊ុនិកដែលតម្រូវឲ្យធ្វើនិយ័តកម្មពីក្រុមហ៊ុន អេ អេស អេ ភីអិលស៊ី។

Sumitomo Mitsui Banking Corporation (SMBC)

SMBC គឺជាធនាគារជប៉ុនធំមួយ ដែលមានប្រតិបត្តិការទូទាំងពិភពលោក។ តាមរយៈសាខាក្នុងស្រុក (មិនរាប់បញ្ចូលអនុសាខា និងភ្នាក់ងារធនាគារ) ក្នុងប្រទេសជប៉ុន និងសាខាក្រៅប្រទេស (រាប់បញ្ចូលទាំងបុត្រសម្ព័ន្ធ អនុសាខា និងការិយាល័យតំណាង) នៅទូទាំងពិភពលោក SMBC ផ្តល់សេវាកម្មយ៉ាងសម្បូរបែប មានដូចជាប្រាក់បញ្ញើ សាជីវកម្មហិរញ្ញវត្ថុ គម្រោងហិរញ្ញវត្ថុ ការវិនិយោគមូលបត្រ ការផ្ទេរប្រាក់ ការប្តូរប្រាក់ សេវាថែរក្សា និងគ្រប់គ្រងប័ណ្ណបំណុលសាជីវកម្ម សេវាធានាទិញមូលបត្រហិរញ្ញវត្ថុនាពេលអនាគត និងសេវា Investment Trust Sales។

SMBC ប្តេជ្ញាធ្វើការឆ្ពោះទៅគោលដៅរបស់ខ្លួន គឺ “ពន្លឿនយុទ្ធសាស្ត្រផ្តោតលើអាស៊ី”។ SMBC បានវិនិយោគធនធានរបស់ខ្លួនយ៉ាងសកម្មក្នុងប្រទេសជាច្រើននៅតំបន់អាស៊ី ដែលមានសក្តានុពលរីកចម្រើនខ្លាំង។ ដើម្បីផ្តល់ជូនអតិថិជនរបស់ធនាគារ អេស៊ីលីដា ឲ្យទទួលបាននូវសេវាកម្មហិរញ្ញវត្ថុសមាហរ័ណកម្មបានល្អប្រសើរ SMBC បានផ្តល់អ្នកជំនាញជាន់ខ្ពស់មកបម្រើការជាទីប្រឹក្សានៅក្នុងផ្នែកសាជីវកម្មអន្តរជាតិរបស់ធនាគារ អេស៊ីលីដា ចាប់តាំងពីឆ្នាំ២០១៣ មក។

ក្រុមហ៊ុនមេរបស់ SMBC គឺ Sumitomo Mitsui Financial Group, Inc. (SMFG) បានចុះបញ្ជីនៅផ្សារភាគហ៊ុនតូក្យូ Nagoya និង New York Exchange។ សម្រាប់ព័ត៌មានបន្ថែមអំពី SMBC សូមទស្សនាគេហទំព័រ៖ www.smfg.co.jp/english

COFIBRED – Compagnie Financière de la BRED (BRED's financial company)

COFIBRED គឺជាបុត្រសម្ព័ន្ធ របស់ BRED Banque Populaire ។ ដោយសារការអភិវឌ្ឍខ្លួនខ្លាំងលើឆាកអន្តរជាតិជាបន្តបន្ទាប់ BRED បានសម្រេចកែប្រែរចនាសម្ព័ន្ធទាំងអស់របស់ខ្លួនរួមមាន បុត្រសម្ព័ន្ធ និងផ្នែកដែលពាក់ព័ន្ធទាំងអស់ឱ្យស្ថិតនៅក្នុងសម្ព័ន្ធតែមួយក្នុងឆ្នាំ២០១៨ ដែលមានឈ្មោះថា Cofibred។ ទ្រព្យសកម្មសរុបរបស់របស់ Cofibred ត្រូវបានរួមបញ្ចូល ពីបុត្រសម្ព័ន្ធចំនួនជាង៨៥ និងស្ថាប័នផ្សេងទៀត ក្នុងវិស័យ ធនាគារ ធានារ៉ាប់រង អ៊ី-ខុមមើស និង/ឬក្រុមហ៊ុនហិរញ្ញវត្ថុនៅទូទាំងពិភពលោក។

ORIX Corporation

ក្រុមហ៊ុន ORIX (TSE: 8591; NYSE: IX) ជាក្រុមហ៊ុនផ្តល់សេវាកម្មហិរញ្ញវត្ថុវិនិយោគ និងប្រតិបត្តិការអាជីវកម្មលើវិស័យចំនួន៦ ដែលរួមមាន សេវាកម្មហិរញ្ញវត្ថុសាជីវកម្ម ភតិសន្យាហិរញ្ញវត្ថុ អចលនទ្រព្យ វិនិយោគ និងប្រតិបត្តិការសេវាកម្មលក់រាយ និងអាជីវកម្មក្រៅប្រទេស។ ORIX បានបង្កើតឡើងនៅឆ្នាំ១៩៦៨ ជាក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ ORIX បានរីកចម្រើនដោយឈានជើងទៅរកវិស័យពាក់ព័ន្ធ និងក្នុងតំបន់ ដើម្បីវិវឌ្ឍអាជីវកម្មរបស់ខ្លួន និងពង្រីកទៅទូទាំងប្រទេស។ តាមរយៈសកម្មភាពអាជីវកម្ម ORIX បានគិតគូរឥតឈប់ឈរពីតម្រូវការទីផ្សារ និងការងារ ដើម្បីចូលរួមចំណែកដល់សង្គម តាមរយៈការអភិវឌ្ឍសេវាកម្មហិរញ្ញវត្ថុឈានមុខគេទូទាំងពិភពលោក និងបន្តខិតខំផ្តល់ជូននូវសេវាកម្មប្រកបដោយភាពច្នៃប្រឌិត ដែលបង្កើតតម្លៃថ្មីសម្រាប់អតិថិជន។ សម្រាប់ព័ត៌មានបន្ថែម សូមទស្សនាគេហទំព័រ៖ www.orix.co.jp/grp/en

Triodos Microfinance Fund, Triodos Fair Share Fund និង Triodos Sustainable Finance Foundation

Triodos Sustainable Finance Foundation (អតីត Triodos-Doen Foundation), Triodos Fair Share Fund និង Triodos Microfinance Fund គឺជាមូលនិធិវិនិយោគបី ដែលគ្រប់គ្រងដោយ Triodos Investment Management។ Triodos Investment Management គឺជាបុត្រសម្ព័ន្ធពេញលេញ និងកាន់កាប់ភាគហ៊ុនចំនួន ១០០% ដោយធនាគារ Triodos ដែលជាធនាគារមួយ មាននិរន្តរភាពឈានមុខគេនៅលើពិភពលោក។ មូលនិធិនេះ ផ្តោតការយកចិត្តទុកដាក់ទៅលើការផ្តល់សេវាហិរញ្ញវត្ថុជូនប្រជាជន និងសហគ្រាសខ្នាតតូចនិងមធ្យមដែលមានចំណូលទាបនៅក្នុងប្រទេសកំពុងអភិវឌ្ឍ ដើម្បីរួមចំណែកក្នុងបរិយាប័ន្នហិរញ្ញវត្ថុប្រកបដោយនិរន្តរភាព។

Triodos Microfinance Fund

Triodo Microfinance Fund បានបង្កើតឡើងនៅក្នុងឆ្នាំ២០០៩ និងជាមូលនិធិបើក-បិទ ដោយមានថ្នាក់ភាគហ៊ុន សម្រាប់វិនិយោគិននីតិបុគ្គល អ្នកមានទ្រព្យសម្បត្តិច្រើន និងអតិថិជនធនាគារឯកជនទូទាំងទ្វីបអឺរ៉ុប។ សកម្មភាពចម្បងរបស់មូលនិធិនេះផ្តោតលើស្ថាប័នមីក្រូហិរញ្ញវត្ថុ និងធនាគារ សហគ្រាសធុនតូច និងមធ្យម ដែលបានបង្កើតឡើងដោយមានឯកសារបញ្ជាក់ត្រឹមត្រូវ។

Triodos Fair Share Fund (គ្រប់គ្រងដោយ Legal Owner Triodos Funds B.V.)

Triodos Fair Share Fund បានបង្កើតឡើងនាឆ្នាំ២០០២ ក្នុងប្រទេសហូលង់ គឺជាមូលនិធិដំបូងគេបង្អស់ និងដ៏កម្រនៅក្នុងពិភពលោក ដែលផ្តល់ឱកាសវិនិយោគក្នុងស្ថាប័នធនាគារធុនតូច និងធម្យមដល់សាធារណជនទូទៅ។

Triodos Sustainable Finance Foundation

Triodos Sustainable Finance Foundation មានគំនិតផ្តួចផ្តើមផ្តល់ហិរញ្ញវត្ថុដែលជួយពន្លឿនស្ថិរភាពនៃការអភិវឌ្ឍទូទាំងពិភពលោក ដោយផ្តោតលើបរិយាប័ន្នហិរញ្ញវត្ថុ។

ភាគហ៊ុនិកសាធារណៈ

ភាគហ៊ុនសាធារណៈគឺជាភាគហ៊ុនិកដែលបានទិញភាគហ៊ុនធនាគារអេស៊ីលីដា ដែលបានបោះផ្សាយលក់នៅលើផ្សារមូលបត្រកម្ពុជា ក្នុងដំណាក់កាលបោះផ្សាយលក់មូលបត្រកម្មសិទ្ធិ លើកដំបូងជាសាធារណៈ។

ក្រុមប្រឹក្សាភិបាល

សមាជិក-សមាជិកាក្រុមប្រឹក្សាភិបាល ត្រូវបានតែងតាំងដោយភាគហ៊ុនិកសម្រាប់អាណត្តិ ៣ឆ្នាំ ដើម្បីធ្វើសកម្មភាពតំណាងឱ្យពួកគេផ្ទាល់ ។ តាមលក្ខន្តិក:បានបញ្ជាក់ថា សមាសភាពក្រុមប្រឹក្សាភិបាលត្រូវមាន ១០រូប និង ៖

- ក្រុមប្រឹក្សាភិបាល ទទួលខុសត្រូវលើការកំណត់យុទ្ធសាស្ត្រ របស់ធនាគារ និងគ្រប់គ្រងរាល់ប្រតិបត្តិការអាជីវកម្ម ។ សមាជិក-សមាជិកាក្រុមប្រឹក្សាភិបាលទាំងអស់ ត្រូវធ្វើកិច្ចការ ដើម្បីជាប្រយោជន៍ខ្ពស់បំផុត សម្រាប់ធនាគារ ។
- អំណាចរបស់ក្រុមប្រឹក្សាភិបាលត្រូវអនុវត្តរួមគ្នា ហើយគ្មានសមាជិក-សមាជិកាណាម្នាក់មានអំណាចក្នុងការផ្តល់ការណែនាំ ឬបង្គាប់បញ្ជាតែឯកឯងលើថ្នាក់ដឹកនាំ ឬបុគ្គលិកណាម្នាក់របស់ធនាគារ ឬចុះហត្ថលេខាលើកិច្ចសន្យា ឬដឹកនាំគ្រប់គ្រងប្រតិបត្តិការរបស់ធនាគារបានឡើយ លើកលែងតែមានការផ្ទេរអំណាចជាក់លាក់ឱ្យអនុវត្ត តាមរយៈសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ។
- សមាជិក-សមាជិកាម្នាក់ៗ អាចពិនិត្យដោយគ្មានកំណត់ ចំពោះឯកសារ និងកំណត់ត្រាផ្សេងៗរបស់ធនាគារ គ្រប់ពេលម៉ោងធ្វើការ ។

ក្រុមប្រឹក្សាភិបាល ធ្វើការជ្រើសតាំងនូវសមាជិកម្នាក់ ឱ្យធ្វើជាប្រធានក្រុមប្រឹក្សាភិបាល តាមរយៈការបោះឆ្នោត ដោយយកតាមសំឡេងភាគច្រើនហើយបុគ្គលនោះជាអ្នកដឹកនាំ នូវរាល់កិច្ចប្រជុំក្រុមប្រឹក្សាភិបាល ក៏ដូចជាមហាសន្និបាតប្រចាំឆ្នាំ ។

ក្រុមប្រឹក្សាភិបាល ទទួលខុសត្រូវលើអភិបាលកិច្ចសាជីវកម្ម និងជំរុញអភិវឌ្ឍន៍ជោគជ័យរបស់ធនាគារ តាមរយៈការដឹកនាំរាល់ប្រតិបត្តិការការងារ និងអាជីវកម្ម ។ ក្រុមប្រឹក្សាភិបាលជាអ្នកតែងតាំង និងអាចដកតំណែងរបស់ប្រធាននាយកប្រតិបត្តិ ។ ក្រុមប្រឹក្សាភិបាលក៏ធានាផងដែរថាធនធានមនុស្ស ដែលចាំបាច់មានគ្រប់គ្រាន់ក្នុងការបង្កើតយុទ្ធសាស្ត្រ និងគោលដៅហិរញ្ញវត្ថុជាមួយថ្នាក់គ្រប់គ្រង ដើម្បីដាក់ឱ្យថ្នាក់គ្រប់គ្រងអនុវត្ត ព្រមទាំងត្រួតពិនិត្យលើការអនុវត្តរបស់ថ្នាក់គ្រប់គ្រងដោយផ្ទាល់ និងតាមរយៈគណៈកម្មាធិការក្រុមប្រឹក្សាភិបាល ។

ក្រុមប្រឹក្សាភិបាលបានបង្កើតគណៈកម្មាធិការ ចំនួន៣ ដូចជា គណៈកម្មាធិការសវនកម្ម គណៈកម្មាធិការតែងតាំង និងលាភការ គណៈកម្មាធិការគ្រប់គ្រងហានិភ័យ និងព័ត៌មានវិទ្យា ព្រមទាំងបង្កើតនូវ គណៈកម្មាធិការផ្សេងទៀត អាស្រ័យទៅតាមតម្រូវការចាំបាច់ ដើម្បីដំណើរការប្រតិបត្តិការអាជីវកម្មរបស់ធនាគារ ។ គណៈកម្មាធិការរបស់ក្រុមប្រឹក្សាភិបាលទាំងនេះ ត្រូវបង្កើតឡើងអាស្រ័យទៅនឹងក្រុមប្រឹក្សាភិបាល ហើយសមាជិក-សមាជិកាទាំងអស់នៅក្នុងគណៈកម្មាធិការ នឹងត្រូវអនុម័តដោយក្រុមប្រឹក្សាភិបាល ។ គណៈកម្មាធិការទាំងនេះ មិនអនុវត្តអំណាចរបស់ក្រុមប្រឹក្សាភិបាលឡើយ លើកលែងតែមានការផ្ទេរសិទ្ធិអំណាចជាផ្លូវការ តែត្រូវផ្តល់អនុសាសន៍ដល់ក្រុមប្រឹក្សាភិបាល ចំពោះសកម្មភាពរួមរបស់ពួកគេ ។ គួរបញ្ជាក់ផងដែរថា សមាជិកភាពនៃគណៈកម្មាធិការមិនកំណត់ថា ត្រូវតែជាសមាជិក-សមាជិកាក្រុមប្រឹក្សាភិបាលនោះទេ ពោលគឺអាចជាអ្នកគ្រប់គ្រង ឬបុគ្គលណាផ្សេងទៀត ដែលសមស្របក្នុងតួនាទីរបស់គណៈកម្មាធិការនីមួយៗ ។ ប៉ុន្តែប្រធាននៃគណៈកម្មាធិការក្រុមប្រឹក្សាភិបាល គឺចាំបាច់ត្រូវតែជាសមាជិក-សមាជិការបស់ក្រុមប្រឹក្សាភិបាល ។ គណៈកម្មាធិការទាំងអស់ត្រូវមានប្រធានជាអភិបាលឯករាជ្យ ។

លោក ឆាយ សឿន ប្រធានក្រុមប្រឹក្សាភិបាល

គណៈកម្មាធិការក្រុមប្រឹក្សាភិបាល ៖ គណៈកម្មាធិការសវនកម្ម

ជនជាតិខ្មែរ កើតក្នុងខែមេសា ឆ្នាំ១៩៥៤ ។ លោកបានចូលរួមក្នុងក្រុមប្រឹក្សាភិបាល នៅខែសីហា ឆ្នាំ២០១៨ ។ លោកបានចូលបម្រើការជាមួយធនាគារ អេស៊ីលីដា ចាប់តាំងពីខែមករា ឆ្នាំ១៩៩៣ រហូតដល់ចូលនិវត្តន៍នៅថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៤ ។ តួនាទីចុងក្រោយមុនចូលនិវត្តន៍របស់លោកនៅក្នុងធនាគារ អេស៊ីលីដា ជាអនុប្រធាននាយកប្រតិបត្តិ និងជាគណៈប្រធាននាយកប្រតិបត្តិហិរញ្ញវត្ថុ ។ លោកធ្លាប់ធ្វើជាគណនេយ្យករនិងជាអនុប្រធានគណនេយ្យករនៃមន្ទីរពាណិជ្ជកម្មខេត្តកំពតចាប់ពីឆ្នាំ១៩៨០ដល់ឆ្នាំ១៩៩២។

បច្ចុប្បន្នលោកជាប្រធានក្រុមប្រឹក្សាភិបាលនៃ ធនាគារ អេស៊ីលីដា, សមាជិកក្រុមប្រឹក្សាភិបាលនៃ ABL, និងសមាជិកក្រុមប្រឹក្សាភិបាលនៃAMM ។

លោកបានបញ្ចប់ថ្នាក់អនុបណ្ឌិតប្រតិបត្តិគ្រប់គ្រងពាណិជ្ជកម្ម ជំនាញហិរញ្ញវត្ថុ និងគណនេយ្យ ពីសាកលវិទ្យាល័យ Preston នៅសហរដ្ឋអាមេរិក ។ លោកក៏បានបញ្ចប់វគ្គសិក្សាស្តីពីអភិបាលក្រុមហ៊ុន ពី GAICD ។

បណ្ឌិត អ៊ុន ចាន់នី អភិបាល

បណ្ឌិត អ៊ុន ចាន់នី ជាជនជាតិខ្មែរ កើតក្នុងខែមិថុនា ឆ្នាំ១៩៦០ ។ លោកបណ្ឌិត ជាប្រធាននាយកប្រតិបត្តិ របស់ធនាគារ អេស៊ីលីដា ចាប់តាំងពីធនាគារបានបង្កើតឡើងនៅក្នុងឆ្នាំ២០០០ ។ លោកបណ្ឌិតបានក្លាយជាសមាជិកក្រុមប្រឹក្សាភិបាលរបស់ ធនាគារ អេស៊ីលីដា នៅខែសីហា ឆ្នាំ២០១៤។ បណ្ឌិត អ៊ុន ចាន់នី ជាសហស្ថាបនិករបស់ សមាគមទីភ្នាក់ងារអភិវឌ្ឍន៍សេដ្ឋកិច្ចក្នុងស្រុកកម្ពុជា (អេស៊ីលីដា) តាំងពីខែមករា ឆ្នាំ១៩៩៣ ។ ក្នុងតួនាទីជាប្រធាននាយកប្រតិបត្តិ លោកបណ្ឌិតដឹកនាំគណៈកម្មាធិការប្រតិបត្តិដែលទទួលខុសត្រូវរៀបចំផែនការយុទ្ធសាស្ត្ររួម និងដំណើរការងារអាជីវកម្មប្រចាំថ្ងៃ ព្រមទាំងប្រតិបត្តិផែនការអាជីវកម្មរបស់ធនាគារ អេស៊ីលីដា និងក្រុមហ៊ុនបុត្រសម្ព័ន្ធ។ លោកបណ្ឌិតទទួលខុសត្រូវផ្ទាល់ចំពោះក្រុមប្រឹក្សាភិបាល ។

ទំនួលខុសត្រូវផ្សេងទៀតរបស់លោកបណ្ឌិត រួមមាន ជាប្រធានក្រុមប្រឹក្សាភិបាល ABL និងAMM ព្រមទាំងជាតំណាងភាគហ៊ុនិក របស់ ABL, ACS, AIB, និងAMM ។ លោកបណ្ឌិតក៏ជាប្រធានក្រុមប្រឹក្សាភិបាលរបស់ AFT។

បណ្ឌិត អ៊ុន ចាន់នី ជាសមាជិកក្រុមប្រឹក្សាភិបាលរបស់ EDF ជាបរធនបាលកិច្ចបង្កើតឡើងដោយរាជរដ្ឋាភិបាលកម្ពុជា។ លោកបណ្ឌិតក៏ជាប្រធានសមាគមធនាគារនៅកម្ពុជា។ លោកបណ្ឌិតជាអ្នកតំណាងឱ្យធនាគារ អេស៊ីលីដា ដែលជាសមាជិករបស់វេទិកាសេដ្ឋកិច្ចពិភពលោក ។

នៅក្នុងឆ្នាំ១៩៩៨ លោកបណ្ឌិតបានបញ្ចប់វគ្គគ្រប់គ្រងស្តីពី FIPED ពីសាកលវិទ្យាល័យ Harvard សហរដ្ឋអាមេរិក។ លោកបណ្ឌិតបានបញ្ចប់ការសិក្សាថ្នាក់បណ្ឌិត ផ្នែកគ្រប់គ្រងអាជីវកម្ម និងបានបញ្ចប់វគ្គសិក្សាស្តីពី អភិបាលក្រុមហ៊ុនពី GAICD។

លោក រ័ត្ន យូម៉េង អភិបាល

ជនជាតិខ្មែរ កើតក្នុងឆ្នាំ១៩៦២ ។ លោក រ័ត្ន យូម៉េង បានបម្រើការឱ្យធនាគារ អេស៊ីលីដា ចាប់ពីខែមករា ឆ្នាំ១៩៩៩ ។ ចាប់ពីខែមករា ឆ្នាំ១៩៩៩ ដល់ខែសីហា ឆ្នាំ២០០៨ លោកបានកាន់តំណែងជាច្រើននៅក្នុងធនាគារ អេស៊ីលីដា ដូចជា ៖ ប្រធានគណនេយ្យករ និងអនុប្រធានហិរញ្ញវត្ថុ (ខែមករា ឆ្នាំ១៩៩៩ ដល់ខែឧសភា ឆ្នាំ២០០៧) ជានាយកនាយកដ្ឋានហិរញ្ញវត្ថុ (ខែមិថុនា ឆ្នាំ២០០៧ ដល់ខែសីហា ឆ្នាំ២០០៨) និងជានាយកប្រតិបត្តិរតនាភិបាល (ខែកញ្ញា ឆ្នាំ២០០៨ ដល់ខែឧសភា ឆ្នាំ២០១៥) និងជា អនុប្រធាននាយកប្រតិបត្តិ និងជាគណៈប្រធាននាយកប្រតិបត្តិរតនាភិបាល (ខែមិថុនា ឆ្នាំ២០១៥ ដល់បច្ចុប្បន្ន) ។

លោកទទួលខុសត្រូវដឹកនាំក្រុមគ្រប់គ្រង និងត្រួតពិនិត្យរតនាភិបាល ដូចជា ៖ នាយកដ្ឋានប្រតិបត្តិការហិរញ្ញវត្ថុ, ការិយាល័យរតនាភិបាល, ការិយាល័យប្រាក់តម្កល់ និងអត្រាប្តូររូបិយប័ណ្ណ និងការិយាល័យរតនពាណិជ្ជកម្ម ។ លោកក៏ជាអ្នកគាំទ្រផ្នែកបច្ចេកទេសដល់ក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ធនាគារ អេស៊ីលីដា ទាក់ទងនឹងការគ្រប់គ្រងមូលនិធិ ។

ចាប់ពីឆ្នាំ២០០១ ដល់ខែកញ្ញា ឆ្នាំ២០១៤ លោកជាអ្នកតំណាងភាគហ៊ុនិករបស់ ASA Plc. ដែលជាភាគហ៊ុនិកក្នុងស្រុកមួយរបស់ធនាគារ អេស៊ីលីដា។ នៅខែសីហា ឆ្នាំ២០១៤ លោកបានក្លាយជាសមាជិកក្រុមប្រឹក្សាភិបាលរបស់ ធនាគារ អេស៊ីលីដា រហូតដល់បច្ចុប្បន្ន។

លោកបានបញ្ចប់ថ្នាក់អនុបណ្ឌិតផ្នែកធនាគារ និងហិរញ្ញវត្ថុ ពីសាកលវិទ្យាល័យ វេស្ទើន នៅទីក្រុងភ្នំពេញ និងបានបញ្ចប់វគ្គសិក្សាស្តីពី អភិបាលក្រុមហ៊ុនពី GAICD ។

លោក Pieter Kooi អភិបាល

គណៈកម្មាធិការក្រុមប្រឹក្សាភិបាល ៖ គណៈកម្មាធិការគ្រប់គ្រងហានិភ័យ និងព័ត៌មានវិទ្យា (ប្រធាន), គណៈកម្មាធិការតែងតាំង និងលាភការ, គណៈកម្មាធិការសវនកម្ម

ជនជាតិហូល្លង់ កើតក្នុងឆ្នាំ១៩៥៨ បានចូលរួមក្នុងក្រុមប្រឹក្សាភិបាលនៅខែតុលា ឆ្នាំ២០០០ ។ ចាប់ពីឆ្នាំ១៩៩៣ លោកបានធ្វើជាទីប្រឹក្សាមីក្រូហិរញ្ញវត្ថុឱ្យអេស៊ីលីដា រយៈពេលជាង ៧ឆ្នាំ ដើម្បីកម្លាយខ្លួនពីកម្មវិធីអភិវឌ្ឍន៍ទៅជាធនាគារពាណិជ្ជ ។ ចាប់ពីឆ្នាំ១៩៩៩ បណ្ឌិត Pieter KOOI បានបម្រើការងារជាទីប្រឹក្សាមីក្រូហិរញ្ញវត្ថុរយៈពេលខ្លី ដល់ស្ថាប័នមីក្រូហិរញ្ញវត្ថុ នៅក្នុង ១៥ប្រទេស ដែលភាគច្រើនស្ថិតក្នុងទ្វីបអ្រាហ្វិក និងអាស៊ី ។ ចាប់ពីខែកញ្ញា ឆ្នាំ២០០២ ដល់ខែធ្នូ ឆ្នាំ២០០៥ លោកមានតួនាទីជានាយកផ្នែកមីក្រូហិរញ្ញវត្ថុរបស់ UNCDF ក្នុងទីក្រុងញូយ៉ក ។ ចាប់ពីខែមីនា ឆ្នាំ២០០៦ រហូតដល់ខែឧសភា ឆ្នាំ២០១១ លោកបានធ្វើជាទីប្រឹក្សាក្រៅម៉ោងឱ្យធនាគារ អេស៊ីលីដា ក្នុងការបង្កើត ABL, អេស៊ីលីដា ត្រេននីង សេនធ័រ (បច្ចុប្បន្នជា AIB), និង ACS ។ បច្ចុប្បន្នលោកធ្វើជាក្រុមប្រឹក្សាភិបាលនៅក្នុងសម្ព័ន្ធធនាគារ ។

លោកទទួលបានអនុបណ្ឌិតផ្នែកហិរញ្ញវត្ថុសាជីវកម្ម និងសង្គមវិទ្យា នៅសាកលវិទ្យាល័យ Erasmus ក្នុងទីក្រុង Rotterdam ប្រទេសហូល្លង់ ។ លោកក៏បានបញ្ចប់ការសិក្សាពី GAICD ។

លោកស្រី ភូរិ រតនា អភិបាល

ជនជាតិខ្មែរ (សញ្ជាតិបារាំង) កើតនៅឆ្នាំ១៩៧២។ លោកស្រី ភូរិ រតនា ជាសមាជិកក្រុមប្រឹក្សាភិបាលនាខែវិច្ឆិកា ឆ្នាំ២០២១។ លោកស្រីជា CFA Charterholder។ លើសពីនេះលោកស្រី ទទួលបានសញ្ញាបត្រថ្នាក់ក្រោយបរិញ្ញាបត្រ (DEA) និងជាបេក្ខជនបណ្ឌិត ជំនាញ ឧស្សាហកម្មសេដ្ឋកិច្ច បរិញ្ញាបត្រជាន់ខ្ពស់វិទ្យាសាស្ត្រ ជំនាញ ពាណិជ្ជកម្មបរទេស និងបរិញ្ញាបត្រជាន់ខ្ពស់សេដ្ឋកិច្ច និងហិរញ្ញវត្ថុ ពីសាកលវិទ្យាល័យប៉ារីស១ Panthéon-Sorbonne។

លោកស្រី រតនា មានបទពិសោធន៍ជាង២០ឆ្នាំ ក្នុងវិស័យពាណិជ្ជកម្មអន្តរជាតិ ការវិនិយោគ ការអភិវឌ្ឍវិស័យឯកជន និងហិរញ្ញវត្ថុ។ លោកស្រីមានប្រវត្តិឆ្នើមជាទីប្រឹក្សា/អ្នកសេដ្ឋកិច្ច រួមទាំងមានបទពិសោធន៍ផ្ទាល់នៅក្នុងតួនាទីជាអ្នកគ្រប់គ្រងជាន់ខ្ពស់។ បច្ចុប្បន្ន លោកស្រី គឺជាទីប្រឹក្សាជាន់ខ្ពស់ សម្រាប់ការវិនិយោគ និងវិស័យឯកជនឲ្យអង្គការអន្តរជាតិផ្សេងៗ និងជាក្រុមប្រឹក្សាផ្តល់យោបល់ដល់សហគ្រាសខ្មែរ អ៊ីមីផែកហាប់ និងស្ថលវើល។ លោកស្រីគឺជាអភិបាលឯករាជ្យនៅធនាគារពាណិជ្ជមួយនៅកម្ពុជា ចាប់ពីឆ្នាំ២០១៨ ដល់ ២០២១ និងនៅ I-Finance Leasing ចាប់ពីឆ្នាំ២០១៨។ បន្ថែមលើនេះ លោកស្រីគឺជាស្ថាបនិក និងជាប្រធានក្រុមប្រឹក្សាភិបាលនៅ Cambodia Community of Investment Professionals (សមាគមន៍ CFA នៅកម្ពុជា) ដើម្បីបណ្តុះបណ្តាលជំនាញក្នុងស្រុកផ្នែកហិរញ្ញវត្ថុ ដើម្បីលើកកម្ពស់កម្ពុជាឲ្យក្លាយជាគោលដៅវិនិយោគ។ តួនាទីកន្លងមកនៅកម្ពុជារបស់លោកស្រីមានជាអាទិ៍ អភិបាលប្រតិបត្តិ EuroCham Cambodia ពីឆ្នាំ២០១៤ ដល់ ២០១៨ ទីប្រឹក្សាធុរកិច្ចនៅ DFDL ដៃគូនៅ private equity firm Cambodia Emerald នៅឆ្នាំ២០០៨ និងអភិបាលនៅ CCFC (French Cambodian Chamber of Commerce)។ លោកស្រីធ្លាប់ធ្វើការនៅប្រទេសស្វីស ក្នុងតួនាទីជា អ្នកគ្រប់គ្រងផលបត្រ នៅធនាគារឯកជនមួយ និងជាអ្នកសេដ្ឋកិច្ចនៅ UNCTAD។

លោក វ៉ាន់ ស៊ូអ៊ៀង អភិបាល

គណៈកម្មាធិការក្រុមប្រឹក្សាភិបាល ៖ គណៈកម្មាធិការតែងតាំង និងលាភការ (ប្រធាន)

ជនជាតិខ្មែរ កើតឆ្នាំ១៩៥៣។ លោក វ៉ាន់ ស៊ូអ៊ៀង បានចូលជាសមាជិកក្រុមប្រឹក្សាភិបាលរបស់ធនាគារអេស៊ីលីដា នៅក្នុងខែកញ្ញា ឆ្នាំ២០២០។ បច្ចុប្បន្នលោកមានតួនាទីនៅក្នុងស្ថាប័នជាច្រើនដូចជា៖ ប្រធានសហព័ន្ធនិយោជន និងសមាគមពាណិជ្ជកម្មកម្ពុជា (CAMFEBA), ប្រធានក្រុមប្រឹក្សាភិបាលសមាគមរោងចក្រកាត់ដេរនៅកម្ពុជា (GMAC), សមាជិក ASEAN Business Advisory Council (ABAC), សមាជិក ASEAN Federation of Textile Industries (AFTEX), ប្រធានកិត្តិយស Cambodia Federation of Equestrian (CFE), អនុប្រធានក្រុមប្រឹក្សាភិបាល National Training Board (NTB), សហប្រធាន Government-Private Sector Working Group, សមាជិក Labor Advisory Committee (LAC), អនុប្រធានក្រុមប្រឹក្សាភិបាល Labor Dispute Resolution Advisory Committee, សមាជិកក្រុមប្រឹក្សាភិបាលបេឡាជាតិសន្តិសុខសង្គម (ប.ស.ស.), Member of Committee of the Review of Cambodia's Implementation of the UN Convention on Anti-Corruption Law, និង Member of the Inception Committee of the National Commercial Arbitration NAC.

លោកក៏មានតួនាទីជា អនុប្រធានក្រុមប្រឹក្សាភិបាល អេស៊ីអា អ៊ិនសូរិន (ខេមបូឌា), អនុប្រធានក្រុមប្រឹក្សាភិបាល Asia properties Cambodia Ltd, ប្រធានក្រុមប្រឹក្សាភិបាល PPS Garment Factory, ប្រធាន PPS Industrial Estate Holding Co., Ltd., ប្រធាន Cambodian Country Club (CCC), ប្រធាន ហ្គោលដេន សូរិយា ម៉ល និងជាប្រធាន boutique Hotel named La Plantation Resort and SPA។

លោកបានបញ្ចប់ការសិក្សាថ្នាក់គណិតវិទ្យា និងវិទ្យាសាស្ត្ររូបវិទ្យា ពីសាលា ACADEMIES DE CRETEIL ក្នុងតំបន់ Fontainebleau ទីក្រុងប៉ារីស នាឆ្នាំ១៩៧២។ លោកក៏បានបញ្ចប់ការសិក្សាពី INSTITUT SUPERIEUR DE GESTION ក្នុងទីក្រុងប៉ារីស ប្រទេសបារាំង នាឆ្នាំ១៩៧៦។

លោក Stéphane MANGIAVACCA អភិបាល

ជនជាតិបារាំង។ លោក Mangiavacca ជាសមាជិកក្រុមប្រឹក្សាភិបាលរបស់ធនាគារ អេស៊ីលីដា ចាប់តាំងពីខែមីនា ឆ្នាំ២០២០មក។ លោកបានចាប់ផ្តើមការងារក្នុងក្រសួងហិរញ្ញវត្ថុបារាំង ប្រចាំការនៅប្រទេសចិន។ បន្ទាប់មកលោកបានក្លាយជានាយកជាន់ខ្ពស់ Quantitative Audit នៃសវនកម្មផ្នែកក្នុងនៃសម្ព័ន្ធ BPCE។ លោកបានចូលបម្រើការងារឱ្យ BRED Banque Populaire ក្នុងឆ្នាំ២០០៩។ លោកមានតួនាទីជាគណៈប្រធាននាយកប្រតិបត្តិហានិភ័យ និងអនុលោមបញ្ញត្តិ របស់សម្ព័ន្ធ BRED មុនក្លាយជាសមាជិកក្រុមប្រឹក្សាភិបាលប្រតិបត្តិ និងជានាយកកិច្ចការអន្តរជាតិ ចាប់តាំងពីឆ្នាំ២០២០។ លោកក៏ជាសមាជិកក្រុមប្រឹក្សាភិបាលនៃបណ្តាធនាគារមួយចំនួនរបស់សម្ព័ន្ធ BRED នៅក្នុងប្រទេសបារាំង និងបណ្តាប្រទេសនានាលើពិភពលោក។ លោកបានបញ្ចប់ការសិក្សាពី ECOLE NATIONALE SUPERIEURE DES SAINT-ETIENNE ជំនាញវិស្វកម្ម និងបានសិក្សានៅ University of New Brunswick ក្នុងប្រទេសកាណាដា។

លោក Kyosuke Hattori អភិបាល

ជនជាតិជប៉ុន កើតក្នុងឆ្នាំ១៩៧៥។ លោក Kyosuke Hattori ជាសមាជិកក្រុមប្រឹក្សាភិបាល នាខែវិច្ឆិកា ឆ្នាំ២០២១។ លោកបានចាប់ផ្តើមការងារជាមួយធនាគារ Sumitomo (បច្ចុប្បន្នជា SMBC) ក្រោយបញ្ចប់ការសិក្សាពីសាកលវិទ្យាល័យសូហ្ស៊ៀ។ នៅខែមេសា ឆ្នាំ២០០១ លោក Hattori ត្រូវបានតែងតាំងជាជំនួយការការិយាល័យធុរកិច្ចសាជីវកម្មស៊ីន-យូហ្គោហាម៉ា នៅ SMBC។ នៅខែតុលា ឆ្នាំ២០០២ លោក Hattori ត្រូវបានតែងតាំងជាជំនួយការការិយាល័យសេវាកម្មហិរញ្ញវត្ថុសាជីវកម្ម នៅរាជធានីតូក្យូ។ នៅខែធ្នូ ឆ្នាំ២០០៣ លោកត្រូវបានផ្ទេរទៅធ្វើការនៅសាខាសិង្គបុរី។ នៅខែកក្កដា ឆ្នាំ២០០៥ លោកត្រូវបានដំឡើងតំណែងជា Vice President នៃសាខាសិង្គបុរី។ នៅខែកក្កដា ឆ្នាំ២០០៩ លោកត្រូវបានតែងតាំងជា Vice President នៃការិយាល័យទំនាក់ទំនងសាធារណៈនៅរាជធានីតូក្យូ។ នៅខែតុលា ឆ្នាំ២០១២ លោកត្រូវបានដំឡើងតំណែងជា Senior Vice President នៃការិយាល័យផែនការសាជីវកម្ម នៅរាជធានីតូក្យូ។ លោកត្រូវបានផ្លាស់ប្តូរកន្លែងធ្វើការទៅធ្វើការនៅនាយកដ្ឋានធុរកិច្ចទីផ្សារកំពុងរីកលូតលាស់ និងការិយាល័យផែនការ ផ្នែកធនាគារអន្តរជាតិ នៅខែមេសា ឆ្នាំ២០១៨ និង២០១៦ ជាបន្តបន្ទាប់។ នៅខែមេសា ឆ្នាំ២០១៧ លោកត្រូវបានដំឡើងតំណែងជា Senior Vice President and Group Head នៃការិយាល័យផែនការ ផ្នែកធនាគារអន្តរជាតិ។ នៅខែមេសា ឆ្នាំ២០២០ លោកត្រូវបានផ្លាស់ប្តូរកន្លែងធ្វើការទៅបម្រើការងារនៅការិយាល័យអភិវឌ្ឍធុរកិច្ច នៅរាជធានីតូក្យូ។ បន្ទាប់មក លោកត្រូវបានផ្លាស់ប្តូរការងារទៅប្រទេសសិង្គបូរី នៅខែមិថុនា ឆ្នាំ២០២១ ក្នុងតួនាទីជាសហប្រធានគ្រប់គ្រងទូទៅការិយាល័យផែនការ នាយកដ្ឋានអាស៊ីប៉ាស៊ីហ្វិក។ លោកបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ ឯកទេសច្បាប់ នៅខែមីនា ឆ្នាំ១៩៩៨។

លោក Albertus Bruggink អភិបាល

ជាជនជាតិហូលង់ដ៍ កើតក្នុងឆ្នាំ១៩៦៣។ លោក Albertus Bruggink បានចូលរួមក្រុមប្រឹក្សាភិបាលនៅខែឧសភា ឆ្នាំ២០២១។ លោកទទួលបានសញ្ញាបត្របណ្ឌិត និងបរិញ្ញាបត្រជាន់ខ្ពស់ គ្រប់គ្រងអាជីវកម្ម ពី Twente University of Technology។

ក្រៅពីធនាគារ អេស៊ីលីដា បច្ចុប្បន្នលោកធ្វើជាទីប្រឹក្សាឯករាជ្យនៅប្រទេសហូលង់ដ៍ និងធ្វើជាអ្នកប្រឹក្សាសាជីវកម្មរបស់ក្រុមហ៊ុន ORIX Corporation នៅទីក្រុងតូក្យូ។ ក្នុងឆ្នាំ២០១៦ លោក Bruggink បានលាលែងពីតំណែងជាប្រធានហិរញ្ញវត្ថុរបស់ធនាគារ Rabobank បន្ទាប់ពីបានបម្រើការអស់រយៈពេល១២ឆ្នាំ។ លោកក៏បម្រើការងារនៅធនាគារ Robobank អស់រយៈពេល៣០ឆ្នាំ ហើយលោកបានកាន់មុខតំណែងជាច្រើន ដូចជា ហិរញ្ញវត្ថុ គ្រប់គ្រងហានិភ័យ និងទីផ្សារមូលធន-រតនាភិបាល ទាំងក្នុងស្រុក និងអន្តរជាតិ។ ក្នុងកំលុងពេលបម្រើការងារ លោកជា សមាជិកក្រុមប្រឹក្សាភិបាលជាច្រើន នៅក្នុងប្រទេសហូលង់ដ៍ និងកាន់តំណែងជាប្រធានគណៈកម្មាធិការសវនកម្ម នៃក្រុមប្រឹក្សាភិបាលជាច្រើនអាណត្តិផងដែរ។ លោកទទួលបានសញ្ញាបត្រអនុបណ្ឌិត ជំនាញ គ្រប់គ្រងពាណិជ្ជកម្ម ពីសាកលវិទ្យាល័យ Twente នៅឆ្នាំ១៩៨៦ និងសញ្ញាបត្របណ្ឌិត ជំនាញ វិស្វកម្មហិរញ្ញវត្ថុ ពីសាកលវិទ្យាល័យ Twente នៅឆ្នាំ១៩៨៩។ បច្ចុប្បន្ន លោកគឺជាសាស្ត្រាចារ្យ ជំនាញ វិស្វកម្មហិរញ្ញវត្ថុ និងគ្រប់គ្រងហានិភ័យ នៅសាកលវិទ្យាល័យ Twente។

បន្ថែមលើនេះ លោកក៏មានតួនាទីជាសមាជិកនៃក្រុមប្រឹក្សាផ្តល់យោបល់ របស់ Medisch Spectrum Twente (ហូលង់ដ៍), Ormat Technologies (សហរដ្ឋអាមេរិក), TFG and XAC bank (ម៉ុងហ្គោលី) និង Gravis Capital Management (ចក្រភពអង់គ្លេស)។

លោក កាយ ឡូត អភិបាល

ជនជាតិខ្មែរ កើតក្នុងឆ្នាំ១៩៧០។ លោក កាយ ឡូត បានចូលរួមក្នុងក្រុមប្រឹក្សាភិបាលនៅខែឧសភា ឆ្នាំ២០២១។ លោកជាសហគ្រិនម្នាក់ដែលមានបទពិសោធន៍គ្រប់គ្រងជាន់ខ្ពស់ ផ្នែកហិរញ្ញវត្ថុ, ធនាគារ, ផ្សព្វផ្សាយ និងទូរគមនាគមន៍។ កាលពីមុនលោកធ្លាប់បានបម្រើការជាអភិបាលឯករាជ្យ និងជាប្រធានគណៈកម្មាធិការសវនកម្ម របស់ស្ថាប័នមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើ ធំជាងគេមួយនៅកម្ពុជា។

បច្ចុប្បន្នលោកគឺជាវិនិយោគិនសកម្មមួយរូបក្នុងវិស័យគំនិតផ្តួចផ្តើមបច្ចេកវិទ្យា និងជាម្ចាស់ភាគហ៊ុននៅក្នុងក្រុមហ៊ុនផ្សព្វផ្សាយឌីជីថល និងសំណង់។ លោកក៏ជាអភិបាលឯករាជ្យរបស់ក្រុមហ៊ុន BSP Finance Cambodia និង Digital Divide Data ដែលជាក្រុមហ៊ុនសិក្សាផលប៉ះពាល់សង្គម មានមូលដ្ឋាននៅក្រុងញូវយ៉ក។

លោកបានទទួលបរិញ្ញាបត្រ ជំនាញគ្រប់គ្រងអាជីវកម្ម ពីសកលវិទ្យាល័យ Kennedy Western ក្នុងប្រទេសឥណ្ឌូនេស៊ី។ លោកក៏បានទទួលវិញ្ញាបនបត្រ IFRS ពី The Association of Chartered Certified Accountants (ACCA)។

គណៈកម្មាធិការប្រតិបត្តិ

ប្រធាននាយកប្រតិបត្តិត្រូវបានតែងតាំងឡើងដោយ ក្រុមប្រឹក្សាភិបាល ដើម្បីទទួលខុសត្រូវ និងមានសិទ្ធិពេញលេញ ក្នុងការចាត់ចែងការងារប្រចាំថ្ងៃរបស់ធនាគារ នៅក្នុងរង្វង់គោលការណ៍ និងយុទ្ធសាស្ត្រ ដែលបានអនុម័តដោយក្រុមប្រឹក្សាភិបាល ។ ទោះជាយ៉ាងណា ភាពច្បាស់លាស់ នៃសិទ្ធិអំណាចអាចត្រូវបានកំណត់ដោយក្រុមប្រឹក្សាភិបាល និងការកត់ត្រាទុកជាផ្លូវការនៅក្នុង "Letters of Reserved Matters" ។

ប្រធាននាយកប្រតិបត្តិ ជាអ្នកតែងតាំង និងដឹកនាំគណៈកម្មាធិការប្រតិបត្តិ ដែលរួមមាន សមាសភាពនៃថ្នាក់ដឹកនាំជាន់ខ្ពស់ ដែលលោកយល់ឃើញថាសមស្រប (ករណីមានការផ្លាស់ប្តូរណាមួយ ត្រូវជូនដំណឹងទៅក្រុមប្រឹក្សាភិបាលឱ្យបានទាន់ពេលវេលា) ។ ប្រធាននាយកប្រតិបត្តិជាអ្នកកំណត់ពេលវេលាប្រជុំ និងកិច្ចដំណើរការ នៃគណៈកម្មាធិការប្រតិបត្តិ ក្រោមការដឹកនាំផ្ទាល់ ប្រកបដោយភាពមធ្យ័តទៅលើ៖

- យុទ្ធសាស្ត្រផ្ទាល់៖ អភិវឌ្ឍគោលការណ៍ កំណត់គោលដៅ យុទ្ធសាស្ត្រ និងទិសដៅ សម្រាប់ដាក់ជូនក្រុមប្រឹក្សាភិបាល ដើម្បីអនុម័ត ។
- ការអនុវត្ត៖ ប្រមូលផ្តុំនូវរាល់ធនធាន ដើម្បីអនុវត្តទៅតាមយុទ្ធសាស្ត្រ ដែលបានព្រមព្រៀង និងប្រតិបត្តិទៅតាមគោលដៅ ដែលបានកំណត់ ។
- ហានិភ័យ៖ កំណត់ និងវាយតម្លៃទៅលើហានិភ័យ នៅក្នុងយុទ្ធសាស្ត្ររបស់ធនាគារ និងចាត់ចែងបញ្ហាដែលកើតឡើង ។
- ការប្រតិបត្តិ៖ ធានាថាធនាគារប្រតិបត្តិស្របតាមតម្រូវការ របស់សាជីវកម្ម ច្បាប់ និងបទប្បញ្ញត្តិផ្សេងៗ ។

បណ្ឌិត អ៊ុន ចាន់នី

ប្រធាននាយកប្រតិបត្តិ



បណ្ឌិត អ៊ុន ចាន់នី ជាជនជាតិខ្មែរ កើតក្នុងខែមិថុនា ឆ្នាំ១៩៦០ ។ លោកបណ្ឌិត ជាប្រធាននាយកប្រតិបត្តិ របស់ធនាគារ អេស៊ីលីដា ភីអិលស៊ី ចាប់តាំងពីធនាគារបានបង្កើតឡើងនៅក្នុងឆ្នាំ២០០០ ។ លោកបណ្ឌិតបានក្លាយជាសមាជិកក្រុមប្រឹក្សាភិបាលរបស់ ធនាគារ អេស៊ីលីដា ភីអិលស៊ី នៅខែសីហា ឆ្នាំ២០១៤។ បណ្ឌិត អ៊ុន ចាន់នី ជាសហស្ថាបនិករបស់ សមាគមទីភ្នាក់ងារអភិវឌ្ឍន៍សេដ្ឋកិច្ចក្នុងស្រុកកម្ពុជា (អេស៊ីលីដា) តាំងពីខែមករា ឆ្នាំ១៩៩៣ ។ ក្នុងតួនាទីជាប្រធាននាយកប្រតិបត្តិ លោកបណ្ឌិតដឹកនាំគណៈកម្មាធិការប្រតិបត្តិ ដែលទទួលខុសត្រូវរៀបចំផែនការយុទ្ធសាស្ត្ររួម និងដំណើរការងារអាជីវកម្មប្រចាំថ្ងៃ ព្រមទាំងប្រតិបត្តិផែនការអាជីវកម្មរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី និងក្រុមហ៊ុនបុត្រសម្ព័ន្ធ។ លោកបណ្ឌិតទទួលខុសត្រូវផ្ទាល់ចំពោះក្រុមប្រឹក្សាភិបាល ។

ទំនួលខុសត្រូវផ្សេងទៀតរបស់លោកបណ្ឌិត រួមមាន ជាប្រធានក្រុមប្រឹក្សាភិបាលធនាគារ អេស៊ីលីដា ឡាវ និងស្ថាប័នមីក្រូហិរញ្ញវត្ថុ អេស៊ីលីដា មីយ៉ាន់ម៉ា ព្រមទាំងជាតំណាងភាគហ៊ុនិក របស់ ធនាគារ អេស៊ីលីដា ឡាវ អេស៊ីលីដា ស៊ីឃ្យូរ៉ីធី ភីអិលស៊ី វិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា និងស្ថាប័នមីក្រូហិរញ្ញវត្ថុ អេស៊ីលីដា មីយ៉ាន់ម៉ា ។ លោកបណ្ឌិតក៏ជាប្រធានក្រុមប្រឹក្សាភិបាលរបស់អេស៊ីលីដា ហ្វាយណាន់ហ្សូល់ ត្រាស់។

បណ្ឌិត អ៊ុន ចាន់នី ជាសមាជិកក្រុមប្រឹក្សាភិបាលរបស់ Entrepreneurship Development Fund (EDF) ជាបរធនបាលកិច្ចបង្កើតឡើងដោយរាជរដ្ឋាភិបាលកម្ពុជា។ លោកបណ្ឌិតក៏ជាប្រធានសមាគមធនាគារនៅកម្ពុជា។ លោកបណ្ឌិតជាអ្នកតំណាងឱ្យធនាគារ អេស៊ីលីដា ភីអិលស៊ី ដែលជាសមាជិករបស់រេទិកាសេដ្ឋកិច្ចពិភពលោក ។

នៅក្នុងឆ្នាំ១៩៩៨ លោកបណ្ឌិតបានបញ្ចប់វគ្គគ្រប់គ្រងស្តីពី ស្ថាប័នហិរញ្ញវត្ថុសម្រាប់អភិវឌ្ឍន៍សហគ្រាសឯកជន (FIPED) ពីសាកលវិទ្យាល័យ Harvard សហរដ្ឋអាមេរិក។ លោកបណ្ឌិតបានបញ្ចប់ការសិក្សាថ្នាក់បណ្ឌិត ផ្នែកគ្រប់គ្រងអាជីវកម្ម និងបានបញ្ចប់វគ្គសិក្សាស្តីពី អភិបាលក្រុមហ៊ុនពីវិទ្យាស្ថានអូស្ត្រាលីសម្រាប់អភិបាលក្រុមហ៊ុន (GAICD)។

- បណ្ឌិត ឡឹង សុភាព អនុប្រធាននាយកប្រតិបត្តិ និងជាគណៈប្រធាននាយកប្រតិបត្តិហានិភ័យ
- លោក ម៉ាច ផៃរ៉ី អនុប្រធាននាយកប្រតិបត្តិ និងជាគណៈប្រធាននាយកប្រតិបត្តិព័ត៌មានវិទ្យា
- លោក លី ថៃ អនុប្រធាននាយកប្រតិបត្តិ និងជាគណៈប្រធាននាយកប្រតិបត្តិអភិបាលកិច្ច
- លោក រ័ត្ន យូម៉េង អនុប្រធាននាយកប្រតិបត្តិ ជាន់ខ្ពស់ និងជាគណៈប្រធាននាយកប្រតិបត្តិរតនាភិបាល
- បណ្ឌិត អ៊ុន ចាន់នី ប្រធាននាយកប្រតិបត្តិ
- បណ្ឌិត សូ ផនណារ៉ា អនុប្រធាននាយកប្រតិបត្តិ ជាន់ខ្ពស់ និងជាគណៈប្រធាននាយិកាប្រតិបត្តិប្រតិបត្តិការ
- លោកស្រី ម៉ារ អមរា អនុប្រធាននាយកប្រតិបត្តិ ជាន់ខ្ពស់ និងជាគណៈប្រធាននាយិកាប្រតិបត្តិហិរញ្ញវត្ថុ
- លោកស្រី ប៊ុត ប៊ុនសីហា អនុប្រធាននាយកប្រតិបត្តិ និងជាគណៈប្រធាននាយិកាប្រតិបត្តិនីតិកម្ម និងលេខាធិការក្រុមហ៊ុន

បណ្ឌិត សូ ផនណារី

អនុប្រធាននាយកប្រតិបត្តិជាន់ខ្ពស់ និងជាគណៈប្រធាននាយិកាប្រតិបត្តិប្រតិបត្តិការ

ជនជាតិខ្មែរ កើតក្នុងខែវិច្ឆិកា ឆ្នាំ១៩៦៣ ។ លោកស្រីបណ្ឌិតបានចូលបម្រើការនៅអេស៊ីលីដា ចាប់តាំងពីថ្ងៃទី១៨ ខែសីហា ឆ្នាំ១៩៩៣ ។

ក្នុងមុខតំណែងជា អនុប្រធាននាយកប្រតិបត្តិជាន់ខ្ពស់ និងជាគណៈប្រធាននាយិកាប្រតិបត្តិប្រតិបត្តិការ លោកស្រីបណ្ឌិតជាសមាជិកា គណៈកម្មាធិការប្រតិបត្តិ ទទួលបន្ទុកដឹកនាំលើប្រតិបត្តិការរបស់ធនាគារ និងគ្រប់គ្រង៦នាយកដ្ឋាន និង១ការិយាល័យ ដែលរួមមាន នាយកដ្ឋានប្រតិបត្តិការ នាយកដ្ឋានទីផ្សារ នាយកដ្ឋានអភិវឌ្ឍន៍ផលិតផល នាយកដ្ឋានសេវាឥណទាន នាយកដ្ឋានសេវាហិរញ្ញវត្ថុ ការិយាល័យហិរញ្ញប្បទានពាណិជ្ជកម្ម និងនាយកដ្ឋានផែនការយុទ្ធសាស្ត្រ។ លោកស្រីបណ្ឌិតទទួលបន្ទុកគ្រប់គ្រងផែនការយុទ្ធសាស្ត្រ និងប្រតិបត្តិការអាជីវកម្មប្រចាំថ្ងៃរបស់ធនាគារ ដោយអភិវឌ្ឍន៍ និងស្រាវជ្រាវសេវាថ្មីៗរបស់ធនាគារ ព្រមទាំងធ្វើផែនការនិងអនុវត្តកំណើននៃការលក់ ។ លោកស្រីបណ្ឌិតទទួលខុសត្រូវទៅលើការដឹកនាំ ត្រួតពិនិត្យ និងវាយតម្លៃលើប្រតិបត្តិការអាជីវកម្មប្រចាំថ្ងៃរបស់ធនាគារ ។

លោកស្រីបណ្ឌិតជាប្រធាន គណៈកម្មាធិការគ្រប់គ្រងផលប័ត្រ និងប្រធានគណៈកម្មាធិការផែនការយុទ្ធសាស្ត្រ ។ លោកស្រីជាសមាជិកាគណៈកម្មាធិការគ្រប់គ្រងទ្រព្យសកម្ម និងអកម្ម និងគណៈកម្មាធិការឥណទាននៃថ្នាក់គ្រប់គ្រង ។

លោកស្រីបណ្ឌិតទទួលខុសត្រូវចំពោះប្រធាននាយកប្រតិបត្តិ ។

លោកស្រីបានបញ្ចប់ថ្នាក់បណ្ឌិត ផ្នែកគ្រប់គ្រងធុរកិច្ច និងបានបញ្ចប់វគ្គសិក្សាស្តីពីអភិបាលក្រុមហ៊ុន ពីវិទ្យាស្ថានអូស្ត្រាលីសម្រាប់ អភិបាលក្រុមហ៊ុន (GAICD) ។

- លោក នេត ពិសិដ្ឋ នាយកប្រតិបត្តិសេវាហិរញ្ញវត្ថុ
- លោក សុខ សុវុត្ថី នាយកប្រតិបត្តិប្រតិបត្តិការ
- លោក ចរ សុភាព នាយកប្រតិបត្តិ អភិវឌ្ឍន៍ផលិតផល
- លោក សុត សារ៉ន នាយកប្រតិបត្តិជាន់ខ្ពស់ គ្រប់គ្រងសេវាឥណទាន
- បណ្ឌិត សូ ផនណារី អនុប្រធាននាយកប្រតិបត្តិជាន់ខ្ពស់ និងជាគណៈប្រធាននាយិកា ប្រតិបត្តិប្រតិបត្តិការ
- លោកស្រី សុខ សោភា នាយិកាប្រតិបត្តិ ជាន់ខ្ពស់ទីផ្សារ
- លោកស្រី អ៊ុំ សោភា នាយិកាការិយាល័យ ហិរញ្ញប្បទានពាណិជ្ជកម្ម
- លោក ស្វាយ ហ៊ៃ នាយកប្រតិបត្តិជាន់ខ្ពស់ ផែនការយុទ្ធសាស្ត្រ

លោកស្រី ម៉ារ អមរា

អនុប្រធាននាយកប្រតិបត្តិជាន់ខ្ពស់ និងជាគណៈប្រធាននាយិកាប្រតិបត្តិហិរញ្ញវត្ថុ

ជនជាតិខ្មែរ កើតក្នុងខែកញ្ញា ឆ្នាំ១៩៦៧ និងបានបម្រើការនៅអេស៊ីលីដា ចាប់តាំងពីខែមិថុនា ឆ្នាំ១៩៩៣ ។ ក្នុងមុខតំណែងជាអនុប្រធាននាយកប្រតិបត្តិជាន់ខ្ពស់ និងជាគណៈប្រធាននាយិកាប្រតិបត្តិហិរញ្ញវត្ថុ លោកស្រីក៏ជាសមាជិកគណៈកម្មាធិការប្រតិបត្តិ ទទួលបន្ទុកគ្រប់គ្រងផែនការយុទ្ធសាស្ត្រ និងប្រតិបត្តិការអាជីវកម្ម ប្រចាំថ្ងៃរបស់ធនាគារ ព្រមទាំងប្រតិបត្តិផែនការអាជីវកម្ម ។ លោកស្រីជាប្រធាន គណៈកម្មាធិការគ្រប់គ្រងទ្រព្យសកម្ម និងអកម្ម និងសមាជិកគណៈកម្មាធិការគ្រប់គ្រងហានិភ័យកម្រិតប្រតិបត្តិ គណៈកម្មាធិការអភិវឌ្ឍផែនការយុទ្ធសាស្ត្រ និងគណៈកម្មាធិការឥណទានកម្រិតប្រតិបត្តិ ។ លោកស្រីក៏ជាអ្នកដឹកនាំការងារ Basel Team ផងដែរ ។ លោកស្រីគ្រប់គ្រងលើនាយកដ្ឋានហិរញ្ញវត្ថុ នាយកដ្ឋានរៀបចំ និងត្រួតពិនិត្យផែនការថវិកា នាយកដ្ឋានវិនិយោគសាធារណ និងការិយាល័យគណនេយ្យគ្រប់គ្រង ។ លោកស្រីទទួលខុសត្រូវផ្ទាល់ចំពោះប្រធាននាយកប្រតិបត្តិ ។

ទំនួលខុសត្រូវផ្សេងទៀតរបស់លោកស្រីរួមមាន ៖ ជាប្រធានក្រុមប្រឹក្សាភិបាល អេស៊ីលីដា ស៊ីឃ្យូរីធី ភីអិលស៊ី និងជាអនុប្រធាននៃអេស៊ីលីដា ហ្វាយណាន់ហ្សូល ត្រាស់ ។

លោកស្រីបានបញ្ចប់វគ្គសិក្សាស្តីពី អភិបាលក្រុមហ៊ុន ពីវិទ្យាស្ថានអូស្ត្រាលីសម្រាប់អភិបាលក្រុមហ៊ុន (GAICD) ក្នុងឆ្នាំ២០១៨ និងបានទទួលបរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអាជីវកម្ម ជំនាញហិរញ្ញវត្ថុនៅសាកលវិទ្យាល័យជាតិគ្រប់គ្រងនៅក្នុងរាជធានីភ្នំពេញ ក្នុងឆ្នាំ២០០៦ និងបានបញ្ចប់បរិញ្ញាបត្រពាណិជ្ជសាស្ត្រ ជំនាញគ្រប់គ្រង ក្នុងឆ្នាំ២០០៣ ។ ក្រៅពីនោះនៅមានវគ្គសិក្សាជាច្រើន ដូចជា គណនេយ្យគ្រប់គ្រង គណនេយ្យហិរញ្ញវត្ថុ និងសវនកម្ម ជាដើម នៅសាកលវិទ្យាល័យ Regent ពីឆ្នាំ១៩៩៦ ដល់ឆ្នាំ១៩៩៨ នៅក្នុងរាជធានីភ្នំពេញ ។

- លោក ឌីក ពៅចន្ទាលា នាយកប្រតិបត្តិរៀបចំ និងត្រួតពិនិត្យផែនការថវិកា
- លោក គួយ រាសនា នាយកប្រតិបត្តិ វិនិយោគសាធារណៈ
- លោកស្រី ម៉ារ អមរា អនុប្រធាននាយកប្រតិបត្តិជាន់ខ្ពស់ និងជាគណៈប្រធាននាយិកាប្រតិបត្តិហិរញ្ញវត្ថុ
- លោកស្រី ម៉េង ម៉ារីយ៉ាន នាយិកាប្រតិបត្តិហិរញ្ញវត្ថុ
- លោកស្រី តូច ច័ន្ទសុភា នាយិកាការិយាល័យគណនេយ្យគ្រប់គ្រង

លោក រ័ត្ន យូម៉ង

អនុប្រធាននាយកប្រតិបត្តិជាន់ខ្ពស់ និងជាគណៈប្រធាននាយកប្រតិបត្តិរតនាភិបាល

ជនជាតិខ្មែរ កើតក្នុងឆ្នាំ១៩៦២ ។ លោក រ័ត្ន យូម៉ង បានបម្រើការឱ្យអេស៊ីលីដា ចាប់ពីខែមករា ឆ្នាំ១៩៩៩ ។ ចាប់ពីខែមករា ឆ្នាំ១៩៩៩ ដល់ខែសីហា ឆ្នាំ២០០៨ លោកបានកាន់តំណែងជាច្រើននៅក្នុងធនាគារ អេស៊ីលីដា ដូចជា ៖ ប្រធានគណនេយ្យករ និងអនុប្រធានហិរញ្ញវត្ថុ (ខែមករា ឆ្នាំ១៩៩៩ ដល់ខែឧសភា ឆ្នាំ២០០៧) ជានាយកនាយកដ្ឋានហិរញ្ញវត្ថុ (ខែមិថុនា ឆ្នាំ២០០៧ ដល់ខែសីហា ឆ្នាំ២០០៨) និងជានាយកប្រតិបត្តិរតនាភិបាល (ខែកញ្ញា ឆ្នាំ២០០៨ ដល់ខែឧសភា ឆ្នាំ២០១៥) និងជាអនុប្រធាននាយកប្រតិបត្តិ និងជាគណៈប្រធាននាយកប្រតិបត្តិរតនាភិបាល (ខែមិថុនា ឆ្នាំ២០១៥ ដល់បច្ចុប្បន្ន) ។

លោកទទួលខុសត្រូវដឹកនាំក្រុមគ្រប់គ្រង និងត្រួតពិនិត្យរតនាភិបាល ដូចជា ៖ នាយកដ្ឋានប្រតិបត្តិការហិរញ្ញវត្ថុ, ការិយាល័យរតនាភិបាល, ការិយាល័យប្រាក់តម្កល់ និងអត្រាប្តូររូបិយប័ណ្ណ និងការិយាល័យរតនពាណិជ្ជកម្ម ។ លោកក៏ជាអ្នកគាំទ្រផ្នែកបច្ចេកទេសដល់ក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី ទាក់ទងនឹងការគ្រប់គ្រងមូលនិធិ ។

ចាប់ពីឆ្នាំ២០០១ ដល់ខែកញ្ញា ឆ្នាំ២០១៤ លោកជាអ្នកតំណាងភាគហ៊ុនិករបស់ក្រុមហ៊ុន អេ អេស អេ ដែលជាភាគហ៊ុនិកក្នុងស្រុកមួយរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី ។ នៅខែសីហា ឆ្នាំ២០១៤ លោកបានក្លាយជាសមាជិកក្រុមប្រឹក្សាភិបាលរបស់ ធនាគារ អេស៊ីលីដា ភីអិលស៊ី ។

លោកបានបញ្ចប់ថ្នាក់អនុបណ្ឌិតផ្នែកធនាគារ និងហិរញ្ញវត្ថុ ពីសាកលវិទ្យាល័យវេស្ទើន នៅទីក្រុងភ្នំពេញ និងបានបញ្ចប់វគ្គសិក្សាស្តីពី អភិបាលក្រុមហ៊ុនពី វិទ្យាស្ថានអូស្ត្រាលីសម្រាប់អភិបាលក្រុមហ៊ុន (GAICD) ។

- លោក ប្រាក់ ច័ន្ទារាសនា
  នាយកការិយាល័យរតនពាណិជ្ជកម្ម
- លោកស្រី សុវណ្ណ ឫទ្ធា
  នាយិការប្រតិបត្តិប្រតិបត្តិការហិរញ្ញវត្ថុ
- លោក រ័ត្ន យូម៉ង
  អនុប្រធាននាយកប្រតិបត្តិជាន់ខ្ពស់ និងជាគណៈប្រធាននាយកប្រតិបត្តិរតនាភិបាល
- លោក រ៉ុធ ហេង
  នាយកជាន់ខ្ពស់ការិយាល័យប្រាក់តម្កល់ និងអត្រាប្តូររូបិយប័ណ្ណ
- លោក ថាន់ សារ៉ុន
  នាយកជាន់ខ្ពស់ការិយាល័យរតនាភិបាល

លោក លី ថៃ

អនុប្រធាននាយកប្រតិបត្តិ
និងជាគណៈប្រធាននាយកប្រតិបត្តិអភិបាលកិច្ច

ជនជាតិខ្មែរ កើតក្នុងខែតុលា ឆ្នាំ១៩៧៥ និងបានបម្រើការនៅអេស៊ីលីដា ចាប់តាំងពីខែធ្នូ ឆ្នាំ១៩៩៧ ។ លោកបានចូលបម្រើការជាមួយអេស៊ីលីដា ក្នុងតួនាទីជា ៖ គណនេយ្យករ (១៩៩៧-១៩៩៩) សវនករផ្ទៃក្នុង (១៩៩៩-២០០០) បេឡាធិការ នាយកសាខា និងនាយកការិយាល័យប្រតិបត្តិការ (២០០០-២០០៤) នាយកនាយកដ្ឋានប្រតិបត្តិការ (២០០៤-២០០៦) និងនាយកប្រតិបត្តិប្រតិបត្តិការ (២០០៦-២០១៦) ។

ក្នុងមុខតំណែងជាអនុប្រធាននាយកប្រតិបត្តិ និងជាគណៈប្រធាននាយកប្រតិបត្តិអភិបាលកិច្ច លោកក៏ជាសមាជិកគណៈកម្មាធិការប្រតិបត្តិ ទទួលបន្ទុកគ្រប់គ្រងផែនការយុទ្ធសាស្ត្រ និងប្រតិបត្តិការអាជីវកម្មប្រចាំថ្ងៃរបស់ធនាគារ ។ លោកទទួលបន្ទុកគ្រប់គ្រង នាយកដ្ឋានធនធានមនុស្ស និងនាយកដ្ឋានរដ្ឋបាល។ លោកទទួលខុសត្រូវដោយផ្ទាល់ចំពោះប្រធាននាយកប្រតិបត្តិ ។

ទំនួលខុសត្រូវផ្សេងទៀតរបស់លោក ជាប្រធានក្រុមប្រឹក្សាភិបាល របស់វិទ្យាស្ថានពាណិជ្ជសាស្ត្រ អេស៊ីលីដា ។

លោកបានទទួលបរិញ្ញាបត្រជាន់ខ្ពស់ ជំនាញហិរញ្ញវត្ថុ ពីសាកលវិទ្យាល័យ បញ្ញាសាស្ត្រ ក្នុងឆ្នាំ២០០៨ ។

- លោកស្រី ពៅ ទិត្យមិថុនា
  នាយិកាប្រតិបត្តិរដ្ឋបាល
- លោក លី ថៃ
  អនុប្រធាននាយកប្រតិបត្តិ និងជាគណៈប្រធាន
  នាយកប្រតិបត្តិអភិបាលកិច្ច
- លោក ហ្ស រតនៈ
  នាយកប្រតិបត្តិធនធានមនុស្ស

លោកស្រី ប៊ុត ប៊ុនសីហា

អនុប្រធាននាយកប្រតិបត្តិ និងជាគណៈប្រធាន នាយិកាប្រតិបត្តិនីតិកម្ម និងលេខាធិការក្រុមហ៊ុន

ជនជាតិខ្មែរ កើតក្នុងខែសីហា ឆ្នាំ១៩៨០ និងបានបម្រើការនៅអេស៊ីលីដា ចាប់តាំងពីខែតុលា ឆ្នាំ២០០៧ ។

ក្នុងមុខតំណែងជាអនុប្រធាននាយកប្រតិបត្តិ និងជាគណៈប្រធាននាយិកាប្រតិបត្តិនីតិកម្ម និងលេខាធិការក្រុមហ៊ុន លោកស្រីក៏ជាសមាជិកាគណៈកម្មាធិការប្រតិបត្តិ ទទួលបន្ទុកគ្រប់គ្រងផែនការយុទ្ធសាស្ត្ររួម និងប្រតិបត្តិការអាជីវកម្មប្រចាំថ្ងៃរបស់ធនាគារ ដោយអនុលោមទៅតាមបទបញ្ញត្តិ ព្រមទាំងទំនាក់ទំនងជាមួយភាគហ៊ុនិក និងក្រុមប្រឹក្សាភិបាល ។ លោកស្រីទទួលបន្ទុកគ្រប់គ្រងលើនាយកដ្ឋាននីតិកម្ម នាយកដ្ឋានលេខាធិការក្រុមហ៊ុន និងបង្ហាញព័ត៌មាន ការិយាល័យគ្រប់គ្រងវិវាទ និងការិយាល័យប្រឹក្សាបុត្រសម្ព័ន្ធ ។ លោកស្រីទទួលខុសត្រូវដោយផ្ទាល់ចំពោះប្រធាននាយកប្រតិបត្តិ ។

លោកស្រីទទួលបានបរិញ្ញាបត្រ និងអនុបណ្ឌិតផ្នែកច្បាប់ ។

- លោក សារ៉ាណ្ណ ម៉ាលីកា
  នាយកការិយាល័យគ្រប់គ្រងវិវាទ
- លោក កែ គឹមសឿន
  នាយកប្រតិបត្តិនីតិកម្ម
- លោកស្រី ប៊ុត ប៊ុនសីហា
  អនុប្រធាននាយកប្រតិបត្តិ និងជាគណៈប្រធាន
  នាយិកាប្រតិបត្តិនីតិកម្ម និងលេខាធិការក្រុមហ៊ុន
- លោក យិន រ៉ារ៉ៃ
  នាយកប្រតិបត្តិលេខាធិការក្រុមហ៊ុន
  និងបង្ហាញព័ត៌មាន
- លោក កែវ ឆពណ្ណពិសី
  នាយកការិយាល័យប្រឹក្សាបុត្រសម្ព័ន្ធ

លោក ម៉ាច ធៃរី

អនុប្រធាននាយកប្រតិបត្តិ
និងជាគណៈប្រធាននាយកប្រតិបត្តិព័ត៌មានវិទ្យា

ជនជាតិខ្មែរ កើតក្នុងខែវិច្ឆិកា ឆ្នាំ១៩៦៥ ។ លោក ម៉ាច ធៃរី បានបម្រើការងារឱ្យអង្គការ-ស្ថាប័នជាច្រើន ដូចជា ធនាគារ ANZ ក្នុងប្រទេសអូស្ត្រាលី សាកលវិទ្យាល័យ Monash, UNHCR ប្រចាំប្រទេសកម្ពុជា អង្គការទស្សនៈពិភពលោកកម្ពុជា អង្គការពលកម្មអន្តរជាតិ និងចុងក្រោយធ្វើជាទីប្រឹក្សាឱ្យអង្គការ អេស៊ីលីដា ក្នុងរយៈពេល៥ឆ្នាំ ។ លោកបានចូលបម្រើការពេញម៉ោងនៅធនាគារ អេស៊ីលីដា ក្នុងខែកក្កដា ឆ្នាំ២០០០ ។ លោក ម៉ាច ធៃរី បានកាន់តំណែងជានាយកប្រតិបត្តិបច្ចេកវិជ្ជាព័ត៌មាន នៃធនាគារ អេស៊ីលីដា ចាប់តាំងពីខែកក្កដា ឆ្នាំ២០០៦ ដល់ខែធ្នូ ឆ្នាំ២០១៧ ។ បន្ទាប់មកលោកក៏ត្រូវបានតែងតាំងជាអនុប្រធាននាយកប្រតិបត្តិ និងជាគណៈប្រធាននាយកប្រតិបត្តិព័ត៌មានវិទ្យា ។ លោកក៏ធ្វើជាប្រធានគណៈកម្មាធិការ IT Steering ផងដែរ។ បច្ចុប្បន្ន លោកជាសមាជិកគណៈកម្មាធិការប្រតិបត្តិ, សមាជិកនៃគណកម្មាធិការនៃក្រុមប្រឹក្សាភិបាល និងសមាជិកនៃគណៈកម្មាធិការផ្សេងទៀតផងដែរ។ ក្នុងតួនាទីជាអនុប្រធាននាយកប្រតិបត្តិ និងជាគណៈប្រធាននាយកប្រតិបត្តិព័ត៌មានវិទ្យា លោកទទួលបន្ទុកគ្រប់គ្រងដោយផ្ទាល់លើនាយកដ្ឋានចំនួន៦ ដែលមានបុគ្គលិកបច្ចេកទេសសរុបជាង៥០០នាក់។

លោកទទួលបានបរិញ្ញាបត្រផ្នែកវិទ្យាសាស្ត្រ ជំនាញវិទ្យាសាស្ត្រកុំព្យូទ័រនិងស្ថិតិ ពីសាកលវិទ្យាល័យ Monash នៅប្រទេសអូស្ត្រាលី ក្នុងឆ្នាំ១៩៨៩ ។ បន្ទាប់មកលោកបានបន្តការសិក្សាផ្នែកប្រព័ន្ធអាជីវកម្ម (Business Systems) និងបានទទួលសញ្ញាបត្រ ក្នុងឆ្នាំ១៩៩០ ពីសាកលវិទ្យាល័យដដែលនោះ ។

- លោកស្រី សោម ចិន្តាមុនី
  នាយិការិយាល័យសេវាកម្មព័ត៌មានវិទ្យា
- លោក អ៊ុក ស្រស់
  នាយកប្រតិបត្តិរៀបចំយុទ្ធសាស្ត្រ និងអភិបាលព័ត៌មានវិទ្យា
- លោក សេង សុខនាង
  នាយកប្រតិបត្តិគ្រប់គ្រងសេវាកម្មឌីជីថល
- លោក ម៉ាច ធៃរី
  អនុប្រធាននាយកប្រតិបត្តិ និងជាគណៈប្រធាននាយកប្រតិបត្តិព័ត៌មានវិទ្យា
- លោក មៀង តាយ
  នាយកប្រតិបត្តិគ្រប់គ្រងសេវាកម្មផ្នែកទន់
- លោក ឆាយ យ៉ារដ្ឋ
  នាយកប្រតិបត្តិសន្តិសុខព័ត៌មានវិទ្យា
- លោក គង់ ដានី
  នាយកប្រតិបត្តិប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធ

បណ្ឌិត ឡឿង សុភាព

អនុប្រធាននាយកប្រតិបត្តិ
និងជាគណៈប្រធាននាយកប្រតិបត្តិហានិភ័យ

ជនជាតិខ្មែរ កើតក្នុងខែមីនា ឆ្នាំ១៩៦៧ ។ លោកបានបម្រើការងារជាមួយ អេស៊ីលីដា ចាប់តាំងពីខែធ្នូ ឆ្នាំ១៩៩៧ ជាគណនេយ្យករ ។ ចាប់ពីពេលនោះមក លោកបានកាន់តំណែង និងតួនាទីផ្សេងៗជាច្រើននៅក្នុងធនាគារ ។ បច្ចុប្បន្ន ក្នុងតួនាទីជាអនុប្រធាននាយកប្រតិបត្តិ និងជាគណៈប្រធាននាយកប្រតិបត្តិហានិភ័យ លោកទទួលខុសត្រូវគ្រប់គ្រងហានិភ័យឥណទាន និងហានិភ័យផ្សេងៗទៀតរបស់ធនាគារទាំងមូល ។ លោកត្រូវបានតែងតាំងជាសមាជិកក្រុមប្រឹក្សាភិបាលរបស់ អេស៊ីលីដា ស៊ីឃ្យូរីធី ភីអិលស៊ី ចាប់តាំងពីខែកក្កដា ឆ្នាំ២០១៧ ។

បណ្ឌិត ឡឿង សុភាព បានបញ្ចប់ថ្នាក់បណ្ឌិតផ្នែកគ្រប់គ្រងពាណិជ្ជកម្ម ពីសាកលវិទ្យាល័យ Preston រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ក្នុងឆ្នាំ២០១២ ។

- លោក អ៊ូ ឌីណា
  នាយកការិយាល័យ
  ត្រួតពិនិត្យឥណទាន
- លោក សឹង ភន
  នាយកប្រតិបត្តិឥណទាន
- បណ្ឌិត ឡឿង សុភាព
  អនុប្រធាននាយកប្រតិបត្តិ និងជា
  គណៈប្រធាននាយកប្រតិបត្តិហានិភ័យ
- លោក ទេព ប៊ុនធឿន
  នាយកប្រតិបត្តិគ្រប់គ្រងហានិភ័យ
- លោក ឆេង រដ្ឋនា
  នាយកប្រតិបត្តិវិភាគទិនន្នន័យ
  ឥណទាន និងស្រាវជ្រាវ

នាយកដ្ឋានអនុលោមបញ្ញត្តិ

លោក ហុក លាងគ្រី

នាយកប្រតិបត្តិអនុលោមបញ្ញត្តិ

ជនជាតិខ្មែរ កើតក្នុងខែធ្នូ ឆ្នាំ១៩៧៧ ។ លោកបានចូលបម្រើការងារជាមួយ អេស៊ីលីដា ចាប់ពីខែកុម្ភៈ ឆ្នាំ២០០២ ។ ក្នុងមុខតំណែងជានាយកប្រតិបត្តិអនុលោមបញ្ញត្តិ លោកទទួលបន្ទុកគ្រប់គ្រងផែនការយុទ្ធសាស្ត្រ និងប្រតិបត្តិការអនុលោមភាពប្រចាំថ្ងៃរបស់ធនាគារ និងក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ធនាគារ ។ ដើម្បីធានានូវឯករាជ្យភាពនៃតួនាទី អនុលោមភាពរបស់ ធនាគារ អេស៊ីលីដា តម្រូវឱ្យលោកជាអ្នករាយការណ៍ដោយផ្ទាល់ជូនគណៈកម្មាធិការគ្រប់គ្រងហានិភ័យ និងព័ត៌មានវិទ្យានៃក្រុមប្រឹក្សាភិបាល ។ លោកត្រូវបានអញ្ជើញឱ្យចូលរួមក្នុងកិច្ចប្រជុំរបស់គណៈកម្មាធិការគ្រប់គ្រងហានិភ័យ និងព័ត៌មានវិទ្យា នៃក្រុមប្រឹក្សាភិបាល ដើម្បីផ្តល់ព័ត៌មាន និងបង្ហាញពីអនុលោមភាព និងបញ្ហាពាក់ព័ន្ធនឹងវិសាលភាព និងគោលបំណងរបស់គណៈកម្មាធិការ ។

លោកទទួលខុសត្រូវដឹកនាំនាយកដ្ឋានអនុលោមបញ្ញត្តិ ដែលមាន ២ការិយាល័យ គឺ ការិយាល័យប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ការិយាល័យត្រួតពិនិត្យអនុលោមបញ្ញត្តិ បុគ្គលិកអនុលោមបញ្ញត្តិនៅក្រុមហ៊ុនបុត្រសម្ព័ន្ធទាំងអស់ផងដែរ ។

លោកទទួលបានសញ្ញាបត្រជាន់ខ្ពស់ចំនួនពីរ គឺ សញ្ញាបត្រជាន់ខ្ពស់ផ្នែកនីតិសាស្ត្រ ឯកទេសផ្នែកនីតិឯកជន ពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ក្នុងឆ្នាំ២០១៦ និងបរិញ្ញាបត្រជាន់ខ្ពស់គ្រប់គ្រងពាណិជ្ជកម្ម ពីសាកលវិទ្យាល័យប្រេស្តុន សហរដ្ឋអាមេរិក (សាខាក្នុងប្រទេសកម្ពុជា) ឆ្នាំ២០១២ ។

លោកបានទទួលបរិញ្ញាបត្រចំនួនពីរ គឺបរិញ្ញាបត្រ សិល្បសាស្ត្រ ជំនាញបង្រៀនភាសាអង់គ្លេស (English Based, International Program) ពីសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជា នៅក្នុងឆ្នាំ២០១០ និងបរិញ្ញាបត្រពាណិជ្ជកម្មរដ្ឋបាល ជំនាញគណនេយ្យ ពីសាកលវិទ្យាល័យន័រតុន ក្នុងឆ្នាំ២០០១ ។

សវនករផ្ទៃក្នុង

លោកស្រី គឹម សុធារី

គណៈប្រធាននាយិកាប្រតិបត្តិជាន់ខ្ពស់សវនកម្មផ្ទៃក្នុង

ជនជាតិខ្មែរ កើតក្នុងខែតុលា ឆ្នាំ១៩៦៥ ។ លោកស្រីបានចូលបម្រើការជាមួយ អេស៊ីលីដា ចាប់តាំងពីខែកញ្ញា ឆ្នាំ១៩៩៤ ។ ក្នុងមុខតំណែងជាគណៈប្រធាននាយិកាប្រតិបត្តិសវនកម្មផ្ទៃក្នុង លោកស្រីទទួលបន្ទុកគ្រប់គ្រងផែនការយុទ្ធសាស្ត្រ និងសវនកម្មផ្ទៃក្នុងប្រចាំថ្ងៃរបស់ធនាគារ ព្រមទាំងប្រតិបត្តិផែនការសវនកម្មផ្ទៃក្នុង ។

ដើម្បីធានាឱ្យបានឯករាជ្យភាព នៃមុខងារជាសវនកម្មផ្ទៃក្នុង លោកស្រីជាអ្នករាយការណ៍ផ្ទាល់ ទៅគណៈកម្មាធិការសវនកម្ម នៃក្រុមប្រឹក្សាភិបាល ។ លោកស្រីត្រូវបានអញ្ជើញឱ្យចូលរួមនៅក្នុងកិច្ចប្រជុំជាលេខារបស់ គណៈកម្មាធិការសវនកម្ម ជាបន្តបន្ទាប់ និងដើម្បីផ្តល់ព័ត៌មាន និងពន្យល់ពីបញ្ហានានាទាក់ទងនឹងវិសាលភាព និងគោលបំណងរបស់គណៈកម្មាធិការ ។

លោកស្រីគ្រប់គ្រង និងដឹកនាំក្រុមសវនកម្មផ្ទៃក្នុង ដែលមាន ២ នាយកដ្ឋាន និង ៨ការិយាល័យ ដូចជា៖ នាយកដ្ឋានអភិវឌ្ឍន៍សវនកម្មផ្ទៃក្នុង នាយកដ្ឋានសវនកម្មប្រព័ន្ធព័ត៌មានវិទ្យា ការិយាល័យសវនកម្មហិរញ្ញវត្ថុ ការិយាល័យសវនកម្មប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ការិយាល័យសវនកម្មឥណទាន និងការិយាល័យរបាយការណ៍សវនកម្ម ។

ទំនួលខុសត្រូវផ្សេងទៀតរបស់លោកស្រី រួមមានជាសមាជិកក្រុមប្រឹក្សាភិបាលធនាគារ អេស៊ីលីដា ឡារ ។

លោកស្រីទទួលបានអនុបណ្ឌិតផ្នែកធនាគារ និងហិរញ្ញវត្ថុ ព្រមទាំងបានបញ្ចប់ការសិក្សាពីវិទ្យាស្ថានអូស្ត្រាលីសម្រាប់អភិបាលក្រុមហ៊ុន (GAICD) ។

- លោក ឈីវ សំណាង នាយកការិយាល័យសវនកម្មប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម
- លោក សុក ហៃ នាយកជាន់ខ្ពស់ការិយាល័យរបាយការណ៍សវនកម្ម
- លោក សុខ ពិសិដ្ឋ នាយកប្រតិបត្តិសវនកម្មប្រព័ន្ធព័ត៌មានវិទ្យា
- លោកស្រី គឹម សុធារី គណៈប្រធាននាយិកាប្រតិបត្តិជាន់ខ្ពស់សវនកម្មផ្ទៃក្នុង
- លោក ថាត ឌីណុត នាយកប្រតិបត្តិអភិវឌ្ឍន៍សវនកម្មផ្ទៃក្នុង
- លោក ទុំ សុខចំរើន នាយកការិយាល័យសវនកម្មហិរញ្ញវត្ថុ
- លោក ចាន់ បូរីដុល្លា នាយកការិយាល័យសវនកម្មឥណទាន

ក្រមសីលធម៌

ក្នុងក្រមសីលធម៌របស់ក្រុមប្រឹក្សាភិបាល គ្រប់គ្រងដោយ ១. អនុស្សរណៈ និងលក្ខន្តិកៈរបស់ធនាគារ ២. កិច្ចព្រមព្រៀងភាគហ៊ុនិក និង ៣. ច្បាប់ និងបទប្បញ្ញត្តិទាំងឡាយដែលពាក់ព័ន្ធរបស់ព្រះរាជាណាចក្រកម្ពុជា ។ ការវិវឌ្ឍឥតឈប់ឈររបស់ធនាគារ គឺទាមទារឱ្យមានការយកចិត្តទុកដាក់ខ្ពស់ ដើម្បីធានាថា បទដ្ឋាននៃការអនុវត្តផ្ទៃក្នុងរបស់សាជីវកម្ម ត្រូវបានរក្សាក្នុងកម្រិតមួយខ្ពស់បំផុត ។ ក្នុងខែមីនា ឆ្នាំ២០០៥ ក្រុមប្រឹក្សាភិបាលបានផ្តល់អនុសាសន៍មួយលើការកំណត់ និងការវាយតម្លៃលើបញ្ហាទាំងមូលនៃអភិបាលកិច្ចសាជីវកម្ម ដើម្បីកំណត់ពីតម្រូវការនៃការរីកលូតលាស់ទៅមុខរបស់ធនាគារ ។ ក្នុងចំណោមបញ្ហាផ្សេងៗ រួមមាន កិច្ចព្រមព្រៀងលើការផ្តល់សេវារបស់ក្រុមប្រឹក្សាភិបាល កម្មវិធីបណ្តុះបណ្តាលតួនាទី មុខងាររបស់ក្រុមប្រឹក្សាភិបាលបញ្ជីវាយតម្លៃក្រុមប្រឹក្សាភិបាល និងក្រមសីលធម៌របស់ក្រុមប្រឹក្សាភិបាល ត្រូវបានរៀបចំដាក់ឱ្យប្រើប្រាស់ ហើយតួនាទីទាក់ទងទៅនឹងប្រាក់លាភការ និងការចំណាយរបស់ក្រុមប្រឹក្សាភិបាល បានរៀបចំជាទម្រង់យ៉ាងច្បាស់លាស់ ។ សមាជិក-សមាជិកាក្រុមប្រឹក្សាភិបាលបានចូលរួមវគ្គសិក្សាស្តីពីអភិបាលក្រុមហ៊ុនអន្តរជាតិ ដែលរៀបចំដោយវិទ្យាស្ថានអូស្ត្រាលី សម្រាប់អភិបាលក្រុមហ៊ុន ដែលជាផ្នែកមួយនៃការប្តេជ្ញាចិត្តរបស់ក្រុមប្រឹក្សាភិបាល ដើម្បីបន្តអភិវឌ្ឍនូវជំនាញវិជ្ជាជីវៈ និងសមត្ថភាពរបស់ខ្លួន ។

កម្មករនិយោជិតគ្រប់រូបរបស់ធនាគារអេស៊ីលីដាស្ថិតក្រោមការគ្រប់គ្រងមួយយ៉ាងតឹងរ៉ឹងនៃក្រមសីលធម៌ ដែលបានកំណត់ក្នុងអនុសញ្ញារួមការងារ ដោយគ្របដណ្តប់លើបញ្ហាមួយចំនួនដូចជាចរិតលក្ខណៈបុគ្គលទំនាក់ទំនងជាមួយអ្នករួមការងារ អតិថិជន និងអ្នកគ្រប់គ្រង អាចិ៍កំបាំងវិជ្ជាជីវៈ វិវាទលើផលប្រយោជន៍ ការទទួលយកអំណោយ ការសម្អាតប្រាក់ និងការបកអាក្រាតកំហុសឆ្គង ។ ឯកសារទាំងនេះ បានត្រួតពិនិត្យសារឡើងវិញយ៉ាងទៀងទាត់ ដោយគណៈកម្មាធិការសវនកម្ម និងសម្របសម្រួលកិច្ចការច្បាប់ ដើម្បីធានាថា វានៅតែមានសុពលភាពប្រើប្រាស់ និងទាន់សម័យ ។

របាយការណ៍ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលបានជួបប្រជុំគ្នាផ្ទាល់នៅរាជធានីភ្នំពេញចំនួន៤លើក គឺខែមីនា មិថុនា កញ្ញា និងធ្នូ ឆ្នាំ២០២១។ អភិបាលរស់នៅបរទេស ដែលមិនអាចចូលរួមកិច្ចប្រជុំផ្ទាល់បាន ដោយសារតែការរឹតបណ្តឹងចំពោះការធ្វើដំណើរ ដើម្បីការពារពីការរីករាលដាលនៃជំងឺកូវីដ-១៩ បានចូលរួមកិច្ចប្រជុំតាមរយៈ Video Con-Call។ ជាធម្មតា កិច្ចប្រជុំនីមួយៗ មានរយៈពេល២ថ្ងៃ ដោយរួមបញ្ចូលទាំងកិច្ចប្រជុំគណៈកម្មាធិការផងដែរ។ លើសពីនេះទៅទៀត ក្រុមប្រឹក្សាភិបាលក៏បានអនុម័តតាមរយៈអ៊ីម៉ែលចំនួន២៣ចំណុច។

សកម្មភាពចម្បងៗ ក្នុងឆ្នាំ២០២១

- ការត្រួតពិនិត្យ និងការអនុម័តគោលការណ៍របស់ធនាគារ។
- ការអនុម័តលើតួនាទីភារកិច្ចរបស់គណៈកម្មាធិការក្រុមប្រឹក្សាភិបាល។
- ការអនុម័តលើការផ្លាស់ប្តូរសមាសភាពគណៈកម្មាធិការក្រុមប្រឹក្សាភិបាល។
- ការអនុម័តលើការផ្លាស់ប្តូរសមាសភាពគណៈក្រុមប្រឹក្សាភិបាល នៃបុត្រសម្ព័ន្ធរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី។
- ការអនុម័តមូលនិធិបម្រុងបន្ថែម សម្រាប់ផែនការមូលនិធិយថាភាព។
- ការអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុរួម និងរបាយការណ៍ហិរញ្ញវត្ថុដោយឡែកសង្ខេបចន្លោះពេល សម្រាប់ដំណាច់ការិយបរិច្ឆេទ៣ខែ និង៩ខែ គិតត្រឹមថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២១ ដែលបានធ្វើសវនកម្មរួច ដោយក្រុមហ៊ុនសវនកម្មឯករាជ្យ GRANT THORNTON (CAMBODIA) LIMITED (GT)។
- ការអនុម័តលើផែនការយុទ្ធសាស្ត្ររបស់ក្រុមហ៊ុនបុត្រសម្ព័ន្ធនៃធនាគារ អេស៊ីលីដា ភីអិលស៊ី សម្រាប់ឆ្នាំ២០២២-២០២៦។
- ការអនុម័តលើផែនការថវិកាសម្រាប់ឆ្នាំ២០២២-២០២៦។
- ការអនុម័ត និងការផ្តល់អនុសាសន៍ទៅភាគហ៊ុនិក ដើម្បីអនុម័តលើការវិនិយោគនៅវិទ្យាស្ថានធនាគារ និងហិរញ្ញវត្ថុ។
- ការអនុម័ត ការទទួលស្គាល់ និងការផ្តល់អនុសាសន៍ទៅភាគហ៊ុនិក ដើម្បីអនុម័តការផ្ទេរភាគហ៊ុនចំនួន៣.៥% (បីកណ្តាក់សញ្ញាហាសិបភាគរយ) នៅធនាគារ អេស៊ីលីដា ភីអិលស៊ី ពី Triodos (TMF, TFSF, and TSFF) ទៅ North Haven Thai Private Equity Rumdul Company (Hong Kong) Limited។
- ការអនុម័ត ការទទួលស្គាល់ និងការផ្តល់អនុសាសន៍ទៅភាគហ៊ុនិក ដើម្បីអនុម័ត North Haven Thai Private Equity Rumdul Company (Hong Kong) Limited ជាភាគហ៊ុនិកថ្មីរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី។
- ការអនុម័ត ការទទួលស្គាល់ និងការផ្តល់អនុសាសន៍ទៅភាគហ៊ុនិក ដើម្បីអនុម័ត Mr. Ong Ling Wei មកពី North Haven Thai Private Equity Rumdul Company (Hong Kong) Limited ជាតំណាងភាគហ៊ុនិកថ្មីរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី។
- អនុម័ត និងការផ្តល់អនុសាសន៍ទៅភាគហ៊ុនិក ដើម្បីអនុម័តលើការកែប្រែលក្ខន្តិកៈរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី។
- ការអនុម័ត និងការជ្រើសរើស និងការផ្តល់អនុសាសន៍ទៅភាគហ៊ុនិក ដើម្បីអនុម័ត និងជ្រើសរើសក្រុមហ៊ុន Grant Thornton ជាសវនករឯករាជ្យរបស់ធនាគារ សម្រាប់ឆ្នាំ២០២២។
- កំណត់កាលបរិច្ឆេទកិច្ចប្រជុំ កាលបរិច្ឆេទកំណត់ទុក និងរបៀបវារៈ សម្រាប់រៀបចំកិច្ចប្រជុំភាគហ៊ុនិកវិសាមញ្ញ ដែលបានធ្វើឡើងនៅក្នុងឆ្នាំ២០២១។
- ការអនុម័តលើកម្ចីដែលផ្តល់ពីម្ចាស់កម្ចីនៅក្នុងស្រុក និងអន្តរជាតិ។
- ការអនុម័តលើផែនការការផ្តល់សហហិរញ្ញប្បទាន (ដំណាក់កាលទី២) រវាងធនាគារ អេស៊ីលីដា ភីអិលស៊ី និងធនាគារសហគ្រាសធុនតូច និងមធ្យម កម្ពុជា។
- ការអនុម័តការបង្កើតអ្នកដំណើរការតតិយភាគី សម្រាប់ MONEYGRAM PAYMENT SYSTEM, INC.។
- ការអនុម័តការបង្កើនកម្រិតកំណត់សួចនាការហានិភ័យឥណទានដល់វិស័យសំណង់ និងអចលនទ្រព្យពីតូចជាង១០% ទៅតូចជាង១២%។
- ការអនុម័តរបាយការណ៍ហិរញ្ញវត្ថុរួម និងរបាយការណ៍ហិរញ្ញវត្ថុដោយឡែកសង្ខេបចន្លោះពេល សម្រាប់ដំណាច់ការិយបរិច្ឆេទ៦ខែ គិតត្រឹមថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២១ ដែលបានធ្វើសវនកម្មរួច ដោយក្រុមហ៊ុនសវនកម្មឯករាជ្យ GRANT THORNTON (CAMBODIA) LIMITED (GT)។
- ការអនុម័តការការទទួលស្គាល់ និងការផ្តល់អនុសាសន៍ទៅភាគហ៊ុនិក ដើម្បីអនុម័តការតែងតាំងលោក Kyosuke Hattori ពី SMBC ជាអភិបាលថ្មីនៅធនាគារ ជំនួសលោក Kenichiro Mori។
- ការអនុម័តលើគោលការណ៍ការដំឡើងកម្រៃសេវាក្រុមប្រឹក្សាភិបាល នៃបុត្រសម្ព័ន្ធធនាគារ អេស៊ីលីដា ភីអិលស៊ី ក្នុងអត្រាដូចគ្នា នៃការដំឡើងកម្រៃសេវាប្រចាំឆ្នាំក្រុមប្រឹក្សាភិបាល ធនាគារ អេស៊ីលីដា ភីអិលស៊ី។
- ការអនុម័តការកំណត់សួចនាការហានិភ័យ។
- ការអនុម័តឲ្យធនាគារបម្រើសេវាបេងកាសួរេនជាម៉ូឌែលភ្នាក់ងារ។
- ការអនុម័តការការតែងតាំង និងការផ្តល់អនុសាសន៍ទៅភាគហ៊ុនិក ដើម្បីអនុម័ត និងតែងតាំងលោកស្រី Ms. Phurik Ratana ជាអភិបាលឯករាជ្យរបស់ធនាគារ អេស៊ីលីដា ភីអិលស៊ី។
- ការអនុម័តរបាយការណ៍ហិរញ្ញវត្ថុរួម និងរបាយការណ៍ហិរញ្ញវត្ថុដោយឡែកសង្ខេបចន្លោះពេល សម្រាប់ដំណាច់ការិយបរិច្ឆេទ៣ខែ គិតត្រឹមថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១ ដែលបានធ្វើសវនកម្មរួច ដោយក្រុមហ៊ុនសវនកម្មឯករាជ្យ GRANT THORNTON (CAMBODIA) LIMITED (GT)។
- ការអនុម័តរបាយការណ៍ប្រចាំឆ្នាំ២០២០។
- ការអនុម័ត និងការផ្តល់អនុសាសន៍ទៅភាគហ៊ុនិក ដើម្បីអនុម័តលើការបែងចែកភាគលាភ និងផ្ទេរសមតុល្យដែលនៅសល់ នៃប្រាក់ចំណេញក្រោយដកពន្ធទៅជាទុនបម្រុងទូទៅរបស់ធនាគារ។
- ការអនុម័តលើរបាយការណ៍ប្រចាំឆ្នាំ២០២០ របស់ប្រធានក្រុមប្រឹក្សាភិបាល។
- ការអនុម័តលើរបាយការណ៍ប្រចាំឆ្នាំ២០២០ របស់ប្រធាននាយកប្រតិបត្តិ។
- ការអនុម័តលើរបាយការណ៍ប្រចាំឆ្នាំ២០២០ របស់គណៈកម្មាធិការក្រុមប្រឹក្សាភិបាលនីមួយៗ។
- ការអនុម័តលើអត្រាអតិផរណាប្រចាំឆ្នាំ២០២០ សម្រាប់ចំណាយជូនកម្មករនិយោជិតរបស់ធនាគារ ចាប់ពីថ្ងៃទី១ ខែមេសា ឆ្នាំ២០២១តទៅ។
- ការអនុម័ត និងការផ្តល់អនុសាសន៍ទៅភាគហ៊ុនិក ដើម្បីអនុម័តលើការតែងតាំង Mr. Stéphane Mangiavacca, Mr. Albertus Bruggink and Drs. Pieter Kooi ជាសមាជិកក្រុមប្រឹក្សាភិបាល សម្រាប់អាណត្តិថ្មី ៣ឆ្នាំបន្ថែមទៀត។
- ការអនុម័តរបៀបវារៈ និងកាលបរិច្ឆេទកំណត់ទុក ដើម្បីកំណត់ភាគហ៊ានិកដែលនឹងត្រូវអញ្ជើញចូលរួមកិច្ចប្រជុំភាគហ៊ុនិកប្រចាំឆ្នាំ ដែលបានធ្វើឡើងនៅថ្ងៃ២២ ខែមេសា ឆ្នាំ២០២២។
- ការអនុម័ត និងការផ្តល់អនុសាសន៍ទៅភាគហ៊ុនិក ដើម្បីអនុម័តកាលបរិច្ឆេទកំណត់ទុក ដើម្បីកំណត់ភាគហ៊ានិកដែលនឹងទទួលភាគលាភ។
- ការអនុម័ត និងការដំឡើងកម្រៃសេវារបស់ក្រុមប្រឹក្សាភិបាល ធនាគារ អេស៊ីលីដា ភីអិលស៊ី។

- ការអនុម័តរបាយការណ៍ហិរញ្ញវត្ថុរួម និងរបាយការណ៍ហិរញ្ញវត្ថុប្រដោយឡែក សម្រាប់ដំណាច់ឆ្នាំ ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ ដែលបានធ្វើសវនកម្មរួច ដោយក្រុមហ៊ុនសវនកម្មឯករាជ្យ KPMG Cambodia Ltd. ។
- ការអនុម័តកិច្ចព្រមព្រមេ ISDA ជាមួយ SMBC Singapore Branch និង BRED Bank (Cambodia) Plc.
- ការអនុម័តរបាយការណ៍ហិរញ្ញវត្ថុរួម និងរបាយការណ៍ហិរញ្ញវត្ថុដោយឡែកសង្ខេបចន្លោះពេល សម្រាប់ដំណាច់ការិយបរិច្ឆេទ៣ខែ និង១២ខែ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ និងរបាយការណ៍របស់សវនករឯករាជ្យ ស្តីពីការត្រួតពិនិត្យព័ត៌មានហិរញ្ញវត្ថុ ដែលបានធ្វើសវនកម្មរួច ដោយក្រុមហ៊ុនសវនកម្មឯករាជ្យ KPMG Cambodia Ltd. ។

របាយការណ៍របស់គណៈកម្មាធិការក្រុមប្រឹក្សាភិបាល

- គណៈកម្មាធិការសវនកម្ម (BACO)
- គណៈកម្មាធិការតែងតាំង និងលាភការ (BRENCO)
- គណៈកម្មាធិការគ្រប់គ្រងហានិភ័យ និងព័ត៌មានវិទ្យា (BRMC)

គណៈកម្មាធិការសវនកម្ម

វិសាលភាព និងគោលបំណង

គណៈកម្មាធិការសវនកម្ម ត្រូវបានបង្កើតឡើងដោយក្រុមប្រឹក្សាភិបាលនៃធនាគារ អេស៊ីលីដា ដើម្បីតាមដាន និងត្រួតពិនិត្យភាពត្រឹមត្រូវនៃរបាយការណ៍ ហិរញ្ញវត្ថុ ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុផ្ទៃក្នុង សវនកម្មផ្ទៃក្នុង និងសេវាកម្ម ដែលផ្តល់ដោយសវនករខាងក្រៅ។

សមាជិក

- លោក Ian S. Lydall — អភិបាលឯករាជ្យ ប្រធាន (ផុតអាណត្តិនៅថ្ងៃទី២១ សីហា ឆ្នាំ២០២១)
- លោក Pieter Kooi — អភិបាលឯករាជ្យ សមាជិក (ប្រធានស្តីទី ចាប់ពីថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២១)
- លោក ឆាយ សឿន — អភិបាលមិនប្រតិបត្តិ សមាជិក
- លោកស្រី ភូរិ រតនា — អភិបាលឯករាជ្យ សមាជិក (ប្រសិទ្ធភាពចាប់ពីថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០២១)

លទ្ធផលការងាររបស់គណៈកម្មាធិការសវនកម្ម ក្នុងឆ្នាំ២០២១

គណៈកម្មាធិការបានរៀបចំកិច្ចប្រជុំចំនួន១០ដងនៅក្នុងឆ្នាំ២០២១ ដែលមាន ៨ដងនៅខែកុម្ភៈ ១ដងនៅខែមីនា ៣ដងនៅឧសភា ១ដងនៅខែសីហា និង១ដងទៀតនៅខែវិច្ឆិកា។ ដំណើរការសំខាន់ៗ មានដូចជា៖

- បានត្រួតពិនិត្យ និងស្នើក្រុមប្រឹក្សាភិបាលសម្រាប់ការអនុម័តចុងក្រោយលើរបាយការណ៍សវនកម្មហិរញ្ញវត្ថុឆ្នាំ២០២០។
- បានត្រួតពិនិត្យ ជាមួយនឹងសវនកម្មខាងក្រៅនូវលិខិតថ្នាក់គ្រប់គ្រងប្រចាំឆ្នាំ២០២០។
- បានត្រួតពិនិត្យ និងតាមដានដំណើរការការអនុវត្ត និងការអភិវឌ្ឍស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ (IFRS) របស់ថ្នាក់គ្រប់គ្រង។
- បានត្រួតពិនិត្យ និងអនុម័តរបាយការណ៍ត្រួតពិនិត្យផ្ទៃក្នុងឆ្នាំ២០២០ ដើម្បីដាក់ជូនធនាគារជាតិ នៃ កម្ពុជា។
- បានត្រួតពិនិត្យ និងអនុម័តរបាយការណ៍សវនកម្មផ្ទៃក្នុងប្រចាំឆ្នាំ២០២០ ដែលត្រូវបង្ហាញជាសាធារណៈ។
- បានត្រួតពិនិត្យ និងលើកសំណើជូនក្រុមប្រឹក្សាភិបាលអនុម័តលើប្រាក់រង្វាន់លើកទឹកចិត្តឆ្នាំ២០២០ ជូនគណៈប្រធាននាយិកាប្រតិបត្តិជាន់ខ្ពស់សវនកម្មផ្ទៃក្នុង។
- បានវាយតម្លៃ និងដាក់ពិន្ទុលើលទ្ធផលការងារឆ្នាំ២០២០ របស់គណៈប្រធាននាយិកាប្រតិបត្តិជាន់ខ្ពស់សវនកម្មផ្ទៃក្នុង ដើម្បីដាក់ជូនក្រុមប្រឹក្សាភិបាលអនុម័ត។
- បានត្រួតពិនិត្យរបាយការណ៍សវនកម្មផ្ទៃក្នុង និងការវិភាគនិន្នាការ ឬហេតុការណ៍នានាប្រចាំឆ្នាំ។
- បានត្រួតពិនិត្យ និងអនុម័តលើផែនការសវនកម្មផ្ទៃក្នុងសម្រាប់ឆ្នាំសារពើពន្ធ២០២២។
- បានត្រួតពិនិត្យ និងលើកសំណើជូនក្រុមប្រឹក្សាភិបាល ដើម្បីអនុម័តលើផែនការប្រាក់រង្វាន់លើកទឹកចិត្តឆ្នាំ២០២២ សម្រាប់គណៈប្រធាននាយិកាប្រតិបត្តិជាន់ខ្ពស់សវនកម្មផ្ទៃក្នុង។
- បានត្រួតពិនិត្យ និងលើកសំណើជូនក្រុមប្រឹក្សាភិបាល ដើម្បីអនុម័តលើតួនាទីភារកិច្ចរបស់គណៈកម្មាធិការសវនកម្ម។
- បានត្រួតពិនិត្យ និងលើកសំណើជូនក្រុមប្រឹក្សាភិបាល ដើម្បីអនុម័តជ្រើសរើសសវនករខាងក្រៅ សម្រាប់ធ្វើការវាយតម្លៃសវនកម្មប្រព័ន្ធព័ត៌មានវិទ្យា។
- បានពិភាក្សា និងលើកសំណើជូនក្រុមប្រឹក្សាភិបាល សម្រាប់ការជ្រើសរើសក្រុមហ៊ុនសវនកម្ម ដើម្បីជាសវនករខាងក្រៅប្រចាំឆ្នាំ២០២២។
- បានត្រួតពិនិត្យគោលការណ៍ផ្សេងៗ៖ គោលការណ៍សវនកម្ម គោលការណ៍ត្រួតពិនិត្យផ្ទៃក្នុង គោលការណ៍បង្ហាញព័ត៌មានសាធីរកម្ម គោលការណ៍ភាគលាភ និងគោលការណ៍ណែនាំទូទៅ។
- បានត្រួតពិនិត្យ និងអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុឆ្នាំ២០២១ សម្រាប់ខែមីនា មិថុនា និងកញ្ញា និងលើកសំណើជូនក្រុមប្រឹក្សាភិបាល ដើម្បីអនុម័តចុងក្រោយ។

គណៈកម្មាធិការតែងតាំង និងលាភការ

វិសាលភាព និងគោលបំណង

គណៈកម្មាធិការនេះត្រូវបានបង្កើតឡើងដោយក្រុមប្រឹក្សាភិបាលនៃធនាគារ អេស៊ីលីដា ដើម្បីផ្តល់មតិយោបល់ដោយឯករាជ្យ ស្តីពីការផ្តល់អនុសាសន៍ជូនក្រុមប្រឹក្សាភិបាល ក្នុងបញ្ហា៖

ក) ការផ្តល់លាភការជូនអភិបាល ប្រធាននាយកប្រតិបត្តិ គណៈប្រធាននាយិកាប្រតិបត្តិជាន់ខ្ពស់សរនកម្មផ្ទៃក្នុង នាយកប្រតិបត្តិអនុលោមបញ្ញត្តិរបស់ធនាគារ និងអភិបាលរបស់ក្រុមហ៊ុនបុត្រសម្ព័ន្ធ និង

ខ) ការជ្រើសរើសបេក្ខភាពដែលសមស្រប សម្រាប់ជាសមាជិកក្រុមប្រឹក្សាភិបាល ប្រធាននាយកប្រតិបត្តិ គណៈប្រធាននាយិកាប្រតិបត្តិជាន់ខ្ពស់សរនកម្មផ្ទៃក្នុង នាយកប្រតិបត្តិអនុលោមបញ្ញត្តិ របស់ធនាគារ។

សមាជិក

- លោក រ៉ាន់ ស៊ូអ៊ីង អភិបាលឯករាជ្យ ប្រធាន
- លោក Pieter Kooi អភិបាលឯករាជ្យ សមាជិក
- លោក Ian S.Lydall អភិបាលឯករាជ្យ សមាជិក (ផុតអាណត្តិនៅថ្ងៃទី២១ ខែសីហា ឆ្នាំ២០២១)
- លោក Albertus Bruggink អភិបាលមិនប្រតិបត្តិ សមាជិក (តែងតាំងជាសមាជិកនៃគណៈកម្មាធិការនេះនៅថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២១)
- លោក Stéphane Mangiavaca អភិបាលមិនប្រតិបត្តិ សមាជិក (តែងតាំងជាសមាជិកនៃគណៈកម្មាធិការនេះនៅថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០២១)

នៅពេលប្រជុំម្តងៗ គណៈកម្មាធិការនេះអាចអញ្ជើញសមាជិកថ្នាក់គ្រប់គ្រង និងទីប្រឹក្សាវិជ្ជាជីវៈខាងក្រៅ ដើម្បីចូលរួមក្នុងកិច្ចប្រជុំទាំងមូល ឬដោយផ្នែកណាមួយ ដើម្បីផ្តល់ពត៌មាន និងការពន្យល់បន្ថែម ដូចដែលពួកគាត់សម្រេចចិត្តតាមករណីចាំបាច់។

លទ្ធផលការងាររបស់គណៈកម្មាធិការតែងតាំង និងលាភការ ក្នុងឆ្នាំ២០២១

គណៈកម្មាធិការតែងតែង និងលាភការ បានប្រជុំចំនួន៨ដង ក្នុងឆ្នាំ២០២១ ដែល ២ដងនៅខែមីនា ២ដងនៅខែឧសភា ១ដងនៅខែមិថុនា ១ដងនៅខែសីហា ១ដងនៅខែវិច្ឆិកា និង១ដងទៀតនៅខែធ្នូ។ ដំណើរការសំខាន់ៗ មានដូចជា៖

- បានត្រួតពិនិត្យ និងស្នើក្រុមប្រឹក្សាភិបាល ដើម្បីអនុម័តចុងក្រោយលើអត្រាអតិផរណាឆ្នាំ២០២០ សម្រាប់ចំណាយជូនកម្មករនិយោជិតរបស់ធនាគារ ចាប់ពីថ្ងៃទី១ ខែមេសា ឆ្នាំ២០២១ តទៅ។
- បានត្រួតពិនិត្យ និងស្នើក្រុមប្រឹក្សាភិបាល ដើម្បីអនុម័តចុងក្រោយក្នុងការផ្តល់ប្រាក់រង្វាន់លើកទឹកចិត្ត និងការបង្កើនប្រាក់បៀវត្សប្រចាំជូនប្រធាននាយកប្រតិបត្តិ សម្រាប់លទ្ធផលការងារប្រចាំឆ្នាំ២០២០។
- បានត្រួតពិនិត្យ និងស្នើក្រុមប្រឹក្សាភិបាល ដើម្បីអនុម័តចុងក្រោយក្នុងការបង្កើនប្រាក់បៀវត្សប្រចាំឆ្នាំជូនប្រធានក្រុមប្រឹក្សាភិបាល។
- បានត្រួតពិនិត្យ និងស្នើក្រុមប្រឹក្សាភិបាល ដើម្បីអនុម័តចុងក្រោយលើរបាយការណ៍ប្រចាំឆ្នាំ២០២០ របស់គណៈកម្មាធិការតែងតែង និងលាភការ។
- បានត្រួតពិនិត្យ និងស្នើក្រុមប្រឹក្សាភិបាល ដើម្បីអនុម័តចុងក្រោយក្នុងការបង្កើនកម្រៃសេវាជូនក្រុមប្រឹក្សាភិបាលរបស់ធនាគារ។
- បានត្រួតពិនិត្យ និងស្នើក្រុមប្រឹក្សាភិបាល ដើម្បីអនុម័តចុងក្រោយលើលក្ខខណ្ឌ និងការរៀបចំសមាសភាពឡើងវិញសម្រាប់អភិបាលឯករាជ្យរបស់ធនាគារ។
- បានត្រួតពិនិត្យ និងស្នើក្រុមប្រឹក្សាភិបាល ដើម្បីអនុម័តនូវសមាសភាពក្រុមប្រឹក្សាភិបាល សមាសភាពគណៈកម្មាធិការក្រុមប្រឹក្សាភិបាល របស់ធនាគារ និងក្រុមហ៊ុនបុត្រសម្ព័ន្ធ។
- បានត្រួតពិនិត្យផែនការសោធននិវត្តន៍ និងអត្ថប្រយោជន៍ចូលនិវត្តន៍របស់កម្មករនិយោជិត។
- បានត្រួតពិនិត្យច្បាប់ និងបទប្បញ្ញត្តិដែលពាក់ព័ន្ធ។
- បានត្រួតពិនិត្យកម្រិតប្រាក់បៀវត្សរ៍របស់ថ្នាក់គ្រប់គ្រងជាន់ខ្ពស់ ដោយការប្រៀបធៀបស្ថាប័នហិរញ្ញវត្ថុដែលមានទំហំប្រហាក់ប្រហែលគ្នា។
- បានត្រួតពិនិត្យដំណើរការអនុម័ត សម្រាប់ផ្តល់លាភការជូនអភិបាលរបស់បុត្រសម្ព័ន្ធ។
- បានត្រួតពិនិត្យគម្រោងកម្មវិធីទស្សនកិច្ចរបស់ក្រុមប្រឹក្សាភិបាល។
- បានត្រួតពិនិត្យ និងស្នើក្រុមប្រឹក្សាភិបាល ដើម្បីអនុម័តគោលការណ៍ដែលពាក់ព័ន្ធ។
- បានត្រួតពិនិត្យកម្រិតចំណាយជាក់ស្តែងលើកម្មករនិយោជិត មកដល់ថ្ងៃនៃរបាយការណ៍។
- បានត្រួតពិនិត្យផែនការស្នងតំណែង សម្រាប់តួនាទីថ្នាក់គ្រប់គ្រងជាន់ខ្ពស់ក្នុងធនាគារ និងក្រុមហ៊ុនបុត្រសម្ព័ន្ធ។
- បានត្រួតពិនិត្យ និងស្នើក្រុមប្រឹក្សាភិបាល ដើម្បីអនុម័តចុងក្រោយលើលក្ខខណ្ឌលទ្ធផលការងាររបស់ប្រធាននាយកប្រតិបត្តិ គណៈប្រធាននាយិកាប្រតិបត្តិជាន់ខ្ពស់សរនកម្មផ្ទៃក្នុង និងនាយកប្រតិបត្តិអនុលោមបញ្ញត្តិ សម្រាប់ឆ្នាំ២០២២។
- បានត្រួតពិនិត្យទម្រង់វាយតម្លៃប្រចាំឆ្នាំរបស់ក្រុមប្រឹក្សាភិបាល និងបានវាយតម្លៃការអនុវត្តការងារប្រចាំឆ្នាំរបស់គណៈកម្មាធិការតែងតែង និងលាភការ។

គណៈកម្មាធិការគ្រប់គ្រងហានិភ័យ និងព័ត៌មានវិទ្យា

វិសាលភាព និងគោលបំណង

គណៈកម្មាធិការនេះត្រូវបានបង្កើតឡើងដោយក្រុមប្រឹក្សាភិបាលនៃធនាគារ អេស៊ីលីដា ដើម្បីជំនួយក្រុមប្រឹក្សាភិបាល និងធានាបាននូវការទទួលខុសត្រូវប្រកបដោយប្រសិទ្ធភាព សម្រាប់ការគ្រប់គ្រងហានិភ័យ អនុលោមបញ្ញត្តិ បច្ចេកវិទ្យាព័ត៌មាន និងត្រួតពិនិត្យជាប្រចាំលើសមត្ថភាពរបស់ថ្នាក់គ្រប់គ្រង ក្នុងការវាយតម្លៃ និងការគ្រប់គ្រងហានិភ័យរបស់ធនាគារ។

សមាជិក

- លោក Pieter Kooi អភិបាលឯករាជ្យ ប្រធាន
- លោក Ian S. Lydall អភិបាលឯករាជ្យ សមាជិក (ផុតអាណត្តិនៅថ្ងៃទី២១ ខែសីហា ឆ្នាំ២០២១)
- លោក កាយ ឡូត អភិបាលមិនប្រតិបត្តិ សមាជិក (តែងតាំងជាសមាជិកនៃគណៈកម្មាធិការនេះ នៅថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២១)
- លោក Kenichiro Mori អភិបាលមិនប្រតិបត្តិ សមាជិក (លាឈប់ពីតួនាទីជាអភិបាល នៅថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០២១)
- លោក Kyosuke Hattori អភិបាលមិនប្រតិបត្តិ សមាជិក (តែងតាំងជាសមាជិកនៃគណៈកម្មាធិការនេះ នៅថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០២១)
- លោក Albertus Bruggink អភិបាលមិនប្រតិបត្តិ សមាជិក (តែងតាំងជាសមាជិកនៃគណៈកម្មាធិការនេះ នៅថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២១ ហើយប្រសិទ្ធភាពនៅថ្ងៃទី១ ខែមករា ឆ្នាំ២០២២)

នៅពេលប្រជុំម្តងៗ គណៈកម្មាធិការនេះអាចអញ្ជើញសមាជិកថ្នាក់គ្រប់គ្រង និងទីប្រឹក្សាវិជ្ជាជីវៈខាងក្រៅ ដើម្បីចូលរួមក្នុងកិច្ចប្រជុំទាំងមូល ឬដោយផ្នែកណាមួយ ដើម្បីផ្តល់ពត៌មាន និងការពន្យល់បន្ថែម ដូចដែលពួកគាត់សម្រេចចិត្តតាមករណីចាំបាច់។

លទ្ធផលសម្រេចបានរបស់គណៈកម្មាធិការគ្រប់គ្រងហានិភ័យ និងព័ត៌មានវិទ្យា ក្នុងឆ្នាំ២០២១

គណៈកម្មាធិការគ្រប់គ្រងហានិភ័យ និងព័ត៌មានវិទ្យា នៃក្រុមប្រឹក្សាភិបាល បានជួបប្រជុំគ្នាចំនួន ១៨ដង ក្នុងឆ្នាំ២០២១ ដែលបានប្រជុំ ២ដងនៅខែមករា ២ដងនៅខែកុម្ភៈ ២ដងនៅខែមីនា ១ដងនៅខែមេសា ១ដងនៅខែមិថុនា ២ដងនៅខែសីហា ២ដងនៅខែកញ្ញា ១ដងនៅខែវិច្ឆិកា និង១ដងទៀតនៅខែធ្នូ។ ដំណើរការសំខាន់ៗ មានដូចជា៖

- បានត្រួតពិនិត្យ និងពិភាក្សាអំពីកម្រងហានិភ័យរបស់សម្ព័ន្ធធនាគារ និងធនាគារ ដែលត្រូវបានបង្ហាញដោយអនុប្រធាននាយកប្រតិបត្តិ និងជាគណៈប្រធានគ្រប់គ្រងហានិភ័យ ដើម្បីធានាថា សូចនាករហានិភ័យសំខាន់ៗ ត្រូវបានអនុវត្តស្របទៅតាមកម្រិតកំណត់ ដែលតម្រូវដោយនិយ័តករ កម្រិតកំណត់ផ្ទៃក្នុង និងកម្រិតកំណត់នៃសូចនាករហានិភ័យសំខាន់ៗ នៃរឿសអាប់ភៃថាយ (RAS-KRIs)។
- បានវាយតម្លៃ និងបានពិភាក្សា អំពីហានិភ័យជាសារវន្ត នាពេលអនាគតរបស់ធនាគារ និងក្រុមហ៊ុនបុត្រសម្ព័ន្ធ។
- សម្រិតសម្រាំងដំណើរការវិភាគហានិភ័យឲ្យបានប្រសើរឡើងបន្ថែមទៀត និងការអនុវត្តសេណារីយ៉ូ ស្ត្រេសតេស្ត និងរ៉ាវ៉ែសស្ត្រេសតេស្ត ដែលបណ្តាលឲ្យមានការកើតឡើងនូវហានិភ័យដំណាលគ្នា រួមទាំងផលប៉ះពាល់នៃការឆ្លងរីករាលដាលនៃកូវីដ-១៩ និងហ្វាស៊ីលីធីរៀបចំឡើងវិញ។
- បានវាយតម្លៃការអភិវឌ្ឍសមតុល្យឥណទានទៅតាមលក្ខណៈវិនិច្ឆ័យផ្សេងៗ និងជាពិសេសទៅលើគុណភាព និងអនុលោមភាពរបស់ឥណទាន ធៀបនឹងគោលការណ៍ផ្ទៃក្នុង។
- បានត្រួតពិនិត្យតាមដានអំពីការអនុវត្តការគ្រប់គ្រងហានិភ័យ និងការវាយតម្លៃអំពីភាពចាស់ទុំនៃវប្បធម៌ហានិភ័យរបស់ធនាគារ អេស៊ីលីដា។
- បានតាមដាន និងពិភាក្សា អំពីការរៀបចំហ្វាស៊ីលីធីឡើងវិញ បុនហិរញ្ញប្បទាន ការធ្វើចំណាត់ថ្នាក់ហ្វាស៊ីលីធីឡើងវិញ និងការលុបចោលហ្វាស៊ីលីធី។
- វិភាគពីផលប៉ះពាល់នៃសេណារីយ៉ូហានិភ័យ ដែលអាចកើតមាននៅលើតារាងតុល្យការ របាយការណ៍ចំណេញ-ខាត និងអនុបាតប្រុងប្រយ័ត្ន។
- បានត្រួតពិនិត្យនូវហានិភ័យដែលអាចមានផលប៉ះពាល់អវិជ្ជមាន ដល់ការប្រតិបត្តិស្តង់ដារអាជីវកម្មកម្រិតខ្ពស់ សម្រាប់សហគមន៍ និងបរិស្ថាន។
- បានត្រួតពិនិត្យ និងវិភាគលើការអភិវឌ្ឍនៃវិស័យធនាគារនៅក្នុងប្រទេសកម្ពុជា ដើម្បីវាយតម្លៃទៅលើហានិភ័យការប្រកួតប្រជែង និងអាជីវកម្ម។
- បានត្រួតពិនិត្យ និងពិភាក្សាលើការអភិវឌ្ឍទីផ្សារសេវាកម្មហិរញ្ញវត្ថុឌីជីថល ឥណទានអាជីវកម្មខ្នាតតូច មធ្យម និងឥណទានអចលនទ្រព្យ និងសំណង់។
- បានពិភាក្សា អំពីយុទ្ធសាស្ត្រក្នុងការគ្រប់គ្រងព្រឹត្តិការណ៍ហានិភ័យដែលអាចកើតមាន ដើម្បីជាអត្ថប្រយោជន៍រយៈពេលវែងរបស់ធនាគារ អេស៊ីលីដា និងអតិថិជនរបស់ខ្លួន។
- បានត្រួតពិនិត្យលទ្ធផលស្ត្រេសតេស្តសន្ទនីយភាព និងផែនការទុនយថាភាព សម្រាប់ឆ្នាំ២០២២ របស់ថ្នាក់គ្រប់គ្រង។
- បានត្រួតពិនិត្យ និងអនុម័តលើសំណើកម្មវិធីមូលនិធិរបស់ថ្នាក់គ្រប់គ្រង សម្រាប់គាំទ្រដល់ប្រតិបត្តិការតាមតម្រូវការ។
- បានត្រួតពិនិត្យរបាយការណ៍របស់នាយកដ្ឋានអនុលោមបញ្ញត្តិ និងបានទទួលរបាយការណ៍វិភាគ អំពីប្រតិបត្តិការសង្ស័យនានា។
- បានត្រួតពិនិត្យ និងអនុម័តលើការកំណត់លក្ខខណ្ឌលើកទឹកចិត្ត សម្រាប់នាយកដ្ឋានអនុលោមបញ្ញត្តិ ព្រមទាំងបានស្នើដល់គណៈកម្មាធិការតែងតែង និងលាភការ ដើម្បីដាក់ជូនក្រុមប្រឹក្សាភិបាលអនុម័ត។
- បានត្រួតពិនិត្យ និងអនុម័តលើផែនការចរិការបស់នាយកដ្ឋានអនុលោមបញ្ញត្តិ សម្រាប់ឆ្នាំសារពើពន្ធ២០២២។
- បានត្រួតពិនិត្យ និងអនុម័តលក្ខខណ្ឌយោងរបស់គណៈកម្មាធិការគ្រប់គ្រងហានិភ័យ និងព័ត៌មានវិទ្យា ព្រមទាំងបានផ្តល់អនុសាសន៍ដល់ក្រុមប្រឹក្សាភិបាល ដើម្បីអនុម័ត។
- បានត្រួតពិនិត្យ និងស្នើនូវគោលការណ៍ជាច្រើនដូចជា៖ គោលការណ៍គ្រប់គ្រងហានិភ័យ ក្របខ័ណ្ឌគ្រប់គ្រងហានិភ័យសន្ទនីយភាព សូចនាករហានិភ័យសំខាន់ៗ នៃរឿសអាប់ភៃថាយ (RAS-KRIs) គោលការណ៍ឥណទាន គោលការណ៍បរិស្ថាន សង្គម និងសហគមន៍ គោលការណ៍ IFRS9 Impairment គោលការណ៍ Credit Scoring គោលការណ៍ត្រួតពិនិត្យផ្ទៃក្នុង គោលការណ៍អនុលោមភាព គោលការណ៍កំណារពារនិវេទនជន គោលការណ៍ប្រឆាំងនឹងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម គោលការណ៍ត្រួតពិនិត្យ-ស្គាល់អតិថិជន គោលការណ៍ប្រតិបត្តិការសម្ព័ន្ធញាតិ គោលការណ៍ទំនាស់ផលប្រយោជន៍ គោលការណ៍ការជួញដូរផ្ទៃក្នុង គោលការណ៍សន្តិសុខព័ត៌មានវិទ្យា និងគោលការណ៍អភិបាលព័ត៌មានវិទ្យា។
- បានធ្វើស្វ័យវាយតម្លៃប្រចាំឆ្នាំ ទៅលើលទ្ធផលសម្រេចបានទាក់ទងទៅនឹងគោលបំណង ភារកិច្ច និងការទទួលខុសត្រូវរបស់គណៈកម្មាធិការគ្រប់គ្រងហានិភ័យ និងព័ត៌មានវិទ្យា ដើម្បីធានាបាននូវការទទួលខុសត្រូវប្រកបដោយប្រសិទ្ធភាព។

តួលេខបរិស្ថាន និងសង្គម

	២០២១	២០២០	២០១៩	២០១៨	២០១៧
សូចនាករលើការអនុវត្តផ្នែកបរិស្ថាន					
សម្ភារ					
ក្រដាស ប្រើគិតជាគីឡូក្រាម /FTE	១០,១៨	១០,៦១	១០,៦០	១០,៦៨	១០,៤២
សំណល់					
សំណល់ក្រដាស គិតជាគីឡូក្រាម /FTE	២,០៦	១,២៣	១,០៣	១,៧៩	២,១៥
ថាមពល					
ចរន្តអគ្គិសនី ប្រើគិតជាគីឡូវ៉ាត់ម៉ោង /FTE	២.០១៣,៤៦	១.៩២២,៨៤	១.៦៧៩,០៩	១.៦៨៦,១៥	១.៦៧៣,៤៦
ប្រេងសាំង ប្រើគិតជាលីត្រ /FTE	៣៥,១៦	៣៦,២៧	៣៦,៦៥	៣៨,២៣	៣៩,៧៦
ប្រេងម៉ាស៊ូត ប្រើគិតជាលីត្រ /FTE	៤០,១៥	៤៦,១១	៤៣,៧០	៤៤,៩៧	៤៩,០៤
ប្រេងម៉ាស៊ីន ប្រើគិតជាលីត្រ /FTE	១,០២	១,២៥	១,១២	១,១៣	១,២៧
ការបញ្ចេញចោលនូវឧស្ម័នកាបូនិក (សមមូល គិតជាពាន់គីឡូក្រាម)[២]					
ចរន្តអគ្គិសនី	១៣.៣៥២	១២.៦៦៨	១១.០៦៧	១១.១៨២	១១.៨៣០
ប្រេងសាំង	១.០១០	១.០៣៥	១.០៨៦	១.១២១	១.១៧៦
ប្រេងម៉ាស៊ូត	១.៣២៩	១.៥១៦	១.៤៣៨	១.៥១៩	១.៦៧២
ទឹក					
ទឹក ប្រើគិតជាម៉ែត្រគូប /FTE	២២,១៩	២០,៤២	២៨,២១	១៥,៥៤	១៥,៨៧
ការធ្វើដំណើរ					
ដោយរថយន្ត គិតជាគីឡូម៉ែត្រ /FTE	៣៦៧,២៩	៥៦៥,៥៩	៥១៤,៥៤	៤៨១,៨២	២៩៥,៩៨
ដោយទោចក្រយានយន្ត គិតជាគីឡូម៉ែត្រ /FTE	១.៧០៥.៥២	១.៨៤៥,០៤	១.៨៣៨,៧៣	១.៨៩៤,៩០	១.៩៤១,៨៦
សូចនាករលើការអនុវត្តផ្នែកសង្គម					
ការបម្រើការងារ					
ចំនួនបុគ្គលិក	១២.០៨១	១២.០១៣	១១.៩៤៨	១២.១៧៧	១២.៤៥៦
ប្រុស	៧.៣៣១	៧.២៥២	៧.១៣២	៧.២៧០	៧.៣៧០
ស្រី	៤.៧៥០	៤.៧៦១	៤.៨១៦	៤.៩០៧	៥.០៨៦
ចំនួនបុគ្គលិក (FTE)	១២.០៥៧	១១.៩៧៥	១១.៩៨៤	១២.៣០៧	១២.៤១៩
ការបណ្តុះបណ្តាល និងការអប់រំ					
ការបណ្តុះបណ្តាល (កម្មវិធីបំពាក់បំប៉ន និងអភិវឌ្ឍវិជ្ជាជីវៈ)	៥.៩១១	៧.២៩៣	៥.០៧៧	៣.៨០១	៦.៥១៧
ការបណ្តុះបណ្តាលបុគ្គលិកចូលថ្មី (កម្មវិធីដំបូង)	៧៧៨	៧៨៨	៩៨៧	៥៤៩	១.១៧៩
ការបណ្តុះបណ្តាលនិស្សិតនៅក្នុងស្រុក	៨១៥	២៣៧	៦៨៥	៦១០	១.០២៥
ការបណ្តុះបណ្តាលនិស្សិតនៅក្រៅប្រទេស	-	៥	៨	-	៥

[១] FTE (Full Time Equivalent): ចំនួនមធ្យមនៃកម្មករនិយោជិត បម្រើការពេញម៉ោងក្នុងមួយឆ្នាំ ។

[២] សមមូលឧស្ម័នកាបូនិក ត្រូវបានគណនាយោងតាមគោលការណ៍របស់ Greenhouse Gas Protocol ។

របាយការណ៍ស្តីពីនិរន្តរភាពបរិស្ថាន និងសង្គម

បេសកកម្មស្តីពីនិរន្តរភាពបរិស្ថាន និងសង្គម

ទន្ទឹមនឹងការខិតខំប្រឹងប្រែង ព្យាយាមឱ្យទទួលបាននូវនិរន្តរភាពខ្ពស់នៃប្រាក់ចំណេញ ធនាគារ អេស៊ីលីដា ក៏គោរពផងដែរចំពោះបរិស្ថាន និងសហគមន៍ដែលយើងរស់នៅ ដោយអនុវត្តតាមទស្សនៈគ្រឹះសំខាន់ទាំងបី "មនុស្ស ផែនដី និងប្រាក់ចំណេញ" ហើយធ្វើការកំណត់ជានិច្ចនូវសូចនាករសម្រាប់វាស់វែង និងរាយការណ៍អំពីសកម្មភាព និងផលប៉ះពាល់ទៅលើសង្គមនិងបរិស្ថាន ។

សមាសធាតុសំខាន់ៗនៃបេសកកម្មរបស់ ធនាគារ អេស៊ីលីដា ទាក់ទងនឹងនិរន្តរភាពបរិស្ថាន និងសង្គម

១. ផ្តល់ជាក្របខ័ណ្ឌសំខាន់នៅក្នុងគោលការណ៍ណែនាំ ដែលក្នុងនោះ ធនាគារ អេស៊ីលីដា អាចអនុវត្តតាមវិធីមួយដែលយើងអាចគ្រប់គ្រងរាល់ប្រតិបត្តិការដែលមានផលប៉ះពាល់ដល់បរិស្ថាន សង្គម និងសហគមន៍ ប្រកបដោយការទទួលខុសត្រូវខ្ពស់ ។

២. បន្តការបំពាក់ប្រព័ន្ធប្រើប្រាស់ថាមពលប្រកបដោយប្រសិទ្ធភាព ក្នុងអគារការិយាល័យ ហើយគ្រប់គ្រងលើការប្រើប្រាស់ថាមពលឱ្យបានហ្មត់ចត់ នៅគ្រប់ទីកន្លែងដែលយើងមានប្រតិបត្តិការ ។

៣. អនុលោមទៅតាមច្បាប់សង្គមដែលយើងរស់នៅ និងធ្វើការយ៉ាងសកម្ម ដើម្បីផ្សព្វផ្សាយវប្បធម៌ដ៏ស្និទ្ធស្នាល ដែលមិនមែនតែចំពោះភាគហ៊ុនិក កម្មករនិយោជិត អតិថិជន និងដៃគូអាជីវកម្មប៉ុណ្ណោះទេ គឺថែមទាំងគោរពចំពោះឯកត្តបុគ្គល នៅក្នុងសហគមន៍របស់យើងទៀតផង ។

៤. ទទួលស្គាល់ថា ការគាំទ្រចំពោះសហគមន៍មិនមែនគ្រាន់តែជាសីលធម៌ល្អប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងធ្វើឱ្យអាជីវកម្មមានលក្ខណៈល្អប្រសើរផងដែរ ពោលគឺមានភាពរឹងមាំ និងភាពរុងរឿង គឺត្រូវបំពេញឱ្យគ្នាទៅវិញទៅមក ។

បរិស្ថាន

ធនាគារអេស៊ីលីដា បានចូលរួមអនុវត្តយ៉ាងពេញលេញ ស្របតាមសន្ធិសញ្ញាអន្តរជាតិ ដែលហាមឃាត់លើការផ្តល់ឥណទាន ឬគាំទ្រចំពោះសកម្មភាពផ្សេងៗ ដែលធ្វើឱ្យប៉ះពាល់ដល់បរិស្ថាន ទាំងសកម្មភាពដែលប្រាសចាកពីសីលធម៌ ឬសកម្មភាពដែលធ្វើឱ្យមានការអន្តរាយចំពោះសិទ្ធិមនុស្ស ។ ដោយឡែក ធនាគារបានដាក់នូវគោលនយោបាយមួយចំនួន ដែលហាមដាច់ខាតរាល់សកម្មភាព ដែលពាក់ព័ន្ធទៅនឹងការបង្ខិតបង្ខំ ឬការរំលោភបំពានលើកម្លាំងពលកម្មកុមារ ការធ្វើពាណិជ្ជកម្មខាងសព្វាវុធនិងរំសេវ ល្បែងស៊ីសង បនល្បែង ផ្ទះបន ការជួញដូរ ឬផលិតផលសត្វព្រៃ (អនុសញ្ញាស្តីពីការជួញដូរជាអន្តរជាតិលើព្រៃឈើ និងសត្វព្រៃដែលជិតផុតពូជ) ដែលច្បាប់បានបញ្ញត្តិ ព្រមទាំងការផលិត ឬការធ្វើពាណិជ្ជកម្មលើវត្ថុធាតុដើមដែលមានជាតិវិទ្យុសកម្ម ឬជាតិគីមី ដែលមានគ្រោះថ្នាក់ក្នុងកម្រិតខ្ពស់ ។ ដំណើរការគ្រប់គ្រងយ៉ាងតឹងរ៉ឹង កំពុងត្រូវបានអនុវត្ត ដែលតម្រូវឱ្យអតិថិជនទាក់ទងមកកាន់បុគ្គលិកដើម្បីបញ្ជាក់ថា អាជីវកម្មរបស់ពួកគាត់ អនុលោមទៅតាមគោលការណ៍ទាំងនេះ ។

ធនាគារ អេស៊ីលីដា បានតែងតាំងមន្ត្រីទទួលបន្ទុកផ្នែកបរិស្ថានចំនួន ៥រូប ដែលទទួលខុសត្រូវទាំងស្រុងលើការងារហ្វឹកហ្វឺន និងវគ្គបំពាក់បំប៉ន ដើម្បីសម្របសម្រួលសកម្មភាពបរិស្ថាន និងត្រួតពិនិត្យលើប្រតិបត្តិការរបស់ធនាគារអេស៊ីលីដា ។

លើសពីនេះទៀត ធនាគារ អេស៊ីលីដា គាំទ្រថាមពលកើតឡើងវិញ ដោយផ្តល់ប្រាក់កម្ចីដល់អតិថិជនទាក់ទងនឹងថាមពលជីវឧស្ម័ន និងថាមពលពន្លឺព្រះអាទិត្យ ។

សូចនាករលើការអនុវត្តផ្នែកបរិស្ថាន

ក្នុងគោលបំណងបង្កើតខ្សែមូលដ្ឋាន សម្រាប់វាស់វែង កិច្ចខិតខំប្រឹងប្រែង ដើម្បីកាត់បន្ថយការប៉ះពាល់បរិស្ថាន នៅក្នុងឆ្នាំ២០០៥ យើងបានបង្កើតប្រព័ន្ធឃ្លាំមើល ចំពោះការប្រើប្រាស់ធនធាន ។ លទ្ធផលត្រូវបានបង្ហាញជាចំណុចចម្បងតាមលំដាប់លំដោយដូចខាងក្រោម ដើម្បីប្រើប្រាស់ជាគំរូសម្រាប់អនុវត្តនាពេលអនាគត ។

ការប្រើប្រាស់ក្រដាស

នៅក្នុងឆ្នាំ២០២១ ការប្រើប្រាស់ក្រដាសបានថយចុះ ៤,០៥% សម្រាប់កម្មករនិយោជិតម្នាក់ៗបើប្រៀបធៀបនឹងឆ្នាំ២០២០ ។ ទោះជាយ៉ាងណាក៏ដោយ ធនាគារនៅតែបន្តជំរុញឱ្យបុគ្គលិកប្រើប្រាស់ប្រព័ន្ធអេឡិចត្រូនិក សម្រាប់ផ្ទុកឯកសារ និងព័ត៌មានផ្សេងៗ ។

សំណល់ក្រដាសបានកើនឡើង ៦៧,៤៨% បើប្រៀបធៀបនឹងឆ្នាំ២០២០ ។

	២០២១	២០២០	២០១៩	២០១៨	២០១៧
សម្ភារ					
ក្រដាស ប្រើគិតជាគីឡូក្រាម /FTE	១០,១៨	១០,៦១	១០,៦០	១០,៦៤	១០,៤២
សំណល់					
សំណល់ក្រដាស គិតជាគីឡូក្រាម /FTE	២,០៦	១,២៣	១,០៣	១,៧៩	២,១៥

ការប្រើប្រាស់ថាមពល

ការប្រើប្រាស់អគ្គិសនីសម្រាប់បុគ្គលិកម្នាក់ៗ បានកើនឡើង ៤,៧១% ក្នុងឆ្នាំ២០២១ បើប្រៀបធៀបឆ្នាំ២០២០ ។ ការប្រើប្រាស់ប្រេងសាំងសម្រាប់បុគ្គលិកម្នាក់ៗ បានថយចុះចំនួន ៣,០៦% ប្រេងម៉ាស៊ូតថយចុះ ១២,៩៣% និងប្រេងម៉ាស៊ីនថយចុះ ១៨,៤០% បើប្រៀបធៀបនឹងឆ្នាំ២០២០ ។

	២០២១	២០២០	២០១៩	២០១៨	២០១៧
ថាមពល					
ចរន្តអគ្គិសនី ប្រើគិតជាគីឡូវ៉ាត់ម៉ោង /FTE	២.០១៣,៤៦	១.៩២២,៨៤	១.៦៧៩,០៩	១.៦៤៦,១៥	១.៦៧៣,៤៦
ប្រេងសាំង ប្រើគិតជាលីត្រ /FTE	៣៥,១៦	៣៦,២៧	៣៦,៦៥	៣៨,២៣	៣៩,៧៦
ប្រេងម៉ាស៊ូត ប្រើគិតជាលីត្រ /FTE	៤០,១៥	៤៦,១១	៤៣,៧០	៤៤,៩៧	៤៩,០៤
ប្រេងម៉ាស៊ីន ប្រើគិតជាលីត្រ /FTE	១,០២	១,២៥	១,១២	១,១៣	១,២៧
ការបញ្ចេញចោលនូវឧស្ម័នកាបូនិក (សមមូល គិតជាពាន់គីឡូក្រាម)					
ចរន្តអគ្គិសនី	១៣.៣៥២	១២.៦៦៤	១១.០៦៧	១១.១៤២	១១.៤៣០
ប្រេងសាំង	១.០១០	១.០៣៥	១.០៤៦	១.១២១	១.១៧៦
ប្រេងម៉ាស៊ូត	១.៣២៩	១.៥១៦	១.៤៣៨	១.៥១៩	១.៦៧២

ការប្រើប្រាស់ទឹក

ការប្រើប្រាស់ទឹកបានកើនឡើង ៨,៦៧% ក្នុងឆ្នាំ២០២១ បើប្រៀបធៀបនឹងឆ្នាំ២០២០ ។

	២០២១	២០២០	២០១៩	២០១៨	២០១៧
ទឹក					
ទឹក ប្រើគិតជាម៉ែត្រគូប /FTE	២២,១៩	២០,៤២	២៨,២១	១៥,៥៤	១៥,៨៧

ការធ្វើដំណើរ

នៅក្នុងឆ្នាំ២០២១ ចម្ងាយផ្លូវសរុបក្នុងការធ្វើដំណើរដោយរថយន្ត ថយចុះ ៣៥,០៦% និងទោចក្រយានយន្ត ថយចុះ ៧,៥៦% បើប្រៀបធៀបនឹងឆ្នាំ២០២០ ។

	២០២១	២០២០	២០១៩	២០១៨	២០១៧
ការធ្វើដំណើរ					
ដោយរថយន្ត គិតជាគីឡូម៉ែត្រ /FTE	៣៦៧,២៩	៥៦៥,៥៩	៥១៨,៥៤	៨៨១,៨២	២៩៥,៩៨
ដោយទោចក្រយានយន្ត គិតជាគីឡូម៉ែត្រ /FTE	១.៧០៥.៥២	១.៨៤៥,០៤	១.៨៣៨,៧៣	១.៨៩៤,៩០	១.៩៤១,៨៦

និរន្តរភាពសង្គម

វប្បធម៌ការងាររួមរបស់ធនាគារអេស៊ីលីដា ត្រូវបានបង្កើតឡើងដោយគោរពតាមសង្គម ដែលធនាគារធ្វើប្រតិបត្តិការ រួមទាំងទស្សនវិស័យលើអ្នកចូលរួមជាមួយយើងទាំងអស់ ដែលក្នុងនោះមិនមែនផ្តោតតែទៅលើភាគហ៊ុនិក បុគ្គលិក អតិថិជន និងដៃគូអាជីវកម្មប៉ុណ្ណោះទេ ប៉ុន្តែផ្តោតលើសហគមន៍ទាំងមូល ។ បន្ថែមពីលើនេះទៀតកម្មវិធីបរិស្ថានដូចដែលបានបង្ហាញខាងលើ ធនាគារបានប្រកាន់ខ្ជាប់នូវគោលការណ៍មួយ គឺគោលការណ៍ស្មើភាពគ្នាចំពោះទំនាក់ទំនងជាមួយសាធារណជនទូទៅ អតិថិជន និងបុគ្គលិក ។ ចំណុចទាំងអស់ខាងលើនេះ ធនាគារ អេស៊ីលីដាបានអនុវត្តដោយចាប់ផ្តើមចេញពីចំណុចសូន្យនៃភាពពុករលួយ ទាំងខាងក្នុង និងខាងក្រៅ និងការប្រព្រឹត្តបំពានទាំងឡាយ ។

ខាងក្រោមនេះ គឺជាគោលការណ៍សំខាន់ៗនៅក្នុងគោលនយោបាយទទួលខុសត្រូវ ក្នុងសង្គមរួមរបស់ធនាគារ អេស៊ីលីដា ៖

បុគ្គលិក

- ធនាគារអេស៊ីលីដា ផ្តល់ឱកាសស្មើគ្នាចំពោះកម្មករនិយោជិតទាំងអស់ ។ លើកលែងតែការងារណាដែលមានហានិភ័យផ្លូវកាយខ្ពស់ (ដូចជាអ្នកយាម និងអ្នកបញ្ជូនសារ) ការតែងតាំងរាល់មុខតំណែង នៅគ្រប់លំដាប់ថ្នាក់ទាំងអស់ គឺផ្អែកទាំងស្រុងលើគុណវុធិដោយមិនរើសអើងចំពោះភេទ ឬកាយពិការភាពឡើយ ។
- ធនាគារអេស៊ីលីដា មានបំណងក្លាយជានិយោជក ដែលមានការអភិវធ្ឍបំផុតនៅកម្ពុជា ក្នុងការឧបត្ថម្ភលើការពិនិត្យ និងការព្យាបាលជំងឺ ប្រាក់សោធននិវត្តន៍ និងអត្ថប្រយោជន៍ដទៃទៀត ដូចជាផ្តល់ ឥណទានសម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួន ឥណទានគេហដ្ឋាន និងផ្តល់លទ្ធភាពឱ្យកម្មករនិយោជិតក្លាយជាម្ចាស់ភាគហ៊ុន នៅពេលដែលកម្មករនិយោជិតនោះឆ្លងផុតការសាកល្បងការងារ ។ ធនាគារអេស៊ីលីដា ផ្តល់ការហ្វឹកហ្វឺនជូនទាំងបុគ្គលិកដែលទើបចូលបម្រើការងារថ្មី និងបុគ្គលិកដែលមានបទពិសោធន៍ស្រាប់ ព្រមទាំងលើកទឹកចិត្តបុគ្គលិកដែលមានបំណងអភិវធ្ឍខ្លួនគេបន្ថែមទៀត ឱ្យទៅសិក្សានៅខាងក្រៅ ។
- គណៈកម្មាធិការគ្រប់គ្រងហានិភ័យ និងព័ត៌មានវិទ្យា ដឹកនាំដោយសមាជិកក្រុមប្រឹក្សាភិបាល មានតួនាទីទទួលខុសត្រូវយ៉ាងសំខាន់ក្នុងការកំណត់ និងការត្រួតពិនិត្យអំពីបទដ្ឋានក្រមសីលធម៌ និងវិជ្ជាជីវៈរបស់ធនាគារ និងការគោរពសិទ្ធិមនុស្ស ។

- ដោយបានធ្វើការពិភាក្សាជាមួយបុគ្គលិក ធនាគារ អេស៊ីលីដាបានរៀបចំនូវគោលនយោបាយសង្គមនានា ដែលគ្របដណ្តប់លើ ៖ ១. ក្រមសីលធម៌ ២. ការគ្រប់គ្រងធនធានមនុស្ស ៣. សុខភាព និងសុវត្ថិភាព ៤. ទំនាក់ទំនងខាងក្រៅ ៥. សេរីភាពបង្កើតសមាគម និងសិទ្ធិក្នុងការចរចាជារួម ។ ឥឡូវអ្វីទាំងអស់នេះ ត្រូវបានផ្សព្វផ្សាយក្នុងប្រព័ន្ធ Lotus Notes ដូច្នេះបុគ្គលិកម្នាក់ៗអាចទទួលនូវអ្វីដែលជាការកែប្រែថ្មី និងទាន់សម័យដោយសេរី (ថែមទាំងមិនចាំបាច់ប្រើក្រដាសផង) ។
- បុគ្គលិកទាំងអស់មានប្រតិភូបុគ្គលិក ដែលពួកគេធ្វើការបោះឆ្នោតជ្រើសរើសដោយផ្ទាល់ដោយមិនរាប់បញ្ចូលថ្នាក់ដឹកនាំ និងគណៈកម្មាធិការកីឡាសម្រាប់បុគ្គលិក ដើម្បីលើកកម្ពស់សុខភាព និងបង្កើននូវចំណងមិត្តភាព ។ នៅការិយាល័យកណ្តាល របស់ធនាគារអេស៊ីលីដាមានគិលានដ្ឋានមួយដែលមានលោកវេជ្ជបណ្ឌិតម្នាក់ និងគិលានុបដ្ឋាយិកា២នាក់ បម្រើការពេញម៉ោង ។ ការអនុវត្តការងារប្រកបដោយសុវត្ថិភាពលើបញ្ហាសុខភាព គឺជាផ្នែកមួយនៃការហ្វឹកហ្វឺនដែលផ្តល់ជូនគ្រប់កម្មករនិយោជិតក្រោមការត្រួតពិនិត្យរបស់លោកវេជ្ជបណ្ឌិត ។ គោលការណ៍សុខុមាលភាព និងសុវត្ថិភាព ដែលស្ថិតក្រោមការទទួលខុសត្រូវផ្ទាល់របស់អនុប្រធាននាយកប្រតិបត្តិ និងជាគណៈប្រធាននាយកប្រតិបត្តិអភិបាលកិច្ច បានដាក់ឱ្យអនុវត្ត នៅក្នុងនោះក៏រួមមានគោលការណ៍ដែលគ្រប់គ្រងដោយគណៈកម្មាធិការមួយ សម្រាប់ជួយគាំទ្រដល់បុគ្គលិកដែលមានជំងឺអេដស៍ ។

	២០២១	២០២០	២០១៩	២០១៨	២០១៧
ការបម្រើការងារ					
ចំនួនបុគ្គលិក	១២,០៨១	១២,០១៣	១១,៩៤៨	១២,១៧៧	១២,៤៥៦
ប្រុស	៧,៣៣១	៧,២៥២	៧,១៣២	៧,២៧០	៧,៣៧០
ស្រី	៤,៧៥០	៤,៧៦១	៤,៨១៦	៤,៩០៧	៥,០៨៦
ចំនួនបុគ្គលិក (FTE)	១២,០៥៧	១១,៩៧៥	១១,៩៨៤	១២,៣០៧	១២,៤១៩
ការបណ្តុះបណ្តាល និងការអប់រំ					
ការបណ្តុះបណ្តាល (កម្មវិធីបំពាក់បំប៉ន និងអភិវឌ្ឍវិជ្ជាជីវៈ)	៥,៩១១	៧,២៩៣	៥,០៧៧	៣,៨០១	៦,៥១៧
ការបណ្តុះបណ្តាលបុគ្គលិកចូលថ្មី (កម្មវិធីដំបូង)	៧៧៨	៩៨៨	៩៨៧	៥៤៩	១,១៧៩
ការបណ្តុះបណ្តាលនិស្សិតនៅក្នុងស្រុក	៤១៥	២៣៧	៦៨៥	៦១០	១,០២៥
ការបណ្តុះបណ្តាលនិស្សិតនៅក្រៅប្រទេស	-	៥	៨	-	៥

សហគមន៍

ធនាគារអេស៊ីលីដា ទទួលស្គាល់ថា ការចូលរួមបំពេញនូវតួនាទីជាប្រជាពលរដ្ឋដ៏ល្អក្នុងសហគមន៍របស់យើង ជាបច្ច័យមួយដ៏ល្អសម្រាប់ផលប្រយោជន៍ និងភាពរុងរឿងរបស់យើងទាំងអស់គ្នា ។ គំនិតផ្តួចផ្តើមសំខាន់ៗដែលយើងកំពុងអនុវត្តគឺ ៖

- អភិវឌ្ឍ និងផ្តល់ជូននូវផលិតផលនិងសេវាកម្ម ឱ្យបានសមស្របប្រកបដោយការសម្រិតសម្រាំងយ៉ាងប្រុងប្រយ័ត្ន និងអភិវឌ្ឍឱ្យសមស្របទៅនឹងតម្រូវការពិសេសក្នុងសង្គមកម្ពុជាយើង ។ ក្នុងឆ្នាំ២០០៦ ធនាគារអេស៊ីលីដា បានបង្កើតនូវសេវាឥណទានគេហដ្ឋានដែលមានអត្រាការប្រាក់ថេររយៈពេល ១៥ឆ្នាំ ដែលអាចធ្វើឱ្យប្រជាជនកម្ពុជាគ្រប់រូប ជាពិសេសសម្រាប់អ្នកដែលមានទ្រព្យសម្បត្តិតិចតួច អាចមានលទ្ធភាពទិញលំនៅដ្ឋានផ្ទាល់ខ្លួនបាន ។
- ពង្រីកបណ្តាញប្រតិបត្តិការ ដោយផ្តល់សេវាកម្មធនាគារដល់សហគមន៍ថ្មីៗ ដែលមានទីតាំងនៅកន្លែងផ្សេងៗ ដោយពង្រីកបណ្តាញប្រតិបត្តិការនៅតាមបណ្តាខេត្ត-រាជធានី និងពង្រីកសេវាកម្មធនាគារតាមរយៈប្រព័ន្ធអនឡាញ ដើម្បីប្រមូលនូវប្រាក់សន្សំឱ្យបានកាន់តែច្រើន ។ ការពង្រីកបណ្តាញប្រតិបត្តិការ អេធីអឹម ដែលបម្រើសេវាកម្ម ២៤ ម៉ោងក្នុងមួយថ្ងៃ និង៧ថ្ងៃក្នុងមួយសប្តាហ៍ នៅគ្រប់បណ្តាខេត្ត-រាជធានីក្នុងឆ្នាំ២០១០ បានបង្ករនូវភាពងាយស្រួលដល់អតិថិជន អាចធ្វើប្រតិបត្តិការបានគ្រប់ពេលវេលា តាមតម្រូវការរបស់ខ្លួនដោយមិនគិតពីម៉ោងបម្រើការងារ ឬថ្ងៃឈប់សម្រាកសាធារណៈឡើយ ។ ក្នុងខែមេសា ឆ្នាំ២០១៧ ធនាគារបានដាក់ឱ្យប្រើប្រាស់នូវសេវា អេស៊ីលីដាម៉ូបាល "សេវាអេស៊ីលីដាយូនីធីទាន់ចិត្ត" គឺជាសេវាហិរញ្ញវត្ថុមួយប្រភេទដែលអនុញ្ញាតឲ្យអតិថិជន និងសាធារណជនទូទៅ ដែលធ្លាប់ ឬមិនធ្លាប់ប្រើសេវាធនាគារពីមុនមកជាមួយធនាគារ អេស៊ីលីដា ភីអិលស៊ី ឬធនាគារផ្សេង អាចធ្វើប្រតិបត្តិការសេវាធនាគារ តាមរយៈទូរស័ព្ទចល័ត ។ ក្នុងឆ្នាំ២០១៤ និង ២០១៥ ធនាគារបានដាក់ឱ្យប្រើប្រាស់សេវាអេស៊ីលីដាអ៊ីនធើណែត និងសេវាអេស៊ីលីដាអ៊ីឌុមមើស ដែលអនុញ្ញាតឱ្យអតិថិជនធ្វើប្រតិបត្តិការសេវាហិរញ្ញវត្ថុ និងទូទាត់ទំនិញ-សេវាកម្មផ្សេងៗ បានគ្រប់ពេលវេលាគ្រប់ទីកន្លែង ។
- អំឡុងខែធ្នូ ឆ្នាំ២០២១ ធនាគារបានសិក្សាស្រាវជ្រាវពីកម្រិតជីវភាពរស់នៅរបស់អតិថិជន ដែលប្រើប្រាស់ឥណទានអាជីវកម្មខ្នាតតូច និង ឥណទានអាជីវកម្មខ្នាតមធ្យម ដើម្បីវាស់ស្ទង់ពីផលប៉ះពាល់នៃសេវាកម្មឥណទានរបស់ធនាគារ អេស៊ីលីដា ។ ការសិក្សាស្រាវជ្រាវនេះធ្វើឡើងចំពោះអតិថិជនចំនួន ២,១៩៧នាក់ (អតិថិជនស្ត្រីមានចំនួន ៥៥%) ដែលជ្រើសរើសដោយចៃដន្យចេញពីអតិថិជនឥណទានចំនួន ៣២៩,៧១០ ដែលក្នុងនោះមាន ៦៧,៧៧% ជាអ្នកជំនួញ, ១៧,១១% ជាកសិករ-កម្មករ និង ១៥,១១% ជាក្រុមហ៊ុនឯកជន-អង្គការក្រៅរដ្ឋាភិបាល-មន្ត្រីរាជការ ។ លទ្ធផលនៃការសិក្សាស្រាវជ្រាវបង្ហាញថា លើគ្រប់វិស័យអតិថិជនចំនួន ៨០,១៥% មានកម្រិតជីវភាពល្អប្រសើរឡើងក្រោយពីបានទទួលឥណទានពីធនាគារ អេស៊ីលីដា ហើយ ៥,៣៧% មិនមានការប្រែប្រួល និង ១៨,៤៧% បានធ្លាក់ចុះ ។

	២០២១	២០២០	២០១៩	២០១៨	២០១៧
កម្រិតជីវភាព					
កើនឡើង	៨០,១៥%	៧៨,៣១%	៩២,៤០%	៩០,៩០%	៨៨,១៣%
នៅថេរ	៥,៣៧%	៦,០៨%	៣,៥៧%	៦,២៣%	៧,៤៦%
ធ្លាក់ចុះ	១៤,៤៧%	១៥,៦១%	៤,០៣%	២,៨៧%	៤,៤១%

- វិធានការយ៉ាងតឹងរ៉ឹង ត្រូវបានដាក់បញ្ចូលក្នុងគោលការណ៍ ដើម្បីហាមឃាត់ដល់ការលក់ ឬការជំរុញឱ្យអតិថិជនយកឥណទានលើសពីសមត្ថភាព ឬការជំរុញឱ្យគាត់ជាវផលិតផល ឬសេវាកម្មដែលមិនសមស្រប ។ តាមគោលការណ៍ ធនាគារអេស៊ីលីដាមិនតម្រូវឱ្យអតិថិជនដាក់ប្រាក់បញ្ញើកាតព្វកិច្ចឡើយ ។
- តម្លាភាព និងភាពជឿជាក់ក្នុងការផ្សព្វផ្សាយ គឺបានប្រតិបត្តិយ៉ាងតឹងរ៉ឹងនៅពេលអភិវឌ្ឍ ផ្សព្វផ្សាយ និងលក់ផលិតផលនិងសេវាកម្មរបស់ធនាគារ ហើយព័ត៌មានពេញលេញ និងលម្អិត បានផ្តល់ជូនអតិថិជនតាមរយៈខិត្តប័ណ្ណផ្សព្វផ្សាយ វេបសាយ និងសម្ភារផ្សព្វផ្សាយដទៃទៀត ។
- ធនាគារអេស៊ីលីដា អនុវត្តស្មើភាពគ្នាក្នុងការផ្តល់ប្រាក់កម្ចី ដោយមិនប្រកាន់ភេទ ឬពូជសាសន៍ ៖ អតិថិជនឥណទានចំនួន ៥៨,៨៦% ជាស្ត្រី ។
- ការរក្សាអាថិកំបាំងសម្រាប់អតិថិជន ត្រូវបានបណ្តុះជាគំនិតសម្រាប់បុគ្គលិកទាំងអស់នៅពេលហ្វឹកហ្វឺន ហើយរាល់ការបំពានត្រូវបានចាត់ទុកថាជាកំហុសធ្ងន់ ។
- ដោយយល់ពីការលំបាកនៃពិការភាពនៅក្នុងប្រទេសកម្ពុជា ធនាគារអេស៊ីលីដាកំពុងតែគិតគូរយ៉ាងយកចិត្តទុកដាក់ក្នុងការសាងសង់ការិយាល័យថ្មី ឬជួសជុលកែលម្អការិយាល័យចាស់ ដើម្បីរៀបចំឱ្យមានភាពងាយស្រួលជូនពួកគាត់ជាពិសេស ។
- ក្នុងនាមជាស្ថាប័នពាណិជ្ជកម្មស្វែងរកប្រាក់ចំណេញ ធនាគារអេស៊ីលីដាពុំបានទទួលជំនួយឧបត្ថម្ភអ្វីឡើយ ប៉ុន្តែនៅពេលវេលាណាមួយ ឬកន្លែងសមស្រប ធនាគារអាចទទួលជំនួយហិរញ្ញវត្ថុ ដើម្បីផ្តល់សេវាកម្មមិនស្វែងរកប្រាក់ចំណេញ ដូចជាការរៀបចំសិក្ខាសាលាសម្រាប់សិក្ខាកាមនៅខាងក្រៅជាដើម ។
- ធនាគារអេស៊ីលីដា ពុំមានចំណងទាក់ទងទៅនឹងគណបក្សនយោបាយ ឬសាសនាណាមួយឡើយ ប៉ុន្តែស្វែងរកនូវសហប្រតិបត្តិការ និងអនុវត្តការងារប្រកបដោយភាពចុះសម្រុងជាមួយរដ្ឋាភិបាលដែលបានជាប់ឆ្នោត ។ ធនាគារចូលរួមយ៉ាងទៀងទាត់ក្នុងកិច្ចប្រជុំជាមួយមន្ត្រីជាន់ខ្ពស់ តាមរយៈសមាគមឧស្សាហកម្ម វេទិកាពាណិជ្ជកម្ម សភាពាណិជ្ជកម្ម និងសកម្មភាពជាក្រុមផ្សេងៗទៀត ។ ការជួបប្រជុំក្នុងលក្ខខណ្ឌជាឯកត្តបុគ្គលជាមួយមន្ត្រីនានា ត្រូវបានធ្វើឡើងប្រកបដោយតម្លាភាព ហើយបញ្ហាសំខាន់ផ្សេងៗត្រូវបានរៀបចំជាកំណត់ហេតុទុក ។ ធនាគារអេស៊ីលីដាមានបញ្ញត្តិយ៉ាងតឹងរ៉ឹងសម្រាប់គ្រប់គ្រងលើ "ការកម្សាន្តមិនសមស្រប" និងសកម្មភាពផ្សេងៗទៀត ដែលអាចបើកចំហរចំពោះរាល់ចម្ងល់លើមូលដ្ឋាននៃសុចរិតភាព ក្នុងនោះរួមមានបញ្ញត្តិលើសេវាកម្មធនាគារក្នុងអត្រាមិនមែនពាណិជ្ជកម្ម (គោលនយោបាយផ្តល់ប្រាក់កម្ចី) ។
- ក្នុងឆ្នាំ២០២១ ធនាគារ អេស៊ីលីដា បានអនុញ្ញាតឱ្យនិស្សិតក្នុងស្រុកចំនួន ៤១៥នាក់ ចុះមកធ្វើកម្មសិក្សា ។
- ក្នុងឆ្នាំ២០២១ ធនាគារ អេស៊ីលីដា ភីអិលស៊ី បានចូលរួមសកម្មភាពសង្គម និងមនុស្សធម៌សំខាន់ៗ តាមរយៈការបរិច្ចាគ ដូចខាងក្រោម ៖

ការអប់រំ

- ឧបត្ថម្ភដល់ **អង្គការមូលនិធិអេស៊ីលីដា-ចាឌីន**សម្រាប់ការអប់រំ ដើម្បីសាងសង់សាលាបឋមសិក្សាពីរខ្នងធ្វើអំពីថ្ម (សាលារំដួលរាសនា និងកាំងចាម) ក្នុងខេត្តឧត្តរមានជ័យ និង ស្ទឹងត្រែង ។

សុខភាព

- ឧបត្ថម្ភដល់ **មូលនិធិគន្ធបុប្ផាកម្ពុជា** ។
- ឧបត្ថម្ភកម្មវិធី (Gold Sponsor) "**ព្រឹត្តិការណ៍ជិះកង់លើភ្នំបូកគោ**" ដែលរៀបចំដោយ សណ្ឋាគារបានស្ពគ៌សុខា។

មនុស្សធម៌

- ឧបត្ថម្ភដល់ **កាកបាទក្រហមកម្ពុជា** ក្នុងកម្មវិធី អបអរខួបទី១៥៨ ទិវាពិភពលោកកាកបាទក្រហម និងអឌ្ឍចន្ទក្រហម ៨ ឧសភា ។

បរិស្ថាន

- ឧបត្ថម្ភកម្មវិធី (Main Sponsor) "**ព្រឹត្តិការណ៍ ដាំកូនឈើ និងសម្អាតទីក្រុង**" ដែលរៀបចំដោយ ក្រសួងបរិស្ថាន មន្ទីរបរិស្ថានខេត្តកំពត។

ឧបត្ថម្ភកម្មវិធីផ្សេងៗ

- ឧបត្ថម្ភធំកម្មវិធីប្រកួតប្រជែង "**ពានរង្វាន់សហគ្រិនថ្នាក់ជាតិ ឆ្នាំ២០២១**" ដែលរៀបចំដោយ **វិទ្យាស្ថានជាតិសហគ្រិនភាព និងនវានុវត្តន៍**។
- ឧបត្ថម្ភ (Bronze Sponsor) កម្មវិធី "**វេទិកាបច្ចេកវិទ្យាកម្ពុជា ឆ្នាំ២០២១**"។
- ឧបត្ថម្ភ (Diamond Sponsor) កម្មវិធី "**មគ្គុទេសក៍ស្តារអាជីវកម្មក្នុងបរិបទកូវីដ-១៩**" ដែលរៀបចំដោយ សមាគមសហគ្រិនវ័យក្មេងកម្ពុជា សមាគមធនាគារនៃកម្ពុជា និងសមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា។

ការផ្តល់ចំណាត់ថ្នាក់

ធនាគារ អេស៊ីលីដា គឺជាធនាគារដំបូងគេនៅក្នុងប្រទេសកម្ពុជា ដែលទទួលបានការផ្តល់ចំណាត់ថ្នាក់ដោយស្ថាប័នផ្តល់ចំណាត់ថ្នាក់ធនាគារអន្តរជាតិ គឺ Standard & Poor's និង GIIRS ។

ចំណាត់ថ្នាក់ នាថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២១	របាយការណ៍វាយតម្លៃផលប៉ះពាល់ ឆ្នាំ២០១៨
S&P Global Ratings	GIIRS Impact Rated
Issuer Credit Rating B+/Stable/B	Impact Business Models Rating SILVER
Stand-Alone Credit Profile (SACP) bb	Operations Rating ★★★★☆

សាខាធនាគារ អេស៊ីលីដា

សូមស្កេន QR ខាងក្រោមដើម្បីបង្ហាញសាខាធនាគារ អេស៊ីលីដា

ព្រះរាជាណាចក្រកម្ពុជា

ធនាគារ អេស៊ីលីដា ភីអិលស៊ី

សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ

ធនាគារ អេស៊ីលីដា ឡាវ

សាធារណរដ្ឋសហភាពមីយ៉ាន់ម៉ា

ស្ថាប័នមីក្រូហិរញ្ញវត្ថុ អេស៊ីលីដា មីយ៉ាន់ម៉ា

ធនាគារដៃគូ

ធនាគារដៃគូសំខាន់ៗ

ប្រាក់	ឈ្មោះធនាគារ	ទីតាំង	SWIFT/BIC
AUD	THE BANK OF NEW YORK MELLON (BNY MELLON)	NEW YORK	IRVTUS3N
CNY	INDUSTRIAL AND COMMERCIAL BANK OF CHINA (HEAD OFFICE)	BEIJING	ICBKCNBJ
	INDUSTRIAL AND COMMERCIAL BANK OF CHINA (BRANCH)	SHENZHEN	ICBKCNBJSZN
EUR	SOCIETE GENERALE	PARIS	SOGEFRPP
	STANDARD CHARTERED BANK AG	FRANKFURT	SCBLDEFX
GBP	STANDARD CHARTERED BANK	LONDON	SCBLGB2L
JPY	SUMITOMO MITSUI BANKING CORPORATION	TOKYO, JAPAN	SMBCJPJT
SGD	UNITED OVERSEAS BANK LIMITED	SINGAPORE	UOVBSGSG
THB	BANGKOK BANK PUBLIC COMPANY LIMITED	BANGKOK	BKKBTHBK
	KRUNG THAI BANK PUBLIC COMPANY LIMITED	BANGKOK	KRTHTHBK
	THANACHART BANK PUBLIC COMPANY LIMITED	BANGKOK	THBKTHBK
	UNITED OVERSEAS BANK (THAI) PUBLIC COMPANY LIMITED	BANGKOK	UOVBTHBK
USD	BANGKOK BANK PUBLIC COMPANY LIMITED	BANGKOK	BKKBTHBK
USD	BANK OF AMERICA, N.A.	NEW YORK-NY	BOFAUS3N
	KEB HANA BANK	SEOUL	KOEXKRSE
	KOOKMIN BANK	SEOUL	CZNBKRSE
	STANDARD CHARTERED BANK	NEW YORK-NY	SCBLUS33
	THE BANK OF NEW YORK MELLON	NEW YORK-NY	IRVTUS3N
	UNITED OVERSEAS BANK LIMITED	SINGAPORE	UOVBSGSG
	WELLS FARGO BANK, N.A. (NEW YORK INTERNATIONAL BRANCH)	NEW YORK-NY	PNBPUS3NNYC
	WOORI BANK	SEOUL	HVBKKRSE
VND	VIETNAM BANK FOR AGRICULTURE AND RURAL DEVELOPMENT	HANOI	VBAAVNVX

ធនាគារដៃគូ

សូមស្កេន QR ដើម្បីបង្ហាញធនាគារដៃគូ

ធនាគារ អេស៊ីលីដា ភីអិលស៊ី
និងក្រុមហ៊ុនបុត្រសម្ព័ន្ធ

របាយការណ៍ហិរញ្ញវត្ថុរួម
និងរបាយការណ៍ហិរញ្ញវត្ថុដោយឡែក
សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់
ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១
និង
របាយការណ៍របស់សវនករឯករាជ្យ
ស្តីពីរបាយការណ៍ហិរញ្ញវត្ថុ

ធនាគារ អេស៊ីលីដា ភីអិលស៊ី និង ក្រុមហ៊ុនបុត្រសម្ព័ន្ធ

របាយការណ៍ហិរញ្ញវត្ថុរួម និង របាយការណ៍ហិរញ្ញវត្ថុដោយឡែក
នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ និងសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់

មាតិកា

	ទំព័រ
របាយការណ៍របស់ក្រុមប្រឹក្សាភិបាល	១ - ៨
របាយការណ៍របស់សវនករឯករាជ្យ	៩ - ១៥
របាយការណ៍ហិរញ្ញវត្ថុ៖	
របាយការណ៍ហិរញ្ញវត្ថុរួម៖	
របាយការណ៍ស្ថានភាពហិរញ្ញវត្ថុរួម	១៦
របាយការណ៍ចំណេញឬខាត និងលទ្ធផល លម្អិតផ្សេងៗរួម	១៧ - ១៨
របាយការណ៍បម្រែបម្រួលមូលធនរួម	១៩ - ២០
របាយការណ៍លំហូរសាច់ប្រាក់រួម	២១ - ២២
របាយការណ៍ហិរញ្ញវត្ថុដោយឡែក៖	
របាយការណ៍ស្ថានភាពហិរញ្ញវត្ថុដោយឡែក	២៣
របាយការណ៍ចំណេញឬខាត និងលទ្ធផល លម្អិតផ្សេងៗដោយឡែក	២៤
របាយការណ៍បម្រែបម្រួលមូលធនដោយឡែក	២៥ -២៦
របាយការណ៍លំហូរសាច់ប្រាក់ដោយឡែក	២៧ - ២៨
កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ	២៩ - ២៤៥

របាយការណ៍របស់ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាល សូមដាក់បង្ហាញរបាយការណ៍របស់ខ្លួន និងរបាយការណ៍ហិរញ្ញវត្ថុរួម របស់ធនាគារ អេស៊ីលីដា ភីអិលស៊ី ហៅកាត់ថា (“ធនាគារ”) និងក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ធនាគារ (ដែលតទៅនេះ ទាំងធនាគារ និងក្រុមហ៊ុនបុត្រសម្ព័ន្ធ ត្រូវហៅកាត់ថា “សម្ព័ន្ធធនាគារ”) និងរបាយការណ៍ហិរញ្ញវត្ថុដោយឡែករបស់ធនាគារ នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ និងសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ (ដែលតទៅនេះហៅកាត់ថា “របាយការណ៍ហិរញ្ញវត្ថុ”)។

អំពីសម្ព័ន្ធធនាគារ និងធនាគារ

មុនថ្ងៃទី១ ខែធ្នូ ឆ្នាំ២០០៣ ធនាគារ អេស៊ីលីដា ភីអិលស៊ី គឺជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ដែលត្រូវបានបង្កើតឡើងក្រោមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ហើយធ្វើប្រតិបត្តិការជាធនាគារឯកទេស ដែលមានទីស្នាក់ការកណ្តាលនៅរាជធានីភ្នំពេញ និងមានសាខាចំនួន ១៥ ក្នុងព្រះរាជាណាចក្រកម្ពុជា។ នៅថ្ងៃទី១ ខែធ្នូ ឆ្នាំ២០០៣ ធនាគារជាតិនៃកម្ពុជា បានផ្តល់អាជ្ញាប័ណ្ណដល់ធនាគារ ជាធនាគារពាណិជ្ជឯកជន សម្រាប់រយៈពេលបីឆ្នាំ គិតចាប់ពីថ្ងៃទី១ ខែធ្នូ ឆ្នាំ២០០៣។ នៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០០៦ អាជ្ញាប័ណ្ណរបស់ធនាគារ ត្រូវបានប្តូរសាជាថ្មីម្តងទៀត ទៅជាអាជ្ញាប័ណ្ណអចិន្ត្រៃយ៍។ ការិយាល័យចុះបញ្ជីរបស់ធនាគារមានទីតាំងស្ថិតនៅអគារលេខ ៦១ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។ ធនាគារ អាចបង្កើតការិយាល័យបន្ថែមទាំងក្នុង និងក្រៅប្រទេស ព្រមទាំងអាចផ្លាស់ប្តូរទីតាំងការិយាល័យ ដែលបានចុះបញ្ជីរួចហើយ ដោយចុះបញ្ជីការផ្លាស់ប្តូរទាំងនោះ នៅក្រសួងពាណិជ្ជកម្ម និងត្រូវមានការអនុម័តយល់ព្រមពីធនាគារជាតិ នៃ កម្ពុជា។

ថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២០ ធនាគារជោគជ័យនៅក្នុងការចុះបញ្ជីនៅលើទីផ្សារមូលបត្រកម្ពុជា។ ភាគហ៊ុនថ្មីត្រូវបានបោះផ្សាយចំនួន ៤.៣៤៤.៨៦៥ ភាគហ៊ុន ក្នុងតម្លៃចារឹក ៤.០០០រៀល (០.៩៨ ដុល្លារអាមេរិក) ក្នុងមួយហ៊ុន នៅក្នុងតម្លៃបោះផ្សាយ ១៦.២០០រៀល (៣.៩៧ ដុល្លារអាមេរិក)។ ធនាគារទទួលបានទឹកប្រាក់ពីការបោះផ្សាយលក់មូលបត្រជាសាធារណៈ លើកដំបូងចំនួន ១៧.០៨២.១០៥ ដុល្លារអាមេរិក និងចំណាយថ្លៃដើមអស់ ១.០៣១.០២៥ ដុល្លារអាមេរិក ដែលទទួលបានបុព្វលាភភាគហ៊ុនចំនួន ១១.៧០៦.២១៥ ដុល្លារអាមេរិក (៤៧.៧២៦.២៣៩ ពាន់រៀល)។ នៅថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០២០ ម្ចាស់ភាគហ៊ុនបានអនុម័តឱ្យកែប្រែលក្ខន្តិកៈក្រុមហ៊ុនទាក់ទងនឹងការបង្កើនដើមទុនសម្រាប់ការបោះផ្សាយលក់មូលបត្រជាសាធារណៈលើកដំបូង។ នៅថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២១ ធនាគារបានដាក់លិខិតស្នើសុំទៅ ធនាគារជាតិនៃកម្ពុជាក្នុងការបង្កើនដើមទុន ហើយត្រូវបានអនុម័តនៅថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២១។ ការកែប្រែលក្ខន្តិកៈក្រុមហ៊ុនក៏ត្រូវបានអនុម័តដោយក្រសួងពាណិជ្ជកម្មនៅថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២១។

ចុះបញ្ជីក្រោមលេខ
Registration No. 00003077

អគារលេខ៦១ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
#61, Preah Monivong Blvd., Sangkat Srah Chork, Khan Daun Penh, Phnom Penh, Kingdom of Cambodia.
ទូរស័ព្ទ Tel: +855 (0) 23 998 777 / 430 999, ទូរសារ Fax: + 855 (0) 23 430 555, ប្រអប់សំបុត្រ P.O.Box 1149
E-mail: acledabank@acledabank.com.kh, Website: www.acledabank.com.kh, SWIFT Code: ACLBKHPP

អំពីសម្ព័ន្ធធនាគារ និងធនាគារ (ត)

ធនាគារ និង ក្រុមហ៊ុនបុត្រសម្ព័ន្ធ រួមមាន អេស៊ីលីដា ឡារ លីមីធីត (ហៅកាត់ថា "ABL") និង ស្ថាប័នមីក្រូហិរញ្ញវត្ថុ អេស៊ីលីដា មីយ៉ាន់ម៉ា (ហៅកាត់ថា "AMM") គឺនៅក្នុងវិស័យហិរញ្ញវត្ថុ និងមានប្រតិបត្តិការ ២៦២សាខាទូទាំងខេត្តក្រុងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ៣៨សាខានៅក្នុងសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ និង ១៧សាខា នៅសាធារណរដ្ឋសហភាពមីយ៉ាន់ម៉ា។ ក្រុមហ៊ុនបុត្រសម្ព័ន្ធផ្សេងៗទៀតរបស់ធនាគារមាន ក្រុមហ៊ុន អេស៊ីលីដា ស៊ីយ្យូរីធី ភីអិលស៊ី (ហៅកាត់ថា "ACS") គឺនៅក្នុងវិស័យមូលបត្រ និងវិទ្យាស្ថាន ពាណិជ្ជសាស្ត្រ អេស៊ីលីដា (ហៅកាត់ថា "AIB") គឺនៅក្នុងវិស័យអប់រំ។

សកម្មភាពអាជីវកម្មចម្បង

ធនាគារធ្វើប្រតិបត្តិការក្រោមបទប្បញ្ញត្តិរបស់ធនាគារជាតិ នៃ កម្ពុជា ដោយផ្តោតជាពិសេសលើការផ្តល់ឥណទាន និងសេវាហិរញ្ញវត្ថុផ្សេងៗទៀត សម្រាប់ប្រជាពលរដ្ឋទូទៅ ក៏ដូចជាសហគ្រាសធុនតូច និងមធ្យម ព្រមទាំងសកម្មភាពអាជីវកម្មដទៃទៀត ដែលក្រុមប្រឹក្សាភិបាលជឿជាក់ថាគាំទ្រដល់គោលបំណងនេះ។

ធនាគារ អេស៊ីលីដា ភីអិលស៊ី កាន់កាប់ភាគហ៊ុនរបស់ ABL ចំនួន ៩៩,៩០% ហើយសកម្មភាពអាជីវកម្មចម្បង គឺការផ្តល់សេវាធនាគារ និងសេវាហិរញ្ញវត្ថុផ្សេងៗទៀតនៅ សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ។

ធនាគារ អេស៊ីលីដា ភីអិលស៊ី កាន់កាប់ភាគហ៊ុនរបស់ ACS ទាំងស្រុង ហើយសកម្មភាពអាជីវកម្មចម្បង គឺការផ្តល់សេវាជាឈ្មួញជើងសាមូលបត្រ និងសេវាផ្សេងៗទៀត ដែលបានអនុម័តដោយគណៈកម្មការមូលបត្រកម្ពុជា។

ធនាគារ អេស៊ីលីដា ភីអិលស៊ី កាន់កាប់ភាគហ៊ុនរបស់ AIB ចំនួន ៧៦,៦០៩០% ហើយសកម្មភាពអាជីវកម្មចម្បង គឺបណ្តុះបណ្តាលកម្រិតបរិញ្ញាបត្ររង កម្រិតបរិញ្ញាបត្រ និងបរិញ្ញាបត្រជាន់ខ្ពស់ លើដេប៉ាតឺម៉ង់គ្រប់គ្រងពាណិជ្ជកម្ម មុខជំនាញហិរញ្ញវត្ថុ និងធនាគារ។

ធនាគារ អេស៊ីលីដា ភីអិលស៊ី កាន់កាប់ភាគហ៊ុនរបស់ AMM ទាំងស្រុង ត្រូវបានអនុញ្ញាតឱ្យធ្វើប្រតិបត្តិការជាស្ថាប័នមីក្រូហិរញ្ញវត្ថុ ទទួលប្រាក់បញ្ញើ ដោយផ្តល់នូវសេវាផ្នែកមីក្រូហិរញ្ញវត្ថុមួយចំនួនជូនទីផ្សារសម្រាប់ប្រជាជនដែលមានប្រាក់ចំណូលទាប និងសកម្មភាពផ្សេងៗទៀតដែលអនុញ្ញាតដោយអាជ្ញាធរត្រួតពិនិត្យផ្នែកមីក្រូហិរញ្ញវត្ថុ។

លទ្ធផលហិរញ្ញវត្ថុ

លទ្ធផលហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរបស់សម្ព័ន្ធធនាគារ និងធនាគារសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០២១ ត្រូវបានបង្ហាញនៅក្នុងរបាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗរួម និងរបាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗដោយឡែកនៅលើទំព័រទី ១៧ - ១៨ និងទំព័រទី ២៤ ។

ដើមទុន និង បុព្វលាភភាគហ៊ុន

ដើមទុន និងបុព្វលាភភាគហ៊ុនត្រូវបានចាត់ថ្នាក់ជាមូលធន។ ចំណាយប្រតិបត្តិការទាក់ទងដោយផ្ទាល់លើការបោះផ្សាយដើមទុនថ្មី ត្រូវបានបង្ហាញក្នុងមូលធនបន្ទាប់ពីបានកាត់ពន្ធពីសាច់ប្រាក់ទទួលបានពីការលក់ភាគហ៊ុន។

ចុះបញ្ជីក្រោមលេខ
Registration No. 00003077

អគារលេខ៦១ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
#61, Preah Monivong Blvd., Sangkat Srah Chork, Khan Daun Penh, Phnom Penh, Kingdom of Cambodia.
ទូរស័ព្ទ Tel: +855 (0) 23 998 777 / 430 999, ទូរសារ Fax: + 855 (0) 23 430 555, ប្រអប់សំបុត្រ P.O.Box 1149
E-mail: acledabank@acledabank.com.kh, Website: www.acledabank.com.kh, SWIFT Code: ACLBKHPP

ទុនបម្រុង និងសំវិធានធន

ពុំមានការប្រែប្រួលជាសារវន្តរវាងទុនបម្រុង និងសំវិធានធននៅក្នុងការិយបរិច្ឆេទទេ ក្រៅពីការបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុនេះ ។

ឥណទានអាក្រក់ និងឥណទានសង្ស័យ

នៅមុនពេលដែលរបាយការណ៍ហិរញ្ញវត្ថុរបស់សម្ព័ន្ធធនាគារ និងធនាគារ ត្រូវបានរៀបចំឡើង ក្រុមប្រឹក្សាភិបាលបានចាត់វិធានការដែលមានមូលដ្ឋានសមស្រប ដើម្បីបញ្ជាក់ថាវិធានការទាក់ទងទៅនឹងការជម្រះបុរេប្រទាន និងឥណទានអាក្រក់ចេញពីបញ្ជី ឬការធ្វើសំវិធានធនបុរេប្រទាន និងឥណទានសង្ស័យ ហើយក្រុមប្រឹក្សាភិបាលជឿជាក់ថារាល់បុរេប្រទាន និងឥណទានអាក្រក់ទាំងអស់ដែលបានដឹងត្រូវបានជម្រះចេញពីបញ្ជី និងបានកត់ត្រាសំវិធានធនពេញលេញសម្រាប់បុរេប្រទាន និងឥណទានអាក្រក់ និងឥណទានសង្ស័យ។

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ និងផ្អែកតាមការយល់ដឹងដ៏សុក្រឹត ក្រុមប្រឹក្សាភិបាលពុំបានដឹងពីស្ថានភាពណាមួយដែលនាំឱ្យចំនួនឥណទាន និងបុរេប្រទានអាក្រក់ដែលបានជម្រះចេញពីបញ្ជី ឬសំវិធានធនលើឥណទាន និងបុរេប្រទានអាក្រក់ និងសង្ស័យនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុនេះ មានចំនួនមិនគ្រប់គ្រាន់ជាសារវន្តនោះឡើយ។

ទ្រព្យសកម្ម

នៅមុនពេលដែលរបាយការណ៍ហិរញ្ញវត្ថុរបស់សម្ព័ន្ធធនាគារ និងធនាគារ ត្រូវបានរៀបចំឡើង ក្រុមប្រឹក្សាភិបាល បានចាត់វិធានការដែលមានមូលដ្ឋានសមស្រប ដើម្បីបញ្ជាក់ថា បណ្តាទ្រព្យសកម្មទាំងឡាយ ដែលទំនងជាមិនអាចបម្រើនៅក្នុងប្រតិបត្តិការអាជីវកម្មទៅតាមតម្លៃដែលបានកត់ត្រានៅក្នុងបញ្ជីគណនេយ្យ ត្រូវបានកាត់បន្ថយឱ្យនៅស្មើនឹងតម្លៃដែលគិតថានឹងអាចប្រើប្រាស់ និងទទួលបានជាក់ស្តែង។

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ និងផ្អែកតាមការយល់ដឹងដ៏សុក្រឹត ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយដែលនឹងធ្វើឱ្យប៉ះពាល់ដល់ការវាយតម្លៃទ្រព្យសកម្ម នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់សម្ព័ន្ធធនាគារ និងធនាគារ ថាមានភាពមិនត្រឹមត្រូវជាសារវន្តនោះទេ។

វិធីសាស្ត្រវាយតម្លៃ

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ និងផ្អែកតាមការយល់ដឹងដ៏សុក្រឹត ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយដែលបានកើតឡើង ហើយអាចបណ្តាលឱ្យប៉ះពាល់ដល់វិធីសាស្ត្រកន្លងមកក្នុងការវាយតម្លៃទ្រព្យសកម្ម និងបំណុលនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់សម្ព័ន្ធធនាគារ និងធនាគារមានភាពមិនត្រឹមត្រូវ ឬមិនសមស្របជាសារវន្តនោះទេ។

បំណុលយថាភាព និងបំណុលផ្សេងៗទៀត

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះពុំមាន៖

(ក) បន្ទុកណាមួយលើទ្រព្យសកម្មរបស់សម្ព័ន្ធធនាគារ និងធនាគារដែលបានកើតឡើងចាប់តាំងពីចុងឆ្នាំមក ដោយសារការដាក់បញ្ចាំសម្រាប់ការធានាចំពោះបំណុលរបស់បុគ្គលណាម្នាក់ឡើយ និង

ចុះបញ្ជីក្រោមលេខ
Registration No. 00003077

អគារលេខ៦១ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
#61, Preah Monivong Blvd., Sangkat Srah Chork, Khan Daun Penh, Phnom Penh, Kingdom of Cambodia.
ទូរស័ព្ទ Tel: +855 (0) 23 998 777 / 430 999, ទូរសារ Fax: + 855 (0) 23 430 555, ប្រអប់សំបុត្រ P.O.Box 1149
E-mail: acledabank@acledabank.com.kh, Website: www.acledabank.com.kh, SWIFT Code: ACLBKHPP

បំណុលយថាភាព និងបំណុលផ្សេងៗទៀត (ត)

(ខ) បំណុលយថាភាពណាមួយដែលកើតមាន ឬអាចនឹងកើតមានឡើងចំពោះសម្ព័ន្ធធនាគារ និងធនាគារចាប់តាំងពីថ្ងៃចុងឆ្នាំមក ក្រៅអំពីប្រតិបត្តិការអាជីវកម្មធម្មតារបស់ធនាគារឡើយ ។

តាមយោបល់របស់ក្រុមប្រឹក្សាភិបាល ពុំមានបំណុលយថាភាព ឬបំណុលផ្សេងៗទៀតរបស់សម្ព័ន្ធធនាគារ និងធនាគារ ដែលត្រូវបំពេញ ឬអាចនឹងត្រូវបំពេញក្នុងអំឡុងពេលដប់ពីរខែបន្ទាប់ពីថ្ងៃបញ្ចប់ឆ្នាំដែលនឹងមាន ឬអាចនឹងមានប៉ះពាល់ជាសារវន្តដល់លទ្ធភាពរបស់សម្ព័ន្ធធនាគារ និងធនាគារក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួនដូចដែលបានកំណត់ និងនៅពេលដែលដល់ថ្ងៃកំណត់សងនោះទេ។

ការប្រែប្រួលកាល:ទេស:

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីកាល:ទេស:ណាមួយដែលមិនបានរៃកញ្ជៃកនៅក្នុងរបាយការណ៍នេះ ឬក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់សម្ព័ន្ធធនាគារ និងធនាគារ ដែលនឹងបណ្តាលឱ្យចំនួនណាមួយដែលបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ មានភាពមិនត្រឹមត្រូវជាសារវន្តនោះទេ។

ប្រតិបត្តិការមិនប្រក្រតី

តាមយោបល់របស់ក្រុមប្រឹក្សាភិបាល លទ្ធផលនៃប្រតិបត្តិការរបស់សម្ព័ន្ធធនាគារ និងធនាគារ ក្នុងឆ្នាំហិរញ្ញវត្ថុនេះ មិនបានទទួលរងនូវផលប៉ះពាល់ជាសារវន្តពីសកម្មភាពប្រតិបត្តិការ ឬព្រឹត្តិការណ៍មិនប្រក្រតីណាមួយឡើយលើកលែងការផ្ទុះឡើងនូវ វីរុស កូវីដ-១៩។

តាមយោបល់របស់ក្រុមប្រឹក្សាភិបាល នៅរវាងដំណាច់ឆ្នាំនេះ រហូតដល់កាលបរិច្ឆេទនៃរបាយការណ៍នេះ ពុំមានសកម្មភាពប្រតិបត្តិការ ឬព្រឹត្តិការណ៍មិនប្រក្រតីណាមួយដែលអាចជះឥទ្ធិពលជាសារវន្តដល់លទ្ធផលនៃប្រតិបត្តិការរបស់សម្ព័ន្ធធនាគារ និងធនាគារ ក្នុងការិយបរិច្ឆេទដែលរបាយការណ៍នេះបានរៀបចំឡើងនោះទេ។

វីរុស កូវីដ-១៩ និងផលប៉ះពាល់លើការខាតបង់ឥណទានរំពឹងទុក

ការខាតបង់ឥណទានរំពឹងទុក ត្រូវបានប៉ាន់ប្រមាណដោយផ្អែកទៅលើលក្ខខណ្ឌសេដ្ឋកិច្ច ដែលបានព្យាករណ៍មួយចំនួននៅក្នុងការិយបរិច្ឆេទរាយការណ៍។ ការផ្ទុះឡើងនៃ វីរុស កូវីដ-១៩ បានរាលដាលលើប្រទេសចិនដីគោកកម្ពុជា និងបណ្តាប្រទេសផ្សេងៗទៀត ធ្វើឱ្យមានការរាំងស្ទះសកម្មភាពអាជីវកម្ម និងសេដ្ឋកិច្ច។ ផលប៉ះពាល់លើផលិតផលក្នុងស្រុកសរុប (ផ.ស.ស) និងសូចនករសំខាន់ផ្សេងៗ ត្រូវបានពិចារណាក្នុងការកំណត់ភាពធ្ងន់ធ្ងរ និងលទ្ធភាពនៃការធ្លាក់ចុះនៃសេដ្ឋកិច្ចដែលប្រើប្រាស់ក្នុងការព្យាករណ៍ការខាតបង់ឥណទានរំពឹងទុក ដែលក្នុងនោះការគណនានៃការខាតបង់ឥណទានរំពឹងទុក នៅស្ថានភាពបច្ចុប្បន្នអាចមានភាពមិនជាក់លាក់។ អ្នកគ្រប់គ្រងបានធ្វើការព្យាករណ៍ផលប៉ះពាល់នៃជំងឺកូវីដ-១៩ ទៅលើសម្ព័ន្ធធនាគារ និងធនាគារ ប៉ុន្តែការព្យាករណ៍អាចនឹងមានការផ្លាស់ ប្តូរជាសារវន្តពេលមានព្រឹត្តិការណ៍ថ្មីកើតឡើង។ មើលកំណត់សម្គាល់លេខ ៤ (ខ) សម្រាប់លម្អិតបន្ថែម។

ចុះបញ្ជីក្រោមលេខ
Registration No. 00003077

អគារលេខ៦១ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
#61, Preah Monivong Blvd., Sangkat Srah Chork, Khan Daun Penh, Phnom Penh, Kingdom of Cambodia.
ទូរស័ព្ទ Tel: +855 (0) 23 998 777 / 430 999, ទូរសារ Fax: + 855 (0) 23 430 555, ប្រអប់សំបុត្រ P.O.Box 1149
E-mail: acledabank@acledabank.com.kh, Website: www.acledabank.com.kh, SWIFT Code: ACLBKHPP

ក្រុមប្រឹក្សាភិបាល និង គណៈកម្មាធិការប្រតិបត្តិ

សមាជិកក្រុមប្រឹក្សាភិបាលដែលបានបម្រើការក្នុងការិយបរិច្ឆេទរាយការណ៍ និងនាថ្ងៃចេញរបាយការណ៍នេះ រួមមាន៖

▪ លោក ឆាយ សឿន	ប្រធានក្រុមប្រឹក្សាភិបាល (អភិបាលមិនប្រតិបត្តិ)
▪ បណ្ឌិត អ៊ុន ចាន់នី	សមាជិក (អភិបាលប្រតិបត្តិ)
▪ លោក រ័ត្ន យូម៉េង	សមាជិក (អភិបាលប្រតិបត្តិ)
▪ លោក Kyosuke Hattori	សមាជិក (អភិបាលមិនប្រតិបត្តិ) ប្រសិទ្ធភាពចាប់ពី ថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០២១
▪ លោក Kenichiro Mori	សមាជិក (អភិបាលមិនប្រតិបត្តិ) លាឈប់នៅ ថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០២១
▪ លោក Albertus Bruggink	សមាជិក (អភិបាលមិនប្រតិបត្តិ) ប្រសិទ្ធភាពចាប់ពី ថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២១
▪ លោក Kay Lot	សមាជិក (អភិបាលមិនប្រតិបត្តិ) ប្រសិទ្ធភាពចាប់ពី ថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២១
▪ អ្នកនាង Mirjam Janssen	សមាជិក (អភិបាលមិនប្រតិបត្តិ) លាឈប់នៅ ថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២១
▪ លោក Stéphane Mangiavacca	សមាជិក (អភិបាលមិនប្រតិបត្តិ)
▪ បណ្ឌិត Pieter Kooi	សមាជិក (អភិបាលឯករាជ្យ)
▪ លោក Van Sou Ieng	សមាជិក (អភិបាលឯករាជ្យ)
▪ លោកស្រី Phurik Ratana	សមាជិក (អភិបាលឯករាជ្យ) ប្រសិទ្ធភាពចាប់ពី ថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ២០២១
▪ លោក Ian S. Lydall	សមាជិក (អភិបាលឯករាជ្យ) លាឈប់នៅ ថ្ងៃទី២១ ខែសីហា ឆ្នាំ២០២១

ចុះបញ្ជីក្រោមលេខ
Registration No. 00003077

អគារលេខ៦១ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
#61, Preah Monivong Blvd., Sangkat Srah Chork, Khan Daun Penh, Phnom Penh, Kingdom of Cambodia.
ទូរស័ព្ទ Tel: +855 (0) 23 998 777 / 430 999, ទូរសារ Fax: + 855 (0) 23 430 555, ប្រអប់សំបុត្រ P.O.Box: 1149
E-mail: acledabank@acledabank.com.kh. Website: www.acledabank.com.kh. SWIFT Code: ACLBKHPP

ក្រុមប្រឹក្សាភិបាល និង គណៈកម្មាធិការប្រតិបត្តិ (ត)

សមាជិកគណៈកម្មាធិការប្រតិបត្តិដែលបានបម្រើការក្នុងការិយបរិច្ឆេទរាយការណ៍ និងនាថ្ងៃចេញរបាយការណ៍នេះ រួមមាន៖

- បណ្ឌិត អ៊ុន ចាន់នី ប្រធាននាយកប្រតិបត្តិ
- បណ្ឌិត សូ ផនណារី អនុប្រធាននាយកប្រតិបត្តិជាន់ខ្ពស់ និងជាគណៈប្រធាននាយិកាប្រតិបត្តិប្រតិបត្តិការ
- លោកស្រី ម៉ារ អមរា អនុប្រធាននាយកប្រតិបត្តិជាន់ខ្ពស់ និងជាគណៈប្រធាននាយិកាប្រតិបត្តិហិរញ្ញវត្ថុ
- លោក រ័ត្ន យូម៉េង អនុប្រធាននាយកប្រតិបត្តិជាន់ខ្ពស់ និងជាគណៈប្រធាននាយកប្រតិបត្តិរតនាភិបាល
- លោក លី ថៃ អនុប្រធាននាយកប្រតិបត្តិ និង ជាគណៈប្រធាននាយកប្រតិបត្តិអភិបាលកិច្ច
- លោកស្រី ប៊ុត ប៊ុនសីហា អនុប្រធាននាយកប្រតិបត្តិ និង ជាគណៈប្រធាននាយិកាប្រតិបត្តិនីតិកម្ម និង លេខាធិការក្រុមហ៊ុន
- លោក ម៉ាច់ ធារី អនុប្រធាននាយកប្រតិបត្តិ និង ជាគណៈប្រធាននាយកប្រតិបត្តិព័ត៌មានវិទ្យា
- បណ្ឌិត ឡឿង សុភាព អនុប្រធាននាយកប្រតិបត្តិ និង ជាគណៈប្រធាននាយកប្រតិបត្តិហានិភ័យ

ការទទួលខុសត្រូវរបស់អ្នកគ្រប់គ្រង និងអ្នកទទួលបន្ទុកលើអភិបាលកិច្ចរបាយការណ៍ហិរញ្ញវត្ថុ

អ្នកគ្រប់គ្រងនិង អ្នកទទួលបន្ទុកលើអភិបាលកិច្ច ទទួលខុសត្រូវក្នុងការបញ្ជាក់ថា របាយការណ៍ហិរញ្ញវត្ថុត្រូវបានរៀបចំឡើង និងបានបង្ហាញត្រឹមត្រូវនូវគ្រប់ទិដ្ឋភាពជាសារវន្ត ទាំងអស់នៃស្ថានភាពហិរញ្ញវត្ថុរបស់សម្ព័ន្ធធនាគារ និងធនាគារ គិតត្រឹមថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០២១ ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និង លំហូរសាច់ប្រាក់ សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ដោយអនុលោមតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា (“ស.រ.ទ.ហ.អ.ក”)។

ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនេះ អ្នកគ្រប់គ្រងនិង អ្នកទទួលបន្ទុកលើអភិបាលកិច្ច ចាំបាច់ត្រូវតែ៖

(i) អនុម័តគោលនយោបាយគណនេយ្យសមស្រប ដែលគាំទ្រដោយការវិនិច្ឆ័យ និងការប៉ាន់ស្មានសមហេតុផល និងប្រកបដោយការប្រុងប្រយ័ត្ន ព្រមទាំងអនុវត្តឱ្យមានសង្គតិភាព។

(ii) អនុវត្តតាមតម្រូវការលាតត្រដាងព័ត៌មាន ដែលអនុលោមទៅតាម ស.រ.ទ.ហ.អ.ក ឬប្រសិនបើមានការប្រាសចាកណាមួយក្នុងការបង្ហាញឱ្យមានភាពពិត និងត្រឹមត្រូវ ការប្រាសចាកទាំងនោះត្រូវបង្ហាញ ពន្យល់ និងកំណត់បរិមាណឱ្យបានសមស្រប នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

(iii) រក្សាទុកកំណត់ត្រាគណនេយ្យឱ្យបានគ្រប់គ្រាន់ និងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងប្រកបដោយប្រសិទ្ធភាព។

ចុះបញ្ជីក្រោមលេខ
Registration No. 00003077

អគារលេខ៦១ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
#61, Preah Monivong Blvd., Sangkat Srah Chork, Khan Daun Penh, Phnom Penh, Kingdom of Cambodia.
ទូរស័ព្ទ Tel: +855 (0) 23 998 777 / 430 999, ទូរសារ Fax: + 855 (0) 23 430 555, ប្រអប់សំបុត្រ P.O.Box: 1149
E-mail: acledabank@acledabank.com.kh, Website: www.acledabank.com.kh, SWIFT Code: ACLBKHPP

ការទទួលខុសត្រូវរបស់អ្នកគ្រប់គ្រង និងអ្នកទទួលបន្ទុកលើអភិបាលកិច្ចរបាយការណ៍ហិរញ្ញវត្ថុ (ក)

(iv) រៀបចំរបាយការណ៍ហិរញ្ញវត្ថុក្នុងការបន្ត និរន្តរភាពនៃដំណើរការអាជីវកម្ម លើកលែងតែមិនមានភាពសមស្រប ដែលសន្មតថាសម្ព័ន្ធធនាគារ និងធនាគារនឹងបន្ត និរន្តរភាពនៃដំណើរការអាជីវកម្មនាពេលអនាគត

(v) ត្រួតពិនិត្យ និងដឹកនាំសម្ព័ន្ធធនាគារ និងធនាគារឱ្យមានប្រសិទ្ធភាព តាមការសម្រេចចិត្តជាសារវន្ត ទាំងអស់ ដែលជះឥទ្ធិពលដល់ប្រតិបត្តិការ និងដំណើរការរបស់សម្ព័ន្ធធនាគារ និងធនាគារ ហើយត្រូវប្រាកដថា កិច្ចការ ទាំងនេះត្រូវបានឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ និង

(vi) ការថែរក្សាទ្រព្យសម្បត្តិរបស់សម្ព័ន្ធធនាគារ និងធនាគារ ហើយក៏ត្រូវចាត់វិធានការឱ្យបានសមស្រប ដើម្បីទប់ ស្កាត់ និងរកឱ្យឃើញការក្លែងបន្លំ និងភាពមិនប្រក្រតីផ្សេងៗ។

អ្នកគ្រប់គ្រង និងអ្នកទទួលបន្ទុកលើអភិបាលកិច្ច ធានាអះអាងថា សម្ព័ន្ធធនាគារ និងធនាគារ បានអនុវត្តតាម រាល់តម្រូវការដូចបាន រាយការណ៍ខាងលើ ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ។

លោកស្រី ម៉ារ អមរា
អនុប្រធាននាយកប្រតិបត្តិជាន់ខ្ពស់ និងជាគណៈប្រធាននាយិការប្រតិបត្តិហិរញ្ញវត្ថុ

ធនាគារ អេស៊ីលីដា ភីអិលស៊ី ACLEDA BANK PLC.

លោកវិសិដ្ឋ អ៊ីន ចាន់ធី
ប្រធាននាយកប្រតិបត្តិ

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ថ្ងៃទី៖ ១៧ ខែកុម្ភៈ ឆ្នាំ២០២២

ការអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុ

របាយការណ៍ហិរញ្ញវត្ថុ ព្រមទាំងកំណត់សម្គាល់ទាំងឡាយដែលភ្ជាប់មកជាមួយដូចដែលបានបង្ហាញនៅទំព័រទី ១៦ ដល់ទី ២៥៥ បានបង្ហាញយ៉ាងត្រឹមត្រូវនូវគ្រប់ទិដ្ឋភាពជាសារវន្តទាំងអស់នៃស្ថានភាពហិរញ្ញវត្ថុរបស់សម្ព័ន្ធធនាគារ និងធនាគារ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ និងលទ្ធផលហិរញ្ញវត្ថុ ព្រមទាំងលំហូរសាច់ប្រាក់របស់សម្ព័ន្ធធនាគារ និងធនាគារ សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ដោយអនុលោមទៅតាម ស.រ.ទ.ហ.អ.ក ត្រូវបានអនុម័តដោយក្រុមប្រឹក្សាភិបាល។

ចុះហត្ថលេខាដោយយោងទៅតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ។

លោក ឆាយ ស្ទឿន
ប្រធានក្រុមប្រឹក្សាភិបាល

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ថ្ងៃទី៖ ២៧ ខែកុម្ភៈ ឆ្នាំ២០២២

Grant Thornton

របាយការណ៍របស់សវនករឯករាជ្យ

ហ្គ្រេន សនថុន (ខេមបូឌា) លីមីធីត
ជាន់ទី២០ អគារកាណាឌីយ៉ា
៣១៥ ផ្លូវព្រះអង្គឌួង
(កែងមហាវិថីព្រះមុនីវង្ស)
សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ
រាជធានីភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា
លេខទូស័ព្ទ +៨៥៥ ២៣ ៩៦៦ ៥២០
www.grantthornton.com.kh

ជូនចំពោះភាគហ៊ុនិកនៃ
ធនាគារ អេស៊ីលីដា ភីអិលស៊ី និងក្រុមហ៊ុនបុត្រសម្ព័ន្ធ

យោបល់

យើងខ្ញុំបានធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុរួមរបស់ ធនាគារ អេស៊ីលីដា ភីអិលស៊ី ហៅកាត់ថា (“ធនាគារ”) និងក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ធនាគារ ដែលតទៅនេះទាំងធនាគារ និង ក្រុមហ៊ុនបុត្រសម្ព័ន្ធ ត្រូវហៅកាត់ថា (“សម្ព័ន្ធធនាគារ”) និងរបាយការណ៍ហិរញ្ញវត្ថុដោយឡែករបស់ធនាគារ ដែលរួមមាន របាយការណ៍ស្ថានភាពហិរញ្ញវត្ថុរួម និងដោយឡែកនាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ របាយការណ៍ចំណេញឬខាត និងលទ្ធផលលម្អិតផ្សេងៗ របាយការណ៍ ស្តីពីបម្រែបម្រួលមូលធន និងលំហូរសាច់ប្រាក់រួម និងដោយឡែក សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ និងកំណត់សម្គាល់ដែលរួមមានគោលនយោបាយគណនេយ្យសំខាន់ៗ ព្រមទាំងព័ត៌មានពន្យល់ផ្សេងៗ ដែលបានបង្ហាញនៅទំព័រទី២៩ ដល់ទី២៥៥ (ហៅកាត់ថា “របាយការណ៍ហិរញ្ញវត្ថុ”)។

ជាមតិរបស់យើងខ្ញុំ របាយការណ៍ហិរញ្ញវត្ថុជាសារវន្ត បានបង្ហាញនូវភាពត្រឹមត្រូវនៃស្ថានភាពហិរញ្ញវត្ថុរបស់សម្ព័ន្ធធនាគារ និងធនាគារ នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់របស់សម្ព័ន្ធធនាគារ និងធនាគារ សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ដោយអនុលោមទៅតាមស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា (“ស.រ.ទ.ហ.អ.ក”) និងសេចក្តីណែនាំពីធនាគារជាតិនៃកម្ពុជា។

មូលដ្ឋានៃមតិសវនកម្ម

យើងខ្ញុំ បានធ្វើសវនកម្មដោយអនុលោមទៅតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា (“ស.ស.អ.ក”)។ ការទទួលខុសត្រូវរបស់យើងខ្ញុំ ដែលស្របតាមស្តង់ដារទាំងនោះ ត្រូវបានរៀបរាប់បន្ថែមទៀតនៅក្នុងកថាខណ្ឌស្តីពី ការទទួលខុសត្រូវរបស់សវនករសម្រាប់ការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ ដែលមាននៅក្នុងរបាយការណ៍របស់យើងខ្ញុំ។ យើងខ្ញុំ មានភាពឯករាជ្យពីសម្ព័ន្ធធនាគារ និងធនាគារ ដោយស្របទៅតាមតម្រូវការក្រមសីលធម៌វិជ្ជាជីវៈ ដែលពាក់ព័ន្ធនឹងសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ នៅក្នុងព្រះរាជាណាចក្រកម្ពុជា ហើយយើងខ្ញុំបានបំពេញនូវទំនួលខុសត្រូវលើក្រមសីលធម៌វិជ្ជាជីវៈស្របតាមតម្រូវការរបស់ស្តង់ដារទាំងនោះ។ យើងខ្ញុំជឿជាក់ថាភស្តុតាងសវនកម្មដែលយើងខ្ញុំប្រមូលបានមានលក្ខណៈគ្រប់គ្រាន់ និងសមស្របសម្រាប់ជាមូលដ្ឋានក្នុងការបញ្ចេញមតិសវនកម្មរបស់យើងខ្ញុំ។

គណនេយ្យការជំនាញ និងសវនការប្រតិស្រុត
សមាជិកភាពហ្គ្រេន សនថុន អន្តរជាតិ។ ហ្គ្រេន សនថុន អន្តរជាតិ និងសមាជិក គឺមិនមែនជាដៃគូរពាណិជ្ជកម្មទូទាំងសកលលោកទេ។ រាល់សេវាកម្មនានាត្រូវបានផ្តល់យ៉ាងឯករាជ្យដោយសមាជិកនីមួយៗ។

Grant Thornton

បញ្ហាសំខាន់ៗក្នុងការធ្វើសវនកម្ម

បញ្ហាសំខាន់ៗ ក្នុងការធ្វើសវនកម្ម គឺជាបញ្ហាមួយដែលតាមការវិនិច្ឆ័យប្រកបដោយវិជ្ជាជីវៈរបស់យើងខ្ញុំ កំណត់ថាជាបញ្ហាសំខាន់បំផុតក្នុងការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុរួម និងដោយឡែកក្នុងឆ្នាំបច្ចុប្បន្ន។ បញ្ហាទាំងនេះត្រូវបានដោះស្រាយក្នុងបរិបទនៃការធ្វើសវនកម្មនិងជាមូលដ្ឋានក្នុងការបញ្ចេញមតិសវនកម្មរបស់យើងខ្ញុំ លើរបាយការណ៍ហិរញ្ញវត្ថុរួមនិងដោយឡែកទាំងមូលដោយមិនមានការបញ្ចេញមតិសវនកម្មដាច់ដោយឡែកសម្រាប់បញ្ហានេះទេ។

បញ្ហាសំខាន់ៗក្នុងការធ្វើសវនកម្ម	**វិធីដែលបញ្ហានេះត្រូវបានដោះស្រាយក្នុងការធ្វើសវនកម្មរបស់យើងខ្ញុំ**
សំវិធានធនសម្រាប់ឱនភាពនៃការខាតបង់តម្លៃទៅលើឥណទានផ្តល់ដល់អតិថិជន	***នីតិវិធីសវនកម្មរបស់យើងខ្ញុំមានដូចខាងក្រោម៖***
យោងទៅលើកំណត់សម្គាល់ ២(ង)(vii) សម្រាប់គោលនយោបាយគណនេយ្យរបស់សម្ព័ន្ធធនាគារ និងធនាគារ ទៅលើឱនភាពនៃឥណទានផ្តល់ដល់អតិថិជន កំណត់សម្គាល់ ៤ ទៅលើការវិនិច្ឆ័យ និងការប៉ាន់ស្មានគណនេយ្យមិនជាក់លាក់សំខាន់ៗ និងកំណត់សម្គាល់ ៣៨.១ សម្រាប់សេចក្តីបង្ហាញពីហានិភ័យឥណទានរបស់សម្ព័ន្ធធនាគារ និងធនាគារ។ ឥណទានផ្តល់ដល់អតិថិជនដែលមានចំនួនប្រមាណ ៦៨,៦៧% និង៦៧,៩៩% នៃទ្រព្យសម្បត្តិសរុបរបស់សម្ព័ន្ធធនាគារ និងធនាគារ។ ផលប័ត្រឥណទានដុលរបស់សម្ព័ន្ធធនាគារ និងធនាគាររួមមានប្រាក់កម្ចីផ្តល់ដល់អតិថិជន ការបោះដុំ និងលក់រាយ សេវាកម្ម និងកសិកម្ម។ យោងទៅលើកំណត់សម្គាល់ ៣៨.១ (ឃ)(២) សម្រាប់ព័ត៌មានលម្អិត។ អតិថិជនរួមមានទាំងក្រុមហ៊ុនសាជីវកម្ម និងឯកត្តជន។ សម្ព័ន្ធធនាគារ និងធនាគារ បានអនុម័តទៅលើ ស.រ.ហ.អ.ក ៩ "ឧបករណ៍ហិរញ្ញវត្ថុ" នៅក្នុងឆ្នាំ២០១៩។ ស.រ.ហ.អ.ក ៩ បានបង្ហាញពីការខាតបង់ឥណទានដែលបានរំពឹងទុក ("ECL") គំរូឱនភាពតម្លៃ ដែលតម្រូវឱ្យប្រើប្រាស់នូវគំរូស្មុគស្មាញ និងការសន្មតសំខាន់ៗអំពីស្ថានភាពសេដ្ឋកិច្ចនាពេលអនាគត និងស្ថានភាពឥណទាន។ ស្តង់ដារគណនេយ្យស្មុគស្មាញនេះតម្រូវឱ្យមានការវិនិច្ឆ័យ និងបកស្រាយខុសៗគ្នា នៅក្នុងការអនុវត្តស្តង់ដារគណនេយ្យទាំងនេះ ជាពិសេសនៅក្នុងយុគសម័យដែលមិនអាចប៉ាន់ស្មានបាន នៃជម្ងឺរាតត្បាត	• យើងខ្ញុំទទួលបានការយល់ដឹង វាយតម្លៃលើការកែតម្រូវ និងការអនុវត្ត ព្រមទាំងពិនិត្យលើប្រសិទ្ធិភាពនៃការគ្រប់គ្រងសំខាន់ៗ ទៅលើសំវិធានធនសម្រាប់ឱនភាពនៃការខាតបង់។ ការត្រួតពិនិត្យក្នុងចំណោមផ្សេងៗទៀតរួមមាន៖ - ការស្នើរសុំឥណទាន និងការត្រួតពិនិត្យឥណទាន - ការកំណត់អត្តសញ្ញាណនៃការកើនឡើងនូវហានិភ័យឥណទានសំខាន់ៗ - ការត្រួតពិនិត្យប្រចាំឆ្នាំជាបន្តរបន្ទាប់នៃលទ្ធភាពនៃការទទួលបានឥណទានរបស់អ្នកខ្ចីនិង - ភាពត្រឹមត្រូវនៃការបញ្ចូលទិន្នន័យ • យើងខ្ញុំបានធ្វើការវាយតម្លៃថាតើវិធីសាស្ត្រ និងការសន្មតដែលបានប្រើប្រាស់នៅក្នុងម៉ូដែល ECL គឺសមស្របជាមួយនឹងតម្រូវការរបស់ ស.រ.ហ.អ.ក ៩ រួមបញ្ចូលទាំងផលប៉ះពាល់នៃជម្ងឺកូវីត-១៩។ • យើងខ្ញុំបានធ្វើការពិនិត្យទៅលើម៉ូដែលលើការត្រួតពិនិត្យទៅលើភាពសមស្របនៃការផ្តល់ចំណាត់ថ្នាក់ និងដំណាក់កាលឥណទានត្រូវបានការវាយតម្លៃ និងការសន្និដ្ឋានរបស់អ្នកគ្រប់គ្រងទៅលើលទ្ធភាពនៃការទទួលបានឥណទាន និងការធ្វើចំណាត់ថ្នាក់ទៅលើឥណទានដែលបានជ្រើសរើស។

គណនេយ្យការជំនាញ និងសវនការប្រតិស្រុត
សមាជិកភាពហ្គ្រេន សនថុន អន្តរជាតិ។ ហ្គ្រេន សនថុន អន្តរជាតិ និងសមាជិក គឺមិនមែនជាដៃគូរពាណិជ្ជកម្មទូទាំងសកលលោកទេ។ រាល់សេវាកម្មនានាត្រូវបានផ្តល់យ៉ាងឯកជ្ញជ្ញដោយសមាជិកនីមួយៗ។

Grant Thornton

បញ្ហាសំខាន់ៗក្នុងការធ្វើសវនកម្ម	វិធីដែលបញ្ហានេះត្រូវបានដោះស្រាយក្នុងការធ្វើសវនកម្មរបស់យើងខ្ញុំ
កូវីត-១៩ ដែលនាំមកនូវភាពមិនច្បាស់លាស់ខ្ពស់នៃការប៉ាន់ស្មាន ។ ការវិនិច្ឆ័យសំខាន់ៗនៅក្នុងការអនុវត្តគណនេយ្យដែលតម្រូវនៅក្នុងការវាស់វែង ECL រួមមានដូចខាងក្រោម៖ • បង្កើតម៉ូដែលដែលសមស្របនៃការវាយតម្លៃដែលបានប្រើប្រាស់ក្នុងការគណនា ECL។ ម៉ូដែលទាំងនេះ គឺមានភាពស្មុគស្មាញ ហើយការវិនិច្ឆ័យគឺត្រូវបានអនុវត្តក្នុងការកំណត់លើការបង្កើតឡើងនូវម៉ូដែលដែលសមស្រប • ការកំណត់អត្តសញ្ញាណនៃឥណទានផ្តល់ដល់អតិថិជនឱ្យទាន់ពេលវេលា និងហិរញ្ញប្បទានដែលមានការកើនឡើងគួរឱ្យកត់សម្គាល់នៅក្នុងហានិភ័យឥណទាន • ការសន្មតដែលបានប្រើប្រាស់នៅក្នុងម៉ូដែល ECL មានដូចជាលំហូរសាច់ប្រាក់នាថ្ងៃអនាគតដែលបានរំពឹងទុក កត្តាម៉ាក្រូសេដ្ឋកិច្ចថ្ងៃអនាគត ទិន្នន័យកំណត់ និង • ផលប៉ះពាល់នៃជម្ងឺរាតត្បាត កូវីត-១៩ ដែលពាក់ព័ន្ធទៅនឹងការវិនិច្ឆ័យសំខាន់ដូចដែលបានរៀបរាប់ខាងលើ។	• យើងខ្ញុំបានវាយតម្លៃទៅលើដំណើរការដែលបានប្រើប្រាស់ដោយអ្នកគ្រប់គ្រងដើម្បីអភិវឌ្ឍន៍ព័ត៌មាននាពេលអនាគត។ ចំពោះគំរូអថេរភាពនៃព័ត៌មាននាពេលអនាគតសំខាន់ៗ យើងខ្ញុំបានធ្វើការប្រៀបធៀបទៅនឹងការព្យាករណ៍ដែលទទួលបានឯករាជ្យ និងព័ត៌មានដែលមានជាសាធារណៈ។ • យើងខ្ញុំបានធ្វើការពិនិត្យទៅលើភាពត្រឹមត្រូវនៃការបញ្ចូលម៉ូដែល ECL សំខាន់ៗ តាមរយៈការ ប្រៀបធៀបជាមួយប្រព័ន្ធនៃប្រភពឯកសារ និង ឯកសារ៖ • យើងខ្ញុំបានគណនាឡើងវិញនូវ ECL ដើម្បីសាកល្បងលើភាព ត្រឹមត្រូវនៃការគណនានៃគំរូ ECL។ • យើងខ្ញុំបានធ្វើការវាយតម្លៃលើភាពគ្រប់គ្រាន់នៃការបកស្រាយដើម្បីធានាបាននូវការអនុលោមលើ ស.រ.ហ.អ.ក ៩។ យើងខ្ញុំក៏បានចូលរួមជាមួយអ្នកឯកទេសរបស់យើងក្នុងការអនុវត្តទៅលើនីតិវិធីខាងលើនៅពេលដែលចាំបាច់ ដែលត្រូវការជំនាញជាក់លាក់ ។

បញ្ហាផ្សេងៗ

របាយការណ៍ហិរញ្ញវត្ថុ របស់ធនាគារ សម្រាប់ ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ ត្រូវបានធ្វើសវនកម្មដោយសវនករផ្សេងទៀត ដែលបានផ្តល់នូវមតិយោបល់របស់ខ្លួនលើរបាយការណ៍ហិរញ្ញវត្ថុ នាថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២១ ដោយបញ្ជាក់ថារបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ ត្រូវបានរៀបចំឡើងដោយបង្ហាញនូវទិដ្ឋភាពពិត និងត្រឹមត្រូវ។

ព័ត៌មានផ្សេងៗ

អ្នកគ្រប់គ្រងមានភារៈកិច្ចទទួលខុសត្រូវលើព័ត៌មានផ្សេងៗ។ ព័ត៌មានផ្សេងៗដែលបានទទួលត្រឹមកាលបរិច្ឆេទនៃរបាយការណ៍សវនកម្មនេះ ជាព័ត៌មាននៅក្នុងរបាយការណ៍របស់ក្រុមប្រឹក្សាភិបាលដែលបានបង្ហាញនៅទំព័រទី ១ ដល់ទី ៨ ដែលយើងខ្ញុំទទួលបានមុនកាលបរិច្ឆេទនៃរបាយការណ៍សវនករនេះ ព្រមជាមួយរបាយការណ៍ប្រចាំឆ្នាំ ដែលត្រូវបានរំពឹងទុកថាបានរៀបចំរួចរាល់សម្រាប់ប្រើប្រាស់បន្ទាប់ពីកាលបរិច្ឆេទនោះ។ ប៉ុន្តែមិនរួមបញ្ចូលរបាយការណ៍ហិរញ្ញវត្ថុ និងនៅក្នុងរបាយការណ៍សវនកម្មរបស់យើងខ្ញុំ ។

គណនេយ្យការជំនាញ និងសវនការប្រតិស្រុត

សមាជិកភាពហ្គ្រេន សនថុន អន្តរជាតិ។ ហ្គ្រេន សនថុន អន្តរជាតិ និងសមាជិក គឺមិនមែនជាដៃគូរពាណិជ្ជកម្មទូទាំងសកលលោកទេ។ រាល់សេវាកម្មនានាត្រូវបានផ្តល់យ៉ាងឯករាជ្យដោយសមាជិកនីមួយៗ។

មតិរបស់យើងខ្ញុំ ទៅលើរបាយការណ៍ហិរញ្ញវត្ថុ មិនបានគ្របដណ្ដប់លើព័ត៌មានផ្សេងៗឡើយ ហើយយើងខ្ញុំមិនធ្វើការផ្ដល់នូវអំណះអំណាងណាមួយទៅលើព័ត៌មាននេះទេ។

ការទទួលខុសត្រូវរបស់យើងខ្ញុំ ពាក់ព័ន្ធនឹងការធ្វើសវនកម្មរបស់យើងខ្ញុំលើរបាយការណ៍ហិរញ្ញវត្ថុ គឺត្រូវអានព័ត៌មានផ្សេងៗ ហើយពិចារណាថាតើព័ត៌មានផ្សេងៗនោះមានភាពមិនស្របគ្នាជាសារវន្តជាមួយរបាយ-ការណ៍ហិរញ្ញវត្ថុឬការយល់ដឹងរបស់យើងខ្ញុំដែលទទួលបាននៅក្នុងការធ្វើសវនកម្មឬមានបង្ហាញនូវកំហុសឆ្គងជាសារវន្ត។

ប្រសិនបើការអានព័ត៌មានផ្សេងៗ ដែលបានទទួលមុនកាលបរិច្ឆេទនៃរបាយការណ៍សវនកម្មនេះ អាចឱ្យយើងខ្ញុំសន្និដ្ឋានថា មានកំហុសឆ្គងជាសារវន្តកើតឡើងលើព័ត៌មានផ្សេងៗនេះ យើងខ្ញុំត្រូវរាយការណ៍ទៅតាមស្ថានភាពជាក់ស្តែង។ យើងខ្ញុំពុំមានអ្វីដែលត្រូវរាយការណ៍ពាក់ព័ន្ធនឹងព័ត៌មានផ្សេងៗនេះទេ។

នៅពេលដែលយើងខ្ញុំអានរបាយការណ៍ប្រចាំឆ្នាំ ប្រសិនបើយើងខ្ញុំសន្និដ្ឋានថា មានការរាយការណ៍ខុសជាសារវន្ត យើងខ្ញុំតម្រូវអោយរាយការណ៍បញ្ហាទាំងនោះជូនក្រុមប្រឹក្សាភិបាល ព្រមជាមួយអភិបាលដែលពាក់ព័ន្ធ និងឆ្លើយតបបញ្ហាផ្សេងៗ ដោយអនុលោមតាមតម្រូវការ CISA ៧២០ (បានកែប្រែ)។

ការទទួលខុសត្រូវលើរបាយការណ៍ហិរញ្ញវត្ថុរបស់អ្នកគ្រប់គ្រង និងអ្នកទទួលខុសត្រូវលើអភិបាលកិច្ច

អ្នកគ្រប់គ្រងមានភារៈទទួលខុសត្រូវលើការរៀបចំ និងការបង្ហាញនូវភាពត្រឹមត្រូវនៃរបាយការណ៍ហិរញ្ញវត្ថុ ដោយអនុលោមទៅតាមស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា និងទទួលខុសត្រូវលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដែលអ្នកគ្រប់គ្រងកំណត់ថាមានភាពចាំបាច់ សម្រាប់ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុឱ្យជៀសផុតពីការបង្ហាញខុសជាសារវន្ត ដោយសារតែការក្លែងបន្លំ ឬកំហុសឆ្គង។

នៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ អ្នកគ្រប់គ្រងមានភារៈទទួលខុសត្រូវលើការវាយតម្លៃនូវ លទ្ធភាពរបស់សម្ព័ន្ធធនាគារ និងធនាគារ ក្នុងការបន្ត និរន្តរភាពអាជីវកម្ម ការលាតត្រដាងព័ត៌មាន ប្រសិនបើពាក់ព័ន្ធនូវបញ្ហាទាំងឡាយដែលទាក់ទងទៅនឹងនិរន្តរភាពអាជីវកម្ម និងប្រើប្រាស់មូលដ្ឋាននិរន្តរភាពនៃគណនេយ្យ លើកលែងតែអ្នកគ្រប់គ្រងមានបំណងចង់ជម្រះបញ្ជី ផ្អាកដំណើរការសម្ព័ន្ធធនាគារ និងធនាគារ ឬគ្មានជម្រើសសមរម្យដទៃទៀតក្រៅពីធ្វើបែបនេះ។

អ្នកទទួលខុសត្រូវលើអភិបាលកិច្ច មានភារៈទទួលខុសត្រូវក្នុងការត្រួតពិនិត្យដំណើរការនៃការរាយការណ៍ហិរញ្ញវត្ថុរបស់សម្ព័ន្ធធនាគារ និងធនាគារ។

គណនេយ្យការជំនាញ និងសវនការប្រតិស្រុត
សមាជិកភាពហ្គ្រេន សនថុន អន្តរជាតិ។ ហ្គ្រេន សនថុន អន្តរជាតិ និងសមាជិក គឺមិនមែនជាដៃគូរពាណិជ្ជកម្មទូទាំងសកលលោកទេ។ រាល់សេវាកម្មនានាត្រូវបានផ្ដល់យ៉ាងឯកជ្ញជ្ញដោយសមាជិកនីមួយៗ។

Grant Thornton

ការទទួលខុសត្រូវរបស់សវនករ សម្រាប់ការធ្វើសវនកម្មរបាយការណ៍ហិរញ្ញវត្ថុ

គោលដៅរបស់យើងខ្ញុំ គឺទទួលបាននូវអំណះអំណាងសមហេតុផលថារបាយការណ៍ហិរញ្ញវត្ថុទាំងមូលមិនមានការបង្ហាញខុសជាសារវន្តដោយសារតែការក្លែងបន្លំ ឬកំហុសឆ្គង និងផ្តល់នូវរបាយការណ៍របស់សវនករដែលរួមបញ្ចូលមតិរបស់យើងខ្ញុំ។ អំណះអំណាងសមហេតុផល គឺជាអំណះអំណាងមានកម្រិតខ្ពស់មួយ ប៉ុន្តែវាមិនអាចធានាថា គ្រប់ពេលនៃការធ្វើសវនកម្មដោយអនុលោមទៅតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា អាចរកឃើញនូវការបង្ហាញខុសជាសារវន្តដែលបានកើតឡើងនោះទេ។ ការបង្ហាញខុសជាសារវន្តអាចកើតឡើងដោយសារការក្លែងបន្លំ ឬកំហុសឆ្គង ហើយត្រូវបានចាត់ទុកថាជាសារវន្ត នៅពេលដែលការក្លែងបន្លំ ឬកំហុសឆ្គងតែមួយ ឬក៏រួមបញ្ចូលគ្នា មានផលប៉ះពាល់ដល់ការសម្រេចចិត្តផ្នែកសេដ្ឋកិច្ចរបស់អ្នកប្រើប្រាស់ ដោយយោងលើរបាយការណ៍ហិរញ្ញវត្ថុនេះ។

ជាផ្នែកមួយនៃការធ្វើសវនកម្ម ដោយអនុលោមតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា យើងខ្ញុំអនុវត្តនូវការវិនិច្ឆ័យដែលប្រកបទៅដោយវិជ្ជាជីវៈ និងរក្សានូវមជ្ឈធាតុនិយម ក្នុងអំឡុងពេលសវនកម្ម។ យើងខ្ញុំក៏បាន៖

- ធ្វើការកំណត់ និងវាយតម្លៃនូវហានិភ័យនៃការបង្ហាញខុសជាសារវន្តលើរបាយការណ៍ហិរញ្ញវត្ថុ ដោយសារតែការក្លែងបន្លំ ឬកំហុសឆ្គង និងទទួលខុសត្រូវលើការរៀបចំ និងការអនុវត្តនូវនីតិវិធីសវនកម្ម ដើម្បីឆ្លើយតបទៅនឹងហានិភ័យទាំងនោះ និងប្រមូលនូវភស្តុតាងដែលមានលក្ខណៈគ្រប់គ្រាន់ និងសម-ស្របជាមូលដ្ឋានសម្រាប់មតិរបស់យើងខ្ញុំ។ ហានិភ័យដែលមិនអាចរកឃើញនូវការបង្ហាញខុសជាសារវន្ត ដែលកើតឡើងដោយសារតែការក្លែងបន្លំមានលក្ខណៈខ្ពស់ជាងការបង្ហាញខុសកើតឡើងពីកំហុសឆ្គង ដោយសារតែការក្លែងបន្លំ អាចរួមបញ្ចូលទាំងការសមគំនិតគ្នា ការលួចបន្លំ ការលុបចោលដោយចេតនាការបកស្រាយមិនពិត ឬមិនអនុវត្តតាមនីតិវិធីគ្រប់គ្រងផ្ទៃក្នុង។
- ទទួលបាននូវការយល់ដឹងអំពីការគ្រប់គ្រងផ្ទៃក្នុង ដែលពាក់ព័ន្ធនឹងការធ្វើសវនកម្ម ក្នុងគោលបំណងដើម្បីរៀបចំនូវនីតិវិធីសវនកម្មដែលសមស្របទៅតាមកាលៈទេសៈ ប៉ុន្តែមិនមែនក្នុងគោលបំណងដើម្បីបញ្ចេញមតិលើប្រសិទ្ធភាពនៃការគ្រប់គ្រងផ្ទៃក្នុងរបស់សម្ព័ន្ធធនាគារ និងធនាគារឡើយ។
- ការវាយតម្លៃលើភាពសមស្របនៃគោលនយោបាយគណនេយ្យដែលបានប្រើប្រាស់ និងភាពសមហេតុផលនៃការប៉ាន់ស្មានគណនេយ្យសំខាន់ៗ ព្រមទាំងការលាតត្រដាងព័ត៌មានពាក់ព័ន្ធដែលបានធ្វើឡើងដោយអ្នកគ្រប់គ្រង។
- ធ្វើការសន្និដ្ឋានលើភាពសមស្របនៃ ការប្រើប្រាស់មូលដ្ឋាននិរន្តរភាពនៃគណនេយ្យរបស់អ្នកគ្រប់គ្រង និងដោយផ្អែកទៅលើភស្តុតាងសវនកម្មដែលទទួលបាន ធ្វើការសន្និដ្ឋានថាតើភាពមិនច្បាស់លាស់សារវន្តពាក់ព័ន្ធទៅនឹងព្រឹត្តិការណ៍ ឬលក្ខខណ្ឌដែលអាចធ្វើឱ្យមានមន្ទិលជាសារវន្តលើលទ្ធភាពរបស់សម្ព័ន្ធធនាគារនិងធនាគារដើម្បីបន្តនិរន្តរភាពអាជីវកម្ម។ ប្រសិនបើយើងខ្ញុំធ្វើការសន្និដ្ឋានថាមានភាពមិនប្រាកដប្រជាជាសារវន្តបានកើតឡើង យើងខ្ញុំចាំបាច់ត្រូវបញ្ចូលនៅក្នុងរបាយការណ៍សវនកម្មរបស់យើងខ្ញុំ ដើម្បីទាញចំណាប់អារម្មណ៍លើការលាតត្រដាងព័ត៌មានពាក់ព័ន្ធនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ឬប្រសិនបើការលាតត្រដាងព័ត៌មានមានលក្ខណៈមិនគ្រប់គ្រាន់ យើងខ្ញុំចាំបាច់ត្រូវធ្វើការកែប្រែមតិរបស់យើងខ្ញុំ។ ការសន្និដ្ឋានរបស់យើងខ្ញុំគឺផ្អែកតាមភស្តុតាងសវនកម្មដែលប្រមូលបានត្រឹមកាលបរិច្ឆេទនៃរបាយការណ៍សវនកម្មរបស់យើងខ្ញុំ។ ទោះជាយ៉ាងណាក៏ដោយ ព្រឹត្តិការណ៍ ឬលក្ខខណ្ឌនាពេលអនាគតអាចធ្វើឱ្យសម្ព័ន្ធធនាគារ និងធនាគារបញ្ឈប់និរន្តរ

គណនេយ្យការជំនាញ និងសវនការប្រតិស្រុត

សមាជិកភាពហ្គ្រេន សនថុន អន្តរជាតិ។ ហ្គ្រេន សនថុន អន្តរជាតិ និងសមាជិក គឺមិនមែនជាដៃគូរពាណិជ្ជកម្មទូទាំងសកលលោកទេ។ រាល់សេវាកម្មនានាត្រូវបានផ្តល់យ៉ាងឯកជ្ញជ្ញដោយសមាជិកនីមួយៗ។

ភាពនៃអាជីវកម្មបាន។

- វាយតម្លៃលើការបង្ហាញ ទម្រង់ និងខ្លឹមសារនៃរបាយការណ៍ហិរញ្ញវត្ថុទាំងមូល ដែលរួមបញ្ចូល ទាំងការលាតត្រដាងព័ត៌មាន និងវាយតម្លៃថាតើរបាយការណ៍ហិរញ្ញវត្ថុបានបង្ហាញពីប្រតិបត្តិការ និងព្រឹត្តិការណ៍ ពាក់ព័ន្ធក្នុងអត្ថន័យដែលអាចសម្រេចបាននូវការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុដ៏ត្រឹមត្រូវ។
- ទទួលបាននូវភស្តុតាងសវនកម្មដែលសមស្រប និងគ្រប់គ្រាន់ ពាក់ព័ន្ធនឹងព័ត៌មានហិរញ្ញវត្ថុរបស់បណ្ដាបុត្រសម្ព័ន្ធ នៅក្នុងសម្ព័ន្ធធនាគារ ដើម្បីបញ្ចេញមតិលើរបាយការណ៍ហិរញ្ញវត្ថុរួម។ យើងខ្ញុំទទួលខុសត្រូវក្នុងការដឹកនាំ ការត្រួតត្រាមើល និងការប្រតិបត្តិនៃសវនកម្មរបស់សម្ព័ន្ធធនាគារ។ យើងខ្ញុំរក្សាការទទួលខុសត្រូវលើមតិសវនកម្មរបស់យើងខ្ញុំ។

យើងខ្ញុំផ្ដល់ព័ត៌មានជូនអ្នកទទួលខុសត្រូវលើអភិបាលកិច្ច រួមបញ្ចូលទាំងបញ្ហាផ្សេងទៀត ដូចជាវិសាលភាព និងពេលវេលាដែលបានគ្រោងទុកសម្រាប់ការធ្វើសវនកម្ម និងការរកឃើញបញ្ហាជាសារវន្តផ្សេងទៀតដែលមានចំណុចខ្វះខាតនៃការគ្រប់គ្រងផ្ទៃក្នុងដែលបានរកឃើញក្នុងអំឡុងពេលធ្វើសវនកម្ម។

យើងខ្ញុំក៏បានផ្ដល់សេចក្ដីបញ្ជាក់ជូនអ្នកទទួលខុសត្រូវលើអភិបាលកិច្ចថា យើងខ្ញុំបានអនុលោមតាមលក្ខខណ្ឌតម្រូវនៃក្រមសីលធម៌វិជ្ជាជីវៈដែលពាក់ព័ន្ធលើឯករាជ្យភាពរបស់យើងខ្ញុំ និងបានជម្រាបជូនពួកគាត់នូវរាល់ទំនាក់ទំនង និងបញ្ហាផ្សេងៗទៀតដែលអាចត្រូវបានយកមកពិចារណាយ៉ាងសមហេតុផល ថាអាចមានទំនាក់ទំនងទៅនឹងការការពារឯករាជ្យភាពរបស់យើងខ្ញុំ។

បញ្ហាដែលយើងខ្ញុំបានជម្រាបជូនអ្នកទទួលខុសត្រូវលើអភិបាលកិច្ច គឺជាបញ្ហាដែលយើងខ្ញុំកំណត់ថាមានសារៈសំខាន់បំផុត នៅក្នុងការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ហើយបញ្ហានេះគឺជាបញ្ហាសំខាន់ក្នុងការធ្វើសវនកម្ម។ យើងខ្ញុំបង្ហាញបញ្ហានេះ នៅក្នុងរបាយការណ៍សវនកម្មលើកលែងតែច្បាប់ ឬបទប្បញ្ញត្តិ រារាំងនូវការលាតត្រដាងជាសាធារណៈអំពីបញ្ហានេះក្នុងការធ្វើសវនកម្ម ឬក៏ក្នុងកាលៈទេសៈដ៏កម្របំផុត នៅពេលដែលយើងខ្ញុំរកឃើញថាបញ្ហានោះ មិនគួរត្រូវបានបង្ហាញក្នុងរបាយការណ៍របស់យើងខ្ញុំ ដោយសារតែផលអវិជ្ជមាន អាចមានច្រើនជាងអត្ថប្រយោជន៍ជាសាធារណៈ ដែលកើតចេញពីការជូនដំណឹងនេះ ។

គណនេយ្យការជំនាញ និងសវនការប្រតិស្រុត
សមាជិកភាពហ្គ្រេន សនថុន អន្តរជាតិ។ ហ្គ្រេន សនថុន អន្តរជាតិ និងសមាជិក គឺមិនមែនជាដៃគូរពាណិជ្ជកម្មទូទាំងសកលលោកទេ។ រាល់សេវាកម្មនានាត្រូវបានផ្ដល់យ៉ាងឯកជ្ញដោយសមាជិកនីមួយៗ។

Grant Thornton

នាយកសវនករជំនាញដែលចូលរួមក្នុងលទ្ធផលសវនកម្មនៅក្នុងរបាយការណ៍សវនករឯករាជ្យនេះគឺ

លោក Ronald C. Almera ។

Grant Thornton

ហ្ស្គ្រេន សនថុន (ខេមបូឌា) លីមីធីត

គណនេយ្យករជំនាញ

សវនករប្រតិស្រុតចុះបញ្ជី

Ronald C. Almera

នាយកសវនករជំនាញ

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០២២

គណនេយ្យករជំនាញ និងសវនការប្រតិស្រុត

សមាជិកភាពហ្ស្គ្រេន សនថុន អន្តរជាតិ។ ហ្ស្គ្រេន សនថុន អន្តរជាតិ និងសមាជិក គឺមិនមែនជាដៃគូរពាណិជ្ជកម្មទូទាំងសកលលោកទេ។ រាល់សេវាកម្មនានាត្រូវបានផ្តល់យ៉ាងឯករាជ្យដោយសមាជិកនីមួយៗ។

ធនាគារ អេស៊ីលីដា អ៊ីអិលស៊ី និង ក្រុមហ៊ុនបុត្រសម្ព័ន្ធ

របាយការណ៍ស្ថានភាពហិរញ្ញវត្ថុរួម
នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ និងសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់

	កំណត់សម្គាល់	២០២១ ដុល្លារអាមេរិក	២០២០ ដុល្លារអាមេរិក	២០២១ ពាន់រៀល (កំណត់សម្គាល់ ៥)	២០២០ ពាន់រៀល (កំណត់សម្គាល់ ៥)
ទ្រព្យសកម្ម					
សាច់ប្រាក់ក្នុងដៃ	៧	៤៥០.៣៧៥.១៤៩	៤១២.៧៥៩.០៥១	១.៨៣៤.៨២៨.៣៥៧	១.៦៦៩.៦១០.៣៦១
ប្រាក់បញ្ញើនៅធនាគារផ្សេងៗ-សុទ្ធ	៨	៥៧៧.១១៧.២៩៨	៥៣៤.៦៥៣.១៤៦	២.៣៥១.១៧៥.៨៧២	២.១៦២.៦៧១.៩៧៦
ការវិនិយោគហិរញ្ញវត្ថុ	៩	៨០១.០៨៤.៣៩២	៥៦៦.៦៧៤.៥២៣	៣.២៦៣.៦១៧.៨១៣	២.២៩២.១៩៨.៤៤៦
ឥណទាននិងបុរេប្រទាន-សុទ្ធ	១០	៥.៣៩៣.៩៥៣.៥០៣	៤.៤៧១.៣០០.៦១៨	២១.៩៧៤.៩៦៦.៥៧១	១៨.០៨៦.៤១១.០០០
ទ្រព្យសកម្មផ្សេងៗ	១១	២៨.១៤១.១៩០	២២.៧៦៦.៩១៣	១១៤.៦៤៧.២០៨	៩២.០៩២.១៦៣
ប្រាក់បញ្ញើតាមច្បាប់	១២	៤១៥.៤៥៦.៩៦០	៣៦០.៣៧៧.០០៨	១.៦៩២.៥៧១.៦៥៥	១.៤៥៧.៧២៤.៩៩៧
ទ្រព្យ និងបរិក្ខារ-សុទ្ធ	១៤	១៣៩.៤៣១.២៤៤	១២៧.៥៤៦.៤៤១	៥៦៨.០៤២.៨៨៨	៥១៥.៩២៥.៣៥៤
ទ្រព្យសកម្មអរូបី-សុទ្ធ	១៥	១២.២៨៦.០៩៨	១៤.៦៩០.៦៧៥	៥០.០៥៣.៥៦៣	៥៩.៤២៣.៧៨០
សិទ្ធិប្រើប្រាស់ទ្រព្យសកម្ម-សុទ្ធ	១៦	២៨.៣៣៧.៨៨៤	២៩.៥២៩.៧៦៨	១១៥.៤៤៨.៥៣៩	១១៩.៤៤៧.៩១២
ទ្រព្យសកម្មពន្ធពន្យារ-សុទ្ធ	១៧	៩.០៦៨.៦០៦	១១.១៩៥.៨៤៥	៣៦.៩៤៥.៥០១	៤៥.២៨៧.១៩៣
ទ្រព្យសកម្មសរុប		៧.៨៥៥.២៥២.៣២៤	៦.៥៥១.៤៩៣.៩៨៨	៣២.០០២.២៩៧.៩៦៧	២៦.៥០០.៧៩៣.១៨២
បំណុលនិងមូលធន					
បំណុល					
ប្រាក់បញ្ញើរបស់ធនាគារនិងស្ថាប័នហិរញ្ញវត្ថុផ្សេងៗ	១៨	៤៨៣.៧៤០.៩៩២	៣១៧.០០៩.៤៥៩	១.៩៧០.៧៦០.៨០១	១.២៨២.៣០៣.២៦២
ប្រាក់បញ្ញើរបស់អតិថិជន	១៩	៥.២៣២.២៧៨.៦៩៣	៤.២៩៤.២៨៦.០៤៨	២១.៣១៦.៣០៣.៣៩៥	១៧.៣៧០.៣៨៧.០៦៤
បំណុលផ្សេងៗ	២០	៧៨.៤២២.១៧១	៦៣.៧៥១.១០៨	៣១៩.៤៩១.៩២៥	២៥៧.៨៧៣.២៣២
ប្រាក់កម្ចី	២១	៦០៨.៤៨៨.៨០៣	៥៤២.៣៩៨.៩១៦	២.៤៧៨.៩៨៣.៣៨៣	២.១៩៤.០០៣.៦១៥
បំណុលបន្ទាប់បន្សំ	២២	១៥៦.៤៩២.៩៤១	១៦៧.១៥៨.៦២៣	៦៣៧.៥៥២.២៤២	៦៧៦.១៥៦.៦៣០
បំណុលឧបករណ៍និស្សន្ទស៍-សុទ្ធ	២៣	៥០៦.១៥៨	-	២.០៦២.០៨៨	-
បំណុលភាគិសន្យា	២៤	២៧.៨៧៤.៩៤០	២៨.៦១៧.៩០២	១១៣.៥៦២.៥០៦	១១៥.៧៥៩.៤១៤
អត្ថប្រយោជន៍និយោជិត	២៥	២៦.០៩៦.៨១៧	១៨.៣៥៤.០៥៥	១០៦.៣១៨.៤៣២	៧៤.២៤២.១៥២
បំណុលពន្ធលើប្រាក់ចំណេញក្នុងការិយបរិច្ឆេទ	៣២(ក)	៣៦.៣១៥.៧៦៧	៣០.២៩២.៣៧០	១៤៧.៩៥០.៤៣៥	១២២.៥៣២.៦៣៧
បំណុលសរុប		៦.៦៥០.២១៧.២៨២	៥.៤៦១.៨៦៨.៤៨១	២៧.០៩២.៩៨៥.២០៧	២២.០៩៣.២៥៨.០០៦
មូលធន					
ដើមទុន	២៦	៤៣៣.១៦៣.០១៩	៤៣៣.១៦៣.០១៩	១.៧៦៤.៧០៦.១៣៩	១.៧៥២.១៤៤.៤១២
បុព្វលាភភាគហ៊ុន	២៦	១១.៧០៦.២១៥	១១.៧០៦.២១៥	៤៧.៦៩១.១២០	៤៧.៣៥១.៦៤០
ទុនបម្រុង	៣៦	៥៩២.៩០៩.៧៤៤	៥០៣.០៩៤.២៣៦	២.៤៣៣.៤៣២.៩១៥	២.០៤៨.៧០៨.៩៩៧
ប្រាក់ចំណេញកន្សាទុក		១៦១.២៦៣.៣០៧	១៤១.៦៦២.០៣៧	៦៣៩.០៦៨.០៩៤	៥៥៩.៣៣០.១២៧
ភាគកម្មមិនមានអភិបាលភាព	៣	៥.៩៩២.៧៥៧	-	២៤.៤១៤.៤៩២	-
មូលធនសរុប		១.២០៥.០៣៥.០៤២	១.០៨៩.៦២៥.៥០៧	៤.៩០៩.៣១២.៧៦០	៤.៤០៧.៥៣៥.១៧៦
បំណុលនិងមូលធនសរុប		៧.៨៥៥.២៥២.៣២៤	៦.៥៥១.៤៩៣.៩៨៨	៣២.០០២.២៩៧.៩៦៧	២៦.៥០០.៧៩៣.១៨២

កំណត់សម្គាល់ដូចមានភ្ជាប់ជាមួយ នៅទំព័រទី២៩ ដល់ទី២៤៥ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។

ធនាគារ អេស៊ីលីដា អ៊ីអិលស៊ី និង ក្រុមហ៊ុនបុត្រសម្ព័ន្ធ

របាយការណ៍ចំណេញ ឬខាត និងលទ្ធផល លម្អិតផ្សេងៗរួម
នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ និងសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់

	កំណត់សម្គាល់	២០២១ ដុល្លារអាមេរិក	២០២០ ដុល្លារអាមេរិក	២០២១ ពាន់រៀល (កំណត់សម្គាល់ ៥)	២០២០ ពាន់រៀល (កំណត់សម្គាល់ ៥)
ចំណូលការប្រាក់	២៧	៥៧៣.៧៩៩.៧៥៣	៥១៥.០៩៤.៤៧៦	២.៣៣៤.២១៧.៣៩៥	២.១០០.០៤០.១៧៩
ចំណាយការប្រាក់	២៨	(១៧២.៣៧០.៨១២)	(១៥០.៧៧៧.៣១៧)	(៧០១.២០៤.៤៦៣)	(៦១៤.៧១៩.១២១)
ចំណូលការប្រាក់សុទ្ធ		៤០១.៤២៨.៩៤១	៣៦៤.៣១៧.១៥៩	១.៦៣៣.០១២.៩៣២	១.៤៨៥.៣២១.០៥៨
ចំណូលកម្រៃនិងជើងសា	២៩	៤២.៩៣៦.៣៦១	៤៥.៧៧៥.១៦៥	១៧៤.៦៦៥.១១៧	១៨៦.៦២៥.៣៤៨
ចំណាយកម្រៃនិងជើងសា		(២.៦៦៦.០០៦)	(១.៧៤២.១២៥)	(១០.៨៤៥.៣១២)	(៧.១០២.៦៤៤)
ចំណូលកម្រៃនិងជើងសាសុទ្ធ		៤០.២៧០.៣៥៥	៤៤.០៣៣.០៤០	១៦៣.៨១៩.៨០៥	១៧៩.៥២២.៧០៤
ការខាតបង់ឱនភាពនៃតម្លៃរបស់ឥណទាន និងបុរេប្រទាន ប្រាក់បញ្ញើនៅធនាគារផ្សេងៗ និងគណនីត្រូវទទួលផ្សេងៗ	១០	(១៣.៥៤១.៩៧៤)	(២០.៧៩៤.០៣១)	(៥៥.០៨៨.៧៥០)	(៨៤.៧៧៧.២៦៤)
ការកត់ត្រាត្រលប់នៃការខាតបង់ឱនភាពនៃតម្លៃកិច្ចសន្យាក្រៅតារាងតុល្យការ	១០	១៣៩.៤៤៩	៥៤.១៥៦	៥៦៧.២៧៩	២២០.៧៩៤
ចំណាយសុទ្ធពីការខាតបង់ឱនភាពនៃតម្លៃ		(១៣.៤០២.៥២៥)	(២០.៧៣៩.៨៧៥)	(៥៤.៥២១.៤៧១)	(៨៤.៥៥៦.៤៧០)
ចំណូលបន្ទាប់ពីខាតបង់ឱនភាពនៃតម្លៃ		៤២៨.២៩៦.៧៧១	៣៨៧.៦១០.៣២៤	១.៧៤២.៣១១.២៦៦	១.៥៨០.២៨៧.២៩២
ចំណូលផ្សេងៗ	៣០	១៩.៩៦១.៦១៧	១៨.៣៥១.៣៥៨	៨១.២០៣.៨៥៨	៧៤.៨១៨.៤៨៧
ចំណាយទូទៅ និងរដ្ឋបាល	៣១	(២៤៣.៥០៤.៩៧១)	(២២៥.៩២៦.២២០)	(៩៩០.៥៧៨.២២២)	(៩២១.១០១.១៩៩)
ចំណេញមុនចំណាយពន្ធលើប្រាក់ចំណេញ		២០៤.៧៥៣.៤១៧	១៨០.០៣៥.៤៦២	៨៣២.៩៣៦.៩០២	៧៣៤.០០៤.៥៨០
ចំណាយពន្ធលើប្រាក់ចំណេញ	៣២(ខ)	(៣៨.០៧៩.០៦៩)	(៣៨.៥៤២.៨៧២)	(១៥៤.៩០៥.៦៥៣)	(១៥៧.១៣៩.២៩១)
ប្រាក់ចំណេញក្នុងការិយបរិច្ឆេទ(យោងទៅទំព័របន្ទាប់)		១៦៦.៦៧៤.៣៤៨	១៤១.៤៩២.៥៩០	៦៧៨.០៣១.២៤៩	៥៧៦.៨៦៥.២៨៩

ធនាគារ អេស៊ីលីដា អ៊ីអិលស៊ី និង ក្រុមហ៊ុនបុត្រសម្ព័ន្ធ

របាយការណ៍ចំណេញ ឬខាត និងលទ្ធផល លម្អិតផ្សេងៗរួម (ត)
នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ និងសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់

	កំណត់សម្គាល់	២០២១ ដុល្លារអាមេរិក	២០២០ ដុល្លារអាមេរិក	២០២១ ពាន់រៀល (កំណត់សម្គាល់ ៥)	២០២០ ពាន់រៀល (កំណត់សម្គាល់ ៥)
ប្រាក់ចំណេញក្នុងការិយបរិច្ឆេទ(យោងមកពីទំព័រមុន)		១៦៦.៦៧៤.៣៤៨	១៤១.៤៩២.៥៩០	៦៧៨.០៣១.២៤៩	៥៧៦.៨៦៥.២៨៩
លទ្ធផលលម្អិតផ្សេងៗ៖					
ធាតុដែលនឹងមិនត្រូវបានចាត់ថ្នាក់ឡើងវិញទៅចំណេញឬខាត៖					
ការវាស់វែងឡើងវិញនៃកាតព្វកិច្ចអត្ថប្រយោជន៍និយោជិត	២៥	(៤.១៤១.២១៥)	១៦៩.៤៤៧	(១៦.៨៤៦.៤៦២)	៦៩០.៨៣៥
ការវាស់វែងឡើងវិញលើផ្នែកដែលមានប្រសិទ្ធិភាពរបស់ឧបករណ៍និស្សន្ទស់ដែលកើតឡើងពីការការពារហានិភ័យលំហូរសាច់ប្រាក់		(៥០៦.១៥៨)	-	(២.០៥៩.០៥១)	-
ធាតុដែលត្រូវ ឬអាចត្រូវបានចាត់ថ្នាក់ឡើងវិញនៅគ្រាបន្ទាប់ទៅចំណេញឬខាត៖					
លម្អៀងពីការប្តូររូបិយប័ណ្ណ		-	-	៥.០៨០.៣៥៨	(៨.១៦០.០២៦)
លទ្ធផល(ខាត)ចំណេញលម្អិតផ្សេងៗក្នុងការិយបរិច្ឆេទ		(៤.៦៤៧.៣៧៣)	១៦៩.៤៤៧	(១៣.៨២៥.១៥៥)	(៧.៤៦៩.១៩១)
លទ្ធផលចំណេញលម្អិតផ្សេងៗក្នុងការិយបរិច្ឆេទសរុប		១៦២.០២៦.៩៧៥	១៤១.៦៦២.០៣៧	៦៦៤.២០៦.០៩៤	៥៦៩.៣៩៦.០៩៨
ប្រាក់ចំណេញក្នុងការិយបរិច្ឆេទដែលផ្តល់ជូនដល់៖					
ភាគហ៊ុនិករបស់ធនាគារ		១៦៦.៩១៣.០៣៨	១៤១.៤៩២.៥៩០	៦៧៩.០០២.២៤០	៥៧៦.៨៦៥.២៨៩
ភាគកម្មមិនមានអភិបាលភាព		(២៣៨.៦៩០)	-	(៩៧០.៩៩១)	-
		១៦៦.៦៧៤.៣៤៨	១៤១.៤៩២.៥៩០	៦៧៨.០៣១.២៤៩	៥៧៦.៨៦៥.២៨៩
លទ្ធផលចំណេញលម្អិតសរុបដែលផ្តល់ជូនដល់៖					
ភាគហ៊ុនិករបស់ធនាគារ		១៦២.២៨២.៧៧១	១៤១.៦៦២.០៣៧	៦៦៥.២៤៨.២០៧	៥៦៩.៣៩៦.០៩៨
ភាគកម្មមិនមានអភិបាលភាព		(២៥៥.៧៩៦)	-	(១.០៤២.១១៣)	-
		១៦២.០២៦.៩៧៥	១៤១.៦៦២.០៣៧	៦៦៤.២០៦.០៩៤	៥៦៩.៣៩៦.០៩៨
ចំណូលក្នុងមួយភាគហ៊ុនផ្តល់ជូនភាគហ៊ុនិករបស់ធនាគារក្នុងការិយបរិច្ឆេទត្រូវបានបង្ហាញដូចខាងក្រោម៖					
ចំណេញក្នុងមួយភាគហ៊ុនមូលដ្ឋាន	៣៣	០.៣៩	០.៣៣	១.៥៧	១.៣៤
ចំណេញក្នុងមួយភាគហ៊ុនថយចុះ	៣៣	០.៣៩	០.៣៣	១.៥៧	១.៣៤

កំណត់សម្គាល់ដូចមានភ្ជាប់ជាមួយ នៅទំព័រទី២៩ ដល់ទី២៤៥ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។

ធនាគារ អេស៊ីលីដា អ៊ីអិលស៊ី និង ក្រុមហ៊ុនបុត្រសម្ព័ន្ធ

របាយការណ៍ស្តីពីបម្រែបម្រួលមូលធនរួម
នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ និងសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់

ផ្ទល់ខ្លួនភាគហ៊ុនកម្មសិទ្ធិរបស់ក្រុមហ៊ុនម

	ដើមទុន		បុព្វលាភភាគហ៊ុន		ទុនបម្រុង		ចំណេញកកុ្សកុ		សរុប		ភាគហ្ម៊ីនមានអត្ថិភាពភាគ		មូលធនសរុប	
	ផ្ទាល់ខ្លួនធនិក	ពាក់ព្រៀប (កំណត់សម្គាល់ ៥)	ផ្ទាល់ខ្លួនធនិក	ពាក់ព្រៀប (កំណត់សម្គាល់ ៥)	ផ្ទាល់ខ្លួនធនិក	ពាក់ព្រៀប (កំណត់សម្គាល់ ៥)	ផ្ទាល់ខ្លួនធនិក	ពាក់ព្រៀប (កំណត់សម្គាល់ ៥)	ផ្ទាល់ខ្លួនធនិក	ពាក់ព្រៀប (កំណត់សម្គាល់ ៥)	ផ្ទាល់ខ្លួនធនិក	ពាក់ព្រៀប (កំណត់សម្គាល់ ៥)	ផ្ទាល់ខ្លួនធនិក	ពាក់ព្រៀប (កំណត់សម្គាល់ ៥)
នាថ្ងៃទី ១ខែមករាឆ្នាំ ២០២១	៨៣៣.១៦៣.០១៩	១.៧៥២.១៥៥.៩១២	១១.៧០៦.២១៥	៩៧.៣៥១.៦៩០	៥០៣.០៩៥.២៣៦	២.០៨៨.៧០៨.៩៩៧	១៩១.៦៦២.០៣៧	៥៥៩.៣៣០.១២៧	១.០៨៩.៦២៥.៥០៧	៤.៩០៧.៥៣៥.១៧៦	-	-	១.០៨៩.៦២៥.៥០៧	៤.៩០៧.៥៣៥.១៧៦
ប្រាក់ចំណេញក្នុងឆ្នាំ	-	-	-	-	-	-	១៦៦.៩១៣.០៣៨	៦៧៩.០០២.២៩០	១៦៦.៩១៣.០៣៨	៦៧៩.០០២.២៩០	(២៣៨.៦៩០)	(៩៧០.៩៩១)	១៦៦.៦៧៨.៣៩៨	៦៧៨.០៣១.២៩៩
លទ្ធផលចំណេញលម្អិតផ្សេងៗ៖														
ការកាត់ដំណើរទៅវិញនៃកាតព្វកិច្ចអត្ថ-ប្រយោជន៍និយោជិត	-	-	-	-	-	-	(៩.១២៩.១០៩)	(១៦.៧៧៦.៨៧៥)	(៩.១២៩.១០៩)	(១៦.៧៧៦.៨៧៥)	(១៧.១០៦)	(៦៩.៥៨៧)	(៩.១៩១.២១៥)	(១៦.៨៩៦.៤៦២)
ការកាត់ដំណើរវិញលើផ្នែកដែលមានសិទ្ធិការយល់ឃញណ៍និសន្ធស់ដែលកើតឡើងពីការការហានិភ័យលំហូរសាច់ប្រាក់	-	-	-	-	-	-	(៥០៦.១៥៨)	(២.០៥៩.០៥១)	(៥០៦.១៥៨)	(២.០៥៩.០៥១)	-	-	(៥០៦.១៥៨)	(២.០៥៩.០៥១)
លម្អៀងពីការប្តូររូបិយប័ណ្ណ	-	-	-	-	-	៥.០៨១.៨៩៣	-	-	-	៥.០៨១.៨៩៣	-	(១.៥៣៥)	-	៥.០៨០.៣៥៨
លទ្ធផលចំណេញសម្គាល់ការសរុបៗសរុបក្នុងឆ្នាំ	-	-	-	-	-	៥.០៨១.៨៩៣	១៦២.២៨២.៧៧១	៦៦០.១៦៦.៣១៨	១៦២.២៨២.៧៧១	៦៦៥.២៩៨.២០៧	(២៥៥.៧៩៦)	(១.០៩២.១១៣)	១៦២.០២៦.៩៧៥	៦៦៤.២០៦.០៩៩
ប្រតិបត្តិការជាមួយភាគហ៊ុនិក														
វិនិយោគធ្វើឡើងដោយម្ចាស់កាន់កាប់ភាគកម្មមិនមានអភិបាលភាព	-	-	-	-	-	-	-	-	-	-	៦.៩៧១.៦៨១	២៨.៣៦០.៧៩៨	៦.៩៧១.៦៨១	២៨.៣៦០.៧៩៨
ភាគលាភបានបង់	-	-	-	-	-	-	(៩២.៤៩៣.២៩៣)	(១៧២.៨៦២.៧១៦)	(៩២.៤៩៣.២៩៣)	(១៧២.៨៦២.៧១៦)	-	-	(៩២.៤៩៣.២៩៣)	(១៧២.៨៦២.៧១៦)
ការផ្ទេរពីប្រាក់ចំណេញក្សាទុកទៅជាទុនបម្រុងទូទៅ	-	-	-	-	-	-	(៩២៣.៨៦៣)	(១.៧២៩.២៧៥)	(៩២៣.៨៦៣)	(១.៧២៩.២៧៥)	-	-	(៩២៣.៨៦៣)	(១.៧២៩.២៧៥)
ការផ្ទេរពីប្រាក់ចំណេញក្សាទុកទៅជាទុនបម្រុងតាមបទប្បញ្ញត្តិ	-	-	-	-	១០០.៩៩៩.៩៣៧	៩០៨.៧៧០.៦៩០	(១០០.៩៩៩.៩៣៧)	(៩០៨.៧៧០.៦៩០)	-	-	-	-	-	-
ការផ្ទេរពីប្រាក់ចំណេញក្សាទុកទៅជាភាគកម្មមិនមានអភិបាលភាព	-	-	-	-	-	-	៧២០.០៩២	២.៩២៩.៣៣៨	៧២០.០៩២	២.៩២៩.៣៣៨	(៧២០.០៩២)	(២.៩២៩.៣៣៨)	-	-
ទុនបម្រុងពីការកែប្រែលក្ខណៈជាម្ចាស់កម្មសិទ្ធិក្នុង AB	-	-	-	-	៣.០២៨.៣១៩	១២.៣១៩.២០២	-	-	៣.០២៨.៣១៩	១២.៣១៩.២០២	-	-	៣.០២៨.៣១៩	១២.៣១៩.២០២
លម្អៀងពីការប្តូររូបិយប័ណ្ណ-ក្រុមហ៊ុនបុត្រសម្ព័ន្ធបរទេស	-	-	-	-	(១៣.៦៩៧.២៩៨)	(៥៥.៧២០.៤០៥)	-	-	(១៣.៦៩៧.២៩៨)	(៥៥.៧២០.៤០៥)	(៣.០៣៦)	(១២.៣៥០)	(១៣.៧០០.២៨៩)	(៥៥.៧៣២.៧៩៥)
លម្អៀងពីការប្តូររូបិយប័ណ្ណ	-	១២.៥៦១.៧២៧	-	៣៣៩.៩៨០	-	១៩.២៧២.៥៣៨	-	-	-	២៧.១៧៣.៧៩៥	-	៣៧.៩៩១	-	២៧.២១១.២៣៦
ប្រតិបត្តិការជាមួយភាគហ៊ុនិកសរុប	-	១២.៥៦១.៧២៧	-	៣៣៩.៩៨០	៨៩.៨១៥.៥០៨	៣៧៩.៦៩២.០២៥	(១៩២.៦៩១.៥០១)	(៥៩០.៥២៨.៣៩៧)	(៥២.៨៦៥.៩៩៣)	(១៨៧.៩៩៥.១១៥)	៦.២៩៨.៥៥៣	២៥.៩៥៦.៦០៥	(៩៦.៦១៧.៩៩០)	(១៦២.៩២៨.៥១០)
នាថ្ងៃទី ៣១ខែធ្នូ ឆ្នាំ ២០២១	៨៣៣.១៦៣.០១៩	១.៧៦៤.៧០៦.១៣៩	១១.៧០៦.២១៥	៩៧.៦៩១.១២០	៥៩២.៩០៩.៧៩៨	២.៩៣៣.៩៣២.៩១៥	១៦១.២៦៣.៣០៧	៦៣៩.០៦៨.០៩៨	១.១៩៩.០៩២.២៨៥	៤.៨៨៨.៨៩៨.២៦៨	៥.៩៩២.៧៥៧	២៨.៩១៤.៩៩២	១.២០៥.០៣៥.០៩២	៤.៩០៩.៣១២.៧៦០

ធនាគារ អេស៊ីលីដា ភីអិលស៊ី និង ក្រុមហ៊ុនបុត្រសម្ព័ន្ធ

របាយការណ៍ស្តីពីបម្រែបម្រួលមូលធនរួម (ត)
នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ និងសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់

	ផ្គត់ផ្គង់ភាគហ៊ុនកម្មសិទ្ធិរបស់ក្រុមហ៊ុនម													
	ដើមទុន		បុព្វលាភភាគហ៊ុន		ទុនបម្រុង		ចំណេញកាត់ទុក		សរុប		ភាគហ៊ុនមិនមានអំណាចគ្រប់គ្រាន		មូលធនសរុប	
	ចំនួនគណនីក	ពាក់ព្រៀល (កំណត់សម្គាល់ ៥)	ចំនួនគណនីក	ពាក់ព្រៀល (កំណត់សម្គាល់ ៥)	ចំនួនគណនីក	ពាក់ព្រៀល (កំណត់សម្គាល់ ៥)	ចំនួនគណនីក	ពាក់ព្រៀល (កំណត់សម្គាល់ ៥)	ចំនួនគណនីក	ពាក់ព្រៀល (កំណត់សម្គាល់ ៥)	ចំនួនគណនីក	ពាក់ព្រៀល (កំណត់សម្គាល់ ៥)	ចំនួនគណនីក	ពាក់ព្រៀល (កំណត់សម្គាល់ ៥)
នាថ្ងៃទី ១ ខែមីនាឆ្នាំ ២០២០	៥២៨.៨១៨.១៥៥	១.៧៥៧.៨៣៣.៩៧៨	-	-	៨១៨.៧៩៨.៧២៦	១.៧០៨.០៨៥.២៦៦	១២០.៨៩៤.៧២០	៨៧៤.៦៦១.៧៧៦	៩៦៤.៨៦១.៦០០	៣.៩៣០.១៨១.០២០	-	-	៩៦៤.៨៦១.៦០០	៣.៩៣០.១៨១.០២០
ប្រាក់ចំណេញក្នុងឆ្នាំ	-	-	-	-	-	-	១៩១.៨៩២.៥៩០	៥៧៦.៨៦៥.២៨៩	១៩១.៨៩២.៥៩០	៥៧៦.៨៦៥.២៨៩	-	-	១៩១.៨៩២.៥៩០	៥៧៦.៨៦៥.២៨៩
លទ្ធផលចំណេញលម្អិតផ្សេងៗ៖														
ការកាត់សែរទ្បើងវិញនៃកាតព្វកិច្ចអត្ត-ប្រយោជន៍និយោជិត	-	-	-	-	-	-	១៦៩.៩៩៧	៦៩០.៨៣៥	១៦៩.៩៩៧	៦៩០.៨៣៥	-	-	១៦៩.៩៩៧	៦៩០.៨៣៥
លម្អៀងពីការប្តូររូបិយប័ណ្ណ	-	-	-	-	-	(៨.១៦០.០២៦)	-	-	-	(៨.១៦០.០២៦)	-	-	-	(៨.១៦០.០២៦)
លទ្ធផលចំណេញលម្អិតផ្សេងៗតាមរយៈចន្លោះ	-	-	-	-	-	(៨.១៦០.០២៦)	១៩១.៦៦២.០៣៧	៥៧៧.៥៥៦.១២៩	១៩១.៦៦២.០៣៧	៥៦៩.៣៩៦.០៩៨	-	-	១៩១.៦៦២.០៣៧	៥៦៩.៣៩៦.០៩៨
ប្រតិបត្តិការជាមួយភាគហ៊ុនិក៖														
ការផ្ទេរពីប្រាក់ចំណេញក្សាទុកទៅជាដើមទុន	-	-	-		(៤.៩៥១.៨៦៩)	(១៨.១៥០.២៥០)	៤.៩៥១.៨៦៩	១៨.១៥០.២៥០	-		-	-	-	-
ភាគលាភបានបង់	-	-	-	-	-	-	(៣២.៧១៨.៨២៥)	(១៣៣.៣៩៤.៦៥០)	(៣២.៧១៨.៨២៥)	(១៣៣.៣៩៤.៦៥០)	-	-	(៣២.៧១៨.៨២៥)	(១៣៣.៣៩៤.៦៥០)
ការផ្ទេរពីប្រាក់ចំណេញក្សាទុកទៅជាទុនបម្រុងទូទៅ	-	-	-	-	៦៦.២៨៥.៧៩៥	២៧០.២៨៧.១៨៦	(៦៦.៧៣០.៥៨៥)	(២៧២.០៦០.៥៩៥)	(៩៩៤.៧៩០)	(១.៨១៣.៨០៩)	-	-	(៩៩៤.៧៩០)	(១.៨១៣.៨០៩)
ការបោះផ្សាយភាគហ៊ុន	៤.៣៩៤.៨៦៥	១៧.៧១៩.០១៥	១១.៧០៦.២១៥	៩៧.៧២៦.២៣៩	-	-	-	-	១៦.០៥១.០៨០	៦៥.៩៩០.២៥៤	-	-	១៦.០៥១.០៨០	៦៥.៩៩០.២៥៤
ការផ្ទេរពីប្រាក់ចំណេញក្សាទុកទៅជាទុនបម្រុងតាមបទប្បញ្ញត្តិ	-	-	-	-	២៥.៨៩៧.១៧៩	១០៥.៥៨២.៧៧៨	(២៥.៨៩៧.១៧៩)	(១០៥.៥៨២.៧៧៨)	-	-	-	-	-	-
លម្អៀងពីការប្តូររូបិយប័ណ្ណ- ក្រុមហ៊ុនបុត្រសម្ព័ន្ធបរទេស	-	-	-	-	៦១៤.៥០៥	២.៥០៤.៩២៩	-	-	៦១៤.៥០៥	២.៥០៤.៩២៩	-	-	៦១៤.៥០៥	២.៥០៤.៩២៩
លម្អៀងពីការប្តូររូបិយប័ណ្ណ	-	(១៣.០០៣.៥៨១)	-	(៣៧៤.៥៩៩)	-	(១១.៤០០.៨៨៦)	-	-	-	(២៤.៧៧៩.០៦៦)	-	-	-	(២៤.៧៧៩.០៦៦)
ប្រតិបត្តិការជាមួយភាគហ៊ុនិកបុប	៤.៣៩៤.៨៦៥	៤.៧១០.៤៣៩	១១.៧០៦.២១៥	៩៧.៣៥១.៦៤០	៨៨.៣៩៥.៥១០	៣៩៨.៧៨៣.៧៥៧	(១២០.៨៩៤.៧២០)	(៩៩២.៨៨៧.៧៧៣)	(១៦.៩៩៨.១៣០)	(៩២.០៩១.៩៩២)	-	-	(១៦.៩៩៨.១៣០)	(៩២.០៩១.៩៩២)
នាថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០២០	៥៣៣.១៦៣.០១៩	១.៧៥២.១៩៤.៩១២	១១.៧០៦.២១៥	៩៧.៣៥១.៦៤០	៥០៣.០៩៤.២៣៦	២.០៩៨.៧០៨.៩៩៧	១៩១.៦៦២.០៣៧	៥៥៩.៣៣០.១២៧	១.០៨៩.៦២៥.៥០៧	៤.៤០៧.៥៣៥.១៧៦	-	-	១.០៨៩.៦២៥.៥០៧	៤.៤០៧.៥៣៥.១៧៦

កំណត់សម្គាល់ដូចមានភ្ជាប់ជាមួយ នៅទំព័រទី ២៩ ដល់ទី ២៥៥ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។

ធនាគារ អេស៊ីលីដា អ៊ីអិលស៊ី និង ក្រុមហ៊ុនបុត្រសម្ព័ន្ធ

របាយការណ៍លំហូរទឹកប្រាក់រួម
នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ និងសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់

	កំណត់សម្គាល់	២០២១ ដុល្លារអាមេរិក	២០២០ ដុល្លារអាមេរិក	២០២១ ពាន់រៀល (កំណត់សម្គាល់ ៥)	២០២០ ពាន់រៀល (កំណត់សម្គាល់ ៥)
លំហូរទឹកប្រាក់ពីសកម្មភាពប្រតិបត្តិការ					
ប្រាក់ចំណេញក្នុងការិយបរិច្ឆេទមុនពេលបង់ពន្ធ		២០៤.៧៥៣.៤១៧	១៨០.០៣៥.៤៦២	៨៣២.៩៣៦.៩០២	៧៣៤.០០៤.៥៨០
និយ័តកម្មលើ៖					
រំលស់របស់ទ្រព្យ និងបរិក្ខារ	១៤	២០.៤១៣.៥៩១	២១.២៤៩.២១៨	៨៣.០៤២.៤៨៨	៨៦.៦៣៣.០៦២
ការខាតបង់ឱនភាពនៃតម្លៃសុទ្ធ	១០	១៣.៤០២.៥២៥	២០.៧៣៩.៨៧៥	៥៤.៥២១.៤៧១	៨៤.៥៥៦.៤៧០
រំលស់របស់សិទ្ធិប្រើប្រាស់ទ្រព្យសកម្ម	១៦	១១.១៩២.២១៩	១០.៦២៧.១២០	៤៥.៥២៩.៩៤៧	៤៣.៣២៦.៧៦៨
អត្ថប្រយោជន៍ប្រាក់បំណាច់អតីតភាពការងារ	២៥(គ)	៨.០៨០.៧២៩	៦.៥៦៣.៧១៩	៣២.៨៧២.៤០៦	២៦.៧៦០.២៨២
រំលស់លើទ្រព្យសកម្មអរូបី	១៥	៣.៨៨៩.៩៦០	៣.៦៦៧.៥៨៣	១៥.៨២៤.៣៥៧	១៤.៩៥២.៧៣៦
ចំណាយអត្ថប្រយោជន៍ពេលចូលនិវត្ត	២៥(ក)	២.០២៩.៨៣១	១.៦៩៧.៣៤១	៨.២៥៧.៣៥៣	៦.៩២០.០៦០
ចំណាយលើមូលនិធិអភិវឌ្ឍន៍វិជ្ជាជីវៈ	២៥(ខ)	១.៥៧៤.៦៥៨	១.៣១២.៦៤១	៦.៤០៥.៧០៩	៥.៣៥១.៦៣៧
និយ័តកម្មលើទ្រព្យ និងបរិក្ខារ		៥៧៨.៩៤៣	១៨.៥៣៤	២.៣៥៥.១៤០	៧៥.៥៦៣
ចំណូលភាគលាភ	៣០	(១១៦.៦១៤)	(១៧៤.៤៧៩)	(៤៧៤.៣៨៦)	(៧១១.៣៥១)
ចំណេញពីការលក់ទ្រព្យ និងបរិក្ខារ ទ្រព្យសកម្មអរូបី និងភតិសន្យា	៣០	(២៤៨.០២៣)	(៣៦៩.៥២៨)	(១.០០៨.៩៥៨)	(១.៥០៦.៥៦៦)
និយ័តកម្មទ្រព្យសកម្មអរូបី		(២៥៦.៨២៩)	២៩០.២៨៤	(១.០៤៤.៧៨០)	១.១៨៣.៤៨៨
ចំណេញពីការប្តូររូបិយប័ណ្ណមិនទាន់បានទទួលស្គាល់		(២.៨៩៩.០១៨)	(២៦២.៣៥៨)	(១១.៧៩៣.២០៥)	(១.០៦៩.៦៣៥)
ទុនបម្រុងសម្រាប់ការប្តូររូបិយប័ណ្ណ		(១៣.៧០០.២៨៤)	៦១៤.៤០៥	(៥៥.៧៣២.៧៥៥)	២.៥០៤.៩២៩
ចំណូលការប្រាក់សុទ្ធ		(៤០១.៤២៨.៩៤១)	(៣៦៤.៣១៧.១៥៩)	(១.៦៣៣.០១២.៩៣២)	(១.៤៨៥.៣២១.០៥៨)
ការខាតបង់ពីប្រតិបត្តិការមុនពេលបម្រែបម្រួលមូលធន		(១៥២.៧៣៣.៨៣៦)	(១១៨.៣០៧.៣៤២)	(៦២១.៣២១.២៤៣)	(៤៨២.៣៣៩.០៣៥)
បម្រែបម្រួល៖					
ប្រាក់បញ្ញើរបស់អតិថិជន		៩៣៧.៩៩២.៦៤៥	២១១.៥៦៣.១៩៥	៣.៨១៥.៧៥៤.០៨០	៨៦២.៥៤៣.១៤៦
ប្រាក់បញ្ញើពីធនាគារផ្សេងៗ និងស្ថាប័នហិរញ្ញវត្ថុផ្សេងៗ		១៦៦.៧៣១.៥៣៣	៣១.៨៣៤.៣១៤	៦៧៨.២៦៣.៨៧៦	១២៩.៧៨៨.៩៩៨
បំណុលផ្សេងៗ		៣.០៤៥.៣៤០	១០.៣០១.៧២៨	១២.៣៨៨.៤៤៣	៤២.០០០.១៤៥
ទ្រព្យសកម្មផ្សេងៗ		(៤.៧០១.៦០៧)	(៥.៥៦០.២៣៧)	(១៩.១២៦.១៣៧)	(២២.៦៦៩.០៨៦)
ប្រាក់បញ្ញើតាមច្បាប់		(១៨.០៩០.៥៧១)	៤៣.៤៩៩.២៨៨	(៧៣.៥៩២.៤៤៣)	១៧៧.១៤២.៧៤៧
ប្រាក់បញ្ញើនៅធនាគារផ្សេងៗ		(៤៣.៨០៩.១៧០)	១៨១.៦០២.០៨៦	(១៧៨.២១៥.៧០៤)	៧៤០.៣៩១.៧០៥
ឥណទាន និងបុរេប្រទាន		(៩៣៣.៣២៥.១២៧)	(៦៥៦.០៦៣.៥៣០)	(៣.៧៩៦.៧៦៦.៦១៧)	(២.៦៣៤.០០១.០១២)
សាច់ប្រាក់សុទ្ធប្រើក្នុងប្រតិបត្តិការ		(៤៤.៨៩០.៧៩៣)	(២៩១.១៨០.៤៩៨)	(១៨២.៦១៥.៧៤៥)	(១.១៨៧.១៤២.៨៩២)
ចំណូលការប្រាក់បានទទួល		៥៧២.៤៥៨.២០៣	៥១៣.៥៩១.៦១៧	២.៣២៨.៧៥៩.៩៧០	២.០៩៣.៩១៣.០២២
អត្ថប្រយោជន៍មូលនិធិអភិវឌ្ឍន៍វិជ្ជាជីវៈបានបង់	២៥(ខ)	(៥.២៧៩)	(២.០៨៥.៣១៥)	(២១.៤៧៥)	(៨.៥០១.៨២៩)
អត្ថប្រយោជន៍ពេលចូលនិវត្តបានបង់	២៥(ក)	(១១០.៣៧០)	(២១៦.៨៤០)	(៤៤៨.៩៨៥)	(៨៨៤.០៥៧)
អត្ថប្រយោជន៍ប្រាក់បំណាច់អតីតភាពការងារបានបង់	២៥(គ)	(៧.៧៨០.០៧៥)	(៦.៩៩៨.២៥៧)	(៣១.៦៤៩.៣៤៥)	(២៨.៥៣១.៨៩៩)
ពន្ធលើប្រាក់ចំណេញបានបង់	៣២(ក)	(៣០.១៥៨.៣៧០)	(៣៥.០៦៤.៦៥២)	(១២២.៦៤៣.៥៦៩)	(១៤២.៩៥៨.៥៨៦)
ចំណាយការប្រាក់បានបង់		(១១៥.៥៤៣.១៣៤)	(១០៥.១២១.៦៦៦)	(៤៧០.០២៩.៤៦៩)	(៤២៨.៥៨១.០៣៣)
សាច់ប្រាក់សុទ្ធបានពីសកម្មភាពប្រតិបត្តិការ (យោងទៅទំព័របន្ទាប់)		៣៧៣.៩៨០.១៨២	៧២.៩២៤.៣៨៩	១.៥២១.៣៥១.៣៨២	២៩៧.៣១២.៧៣១

ធនាគារ អេស៊ីលីដា អ៊ីអិលស៊ី និង ក្រុមហ៊ុនបុត្រសម្ព័ន្ធ

របាយការណ៍លំហូរទឹកប្រាក់រួម (ត)
នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ និងសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់

	កំណត់សម្គាល់	២០២១ ដុល្លារអាមេរិក	២០២០ ដុល្លារអាមេរិក	២០២១ ពាន់រៀល (កំណត់សម្គាល់ ៥)	២០២០ ពាន់រៀល (កំណត់សម្គាល់ ៥)
សាច់ប្រាក់សុទ្ធបានពីសកម្មភាពប្រតិបត្តិការ (យោងមកពីទំព័រមុន)		៣៧៣.៩៨០.១៨២	៧២.៩២៤.៣៨៩	១.៥២១.៣៥១.៣៨២	២៩៧.៣១២.៧៣១
លំហូរទឹកប្រាក់ពីសកម្មភាពវិនិយោគ					
ការប្រាក់បានមកពីការវិនិយោគ		៨៤៣.៤៦៧	១.៨៧៦.៥៥៦	៣.៤៣១.២២៤	៧.៦៥០.៧១៩
សាច់ប្រាក់បានពីការលក់ទ្រព្យ និងឥវ៉ាន់និងទ្រព្យសកម្មអរូបី		៧៨៦.៦០៩	៤០៨.៩៥៨	៣.១៩៩.៩២៥	១.៦៦៧.៣២២
ភាគលាភបានទទួល		១១៦.៦១៤	១៧៤.៤៧៩	៤៧៤.៣៨៦	៧១១.៣៥១
សាច់ប្រាក់បានមកពីការវិនិយោគដល់កាលកំណត់		១០៣.១៦៦	-	៤១៩.៦៧៩	-
សាច់ប្រាក់បានពីការលុបចោលកាតិសន្យា		(៣.៤២០)	-	(១៣.៩១៣)	-
ការវិនិយោគបន្ថែម		(៣៦.១៤១)	-	(១៤៧.០២២)	-
ការវិនិយោគហិរញ្ញវត្ថុ		(១.៥២២.១៧៧)	២២.៩៤៦.៥៧៦	(៦.១៩២.២១៦)	៩៣.៥៥៣.១៩០
ការទិញទ្រព្យសកម្មអរូបី	១៥	(១.៧៩៦.៧២៧)	(៩.៦៨៩.២៣១)	(៧.៣០៩.០៨៥)	(៣៩.៥០២.៩៩៥)
ការទិញទ្រព្យនិងឥវ៉ាន់	១៤	(៣៣.១០៩.៨៩៨)	(១៧.៧០៤.៨៨៩)	(១៣៤.៦៩១.០៦៥)	(៧២.១៨១.២០២)
សាច់ប្រាក់ប្រើក្នុងសកម្មភាពវិនិយោគ		(៣៤.៦១៨.៥០៧)	(១.៩៨៧.១៥១)	(១៤០.៨២៨.០៨៧)	(៨.១០១.៦១៥)
លំហូរសាច់ប្រាក់ពីសកម្មភាពហិរញ្ញប្បទាន					
សាច់ប្រាក់បានពីប្រាក់កម្ចី		២០៥.០៤០.២២៤	១៧៨.៥៩០.៤៧៨	៨៣៤.១០៣.៦៣១	៧២៨.១១៣.៣៧៩
វិនិយោគធ្វើឡើងដោយម្ចាស់ភាគកម្មមិនមានអភិបាលភាពរបស់ AIB	១៣	១០.០០០.០០០	-	៤០.៦៨០.០០០	-
សាច់ប្រាក់បានពីបំណុលបន្ទាប់បន្សំ		-	៣៥.០០០.០០០	-	១៤២.៦៩៥.០០០
សាច់ប្រាក់បានពីបុព្វលាភភាគហ៊ុន		-	១១.៧០៦.២១៥	-	៤៧.៧២៦.២៣៩
សាច់ប្រាក់បានពីការបោះផ្សាយភាគហ៊ុន	២៦	-	៤.៣៩៤.៨៦៥	-	១៧.៧១៤.០១៥
ការរង់ពន្ធលើការបង្កើនដើមទុនរបស់ ABL	១៣	(៤២៣.៨៦៣)	(៤៤៤.៧៩០)	(១.៧២៤.២៧៥)	(១.៨១៣.៤០៩)
ការទូទាត់បំណុលបន្ទាប់បន្សំ		(១១.០០០.០០០)	(៧.១៤៣.៩៥៧)	(៤៤.៧៤៨.០០០)	(២៩.១២៥.៩១៣)
ការទូទាត់បំណុលកាតិសន្យា	២៤	(១២.៦២២.៥៨៨)	(១១.៨៣៣.២៧៤)	(៥១.៣៤៨.៦៧២)	(៤៨.២៤៤.២៥៨)
ការទូទាត់ភាគលាភ	២៦	(៤២.៤៩៣.២៩៣)	(៣២.៧១៨.៨២៥)	(១៧២.៨៦២.៧១៦)	(១៣៣.៣៩៤.៦៥០)
ចំណាយការប្រាក់បានបង់		(៥២.៧៣៥.១៤២)	(៤៨.៨៨៩.៦៤០)	(២១៤.៥២៦.៥៥៨)	(១៩៩.៣២៣.០៦២)
ការសងប្រាក់កម្ចី		(១២៨.៩៩៣.២២៤)	(២០១.១៦៣.២៦៣)	(៥២៤.៧៤៤.៤៣៥)	(៨២០.១៤២.៦២៣)
សាច់ប្រាក់សុទ្ធប្រើក្នុងសកម្មភាពហិរញ្ញប្បទាន		(៣៣.២២៧.៨៨២)	(៧២.៥៥២.១៩១)	(១៣៥.១៧១.០២៥)	(២៩៥.៧១៥.២៨២)
ការកើនឡើង(ថយចុះ)សាច់ប្រាក់ និងសាច់ប្រាក់សមមូលសុទ្ធ		៣០៦.១៣៣.៧៩៣	(១.៦១៤.៩៥៣)	១.២៤៥.៣៥២.២៧០	(៦.៥៨៤.១៦៦)
សាច់ប្រាក់ និងសាច់ប្រាក់សមមូលនៅដើមការិយបរិច្ឆេទ	៣៤	១.៤៩៧.១០៥.៥០៤	១.៤៩៨.៧២០.៤៥៧	៦.០៥៥.៧៩១.៧៦៤	៦.១០៧.២៨៥.៨៦២
លម្អៀងពីការប្តូរូបិយប័ណ្ណ		-	-	៤៥.២៥២.៨៦២	(៤៤.៩០៩.៩៣២)
សាច់ប្រាក់ និងសាច់ប្រាក់សមមូលនៅចុងការិយបរិច្ឆេទ	៣៤	១.៨០៣.២៣៩.២៩៧	១.៤៩៧.១០៥.៥០៤	៧.៣៤៦.៣៩៦.៨៩៦	៦.០៥៥.៧៩១.៧៦៤

នៅអំឡុងការិយបរិច្ឆេទ សម្ព័ន្ធធនាគារបានចុះកិច្ចសន្យាជួលថ្មី និងទទួលស្គាល់សិទ្ធិប្រើប្រាស់ទ្រព្យសកម្មចំនួន ១០.៩១៨.៨១៤ ដុល្លារអាមេរិក (ឆ្នាំ២០២០៖ ៧.៩៦៦.៨៦៧ ដុល្លារអាមេរិក) ព្រមទាំងបំណុលកាតិសន្យាដែលពាក់ព័ន្ធរបស់វា ដែលជាប្រតិបត្តិការមិនមែនសាច់ប្រាក់។

កំណត់សម្គាល់ដូចមានភ្ជាប់ជាមួយ នៅទំព័រទី២៩ ដល់ទី២៤៥ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។

ធនាគារ អេស៊ីលីដា អ៊ីអិលស៊ី និង ក្រុមហ៊ុនបុត្រសម្ព័ន្ធ

របាយការណ៍ស្ថានភាពហិរញ្ញវត្ថុដោយឡែក
នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ និងសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់

	កំណត់សម្គាល់	២០២១ ដុល្លារអាមេរិក	២០២០ ដុល្លារអាមេរិក	២០២១ ពាន់រៀល (កំណត់សម្គាល់ ៥)	២០២០ ពាន់រៀល (កំណត់សម្គាល់ ៥)
ទ្រព្យសកម្ម					
សាច់ប្រាក់ក្នុងដៃ	៧	៤៣៩.៤៦៥.៩៨០	៤០០.៨១៦.១២៦	១.៧៩០.៣៨៥.៤០៣	១.៦២១.៣០១.២៣០
ប្រាក់បញ្ញើនៅធនាគារផ្សេងៗ	៨	៥៤៣.៤២៦.៩២០	៥០៧.៦២៩.៤០៧	២.២១៣.៩២១.២៧២	២.០៥៣.៣៦០.៩៥១
ការវិនិយោគហិរញ្ញវត្ថុ	៩	៨០១.០៨៤.៣៩២	៥៦៦.៦៧៤.៥២៣	៣.២៦៣.៦១៧.៨១៣	២.២៩២.១៩៨.៤៤៦
ឥណទាននិងបុរេប្រទាន-សុទ្ធ	១០	៥.២៣២.០៥៨.៩២០	៤.២៩២.៦៤៩.១៥៩	២១.៣១៥.៤០៨.០៤០	១៧.៣៦៣.៧៦៥.៨៤៨
ទ្រព្យសកម្មផ្សេងៗ	១១	២៦.០៤៩.៥១៣	២០.២៥៦.១១០	១០៦.១២៥.៧១៧	៨១.៩៣៥.៩៦៥
ប្រាក់បញ្ញើតាមច្បាប់	១២	៥១២.៩៨៦.៤៥៤	៣៥៦.៧៥៣.៧៥៦	១.៦៨២.៥០៦.៨១៤	១.៤៤៣.០៦៨.៩៤៣
ការវិនិយោគក្នុងក្រុមហ៊ុនបុត្រសម្ព័ន្ធ	១៣	៩១.១១៧.៧១៦	៩១.១១៥.៥៧១	៣៧១.២១៣.៥៧៥	៣៦៨.៥៦២.៤៨៥
ទ្រព្យ និងបរិក្ខារ-សុទ្ធ	១៤	១០៤.៤៣៧.១៨៣	៩០.៨៣៦.៤២២	៤២៥.៤៧៧.០៨៤	៣៦៧.៤៣៣.៣២៧
ទ្រព្យសកម្មអរូបី-សុទ្ធ	១៥	១១.៤១៥.៨៥៣	១៣.៨៨៤.៥៥៨	៤៦.៥០៨.១៨៥	៥៦.១៦៣.០៣៧
សិទ្ធិប្រើប្រាស់ទ្រព្យសកម្ម-សុទ្ធ	១៦	២៥.៥៩៦.៧២៧	២៦.១៨២.១៧២	១០៤.២៨១.០៦៦	១០៥.៩០៦.៨៨៦
ទ្រព្យសកម្មពន្ធពន្យារ-សុទ្ធ	១៧	៧.៥២៣.៧១៧	១២.៦៨៥.៩៤៧	៣០.៦៥១.៦២៣	៥១.៣១៤.៦៥៦
ទ្រព្យសកម្មសរុប		៧.៦៩៥.១៦៣.៣៧៥	៦.៣៧៩.៤៨៣.៧៥១	៣១.៣៥០.០៩៥.៥៩២	២៥.៨០៥.០១១.៧៧៤
បំណុលនិងមូលធន					
បំណុល					
ប្រាក់បញ្ញើរបស់ធនាគារនិងស្ថាប័នហិរញ្ញវត្ថុផ្សេងៗ	១៨	៤៥៥.៦០៦.៨៣៥	២៩៦.៧៦៤.៥៥៤	១.៨៥៦.១៤២.២៤៦	១.២០០.៤១២.៦២១
ប្រាក់បញ្ញើរបស់អតិថិជន	១៩	៥.១២៦.៩២៦.៩៩០	៤.១៨០.២៦៨.៧៣៧	២០.៨៨៧.១០០.៥៥៧	១៦.៩០៩.១៨៧.០៤១
បំណុលផ្សេងៗ	២០	៧៦.៧០២.១៧៩	៦២.៤០៨.៨៨២	៣១២.៤៨៤.៦៧៧	២៥២.៤៤៣.៩២៨
ប្រាក់កម្ចី	២១	៥៨៣.៦៤១.០៥៦	៥០៧.៣៥២.៩១៦	២.៣៧៧.៧៥៣.៦៦២	២.០៥២.២៤២.៥៤៥
បំណុលបន្ទាប់បន្សំ	២២	១៥៦.៤៩២.៩៤១	១៦៧.១៥៨.៦២៣	៦៣៧.៥៥២.២៤២	៦៧៦.១៥៦.៦៣០
បំណុលឧបការណ៍និស្សន្ទស៍-សុទ្ធ	២៣	៥០៦.១៥៨	-	២.០៦២.០៨៨	-
បំណុលកាតិសន្យា	២៤	២៥.៣៧១.៧៣៦	២៥.៧៧២.៣៨៥	១០៣.៣៦៤.៤៥២	១០៤.២៤៩.២៩៧
អត្ថប្រយោជន៍និយោជិត	២៥	២៥.៣៣១.៨០៧	១៧.៧៨១.៧៦៣	១០៣.២០១.៧៨២	៧១.៩២៧.២៣១
បំណុលពន្ធលើប្រាក់ចំណូលបច្ចុប្បន្ន	៣២(ក)	៣៥.៤៩១.៣២៩	២៧.៩៥០.៣៣៤	១៤៤.៥៩១.៦៧៤	១១៣.០៥៩.១០១
បំណុលសរុប		៦.៤៨៦.០៧១.០៣១	៥.២៨៥.៤៥៨.១៩៤	២៦.៤២៤.២៥៣.៣៨០	២១.៣៧៩.៦៧៨.៣៩៤
មូលធន					
ដើមទុន	២៦	៤៣៣.១៦៣.០១៩	៤៣៣.១៦៣.០១៩	១.៧៦៤.៧០៦.១៣៩	១.៧៥២.១៤៤.៤១២
បុព្វលាភភាគហ៊ុន	២៦	១១.៧០៦.២១៥	១១.៧០៦.២១៥	៤៧.៦៩១.១២០	៤៧.៣៥១.៦៤០
ទុនបម្រុង	៣៦	៦០៧.៨៨១.៥៦០	៥១០.៧៤១.៥៥៤	២.៤៩៤.០៣៩.២៨២	២.០៧៩.៣៥៧.៨០២
ប្រាក់ចំណេញកា្សទុក		១៥៦.៣៤១.៥៥០	១៣៨.៤១៤.៧៦៩	៦១៩.៤០៥.៦៧១	៥៤៦.៤៧៩.៥២៦
មូលធនសរុប		១.២០៩.០៩២.៣៥៤	១.០៩៤.០២៥.៥៥៧	៤.៩២៥.៨៤២.២១២	៤.៤២៥.៣៣៣.៣៨០
បំណុលនិងមូលធនសរុប		៧.៦៩៥.១៦៣.៣៧៥	៦.៣៧៩.៤៨៣.៧៥១	៣១.៣៥០.០៩៥.៥៩២	២៥.៨០៥.០១១.៧៧៤

កំណត់សម្គាល់ដូចមានភ្ជាប់ជាមួយ នៅទំព័រទី២៩ ដល់ទី២៤៥ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។

ធនាគារ អេស៊ីលីដា អ៊ីអិលស៊ី និង ក្រុមហ៊ុនបុត្រសម្ព័ន្ធ

របាយការណ៍ចំណេញ ឬខាត និងលទ្ធផល លម្អិតផ្សេងៗដោយឡែក នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ និងសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់

	កំណត់សម្គាល់	២០២១ ដុល្លារអាមេរិក	២០២០ ដុល្លារអាមេរិក	២០២១ ពាន់រៀល (កំណត់សម្គាល់ ៥)	២០២០ ពាន់រៀល (កំណត់សម្គាល់ ៥)
ចំណូលការប្រាក់	២៧	៥៣៧.៤២០.៥៨០	៤៧៨.៧៣៩.៣៤១	២.១៨៦.២២៦.៩១៩	១.៩៥១.៨២០.២៩៣
ចំណាយការប្រាក់	២៨	(១៦៣.១៦៣.៨៩០)	(១៣៩.៨៥៦.១៤៧)	(៦៦៣.៧៥០.៧០៥)	(៥៧០.១៩៣.៥១១)
ចំណូលការប្រាក់សុទ្ធ		៣៧៤.២៥៦.៦៩០	៣៣៨.៨៨៣.១៩៤	១.៥២២.៤៧៦.២១៤	១.៣៨១.៦២៦.៧៨២
ចំណូលកម្រៃនិងជើងសា	២៩	៣៨.៨២៥.៧២០	៤២.៣៥៤.០៩៤	១៥៧.៩៤៣.០២៩	១៧២.៦៧៧.៦៤១
ចំណាយកម្រៃនិងជើងសា		(២.៣៩៣.៦៦៦)	(១.៥២៦.៣៧០)	(៩.៧៣៧.៤៣៣)	(៦.២២៣.០១០)
ចំណូលកម្រៃនិងជើងសាសុទ្ធ		៣៦.៤៣២.០៥៤	៤០.៨២៧.៧២៤	១៤៨.២០៥.៥៩៦	១៦៦.៥៥៤.៦៣១
ការខាតបង់ឱនភាពនៃតម្លៃរបស់ឥណទាន និងបុរេប្រទានប្រាក់បញ្ញើនៅធនាគារផ្សេងៗ និងគណនីត្រូវទទួលផ្សេងៗ	១០	(៣១៦.៧៥៤)	(១៦.២៤៧.៦៧៦)	(១.២៨៨.៥៥៥)	(៦៦.២៤១.៧៧៥)
ការកត់ត្រាត្រលប់នៃការខាតបង់ឱនភាពនៃតម្លៃកិច្ចសន្យាក្រៅតារាងតុល្យការ	១០	៣៨០.៥៦៩	១៣២.០៨២	១.៥៤៨.១៥៥	៥៣៨.៤៩៨
ចំណាយសុទ្ធពីការខាតបង់ឱនភាពនៃតម្លៃ		៦៣.៨១៥	(១៦.១១៥.៥៩៤)	២៥៩.៦០០	(៦៥.៧០៣.២៧៧)
ចំណូលបន្ទាប់ពីការខាតបង់ឱនភាពនៃតម្លៃ		៤១០.៧៥២.៥៥៩	៣៦៣.៥៩៥.៣២៤	១.៦៧០.៩៤១.៤១០	១.៤៨២.៣៧៨.១៣៦
ចំណូលផ្សេងៗ	៣០	១៨.៣៧៨.៨៥២	១៦.៦៦២.៧៤៨	៧៤.៧៦៥.១៧០	៦៧.៩៣៤.០២៤
ចំណាយទូទៅនិងរដ្ឋបាល	៣១	(២២៧.៤៦៩.២២៧)	(២០៨.១០៣.៧៥៧)	(៩២៥.៣៤៤.៨១៥)	(៨៤៨.៤៣៩.០១៧)
ចំណេញមុនចំណាយពន្ធលើប្រាក់ចំណេញ		២០១.៦៦២.១៨៤	១៧២.១៥៤.៣១៥	៨២០.៣៦១.៧៦៥	៧០១.៨៧៣.១៤៣
ចំណាយពន្ធលើប្រាក់ចំណេញ	៣២(ខ)	(៣៩.៥៧៧.៣៣៣)	(៣៣.៨១២.១៣៩)	(១៦១.០០០.៥៩១)	(១៣៧.៨៥២.០៩១)
ប្រាក់ចំណេញក្នុងការិយបរិច្ឆេទ		១៦២.០៨៤.៨៥១	១៣៨.៣៤២.១៧៦	៦៥៩.៣៦១.១៧៤	៥៦៤.០២១.០៥២
លទ្ធផលចំណេញលម្អិតផ្សេងៗ៖					
ធាតុដែលនឹងមិនត្រូវបានចាត់ថ្នាក់ឡើងវិញទៅចំណេញឬខាត៖					
ការវាស់វែងឡើងវិញនៃកាតព្វកិច្ចអត្ថប្រយោជន៍និយោជិត	២៥	(៤.០១៨.៦១៥)	៧២.៥៩៣	(១៦.៣៤៧.៧២៦)	២៩៥.៩៦២
ការវាស់វែងឡើងវិញលើផ្នែកដែលមានប្រសិទ្ធិភាពរបស់ឧបករណ៍និស្សន្ទស៍ដែលកើតឡើងពីការការពារហានិភ័យលំហូរសាច់ប្រាក់		(៥០៦.១៥៨)	-	(២.០៥៩.០៥១)	-
ធាតុដែលត្រូវ ឬអាចត្រូវបានចាត់ថ្នាក់ឡើងវិញនៅគ្រាបន្ទាប់ទៅចំណេញឬខាត៖					
លម្អៀងពីការប្តូររូបិយប័ណ្ណ		-	-	៤.៩៥៩.៣៩០	(៧.៩៦១.៧៩៧)
លទ្ធផល(ខាត)ចំណេញលម្អិតផ្សេងៗក្នុងការិយបរិច្ឆេទ		(៤.៥២៩.៧៧៣)	៧២.៥៩៣	(១៣.៩៤៧.៣៨៧)	(៧.៦៦៥.៨៣៥)
លទ្ធផលចំណេញលម្អិតផ្សេងៗក្នុងការិយបរិច្ឆេទសរុប		១៥៧.៥៦០.០៧៨	១៣៨.៩១៤.៧៦៩	៦៩៥.៩១៣.៧៨៧	៥៥៦.៣៥៥.២១៧

កំណត់សម្គាល់ដូចមានភ្ជាប់ជាមួយ នៅទំព័រទី២៩ ដល់ទី២៩៥ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។

ធនាគារ អេស៊ីលីដា ភីអិលស៊ី និង ក្រុមហ៊ុនបុត្រសម្ព័ន្ធ

របាយការណ៍ស្តីពីបម្រែបម្រួលមូលធនដោយឡែក
នាថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០២១ និងសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់

	ដើមទុន		បុព្វលាភភាគហ៊ុន		ទុនបម្រុង		ចំណេញរក្សាទុក		មូលធនសរុប	
	ដុល្លារអាមេริក	រៀល (កំណត់សម្គាល់ ៥)	ដុល្លារអាមេริក	រៀល (កំណត់សម្គាល់ ៥)	ដុល្លារអាមេริក	រៀល (កំណត់សម្គាល់ ៥)	ដុល្លារអាមេริក	រៀល (កំណត់សម្គាល់ ៥)	ដុល្លារអាមេริក	រៀល (កំណត់សម្គាល់ ៥)
នាថ្ងៃទី ១ ខែមករា ឆ្នាំ ២០២១	៤៣៣.១៦៣.០១៩	១.៧៥២.១៩៩.៩១២	១១.៧០៦.២១៥	៤៧.៣៥១.៦៩០	៥១០.៧៩១.៥៥៦	២.០៧៩.៣៥៧.៨១០	១៣៨.៩១៤.៧៦៩	៥៩៦.៩៧៩.៥២៦	១.០៩៩.០២៥.៥៥៩	៤.៩២៥.៣៣៣.៣៨៨
ប្រាក់ចំណេញក្នុងឆ្នាំ	-	-	-	-	-	-	១៦២.០៨៤.៨៥១	៦៥៩.៣៦១.១៧៤	១៦២.០៨៤.៨៥១	៦៥៩.៣៦១.១៧៤
លទ្ធផលចំណេញលម្អិតផ្សេងៗ៖										
ការវាស់វែងឡើងវិញលើផ្នែកដែលមានប្រសិទ្ធិភាពរបស់ឧបករណ៍និស្សន្ទស់ដែលកើតឡើងពីការការពារហានិភ័យលំហូរសាច់ប្រាក់	-	-	-	-	-	-	(៥០៦.១៥៨)	(២.០៥៩.០៥១)	(៥០៦.១៥៨)	(២.០៥៩.០៥១)
ការវាស់វែងឡើងវិញនៃកាតព្វកិច្ចអត្ថប្រយោជន៍និយោជិត	-	-	-	-	-	-	(៤.០១៨.៦១៥)	(១៦.៣៤៧.៧២៦)	(៤.០១៨.៦១៥)	(១៦.៣៤៧.៧២៦)
លម្អៀងពីការប្តូរូបិយប័ណ្ណ	-	-	-	-	-	៤.៩៥៩.៣៩០	-	-	-	៤.៩៥៩.៣៩០
លទ្ធផលចំណេញលម្អិតផ្សេងៗសរុបក្នុងឆ្នាំ	-	-	-	-	-	៤.៩៥៩.៣៩០	១៥៧.៥៦០.០៧៨	៦៤០.៩៥៤.៣៩៧	១៥៧.៥៦០.០៧៨	៦៤៥.៩១៣.៧៨៧
ប្រតិបត្តិការជាមួយភាគហ៊ុនិក៖										
ភាគលាភបានបង់	-	-	-	-	-	-	(៤២.៤៩៣.២៩៣)	(១៧២.៨៦២.៧១៦)	(៤២.៤៩៣.២៩៣)	(១៧២.៨៦២.៧១៦)
ការផ្ទេរពីប្រាក់ចំណេញរក្សាទុកទៅទុនបម្រុងតាមទប្បញ្ញត្តិ	-	-	-	-	៩៧.១៤០.០០៤	៣៩៥.១៦៥.៥៣៦	(៩៧.១៤០.០០៤)	(៣៩៥.១៦៥.៥៣៦)	-	-
លម្អៀងពីការប្តូរូបិយប័ណ្ណ	-	១២.៥៦១.៧២៧	-	៣៣៩.៤៨០	-	១៤.៥៥៦.៥៤៦	-	-	-	២៧.៤៥៧.៧៥៣
ប្រតិបត្តិការជាមួយភាគហ៊ុនិកសរុប	-	១២.៥៦១.៧២៧	-	៣៣៩.៤៨០	៩៧.១៤០.០០៤	៤០៩.៧២២.០៨២	(១៣៩.៦៣៣.២៩៧)	(៥៦៨.០២៨.២៥២)	(៤២.៤៩៣.២៩៣)	(១៩៥.៤០៤.៩៦៣)
នាថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០២១	៤៣៣.១៦៣.០១៩	១.៧៦៤.៧០៦.១៣៩	១១.៧០៦.២១៥	៤៧.៦៩១.១២០	៦០៧.៨៨១.៥៦០	២.៤៩៤.០៣៩.២៨២	១៥៦.៣៤១.៥៥០	៦១៩.៤០៥.៦៧១	១.២០៩.០៩២.៣៤៤	៤.៩២៥.៨៤២.២១២

ធនាគារ អេស៊ីលីដា អ៊ីអិលស៊ី និង ក្រុមហ៊ុនបុត្រសម្ព័ន្ធ

របាយការណ៍ស្តីពីបម្រែបម្រួលមូលធនដោយឡែក
នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ និងសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់

	ដើមទុន		បុព្វលាភភាគហ៊ុន		ទុនបម្រុង		ចំណេញកាត់ទុក		មូលធនសរុប	
	ដុល្លារអាមេริក	រៀល (កំណត់សម្គាល់ ៥)	ដុល្លារអាមេริក	រៀល (កំណត់សម្គាល់ ៥)	ដុល្លារអាមេริក	រៀល (កំណត់សម្គាល់ ៥)	ដុល្លារអាមេริក	រៀល (កំណត់សម្គាល់ ៥)	ដុល្លារអាមេริក	រៀល (កំណត់សម្គាល់ ៥)
នាថ្ងៃទី ១ ខែមករា ឆ្នាំ ២០២០	៤២៨.៨១៨.១៥៤	១.៧៤៧.៤៣៣.៩៧៨	-	-	៤២៥.៧០៩.៦១២	១.៧៥២.៣៦៨.៦៥៦	១១៧.៧៥០.៧៦៧	៤៦២.២៣២.៣៨៩	៩៧២.២៧៨.៥៣៣	៣.៩៦២.០៣៥.០២៣
ប្រាក់ចំណេញក្នុងឆ្នាំ	-	-	-	-	-	-	១៣៨.៣៥២.១៧៦	៥៦៤.០២១.០៥២	១៣៨.៣៥២.១៧៦	៥៦៤.០២១.០៥២
លទ្ធផលចំណេញលម្អិតផ្សេងៗ៖										
ការវាស់វែងឡើងវិញនៃការពិចារណាតម្លៃ	-	-	-	-	-	-	៧២.៥៩៣	២៩៥.៩៦២	៧២.៥៩៣	២៩៥.៩៦២
លម្អៀងពីការប្តូរប្រាក់	-	-	-	-	-	(៧.៩៦១.៧៩៧)	-	-	-	(៧.៩៦១.៧៩៧)
លទ្ធផលចំណេញលម្អិតផ្សេងៗសរុបក្នុងឆ្នាំ	-	-	-	-	-	(៧.៩៦១.៧៩៧)	១៣៨.៤១៤.៧៦៩	៥៦៤.៣១៧.០១៤	១៣៨.៤១៤.៧៦៩	៥៥៦.៣៥៥.២១៧
ប្រតិបត្តិការជាមួយភាគហ៊ុនិក៖										
ភាគលាភដែលបានបង់	-	-	-	-	-	-	(៣២.៧១៨.៨២៥)	(១៣៣.៣៩៤.៦៥០)	(៣២.៧១៨.៨២៥)	(១៣៣.៣៩៤.៦៥០)
ការផ្ទេរពីប្រាក់ចំណេញក្សាទុកទៅជាដើមទុនបម្រុង	-	-	-	-	៦៦.៩៤៩.៣០៥	២៧២.៩៥២.៣១៦	(៦៦.៩៤៩.៣០៥)	(២៧២.៩៥២.៣១៦)	-	-
ការបោះផ្សាយភាគហ៊ុន	៤.៣៥៤.៨៦៥	១៧.៧១៤.០១៥	១១.៧០៦.២១៥	៤៧.៧២៦.២៣៩	-	-	-	-	១៦.០៥១.០៨០	៦៥.៤៤០.២៥៤
ការផ្ទេរពីប្រាក់ចំណេញក្សាទុកទៅទុនបម្រុងតាមបទប្បញ្ញត្តិ	-	-	-	-	១៨.០៨២.៦៣៧	៧៣.៧២២.៩១១	(១៨.០៨២.៦៣៧)	(៧៣.៧២២.៩១១)	-	-
លម្អៀងពីការប្តូរប្រាក់	-	(១៣.០០៣.៥៨១)	-	(៣៧៤.៥៩៩)	-	(១១.៧២៤.២៨៤)	-	-	-	(២៥.១០២.៤៦៤)
ប្រតិបត្តិការជាមួយភាគហ៊ុនិកសរុប	៤.៣៥៤.៨៦៥	៤.៧១០.៤៣៤	១១.៧០៦.២១៥	៤៧.៣៥១.៦៤០	៨៥.០៣១.៩៤២	៣៣៤.៩៥០.៩៤៣	(១១៧.៧៥០.៧៦៧)	(៤៨០.០៦៩.៨៧៧)	(១៦.៦៦៧.៧៤៥)	(៩៣.០៥៦.៨៦០)
នាថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០២០	៤៣៣.១៦៣.០១៩	១.៧៥២.១៩៤.៩១២	១១.៧០៦.២១៥	៤៧.៣៥១.៦៤០	៥១០.៧៩១.៥៥៤	២.០៧៩.៣៥៧.៨០២	១៣៨.៤១៤.៧៦៩	៥៤៦.៤៧៩.៥២៦	១.០៩៤.០២៥.៥៥៧	៤.៤២៥.៣៣៣.៣៨០

កំណត់សម្គាល់ដូចមានភ្ជាប់ជាមួយ នៅទំព័រទី២៩ ដល់ទី២៤៥ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។

ធនាគារ អេស៊ីលីដា អ៊ីអិលស៊ី និង ក្រុមហ៊ុនបុត្រសម្ព័ន្ធ

របាយការណ៍លំហូរទឹកប្រាក់ដោយឡែក
នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ និងសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់

	កំណត់សម្គាល់	២០២១ ដុល្លារអាមេរិក	២០២០ ដុល្លារអាមេរិក	២០២១ ពាន់រៀល (កំណត់សម្គាល់ ៥)	២០២០ ពាន់រៀល (កំណត់សម្គាល់ ៥)
លំហូរសាច់ប្រាក់ពីសកម្មភាពប្រតិបត្តិការ					
ប្រាក់ចំណេញក្នុងការិយបរិច្ឆេទមុនពេលបង់ពន្ធ		២០១.៦៦២.១៨៤	១៧២.១៥៤.៣១៥	៨២០.៣៦១.៧៦៥	៧០១.៨៧៣.១៤៣
និយ័តកម្មលើ៖					
រំលស់របស់ទ្រព្យ និងបរិក្ខារ	១៤	១៨.១៥៥.២២៩	១៩.១៨១.១៥១	៧៣.៨៥៥.៤៧២	៧៨.២០១.៥៥៣
រំលស់របស់សិទ្ធិប្រើប្រាស់ទ្រព្យសកម្ម	១៦	១០.៣៨៧.៦៧៩	៩.៧៧០.៦៣៨	៤២.២៥៧.០៧៨	៣៩.៨៣៤.៨៩១
អត្ថប្រយោជន៍ប្រាក់បំណាច់អតីតភាពការងារ	២៥(គ)	៧.៨៩៦.១៥៨	៦.៣៧៨.៧៣៨	៣២.១២១.៥៧១	២៦.០០៦.១១៥
រំលស់លើទ្រព្យសកម្មអរូបី	១៥	៣.៤៧៧.៣៨២	៣.៣៣៩.៥១០	១៤.១៤៥.៩៩០	១៣.៦១៥.១៨២
ចំណាយអត្ថប្រយោជន៍ពេលចូលនិវត្ត	២៥(ក)	១.៩៥៨.៧១៥	១.៥៧៧.៦៧៧	៧.៩៦៨.០៥៣	៦.៤៣២.១៨៩
ចំណាយលើ មូលនិធិអភិវឌ្ឍន៍វិជ្ជាជីវ:	២៥(ខ)	១.៥៦១.៧៨៣	១.៣១២.៦៤១	៦.៣៥៣.៣៣៣	៥.៣៥១.៦៣៧
និយ័តកម្មលើទ្រព្យ និងបរិក្ខារ		៥៧៨.៩៤៣	១៨.៥៣៤	២.៣៥៥.១៤០	៧៥.៥៦៣
ខាតឱនភាពនៃតម្លៃសុទ្ធ	១០	(៦៣.៨១៥)	១៦.១១៥.៥៩៤	(២៥៩.៦០០)	៦៥.៧០៣.២៧៧
ចំណូលភាគលាភ	៣០	(១១៦.៦១៤)	(១៧៤.៤៧៩)	(៤៧៤.៣៨៦)	(៧១១.៣៥១)
ចំណេញពីការលក់ទ្រព្យ និងបរិក្ខារ ទ្រព្យសកម្មអរូបី និងកត្តិសន្យា	៣០	(២៥៣.៤២៦)	(៣២៦.២៩៩)	(១.០៣០.៩៣៧)	(១.៣៣០.៣២១)
និយ័តកម្មលើទ្រព្យសកម្មអរូបី		(២៥៦.៨២៨)	២៩០.២៨៤	(១.០៤៤.៧៧៦)	១.១៨៣.៤៨៨
ចំណេញពីការប្តូររូបិយប័ណ្ណមិនទាន់បានទទួលស្គាល់		(១.១០៩.៣៣៦)	(២២៧.៧៩៤)	(៤.៥១២.៧៧៩)	(៩២៨.៧១៦)
ចំណូលការប្រាក់សុទ្ធ		(៣៧៤.២៥៦.៦៩០)	(៣៣៨.៨៨៣.១៩៤)	(១.៥២២.៤៧៦.២១៤)	(១.៣៨១.៦២៦.៧៨២)
ការខាតបង់ពីប្រតិបត្តិការមុនពេលបម្រែបម្រួលមូលធន		(១៣០.៣៧៨.៦៣៦)	(១០៩.៤៧២.៦៨៤)	(៥៣០.៣៨០.២៩០)	(៤៤៦.៣២០.១៣២)
បម្រែបម្រួល៖					
ប្រាក់បញ្ញើរបស់អតិថិជន		៩៤៦.៦៥៨.២៥៣	១៩៨.១២២.១៧៨	៣.៨៥១.០០៥.៧៧៣	៨០៧.៧៤៤.១២០
ប្រាក់បញ្ញើនៅធនាគារនិងស្ថាប័នហិរញ្ញវត្ថុផ្សេងៗ		១៥៨.៨៤២.២៨១	២២.៥៨៦.៨៣៣	៦៤៦.១៧០.៣៩៩	៩១.៦៧៨.៨១៨
បំណុលផ្សេងៗ		២.០៩៦.៥២១	១១.៥៨៣.៧៥៦	៨.៥២៨.៦៤៧	៤៧.២២៦.៩៧៣
ទ្រព្យសកម្មផ្សេងៗ		(៥.០៩៧.៦៨១)	(៤.៩១០.០៧៥)	(២០.៧៣៧.៣៦៦)	(២០.០១៨.៣៧៦)
ប្រាក់បញ្ញើតាមច្បាប់		(២៩.៩៥២.៨២១)	៥២.០៤៧.៥៥៨	(១២១.៨៤៨.០៧៦)	១៧១.៤២៧.៨៩៤
ប្រាក់បញ្ញើនៅធនាគារផ្សេងៗ		(៣៣.០៧៧.៨៥២)	១៨១.៣៥៩.៣៨៧	(១៣៤.៥៦០.៧០២)	៧៣៩.៤០២.២២១
ឥណទាន និងបុរេប្រទាន		(៩៣៩.០៧០.៦២៣)	(៦២២.២៤៨.០៧៩)	(៣.៨២០.១៣៩.២៩៤)	(២.៥៣៦.៩០៥.៤១៨)
សាច់ប្រាក់សុទ្ធប្រើក្នុងប្រតិបត្តិការ		(២៩.៩៨០.៥៥៨)	(២៨១.០៣១.១២៦)	(១២១.៩៦០.៩០៩)	(១.១៤៥.៧៦៣.៩០០)
ចំណូលការប្រាក់បានទទួល		៥៣៦.០៧២.៩៩៦	៤៧៧.២៣៧.១៥៩	២.១៨០.៧៤៤.៩៤៨	១.៩៤៥.៦៩៥.៨៩៧
អត្ថប្រយោជន៍មូលនិធិអភិវឌ្ឍន៍វិជ្ជាជីវ:បានបង់	២៥(ខ)	(៥.២៧៩)	(២.០៨៥.៣១៥)	(២១.៤៧៥)	(៨.៥០១.៨២៩)
អត្ថប្រយោជន៍ពេលចូលនិវត្តបានបង់	២៥(ក)	(១១០.៣៧០)	(១៤៣.០០៩)	(៤៤៨.៩៨៥)	(៥៨៣.០២៧)
អត្ថប្រយោជន៍ប្រាក់បំណាច់អតីតភាពការងារបានបង់	២៥(គ)	(៧.៦៤៣.៥៧១)	(៦.៨១៥.២៤៨)	(៣១.០៩៤.០៤៧)	(២៧.៧៨៥.៧៦៦)
ពន្ធលើប្រាក់ចំណូលបានបង់	៣២(ក)	(២៦.៨៧៤.១០៨)	(៣៣.៧១៥.៥៦៩)	(១០៩.៣២៣.៨៧១)	(១៣៧.៤៥៤.៣៧៥)
ចំណាយការប្រាក់បានបង់		(១០៨.៩១០.៣២២)	(៩៩.៣៤៣.១៩៨)	(៤៤៣.០៤៧.១៩០)	(៤០៥.០២២.២១៨)
សាច់ប្រាក់សុទ្ធបានពីសកម្មភាពប្រតិបត្តិការ(យោងទៅមុំ ០ បន្ទាប់)		៣៦២.៥៤៨.៧៨៨	៥៤.១០៣.៦៩៩	១.៤៧៤.៨៤៨.៤៧១	២២០.៥៨០.៧៨២

ធនាគារ អេស៊ីលីដា ភីអិលស៊ី និង ក្រុមហ៊ុនបុត្រសម្ព័ន្ធ

របាយការណ៍លំហូរទឹកប្រាក់ដោយឡែក (ត)
នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ និងសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់

	កំណត់សម្គាល់	២០២១ ដុល្លារអាមេរិក	២០២០ ដុល្លារអាមេរិក	២០២១ ពាន់រៀល (កំណត់សម្គាល់ ៥)	២០២០ ពាន់រៀល (កំណត់សម្គាល់ ៥)
សាច់ប្រាក់សុទ្ធបានពីសកម្មភាពប្រតិបត្តិការ(យោងមកពីទំព័រមុន)		៣៦២.៥៤៨.៧៨៨	៥៤.១០៣.៦៩៩	១.៤៧៤.៨៤៨.៤៧១	២២០.៥៨០.៧៨២
លំហូរទឹកប្រាក់ពីសកម្មភាពវិនិយោគ					
ការប្រាក់បានមកពីការវិនិយោគ		៨៤៣.៤៦៦	១.៨៧៦.៥៥៦	៣.៤៣១.២២០	៧.៦៥០.៧១៩
សាច់ប្រាក់បានពីការលក់ទ្រព្យនិងឧបករណ៍		៧៦៣.១៣២	៣៩៨.១០៥	៣.១០៤.៤២១	១.៩១៩.២២៤
ភាគលាភបានទទួល		១១៦.៦១៤	១៧៤.៤៧៩	៤៧៤.៣៨៦	៧១១.៣៥១
សាច់ប្រាក់បានមកពីការវិនិយោគដល់កាលកំណត់		៩៣.១១១	-	៣៧៨.៧៧៦	-
ការវិនិយោគក្នុងក្រុមហ៊ុនបុត្រសម្ព័ន្ធបន្ថែម	១៣	(២.១៤៥)	២០.០០០	(៨.៧២៦)	៨១.៥៤០
សាច់ប្រាក់បានពីការលុបចោលភតិសន្យា		(៣.៤២០)	-	(១៣.៩១៣)	-
ការវិនិយោគបន្ថែម		(៣៦.១៤១)	-	(១៤៧.០២២)	-
ការទិញទ្រព្យសកម្មអរូបី	១៥	(១.២៥៧.៦២៩)	(៩.៦០៣.២៩៧)	(៥.១១៦.០៣៥)	(៣៩.១៥២.៦៤២)
ការវិនិយោគហិរញ្ញវត្ថុ		(១.៥១២.១២២)	២២.៩៤៦.៥៧៦	(៦.១៥១.៣១២)	៩៣.៥៥៣.១៩០
ការទិញទ្រព្យ និងឧបករណ៍	១៤	(៣២.២១២.៥៤១)	(១៧.០៩៣.៧៩១)	(១៣១.០៤០.៦១៧)	(៦៩.៦៩១.៣៨៦)
សាច់ប្រាក់ប្រើក្នុងសកម្មភាពវិនិយោគ		(៣៣.២០៧.៦៧៥)	(១.៣៣១.៣៧២)	(១៣៥.០៨៨.៨២២)	(៥.៥២៨.០០៤)
លំហូរសាច់ប្រាក់ពីសកម្មភាពហិរញ្ញប្បទាន					
សាច់ប្រាក់បានពីប្រាក់កម្ចី		១៧៨.១៣៦.៣៥២	១៧៥.៤៩៨.០៨១	៧២៤.៦៥៨.៦៨០	៧១៥.៥០៥.៦៧៦
សាច់ប្រាក់បានពីបំណុលបន្ទាប់បន្សំ		-	៣៥.០០០.០០០	-	១៤២.៦៩៥.០០០
សាច់ប្រាក់បានពីបុព្វលាភភាគហ៊ុន		-	១១.៧០៦.២១៥	-	៤៧.៧២៦.២៣៩
សាច់ប្រាក់បានពីការបោះផ្សាយភាគហ៊ុន	២៦	-	៤.៣៤៤.៨៦៥	-	១៧.៧១៤.០១៥
ការទូទាត់បំណុលបន្ទាប់បន្សំ		(១១.០០០.០០០)	(៧.១៤៣.៩៥៧)	(៤៤.៧៤៨.០០០)	(២៩.១២៥.៩១៣)
ការទូទាត់បំណុលភតិសន្យា	២៤	(១១.៨៧២.៣៨០)	(១០.៨៨៣.៤០៦)	(៤៨.២៩៦.៨៤២)	(៤៤.៣៧១.៦៤៦)
ចំណាយការប្រាក់បានបង់		(៤១.៨៩៤.៣៤៧)	(៤៤.២៧៧.៥១៦)	(១៧០.៤២៦.២០៤)	(១៨០.៥១៩.៤៣៣)
ការទូទាត់ភាគលាភ	២៦	(៤២.៤៩៣.២៩៣)	(៣២.៧១៨.៨២៥)	(១៧២.៨៦២.៧១៦)	(១៣៣.៣៩៤.៦៥០)
ការសងប្រាក់កម្ចី		(៩៩.៥៣៤.៥១៦)	(១៨៦.២១៣.២៩៣)	(៤០៤.៩០៦.៤១១)	(៧៥៩.១៩១.៥៩៦)
សាច់ប្រាក់សុទ្ធ ប្រើក្នុងសកម្មភាពហិរញ្ញប្បទាន		(២៨.៦៥៨.១៨៤)	(៥៤.៦៨៧.៨៣៦)	(១១៦.៥៨១.៤៩៣)	(២២២.៩៦២.៣០៨)
ការកើនឡើង(ថយចុះ)សាច់ប្រាក់ និងសាច់ប្រាក់សមមូលសុទ្ធ		៣០០.៦៨២.៩២៩	(១.៩១៥.៥០៩)	១.២២៣.១៧៨.១៥៦	(៧.៨០៩.៥៣០)
សាច់ប្រាក់ និងសាច់ប្រាក់សមមូលនៅដើមការិយបរិច្ឆេទ	៣៤	១.៤៥៧.៦៩៧.៩៣៩	១.៤៥៩.៦១៣.៤៤៨	៥.៨៩៦.៣៨៨.១៦៣	៥.៩៤៧.៩២៤.៨០១
លម្អៀងពីការប្តូរប្រាក់		-	-	៤៤.០៧៧.៣៣៧	(៤៣.៧២៧.១០៨)
សាច់ប្រាក់ និងសាច់ប្រាក់សមមូលនៅចុងការិយបរិច្ឆេទ	៣៤	១.៧៥៨.៣៨០.៨៦៨	១.៤៥៧.៦៩៧.៩៣៩	៧.១៦៣.៦៤៣.៦៥៦	៥.៨៩៦.៣៨៨.១៦៣

នៅអំឡុងការិយបរិច្ឆេទ ធនាគារបានចុះកិច្ចសន្យាជួលថ្មី និងទទួលស្គាល់សិទ្ធិប្រើប្រាស់ទ្រព្យសកម្មចំនួន ១០.៥៧១.៩០៥ ដុល្លារអាមេរិក (ឆ្នាំ២០២០៖ ៧.៤០៤.៥១៣ ដុល្លារអាមេរិក) ព្រមទាំងបំណុលភតិសន្យាដែលពាក់ព័ន្ធរបស់វា ដែលជាប្រតិបត្តិការមិនមែនសាច់ប្រាក់។

កំណត់សម្គាល់ដូចមានភ្ជាប់ជាមួយ នៅទំព័រទី២៩ ដល់ទី២៤៥ គឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។

ធនាគារ អេស៊ីលីដា ភីអិលស៊ី និង ក្រុមហ៊ុនបុត្រសម្ព័ន្ធ

កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ
នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ និងសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់

១. ព័ត៌មានទូទៅ

មុនថ្ងៃទី១ ខែធ្នូ ឆ្នាំ២០០៣ ធនាគារ អេស៊ីលីដា ភីអិលស៊ី (ហៅកាត់ថា "ធនាគារ") គឺជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ដែលបង្កើតឡើងក្រោមច្បាប់ព្រះរាជាណាចក្រកម្ពុជា ហើយធ្វើប្រតិបត្តិការជាធនាគារឯកទេសដែលមានទីស្នាក់ការកណ្តាលនៅរាជធានីភ្នំពេញ និងមានសាខាចំនួន ១៤ ក្នុងព្រះរាជាណាចក្រកម្ពុជា។ នៅថ្ងៃទី១ ខែធ្នូ ឆ្នាំ២០០៣ ធនាគារជាតិនៃកម្ពុជា បានផ្តល់អាជ្ញាប័ណ្ណដល់ធនាគារ ជាធនាគារពាណិជ្ជឯកជនសម្រាប់រយៈពេល ៣ឆ្នាំ គិតចាប់ពីថ្ងៃទី១ ខែធ្នូ ឆ្នាំ២០០៣។ នៅថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០០៦ អាជ្ញាប័ណ្ណរបស់ធនាគារត្រូវបានធ្វើជាថ្មីម្តងទៀតទៅជាអាជ្ញាប័ណ្ណអចិន្ត្រៃយ៍។ ថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០២០ ធនាគារជោគជ័យនៅក្នុងការចុះបញ្ជីនៅលើទីផ្សារមូលបត្រកម្ពុជា។

ការិយាល័យចុះបញ្ជីរបស់ធនាគារមានទីតាំងស្ថិតនៅអគារលេខ ៦១ មហាវិថីព្រះមុនីវង្ស សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

ធនាគារធ្វើប្រតិបត្តិការក្រោមការត្រួតពិនិត្យរបស់ធនាគារជាតិនៃកម្ពុជា ដោយផ្តោតជាពិសេសលើការផ្តល់ឥណទាន និងសេវាហិរញ្ញវត្ថុផ្សេងៗទៀតសម្រាប់ប្រជាពលរដ្ឋទូទៅ ក៏ដូចជាសហគ្រាសធុនតូច និងមធ្យម ព្រមទាំងសកម្មភាពអាជីវកម្មដទៃទៀត ដែលក្រុមប្រឹក្សាភិបាលជឿជាក់ថាគាំទ្រដល់គោលបំណងនេះ។

ធនាគារមានបុត្រសម្ព័ន្ធចំនួន៤ (ដែលហៅថា "សម្ព័ន្ធធនាគារ") ដែលធ្វើប្រតិបត្តិការនៅសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ នៅសាធារណរដ្ឋសហភាពមីយ៉ាន់ម៉ា និងនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ សកម្មភាពចម្បងៗរបស់ក្រុមហ៊ុនបុត្រសម្ព័ន្ធ ត្រូវបានលាតត្រដាងនៅក្នុងកំណត់សម្គាល់ ១៣ លើរបាយការណ៍ហិរញ្ញវត្ថុ។ បច្ចុប្បន្នសម្ព័ន្ធធនាគារមានសាខាចំនួន ២៦២ ទូទាំងខេត្តក្រុងនៅក្នុងព្រះរាជាណាចក្រកម្ពុជា ៣៨សាខានៅសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ និង១៧សាខា នៅសាធារណរដ្ឋសហភាពមីយ៉ាន់ម៉ា។

នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ សម្ព័ន្ធធនាគារ និងធនាគារ មានបុគ្គលិកចំនួន ១៣.៦៧៤ នាក់ និង ១២.០៨១ នាក់ (ឆ្នាំ២០២០៖ ១៣.៧០៤ នាក់ និង ១២.០១៣ នាក់)។

២. សេចក្តីសង្ខេបអំពីគោលនយោបាយគណនេយ្យសំខាន់ៗ

គោលនយោបាយគណនេយ្យសំខាន់ៗខាងក្រោមនេះ ត្រូវបានអនុវត្តដោយសម្ព័ន្ធធនាគារ និងធនាគារ ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនេះ។ គោលនយោបាយទាំងអស់នេះ ត្រូវបានយកមកអនុវត្តប្រកបដោយសង្គតិភាពនៅគ្រប់ឆ្នាំ លើកលែងតែមានការបញ្ជាក់បន្ថែម។

(ក) មូលដ្ឋាននៃការរៀបចំ និងបង្ហាញ

របាយការណ៍ហិរញ្ញវត្ថុរបស់សម្ព័ន្ធធនាគារ និងធនាគារ ត្រូវបានរៀបចំឡើងដោយអនុលោមទៅតាមស្តង់ដារ របាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ហៅកាត់ថា ("ស.រ.ទ.ហ.អ.ក")។ របាយការណ៍ហិរញ្ញវត្ថុរួម និងដោយឡែក ត្រូវបានរៀបចំឡើងទៅតាមមូលដ្ឋានថ្លៃដើមលើកលែងតែធាតុមួយចំនួនដែលមិនត្រូវបានរៀបចំឡើងទៅតាមមូលដ្ឋានថ្លៃដើមមានដូចជា៖

ធនាគារ អេស៊ីលីដា ភីអិលស៊ី និង ក្រុមហ៊ុនបុត្រសម្ព័ន្ធ

កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ
នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ និងសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់

២. សេចក្តីសង្ខេបអំពីគោលនយោបាយគណនេយ្យសំខាន់ៗ (ត)

(ក) មូលដ្ឋាននៃការរៀបចំ (ត)

- ឧបករណ៍ហិរញ្ញវត្ថុតាមរំលស់ថ្លៃដើម
- ឧបករណ៍ហិរញ្ញវត្ថុ រួមញ្ចូលទាំងនិស្សន្ទស៍ដែលបានកំណត់តម្លៃតាមតម្លៃសមស្រប
- បានកំណត់ជាទ្រព្យសកម្មដែលមានអត្ថប្រយោជន៍ ឬកាតព្វកិច្ច
- សំវិធានធនដែលបានវាស់វែង តាមការចំណាយដែលបានប៉ាន់ស្មានល្អបំផុត ដែលតម្រូវឱ្យទូទាត់នូវកាតព្វកិច្ចបច្ចុប្បន្នជាមួយការធ្វើអប្បហាប្រសិនបើមានផលប៉ះពាល់ជាសារវន្តទៅលើតម្លៃនៃសាច់ប្រាក់។

ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ អនុលោមទៅតាម ស.រ.ទ.ហ.អ.ក តម្រូវឱ្យប្រើប្រាស់ការប៉ាន់ស្មានគណនេយ្យសំខាន់ៗ។ វាក៏តម្រូវឱ្យក្រុមប្រឹក្សាភិបាលធ្វើការវិនិច្ឆ័យក្នុងដំណើរការអនុវត្តគោលនយោបាយគណនេយ្យរបស់សម្ព័ន្ធធនាគារ និងធនាគារ។ ផ្នែកពាក់ព័ន្ធនឹងការវិនិច្ឆ័យ ឬភាពស្មុគស្មាញដែលមានកម្រិតខ្ពស់ ឬផ្នែកដែលមានការសន្មត និងការប៉ាន់ស្មានជាសារវន្តចំពោះរបាយការណ៍ហិរញ្ញវត្ថុត្រូវបានបង្ហាញនៅក្នុងកំណត់សម្គាល់ ៤។

អ្នកគ្រប់គ្រងលាតត្រដាងរបាយការណ៍ហិរញ្ញវត្ថុដោយផ្អែកលើសន្ទនីយភាព។ ព័ត៌មានអំពីទ្រព្យសកម្មរយៈពេលខ្លី និងវែង និងបំណុលរយៈពេលខ្លី និងវែងបានលាតត្រដាងនៅក្នុងផ្នែកការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុនៅក្នុងកំណត់សម្គាល់ ៣៨។ ទ្រព្យសកម្ម និងបំណុលដែលលើស១២ខែ គឺត្រូវចាត់ទុកជាទ្រព្យសកម្មរយៈពេលវែង និងបំណុលរយៈពេលវែង។

(ខ) ការប្រើប្រាស់ស្តង់ដារថ្មី និងស្តង់ដារគណនេយ្យដែលបានកែសម្រួល

(i) ស្តង់ដារថ្មី និងស្តង់ដារគណនេយ្យដែលបានកែសម្រួលដែលចូលជាធរមាននៅក្នុងអំឡុងការិយបរិច្ឆេទ

សម្ព័ន្ធធនាគារ និងធនាគារបានប្រើប្រាស់ស្តង់ដារថ្មី និងស្តង់ដារគណនេយ្យដែលបានកែសម្រួលទាំងអស់នាថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០២១។ ស្តង់ដារថ្មី និងស្តង់ដារគណនេយ្យដែលបានកែសម្រួល និងសេចក្តីបកស្រាយដែលទាក់ទងទៅនឹងរបាយការណ៍ហិរញ្ញវត្ថុរបស់សម្ព័ន្ធធនាគារ និងធនាគារមានដូចជា៖

- សម្បទានការជួលទាក់ទងនឹងជម្ងឺកូវីដ-១៩ បន្ទាប់ពីថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០២១ (វិសោធនកម្មលើ ស.រ.ហ.អ.ក ១៦ ភតិសន្យា)

  អ្នកគ្រប់គ្រងបានធ្វើការគណនាលើការប្រើប្រាស់ស្តង់ដារថ្មីខាងក្រោម គឺមិនមានការប៉ះពាល់ជាសារវន្តទៅលើរបាយការណ៍ហិរញ្ញវត្ថុរបស់សម្ព័ន្ធធនាគារ និងធនាគារឡើយ។

- កំណែទម្រង់អត្រាការប្រាក់ - ដំណាក់កាលទី ២ (វិសោធនកម្ម "ស.រ.ហ.អ.ក ៩" ឧបករណ៍ហិរញ្ញវត្ថុ "ស.គ.អ.ក ៣៩" ឧបករណ៍ហិរញ្ញវត្ថុ "ស.រ.ហ.អ.ក ៧" ឧបករណ៍ហិរញ្ញវត្ថុ "ស.រ.ហ.អ.ក ៥" កិច្ចសន្យាធានារ៉ាប់រង និង "ស.រ.ហ.អ.ក ១៦"): ត្រូវបានវាយតម្លៃថាមិនត្រូវបានយកមកអនុវត្តនៅក្នុងសម្ព័ន្ធធនាគារ និងធនាគារ។

ធនាគារ អេស៊ីលីដា ភីអិលស៊ី និង ក្រុមហ៊ុនបុត្រសម្ព័ន្ធ

កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ និងសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់

២. សេចក្តីសង្ខេបអំពីគោលនយោបាយគណនេយ្យសំខាន់ៗ (ត)

(ខ) ការប្រើប្រាស់ស្តង់ដារថ្មី និងស្តង់ដារគណនេយ្យដែលបានកែសម្រួល (ត)

(i) **ស្តង់ដារថ្មី និងស្តង់ដារគណនេយ្យដែលបានកែសម្រួលដែលចូលជាធរមាននៅក្នុងអំឡុងការិយបរិច្ឆេទ(ត)**

- ការពន្យាពេលលើការលើកលែងជាបណ្តោះអាសន្នក្នុងការអនុវត្តលើស្តង់ដារ ស.រ.ហ.អ.ក ៩ (វិសោធនកម្មលើ ស.រ.ហ.អ.ក ៤)

(ii) **ស្តង់ដារថ្មី និងស្តង់ដារគណនេយ្យដែលបានកែសម្រួលដែលមិនទាន់ចូលជាធរមាន**

នៅថ្ងៃអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុនេះ មានស្តង់ដារថ្មី និងស្តង់ដារគណនេយ្យដែលបានកែសម្រួលបានចេញផ្សាយប៉ុន្តែមិនទាន់ចូលជាធរមាន ហើយមិនត្រូវមានសម្រាប់សម្ព័ន្ធធនាគារ និងធនាគារមានដូចខាងក្រោម៖

- ស.រ.ហ.អ.ក ១៧ កិច្ចសន្យាធានារ៉ាប់រង
- ឯកសារយោងចំពោះក្របខណ្ឌទស្សនទាន (វិសោធនកម្មលើ ស.រ.ហ.អ.ក ៣ ការរួមបញ្ចូលអាជីវកម្ម)
- ចំណាត់ថ្នាក់បំណុលរយៈពេលខ្លី ឬរយៈពេលវែង ពន្យារពេលចូលជាធរមាន (វិសោធនកម្មលើ ស.គ.អ.ក ១ ការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុ)
- ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ ចំណូលពីការលក់មុនពេលប្រើប្រាស់(វិសោធនកម្មលើ ស.គ.អ.ក១៦ ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ)
- កិច្ចសន្យាស្មុគស្មាញ ថ្លៃដើម្បីបំពេញកិច្ចសន្យា(វិសោធនកម្មលើ ស.គ.អ.ក៣៧ សំវិធានធន បំណុលយថាហេតុ និងទ្រព្យសកម្មយថាហេតុ)
- ការកែលម្អប្រចាំឆ្នាំលើស្តង់ដារ ស.រ.ហ.អ.ក ២០១៨ - ២០២០
- ការលាតត្រដាងគោលនយោបាយគណនេយ្យ (វិសោធនកម្មលើ ស.គ.អ.ក ១ និងការអនុវត្តរបាយការណ៍ ស.រ.ហ.អ.ក ២)
- និយមន័យនៃការប៉ាន់ស្មានគណនេយ្យ (វិសោធនកម្មលើ ស.គ.អ.ក ៨ គោលការណ៍គណនេយ្យ បម្រែបម្រួលការប៉ាន់ស្មានគណនេយ្យ និងកំហុសឆ្គង)
- ពន្ធពន្យារទាក់ទងនឹងទ្រព្យសកម្ម និងបំណុលដែលកើតឡើងពីប្រតិបត្តិការឯកតោភាគី (វិសោធនកម្មលើ ស.គ.អ.ក១២ ពន្ធលើប្រាក់ចំណេញ)
- អនុវត្តលើកដំបូងនៃ ស.រ.ហ.អ.ក ១៧ និង ស.រ.ហ.អ.ក ៩-ព័ត៌មានប្រៀបធៀប (វិសោធនកម្មលើ ស.រ.ហ.អ.ក ១៧)

អ្នកគ្រប់គ្រងបានសន្មតថាការមិនប្រើប្រាស់ស្តង់ដារថ្មីរៀបរាប់ខាងលើទាំងនេះ នឹងមិនមានការប៉ះពាល់ជាសារវន្ត សម្រាប់របាយការណ៍ហិរញ្ញវត្ថុរបស់សម្ព័ន្ធធនាគារ និងធនាគារនៅពេលខាងមុខឡើយ។

ធនាគារ អេស៊ីលីដា អ៊ីអិលស៊ី និង ក្រុមហ៊ុនបុត្រសម្ព័ន្ធ

កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ និងសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់

២. សេចក្តីសង្ខេបអំពីគោលនយោបាយគណនេយ្យសំខាន់ៗ (ត)

(ค) របាយការណ៍ហិរញ្ញវត្ថុរួម

(i) ក្រុមហ៊ុនបុត្រសម្ព័ន្ធ

ក្រុមហ៊ុនបុត្រសម្ព័ន្ធ គឺជាក្រុមហ៊ុនទាំងឡាយណាដែលសម្ព័ន្ធមានអភិបាលភាព។ សម្ព័ន្ធអភិបាលក្រុមហ៊ុនមួយនៅពេលដែលសម្ព័ន្ធប្រឈម ឬមានសិទ្ធិចំពោះផលអថេរពីការវិនិយោគជាមួយក្រុមហ៊ុន និងមានឥទ្ធិពលទៅលើផលទាំងនោះតាមរយៈសិទ្ធិអំណាចរបស់ខ្លួនក្នុងការដឹកនាំសកម្មភាពដែលពាក់ព័ន្ធរបស់ក្រុមហ៊ុន។

របាយការណ៍ហិរញ្ញវត្ថុរួម គឺរួមបញ្ចូលនូវរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ និង ក្រុមហ៊ុនបុត្រសម្ព័ន្ធទាំងអស់ ដែលបានរៀបចំក្នុងឆ្នាំហិរញ្ញវត្ថុនេះ។

ក្រុមហ៊ុនបុត្រសម្ព័ន្ធ ត្រូវបានរួមបញ្ចូលគ្នាចាប់ពីកាលបរិច្ឆេទដែលអភិបាលភាពត្រូវបានផ្ទេរទៅឱ្យសម្ព័ន្ធធនាគារ និងបញ្ឈប់ការរួមបញ្ចូលគ្នាចាប់ពីកាលបរិច្ឆេទដែលអភិបាលភាពបានបញ្ចប់។

រាល់ប្រតិបត្តិការ និងសមតុល្យជាសារវន្តរវាងសម្ព័ន្ធធនាគារត្រូវបានលុបចោល ហើយរបាយការណ៍ហិរញ្ញវត្ថុរួម ឆ្លុះបញ្ចាំងតែប្រតិបត្តិការខាងក្រៅតែប៉ុណ្ណោះ។ នៅពេលចាំបាច់ គោលនយោបាយគណនេយ្យរបស់ក្រុមហ៊ុនបុត្រសម្ព័ន្ធ ត្រូវបានផ្លាស់ប្តូរដើម្បីធានាឱ្យបាននូវសង្គតិភាពជាមួយនឹងគោលនយោបាយដែលអនុវត្តដោយសម្ព័ន្ធ។

(ii) ការផ្លាស់ប្តូរអត្ថប្រយោជន៍ភាគហ៊ុនិកក្នុងក្រុមហ៊ុនបុត្រសម្ព័ន្ធ ដោយមិនផ្លាស់ប្តូរអភិបាលភាព

ប្រតិបត្តិការជាមួយភាគកម្មមិនមានអភិបាលភាព ដែលមិនធ្វើឱ្យមានការបាត់បង់អភិបាលភាពត្រូវបានកត់ត្រាជាប្រតិបត្តិការមូលធន ដូចប្រតិបត្តិការជាមួយម្ចាស់ក្រុមហ៊ុនក្នុងនាមជាម្ចាស់ដែរ។ ករណីមានការទិញពីភាគកម្មមិនមានអភិបាលភាព លម្អៀងរវាង តម្លៃតបស្នងដែលបានបង់ និងចំណែកពាក់ព័ន្ធនៃតម្លៃយោងទ្រព្យសកម្មសុទ្ធរបស់ក្រុមហ៊ុនបុត្រសម្ព័ន្ធដែលបានទិញ ត្រូវបានកត់ត្រាដកចេញពីមូលធន។ ករណីមានការលក់ភាគកម្មមិនមានអភិបាលភាព លម្អៀងរវាង តម្លៃតបស្នងដែលបានទទួល និងចំណែកពាក់ព័ន្ធនៃតម្លៃយោងទ្រព្យសកម្មសុទ្ធរបស់ក្រុមហ៊ុនបុត្រសម្ព័ន្ធដែលបានលក់ក៏ត្រូវកត់ត្រាក្នុងមូលធនដែរ។

(iii) ការលក់នៃក្រុមហ៊ុនបុត្រសម្ព័ន្ធ

នៅពេលដែលសម្ព័ន្ធលែងមានអភិបាលភាព អត្ថប្រយោជន៍ដែលមាននៅក្នុងក្រុមហ៊ុនត្រូវបានវាស់វែងឡើងវិញទៅតាមតម្លៃសមស្រប នៅកាលបរិច្ឆេទដែលអភិបាលភាពបានបាត់បង់ ជាមួយនឹងការផ្លាស់ប្តូរនៃតម្លៃ ដែលត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ចំណេញ ឬខាត។ តម្លៃសមស្របគឺជាតម្លៃយោងដំបូងសម្រាប់គោលបំណងគណនេយ្យជាបន្តបន្ទាប់ សម្រាប់អត្ថប្រយោជន៍ដែលត្រូវទទួលបានទុកជាសមាគត ការដាក់ទុនរួមគ្នា ឬទ្រព្យសកម្មហិរញ្ញវត្ថុ។

ធនាគារ អេស៊ីលីដា ភីអិលស៊ី និង ក្រុមហ៊ុនបុត្រសម្ព័ន្ធ

កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ និងសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់

២. សេចក្តីសង្ខេបអំពីគោលនយោបាយគណនេយ្យសំខាន់ៗ (ត)

(គ) របាយការណ៍ហិរញ្ញវត្ថុរួម (ត)

(iii) ការលក់នៃក្រុមហ៊ុនបុត្រសម្ព័ន្ធ (ត)

លើសពីនេះទៀត ចំនួនទឹកប្រាក់ដែលត្រូវបានទទួលស្គាល់នៅគ្រាមុននៅក្នុងលទ្ធផលលម្អិតផ្សេងៗទាក់ទងនឹងអង្គភាពនោះ ត្រូវកត់ត្រាដូចករណីដែលសម្ព័ន្ធបានលក់ដោយផ្ទាល់នៃទ្រព្យសកម្ម ឬសងបំណុលដែលពាក់ព័ន្ធ។ វាអាចមានន័យថា ចំនួនដែលបានទទួលនៅគ្រាមុននៅក្នុងលទ្ធផលលម្អិតផ្សេងៗ ត្រូវបានចាត់ថ្នាក់ឡើងវិញទៅរបាយការណ៍ប្រាក់ចំណេញ ឬខាត។

(iv) ការវិនិយោគក្នុងក្រុមហ៊ុនបុត្រសម្ព័ន្ធ

ការវិនិយោគក្នុងក្រុមហ៊ុនបុត្រសម្ព័ន្ធ ត្រូវបានរាយការណ៍តាមថ្លៃដើម ដកការខាតបង់ឱនភាពនៃតម្លៃបង្គរនៅក្នុងរបាយការណ៍ដោយឡែករបស់ធនាគារ។ នៅពេលលក់ការវិនិយោគនោះចេញវិញ តម្លៃលម្អៀងរវាងតម្លៃតបស្នងដែលបានមកពីការលក់ និងតម្លៃយោងរបស់វា ត្រូវបានកត់ត្រានៅក្នុងរបាយការណ៍ចំណេញឬខាត និង លទ្ធផលលម្អិតផ្សេងៗ ។

ចំនួនទឹកប្រាក់ដែលត្រូវទទួលបានពីក្រុមហ៊ុនបុត្រសម្ព័ន្ធ ដែលធនាគារមិនរំពឹងថានឹងសងត្រឡប់មកវិញនាពេលអនាគត ត្រូវបានចាត់ទុកជាផ្នែកមួយនៃការវិនិយោគរបស់ធនាគារនៅក្នុងក្រុមហ៊ុនបុត្រសម្ព័ន្ធ។

(ឃ) ការប្រែសម្រួលរូបិយប័ណ្ណបរទេស

(i) រូបិយប័ណ្ណមុខងារ និងរូបិយប័ណ្ណសម្រាប់ការបង្ហាញ

ធាតុនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុននៃសម្ព័ន្ធ ត្រូវបានវាស់វែងដោយប្រើប្រាស់រូបិយប័ណ្ណនៃបរិស្ថានសេដ្ឋកិច្ចសំខាន់ដែលក្រុមហ៊ុនប្រើនៅក្នុងកិច្ចប្រតិបត្តិការ (“រូបិយប័ណ្ណមុខងារ”)។ របាយការណ៍ហិរញ្ញវត្ថុ ត្រូវបានបង្ហាញជាប្រាក់ដុល្លារអាមេរិក ដែលជារូបិយប័ណ្ណមុខងារ និងជារូបិយប័ណ្ណសម្រាប់ការបង្ហាញរបស់ សម្ព័ន្ធ ធនាគារ និងធនាគារ។

(ii) ប្រតិបត្តិការ និងសមតុល្យ

ប្រតិបត្តិការជារូបិយប័ណ្ណផ្សេងៗក្រៅពីប្រាក់ដុល្លារអាមេរិក ត្រូវបានប្រែសម្រួលទៅជារូបិយប័ណ្ណមុខងារតាមអត្រាប្តូរប្រាក់ នាកាលបរិច្ឆេទនៃប្រតិបត្តិការនោះ។ ចំណេញ និងខាតពីការប្តូររូបិយប័ណ្ណបរទេសដែលកើតមកពីការទូទាត់នៃប្រតិបត្តិការទាំងនេះ និងពីការប្រែសម្រួលអត្រាប្តូរប្រាក់ នៅចុងការិយបរិច្ឆេទរបស់ទ្រព្យសកម្ម និងបំណុលរូបិយវត្ថុនានា ដែលកំណត់ជារូបិយប័ណ្ណផ្សេងៗ ក្រៅពីប្រាក់ដុល្លារអាមេរិក ត្រូវបានកត់ត្រានៅក្នុងរបាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗ។

ធនាគារ អេស៊ីលីដា ភីអិលស៊ី និង ក្រុមហ៊ុនបុត្រសម្ព័ន្ធ

កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ និងសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់

២. សេចក្តីសង្ខេបនៃគោលនយោបាយគណនេយ្យសំខាន់ៗ (ត)

(ឃ) ការប្រែសម្រួលរូបិយប័ណ្ណបរទេស (ត)

(iii) សម្ព័ន្ធធនាគារ

របាយការណ៍លទ្ធផល និងស្ថានភាពហិរញ្ញវត្ថុនៃកិច្ចប្រតិបត្តិការក្រៅប្រទេស (ដែលមិនមានរូបិយប័ណ្ណនៃសេដ្ឋកិច្ចដែលមានអតិផរណាខ្ពស់ហួសហេតុ) ដែលមានរូបិយប័ណ្ណមុខងារខុសគ្នាពីរូបិយប័ណ្ណសម្រាប់ការបង្ហាញរបស់ធនាគារ ត្រូវបានប្រែសម្រួលទៅជារូបិយប័ណ្ណសម្រាប់ការបង្ហាញ ដូចខាងក្រោម៖

ក) ទ្រព្យសកម្ម និងបំណុល សម្រាប់របាយការណ៍ស្ថានភាពហិរញ្ញវត្ថុនីមួយៗ ដែលបានបង្ហាញ ត្រូវបានប្រែសម្រួលតាមអត្រាបិទបញ្ជីនៅចុងការិយបរិច្ឆេទនៃរបាយការណ៍។

ខ) ប្រាក់ចំណូលនិងចំណាយ សម្រាប់ការរាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗនីមួយៗ ត្រូវបានប្រែសម្រួលតាមអត្រាប្តូរប្រាក់ជាមធ្យម (លើកលែងតែអត្រាមធ្យមនេះមិនមែនជាភាពប្រហាក់ប្រហែលសមហេតុផលនៃផលប៉ះពាល់បង្គរបស់អត្រានៅកាលបរិច្ឆេទប្រតិបត្តិការ ក្នុងករណីដែលចំណូលនិងចំណាយត្រូវបានប្រែសម្រួលតាមអត្រានៅកាលបរិច្ឆេទនៃប្រតិបត្តិការនេះ) និង

គ) រាល់ភាពខុសគ្នានៃលម្អៀងពីការប្តូររូបិយប័ណ្ណ ត្រូវបានទទួលស្គាល់ជាសមាសធាតុដាច់ដោយឡែកនៃមូលធន។

លម្អៀងពីការប្តូររូបិយប័ណ្ណដែលកើតឡើងពីការប្រែសម្រួលនៃការវិនិយោគសុទ្ធ នៅក្នុងកិច្ចប្រតិបត្តិការបរទេសណាមួយ ត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍លទ្ធផលលម្អិតផ្សេងៗ នៅក្នុងមូលដ្ឋាននៃការរួមបញ្ចូលគ្នា។ នៅពេលកិច្ចប្រតិបត្តិការបរទេស ត្រូវបានលក់ដោយផ្នែក លម្អៀងពីការប្តូររូបិយប័ណ្ណ ត្រូវបានចាត់ថ្នាក់ឡើងវិញទៅរបាយការណ៍ចំណេញ ឬខាត និងលទ្ធផល លម្អិតផ្សេងៗរួមដែលជាផ្នែកមួយនៃចំណេញ ឬខាតពីការលក់។

(ង) ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ

(i) ការទទួលស្គាល់ និងការវាស់វែងលើកដំបូង

សម្ព័ន្ធធនាគារ និងធនាគារទទួលស្គាល់លើកដំបូងនូវឥណទាននិងបុរេប្រទាន ប្រាក់បញ្ញើ ប្រាក់កម្ចី និងបំណុលបន្ទាប់បន្សំ នៅកាលបរិច្ឆេទដែលកើតមាន។ ឧបករណ៍ហិរញ្ញវត្ថុផ្សេងទៀត (រួមមានការទិញ និងលក់ទ្រព្យសកម្មហិរញ្ញវត្ថុជាប្រចាំ) ត្រូវបានទទួលស្គាល់នៅកាលបរិច្ឆេទជួញដូរ ដែលសម្ព័ន្ធធនាគារ និងធនាគារក្លាយជាភាគីនៃកិច្ចសន្យារបស់របស់ឧបករណ៍។

ធនាគារ អេស៊ីលីដា ភីអិលស៊ី និង ក្រុមហ៊ុនបុត្រសម្ព័ន្ធ

កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ និងសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់

២. សេចក្តីសង្ខេបនៃគោលនយោបាយគណនេយ្យសំខាន់ៗ (ត)

(ង) ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (ត)

(i) ការទទួលស្គាល់ និងការវាស់វែងលើកដំបូង (ត)

ទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ ត្រូវបានវាស់វែងលើកដំបូងតាមតម្លៃសមស្រប បូកនឹង (សម្រាប់ឧបករណ៍ដែលមិនមែនវាស់វែងតាមតម្លៃសមស្របតាមរយៈចំណេញ ឬខាត ("FVTPL") ចំណាយប្រតិបត្តិការដែលកើតមកពីការទិញ ឬចេញផ្សាយទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ។

(ii) ការធ្វើចំណាត់ថ្នាក់

នៅក្នុងការទទួលស្គាល់លើកដំបូង ទ្រព្យសកម្មហិរញ្ញវត្ថុ ត្រូវបានចាត់ថ្នាក់ជា: តម្លៃដកវិលស់តម្លៃសមស្របតាមរយៈលទ្ធផលលម្អិតផ្សេងៗ ("FVOCI") ឬតម្លៃសមស្របតាមរយៈចំណេញ ឬខាត ("FVTPL")។

ទ្រព្យសកម្មហិរញ្ញវត្ថុ ត្រូវបានវាស់វែងតាមតម្លៃដកវិលស់ ប្រសិនបើវាបំពេញតាមលក្ខខណ្ឌទាំងពីរដូចខាងក្រោម ហើយមិនត្រូវបានកំណត់ជា FVTPL នោះទេ៖

- ទ្រព្យសកម្មដែលមាននៅក្នុងម៉ូដែលអាជីវកម្ម ក្នុងគោលបំណងរក្សាទុកដើម្បីការប្រមូលសាច់ប្រាក់តាមកិច្ចសន្យា និង
- លក្ខខណ្ឌនៃកិច្ចសន្យារបស់ទ្រព្យសកម្មហិរញ្ញវត្ថុ ផ្តល់នូវកាលបរិច្ឆេទជាក់លាក់ចំពោះលំហូរសាច់ប្រាក់ដែលជាត្រូវទូទាត់តែប្រាក់ដើម និងការប្រាក់ តាមបរិមាណប្រាក់ដើមនៅជំពាក់ ("SPPI")។

ឧបករណ៍បំណុល ត្រូវបានវាស់វែងតាម FVOCI លុះត្រាតែវាបានបំពេញតាមលក្ខខណ្ឌទាំងពីរដូចខាងក្រោម ហើយមិនត្រូវបានកំណត់ជា FVTPL នោះទេ៖

- ទ្រព្យសកម្មដែលមាននៅក្នុងម៉ូដែលអាជីវកម្ម ក្នុងគោលបំណងរក្សាទុកដើម្បីការប្រមូលសាច់ប្រាក់តាមកិច្ចសន្យា និងការលក់ទ្រព្យសកម្មហិរញ្ញវត្ថុ និង
- លក្ខខណ្ឌនៃកិច្ចសន្យារបស់ទ្រព្យសកម្មហិរញ្ញវត្ថុ ផ្តល់នូវកាលបរិច្ឆេទជាក់លាក់ចំពោះលំហូរសាច់ប្រាក់ដែលជា SPPI។

សម្រាប់ការទទួលស្គាល់ការវិនិយោគលើមូលធនលើកដំបូង ដែលមិនត្រូវបានកាន់កាប់សម្រាប់ជួញដូរ សម្ព័ន្ធធនាគារ និងធនាគារ ត្រូវអាចជ្រើសរើសជាស្ថាពរដើម្បីបង្ហាញការប្រែប្រួលតម្លៃសមស្របនៅគ្រាបន្ទាប់ក្នុងលទ្ធផលលម្អិតផ្សេងៗ។ ការជ្រើសរើសនេះធ្វើឡើងដោយផ្អែកមូលដ្ឋានតាមការវិនិយោគនីមួយៗ។

២. សេចក្តីសង្ខេបនៃគោលនយោបាយគណនេយ្យសំខាន់ៗ (ត)

(ង) ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (ត)

(ii) ការធ្វើចំណាត់ថ្នាក់ (ត)

ទ្រព្យសកម្មហិរញ្ញវត្ថុទាំងអស់ផ្សេងទៀតដែលត្រូវបានចាត់ថ្នាក់តាមការវាស់វែងតាម FVTPL

លើសពីនេះ សម្រាប់ការទទួលស្គាល់លើកដំបូង សម្ព័ន្ធធនាគារ និងធនាគារអាចនឹងកំណត់ជាស្ថាពរនូវទ្រព្យសកម្មហិរញ្ញវត្ថុ វាស់វែងតាម FVTPL ប្រសិនមិនបំពេញតាមលក្ខខណ្ឌក្នុងការវាស់វែងតាមតម្លៃដកវិលស់ ឬតាម FVOCI ប្រសិនបើអនុវត្តដូច្នេះត្រូវលុបបំបាត់ឬកាត់បន្ថយជាសារវន្តនូវភាពមិនស៊ីគ្នានៃគណនេយ្យដែលនឹងកើតឡើង។

ការវាយតម្លៃម៉ូដែលអាជីវកម្ម

សម្ព័ន្ធធនាគារ និងធនាគារ ធ្វើការវាយតម្លៃអំពីគោលបំណងនៃម៉ូដែលអាជីវកម្ម ដែលទ្រព្យសកម្មមួយត្រូវបានកាន់កាប់ក្នុងកម្រិតសម្គាធហ្វាស៊ីលីធីមួយ ព្រោះវាឆ្លុះបញ្ចាំងបានល្អបំផុតអំពីមធ្យោបាយដែលអាជីវកម្មត្រូវបានគ្រប់គ្រង និងព័ត៌មាន ដែលបានផ្តល់ជូនអ្នកគ្រប់គ្រង។ ព័ត៌មានទាំងនោះរួមមាន៖

- គោលនយោបាយ និងគោលបំណងដែលបានចែងសម្រាប់សម្គាធហ្វាស៊ីលីធី និងការអនុវត្តជាក់ស្តែងនូវគោលនយោបាយទាំងនោះ។ ជាពិសេសថាតើយុទ្ធសាស្ត្ររបស់អ្នកគ្រប់គ្រង ផ្តោតលើការស្វែងរកចំណូលការប្រាក់តាមកិច្ចសន្យា រក្សានូវទម្រង់អត្រាការប្រាក់ជាក់លាក់មួយ ធ្វើឱ្យស៊ីសង្វាក់គ្នារវាងរយៈពេលនៃទ្រព្យសកម្មហិរញ្ញវត្ថុ ទៅនឹងរយៈពេលនៃបំណុល ដែលជាហិរញ្ញប្បទានរបស់ទ្រព្យសកម្មទាំងនោះ ឬការធ្វើឱ្យមានលំហូរសាច់ប្រាក់តាមរយៈការលក់ទ្រព្យសកម្ម
- វិធីក្នុងការវាយតម្លៃលទ្ធផលនៃសម្គាធហ្វាស៊ីលីធី និងវិធីរាយការណ៍ទៅអ្នកគ្រប់គ្រងរបស់សម្ព័ន្ធធនាគារ និងធនាគារ
- ហានិភ័យដែលជះឥទ្ធិពលដល់លទ្ធផលនៃម៉ូដែលអាជីវកម្ម (និងទ្រព្យសកម្មហិរញ្ញវត្ថុដែលមាននៅក្នុងម៉ូដែលអាជីវកម្មនោះ) និងយុទ្ធសាស្ត្រសម្រាប់គ្រប់គ្រងហានិភ័យទាំងនោះ
- របៀបដែលអ្នកគ្រប់គ្រងអាជីវកម្មទទួលបានការទូទាត់ (ឧទាហរណ៍៖ តើការទូទាត់ផ្អែកលើតម្លៃសមស្របនៃទ្រព្យសកម្មដែលបានគ្រប់គ្រង ឬសាច់ប្រាក់តាមកិច្ចសន្យាដែលបានប្រមូល) និង
- ភាពញឹកញាប់ បរិមាណនិងរយៈពេលនៃការលក់ក្នុងគ្រាមុន មូលហេតុនៃការលក់ទាំងនោះ និងការរំពឹងទុកអំពីសកម្មភាពនៃការលក់នាពេលអនាគត។ ទោះជាយ៉ាងណាក៏ដោយ ព័ត៌មានអំពីសកម្មភាពនៃការ

ធនាគារ អេស៊ីលីដា ភីអិលស៊ី និង ក្រុមហ៊ុនបុត្រសម្ព័ន្ធ

កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ និងសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់

២. សេចក្តីសង្ខេបនៃគោលនយោបាយគណនេយ្យសំខាន់ៗ (ត)

(ង) ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (ត)

(ii) ការធ្វើចំណាត់ថ្នាក់ (ត)

ការវាយតម្លៃម៉ូដែលអាជីវកម្ម (ត)

លក់មិនត្រូវបានយកមកពិចារណាដាច់ដោយឡែកឡើយ ប៉ុន្តែជាផ្នែកមួយនៃការវាយតម្លៃទាំងមូលនៃវិធីសាស្ត្រដែលសម្ព័ន្ធធនាគារ និងធនាគារ បានចែងអំពីគោលបំណងសម្រាប់សម្រេចបានការគ្រប់គ្រងទ្រព្យសកម្មហិរញ្ញវត្ថុ និងវិធីសាស្ត្រក្នុងការទទួលបានលំហូរសាច់ប្រាក់។

ទ្រព្យសកម្មហិរញ្ញវត្ថុដែលទុកសម្រាប់ការជួញដូរ ឬចាត់ចែង ហើយដែលលទ្ធផលរបស់ទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានវាយតម្លៃតាមមូលដ្ឋានតម្លៃសមស្រប ត្រូវបានវាស់វែងតាម FVTPL ព្រោះទ្រព្យសកម្មទាំងនោះមិនមែនទុកសម្រាប់ប្រមូលសាច់ប្រាក់តាមកិច្ចសន្យា ឬមិនមែនទុកសម្រាប់ទាំងការប្រមូលសាច់ប្រាក់តាមកិច្ចសន្យានិងសម្រាប់លក់ឡើយ។

ការវាយតម្លៃថាតើលំហូរសាច់ប្រាក់តាមកិច្ចសន្យាជាការទូទាត់តែប្រាក់ដើម និងការប្រាក់

ចំពោះគោលបំណងនៃការវាយតម្លៃនេះ "ប្រាក់ដើម" គឺជាតម្លៃសមស្របនៃទ្រព្យសកម្មហិរញ្ញវត្ថុនៅពេលទទួលស្គាល់លើកដំបូង។ "ការប្រាក់" គឺជាតម្លៃតបស្នងមួយសម្រាប់ពេលវេលានៃការប្រើប្រាស់ទឹកប្រាក់ សម្រាប់រយៈពេលណាមួយ និងសម្រាប់ហានិភ័យដែលពាក់ព័ន្ធនឹងបរិមាណប្រាក់ដើម នៅជាប់ជំពាក់ក្នុងអំឡុងពេលជាក់លាក់មួយ និងសម្រាប់ចំណាយរួមទាំងហានិភ័យក្នុងការផ្តល់កម្ចីជាមូលដ្ឋានផ្សេងៗទៀត (ដូចជាហានិភ័យសន្ទនីយភាព និងចំណាយរដ្ឋបាល) រួមទាំងកម្រិតប្រាក់ចំណេញ។

សម្ព័ន្ធធនាគារ និងធនាគារពិចារណាទៅលើលក្ខខណ្ឌកិច្ចសន្យារបស់ឧបករណ៍ហិរញ្ញវត្ថុ ដើម្បីវាយតម្លៃថាតើសាច់ប្រាក់តាមកិច្ចសន្យា គឺសម្រាប់ទូទាត់តែប្រាក់ដើម និងការប្រាក់ដែរ ឬទេ។ វារួមបញ្ចូលការវាយតម្លៃថាតើទ្រព្យសកម្មហិរញ្ញវត្ថុ មានលក្ខខណ្ឌកិច្ចសន្យាដែលអាចផ្លាស់ប្តូរពេលវេលា ឬចំនួនលំហូរសាច់ប្រាក់តាមកិច្ចសន្យាដែលមិនអាចបំពេញតាមលក្ខខណ្ឌនៃការទូទាត់តែប្រាក់ដើម និងការប្រាក់។

ក្នុងការវាយតម្លៃ សម្ព័ន្ធធនាគារ និងធនាគារ ពិចារណាលើ៖

- ព្រឹត្តិការណ៍ជាយថាហេតុដែលអាចផ្លាស់ប្តូរចំនួន និងពេលវេលានៃលំហូរសាច់ប្រាក់
- លក្ខណៈពិសេសជាអានុភាព
- លក្ខខណ្ឌសងប្រាក់មុនកាលកំណត់ និងការពន្យារពេលសង
- លក្ខខណ្ឌដែលកម្រិតសម្ព័ន្ធធនាគារ និងធនាគារក្នុងការទាមទារមកវិញនូវសាច់ប្រាក់ពីទ្រព្យសកម្មជាក់លាក់ (ដូចជា ឥណទានមានទ្រព្យដាក់បញ្ចាំជាក់លាក់) និង

ធនាគារ អេស៊ីលីដា ភីអិលស៊ី និង ក្រុមហ៊ុនបុត្រសម្ព័ន្ធ

កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ និងសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់

២. សេចក្តីសង្ខេបអំពីគោលនយោបាយគណនេយ្យសំខាន់ៗ (ត)

(ង) ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (ត)

(ii) ការធ្វើចំណាត់ថ្នាក់ (ត)

ការវាយតម្លៃថាតើលំហូរសាច់ប្រាក់តាមកិច្ចសន្យាជាការទូទាត់តែប្រាក់ដើម និងការប្រាក់ (ត)

- លក្ខណៈពិសេសដែលកែប្រែតម្លៃតបស្នងអំពីពេលវេលានៃការប្រើប្រាស់ទឹកប្រាក់ (ឧទាហរណ៍ ការកំណត់អត្រាការ ប្រាក់ឡើងវិញតាមរយៈពេលកំណត់) ។

សម្ព័ន្ធធនាគារ និងធនាគារមានសម្តាធឥណទានមានអត្រាថេរយៈពេលវែងដែលសម្ព័ន្ធធនាគារ និងធនាគារ មានជម្រើសស្នើឱ្យកែប្រែអត្រាការប្រាក់នៅកាលបរិច្ឆេទនៃការកំណត់ជាថ្មីឡើងវិញតាមរយៈពេលកំណត់។ សិទ្ធិ កំណត់ឡើងវិញទាំងនេះ ត្រូវបានកម្រិតតាមអត្រាទីផ្សារនៅពេលមានការកែប្រែដែលសម្ព័ន្ធធនាគារ និងធនាគារមាន ជម្រើសក្នុងការទទួលយកអត្រាការប្រាក់ ដែលបានកែតម្រូវ ឬ សងប្រាក់ដើមឥណទានដោយមិនមានការពិន័យ។ សម្ព័ន្ធធនាគារ និងធនាគារបានកំណត់ថា លំហូរសាច់ប្រាក់តាមកិច្ចសន្យានៃឥណទានទាំងនេះ គឺជា SPPI ពីព្រោះ ការជម្រើសមានការផ្លាស់ប្តូរអត្រាការប្រាក់តាមរបៀបមួយដែលជាតម្លៃតបស្នង សម្រាប់ពេលវេលានៃការប្រើប្រាស់ សាច់ប្រាក់ ហានិភ័យឥណទាន ចំណាយ និងហានិភ័យក្នុងការផ្តល់កម្ចីជាមូលដ្ឋានផ្សេងៗទៀត ទាក់ទងនឹងចំនួន ប្រាក់ដើមដែលនៅជាប់ជំពាក់។

ឥណទានដែលមានទ្រព្យដាក់បញ្ចាំជាក់លាក់

ក្នុងករណីខ្លះ ឥណទានដែលផ្តល់ដោយសម្ព័ន្ធធនាគារ និងធនាគារ ដែលត្រូវបានធានាដោយទ្រព្យដាក់បញ្ចាំ របស់អតិថិជន បានកម្រិតសម្ព័ន្ធធនាគារ និងធនាគារក្នុងការទាមទារលំហូរសាច់ប្រាក់របស់ទ្រព្យដាក់បញ្ចាំ (ឥណទានដែលមានទ្រព្យដាក់បញ្ចាំជាក់លាក់)។ ក្នុងករណីនេះ សម្ព័ន្ធធនាគារ និងធនាគារធ្វើការវិនិច្ឆ័យក្នុងការវាយ តម្លៃថាតើឥណទាននោះ បំពេញតាមលក្ខខណ្ឌទូទាត់តែប្រាក់ដើម និងការប្រាក់ដែរ ឬទេ។ ជាទូទៅសម្ព័ន្ធធនាគារ និងធនាគារ ពិចារណាលើព័ត៌មានខាងក្រោមក្នុងការវិនិច្ឆ័យ៖

- ថាតើកិច្ចសន្យាមានបញ្ជាក់ច្បាស់ពីចំនួន និងកាលបរិច្ឆេទនៃសំណងឥណទានដែរ ឬទេ
- តម្លៃសមស្របនៃទ្រព្យបញ្ចាំពាក់ព័ន្ធនឹងចំនួននៃទ្រព្យសកម្មហិរញ្ញវត្ថុដែលមានការធានា
- សមត្ថភាព និងឆន្ទៈរបស់អតិថិជន ក្នុងការទូទាត់សងតាមកិច្ចសន្យា ទោះបីមានឱនភាពនៃតម្លៃ ទ្រព្យបញ្ចាំក៏ដោយ
- ថាតើអតិថិជនគឺជារូបវន្តបុគ្គល ឬជាអង្គភាពប្រតិបត្តិការសំខាន់ ឬជាអង្គភាពដែលមានគោលបំណង ពិសេស

ធនាគារ អេស៊ីលីដា ភីអិលស៊ី និង ក្រុមហ៊ុនបុត្រសម្ព័ន្ធ

កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ និងសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់

២. សេចក្តីសង្ខេបអំពីគោលនយោបាយគណនេយ្យសំខាន់ៗ (ត)

(ង) ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (ត)

(ii) ការធ្វើចំណាត់ថ្នាក់ (ត)

ឥណទានដែលមានទ្រព្យដាក់បញ្ចាំជាក់លាក់ (ត)

- ហានិភ័យរបស់សម្ព័ន្ធធនាគារ និងធនាគារនៃការបាត់បង់ទ្រព្យសកម្ម ទាក់ទងនឹងឥណទានដែលទ្រព្យដាក់បញ្ចាំពេញលេញ
- វិសាលភាពដែលទ្រព្យដាក់បញ្ចាំបង្ហាញពីទ្រព្យសកម្មរបស់អតិថិជនទាំងអស់ ឬជាផ្នែកណាមួយ និង
- ថាតើសម្ព័ន្ធធនាគារ និងធនាគារនឹងទទួលបានអត្ថប្រយោជន៍ពីការកើនតម្លៃនៃទ្រព្យសកម្មនេះ ឬទេ។

ការធ្វើចំណាត់ថ្នាក់ឡើងវិញ

ទ្រព្យសកម្មហិរញ្ញវត្ថុមិនត្រូវបានធ្វើចាត់ថ្នាក់ឡើងវិញបន្ទាប់ពីការទទួលស្គាល់លើកដំបូងឡើយ លើកលែងតែក្នុងអំឡុងពេលបន្ទាប់ពីសម្ព័ន្ធធនាគារ និងធនាគារផ្លាស់ប្តូរម៉ូដែលអាជីវកម្មរបស់ខ្លួន ក្នុងការគ្រប់គ្រងទ្រព្យសកម្មហិរញ្ញវត្ថុ។

បំណុលហិរញ្ញវត្ថុ

សម្ព័ន្ធធនាគារ និងធនាគារ បានចាត់ថ្នាក់បំណុលហិរញ្ញវត្ថុរបស់ខ្លួន (ក្រៅពីការធានាហិរញ្ញវត្ថុ និងការសន្យាផ្តល់ឥណទាន) ជាការវាស់វែងតាមតម្លៃដកវិលស់ថ្លៃដើម ឬ FVTPL។

(iii) ការឈប់ទទួលស្គាល់

ទ្រព្យសកម្មហិរញ្ញវត្ថុ

សម្ព័ន្ធធនាគារ និងធនាគារ ឈប់ទទួលស្គាល់ទ្រព្យសកម្មហិរញ្ញវត្ថុ នៅពេលដែលសិទ្ធិតាមកិច្ចសន្យាក្នុងការទទួលលំហូរសាច់ប្រាក់ពីទ្រព្យសកម្មហិរញ្ញវត្ថុផុតកំណត់ (សូមមើល(iv)) ឬការផ្ទេរសិទ្ធិទទួលលំហូរសាច់ប្រាក់តាមកិច្ចសន្យាក្នុងប្រតិបត្តិការ ដែលរាល់ហានិភ័យ និងផលចំណេញស្នើរតែទាំងអស់នៃភាពជាកម្មសិទ្ធិ នៃទ្រព្យសកម្មហិរញ្ញវត្ថុ ត្រូវបានផ្ទេរ ឬក្នុងករណីដែលសម្ព័ន្ធធនាគារ និងធនាគារមិនផ្ទេរ ឬមិនរក្សាទុកនូវហានិភ័យ និងផលចំណេញស្នើរតែទាំងអស់នៃភាពជាកម្មសិទ្ធិ ហើយវាមិនរក្សាអភិបាលភាពនៃទ្រព្យសកម្មហិរញ្ញវត្ថុ។

ធនាគារ អេស៊ីលីដា ភីអិលស៊ី និង ក្រុមហ៊ុនបុត្រសម្ព័ន្ធ

កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ និងសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់

២. សេចក្តីសង្ខេបអំពីគោលនយោបាយគណនេយ្យសំខាន់ៗ (ត)

(ង) ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (ត)

(iii) ការឈប់ទទួលស្គាល់ (ត)

ទ្រព្យសកម្មហិរញ្ញវត្ថុ (ត)

នៅពេលដែលមានការឈប់ទទួលស្គាល់ទ្រព្យសកម្មហិរញ្ញវត្ថុ ភាពលម្អៀងរវាងតម្លៃយោងរបស់ទ្រព្យសកម្ម (ឬតម្លៃយោងដែលជាចំណែកនៃទ្រព្យសកម្មដែលឈប់ទទួលស្គាល់) និងផលបូកនៃ (i). តម្លៃតបស្នងដែលទទួលបាន (រាប់បញ្ចូលទាំងទ្រព្យសកម្មថ្មីដែលទទួលបាន ដកបំណុលថ្មីដែលបានទទួលយក) និង (ii). ចំណេញ ឬខាតសរុប ដែលបានទទួលស្គាល់ក្នុងលទ្ធផលលម្អិតផ្សេងៗ ត្រូវបានទទួលស្គាល់នៅក្នុងចំណេញ ឬខាត ។

ការចំណេញ ឬខាតបង់សរុប ដែលត្រូវបានទទួលស្គាល់នៅក្នុងលទ្ធផលលម្អិតផ្សេងៗ ទាក់ទងនឹងមូលបត្រវិនិយោគមូលធន ដែលបានកំណត់ជា FVOCI មិនត្រូវបានទទួលស្គាល់នៅក្នុងប្រាក់ចំណេញ ឬខាត នៅពេលដែលមានការឈប់ទទួលស្គាល់នូវមូលបត្របែបនេះឡើយ ។ ភាគកម្មលើទ្រព្យសកម្មហិរញ្ញវត្ថុ ដែលបានផ្ទេរដែលមានលក្ខណៈគ្រប់គ្រាន់សម្រាប់ការឈប់ទទួលស្គាល់ដែលត្រូវបានបង្កើត ឬរក្សាទុកដោយសម្ព័ន្ធធនាគារ និងធនាគារ ត្រូវបានទទួលស្គាល់ជា ទ្រព្យសកម្ម ឬបំណុលដាច់ដោយឡែក។

បំណុលហិរញ្ញវត្ថុ

សម្ព័ន្ធធនាគារ និងធនាគារឈប់ទទួលស្គាល់បំណុលហិរញ្ញវត្ថុមួយ នៅពេលកាតព្វកិច្ចតាមកិច្ចសន្យាត្រូវបានបោះបង់ចោល ឬត្រូវបានលុបចោល ឬផុតកាលកំណត់។

(iv) ការកែប្រែនៃទ្រព្យសកម្មហិរញ្ញវត្ថុនិងបំណុលហិរញ្ញវត្ថុ

ទ្រព្យសកម្មហិរញ្ញវត្ថុ

ប្រសិនបើលក្ខខណ្ឌនៃទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានកែប្រែ នោះសម្ព័ន្ធធនាគារ និងធនាគារវាយតម្លៃថា តើលំហូរសាច់ប្រាក់នៃទ្រព្យសកម្មដែលបានកែប្រែនោះ មានភាពខុសគ្នាខ្លាំង ឬទេ។

ប្រសិនបើលំហូរសាច់ប្រាក់មានភាពខុសគ្នាខ្លាំង នោះសិទ្ធិតាមកិច្ចសន្យាចំពោះលំហូរសាច់ប្រាក់ពីទ្រព្យសកម្ម

ធនាគារ អេស៊ីលីដា អ៊ីអិលស៊ី និង ក្រុមហ៊ុនបុត្រសម្ព័ន្ធ

កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ និងសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់

២. សេចក្តីសង្ខេបអំពីគោលនយោបាយគណនេយ្យសំខាន់ៗ (ត)

(ង) ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (ត)

(iv) ការកែប្រែនៃទ្រព្យសកម្មហិរញ្ញវត្ថុនិងបំណុលហិរញ្ញវត្ថុ (ត)

ទ្រព្យសកម្មហិរញ្ញវត្ថុ (ត)

ហិរញ្ញវត្ថុដើម ត្រូវបានចាត់ទុកថាផុតកាលកំណត់។ ក្នុងករណីនេះទ្រព្យសកម្មហិរញ្ញវត្ថុដើម ត្រូវឈប់ទទួលស្គាល់ (សូមមើល (iii)) ហើយទ្រព្យសកម្មហិរញ្ញវត្ថុថ្មីមួយត្រូវបានទទួលស្គាល់តាមតម្លៃសមស្រប ឬកនឹង ចំណាយប្រតិបត្តិការ ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់។ ថ្លៃសេវានានាដែលទទួលបានជាផ្នែកនៃការកែប្រែនេះ ត្រូវបានកត់ត្រាដូចខាងក្រោម៖

- ថ្លៃសេវាដែលត្រូវបានពិចារណាក្នុងការកំណត់តម្លៃសមស្របនៃទ្រព្យសកម្មថ្មី និងថ្លៃសេវាដែលជាសំណងនៃចំណាយប្រតិបត្តិការដែលដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ត្រូវបានរាប់បញ្ចូលក្នុងការវាស់វែងលើកដំបូងនៃទ្រព្យសកម្ម និង
- ថ្លៃសេវាផ្សេងទៀតត្រូវបានរាប់បញ្ចូលក្នុងចំណេញ ឬខាត ដែលជាផ្នែកមួយនៃការចំណេញ ឬខាតលើ ការឈប់ទទួលស្គាល់។

ប្រសិនបើលំហូរសាច់ប្រាក់ត្រូវបានកែប្រែនៅពេលដែលអតិថិជនជួបការលំបាកផ្នែកហិរញ្ញវត្ថុ នោះគោលបំណងនៃការកែប្រែជាទូទៅគឺដើម្បីទទួលបានមកវិញជាអតិបរមានៃលក្ខខណ្ឌតាមកិច្ចសន្យាដើម ជាជាងបង្កើតទ្រព្យសកម្មថ្មីដែលមានលក្ខខណ្ឌខុសគ្នាខ្លាំង។ ប្រសិនបើសម្ព័ន្ធធនាគារ និងធនាគារមានគម្រោងកែប្រែទ្រព្យសកម្មហិរញ្ញវត្ថុតាមរបៀបមួយដែលអាចនាំឱ្យមានការលើកលែងចំពោះលំហូរសាច់ប្រាក់ នោះត្រូវពិចារណាជាដំបូងថាតើផ្នែកមួយនៃទ្រព្យសកម្មគួរតែត្រូវបានលុបចេញពីបញ្ជី មុនពេលធ្វើការកែប្រែកើតឡើងដែរ ឬទេ (សូមមើលគោលនយោបាយការលុបចេញពីបញ្ជីនៅខាងក្រោម)។ វិធីសាស្ត្រនេះមានផលប៉ះពាល់ដល់លទ្ធផលនៃការវាយតម្លៃបរិមាណ និងមានន័យថាលក្ខណៈវិនិច្ឆ័យនៃកាឈប់ទទួលស្គាល់ ជាធម្មតាមិនបំពេញបានករណីទាំងនេះទេ។

ប្រសិនបើការកែប្រែទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានវាស់វែងតាមតម្លៃដកវិលស់ ឬ FVOCI មិនបណ្តាលឱ្យមានការឈប់ទទួលស្គាល់ទ្រព្យសកម្មហិរញ្ញវត្ថុទេ នោះសម្ព័ន្ធធនាគារ និងធនាគារនឹងគណនាឡើងវិញនូវតម្លៃយោងដុលនៃទ្រព្យសកម្មហិរញ្ញវត្ថុជាមុន ដោយប្រើអត្រាការប្រាក់ប្រសិទ្ធភាពដំបូងនៃទ្រព្យសកម្ម និងទទួលស្គាល់លទ្ធផលនៃការកែតម្រូវជាចំណេញ ឬខាត នៅក្នុងរបាយការណ៍ចំណេញ ឬខាត។ សម្រាប់ទ្រព្យសកម្មហិរញ្ញវត្ថុដែលមានអត្រាអថេរ អត្រាការប្រាក់ប្រសិទ្ធភាពដំបូងដែលធ្លាប់បានប្រើដើម្បីគណនាចំណេញ ឬខាតពីការកែប្រែ ត្រូវបានកែតម្រូវដើម្បីឆ្លុះបញ្ចាំងពីលក្ខខណ្ឌទីផ្សារបច្ចុប្បន្ននៅពេលដែលធ្វើការកែប្រែ។ រាល់ចំណាយ ឬថ្លៃសេវាដែលកើតឡើង និងថ្លៃសេវាទទួលបានដែលជាផ្នែកមួយនៃការកែប្រែធ្វើការកែតម្រូវតម្លៃយោងដុលរបស់ទ្រព្យសកម្មហិរញ្ញវត្ថុដែលបានធ្វើការប្រែ និងត្រូវបានរំលស់ផ្អែកលើរយៈពេលដែលនៅសល់នៃទ្រព្យសកម្មហិរញ្ញវត្ថុដែលបានកែប្រែនោះ។

២. សេចក្តីសង្ខេបអំពីគោលនយោបាយគណនេយ្យសំខាន់ៗ (ត)

(ង) ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (ត)

(iv) ការកែប្រែទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (ត)

ទ្រព្យសកម្មហិរញ្ញវត្ថុ (ត)

ប្រសិនបើការកែប្រែនេះ ត្រូវបានធ្វើឡើងដោយសារតែអតិថិជនជួបការលំបាកផ្នែកហិរញ្ញវត្ថុ (សូមមើល (vii)) នោះចំណេញ ឬខាតត្រូវបានបង្ហាញជាមួយគ្នានឹងការខាតបង់លើឱនភាពនៃតម្លៃរបស់ទ្រព្យសកម្ម។ ក្នុងករណីផ្សេងទៀត ត្រូវបានបង្ហាញជាចំណូលការប្រាក់ ដែលគណនាដោយប្រើវិធីសាស្ត្រអត្រាការប្រាក់ប្រសិទ្ធភាព (សូមមើល (កំណត់សម្គាល់២ (ទ)))។

បំណុលហិរញ្ញវត្ថុ

សម្ព័ន្ធធនាគារ និងធនាគារ ឈប់ទទួលស្គាល់បំណុលហិរញ្ញវត្ថុ នៅពេលដែលលក្ខខណ្ឌរបស់វាត្រូវបានកែប្រែ ហើយលំហូរសាច់ប្រាក់នៃបំណុលដែលបានកែប្រែនោះមានភាពខុសគ្នាខ្លាំង។ ក្នុងករណីនេះ បំណុលហិរញ្ញវត្ថុថ្មីមួយ ត្រូវបានទទួលស្គាល់តាមតម្លៃសមស្រប។ ភាពលម្អៀងរវាងតម្លៃយោងនៃបំណុលហិរញ្ញវត្ថុដែលត្រូវបានឈប់ទទួលស្គាល់ និងតម្លៃតបស្នងដែលបានទូទាត់ ត្រូវបានទទួលស្គាល់នៅក្នុងចំណេញ ឬ ខាត។ តម្លៃតបស្នងដែលបានទូទាត់រួមមាន ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុដែលបានផ្ទេរ (ប្រសិនបើមាន) និងការទទួលយកបំណុលថ្មី រួមទាំងបំណុលហិរញ្ញវត្ថុដែលបានកែប្រែថ្មី។

ប្រសិនបើការកែប្រែបំណុលហិរញ្ញវត្ថុនេះមិនធ្វើឱ្យមានការឈប់ទទួលស្គាល់ទេ នោះតម្លៃដករំលស់នៃបំណុលត្រូវបានគណនាឡើងវិញដោយធ្វើអឬ្ធការលំហូរសាច់ប្រាក់ដែលបានកែប្រែ តាមអត្រាការប្រាក់ប្រសិទ្ធភាពដំបូង ហើយលទ្ធផលនៃចំណេញ ឬខាត ត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ចំណេញ ឬខាត។ សម្រាប់បំណុលហិរញ្ញវត្ថុដែលមានអត្រាអថេរ អត្រាការប្រាក់ប្រសិទ្ធភាពដំបូងដែលធ្លាប់បានប្រើដើម្បីគណនាចំណេញ ឬខាតពីការកែប្រែ ត្រូវបានកែតម្រូវដើម្បីឆ្លុះបញ្ចាំងពីលក្ខខណ្ឌទីផ្សារបច្ចុប្បន្ននៅពេលដែលធ្វើការកែប្រែ។ រាល់ចំណាយ និងថ្លៃសេវាដែលកើតឡើង ត្រូវបានទទួលស្គាល់ជាការកែតម្រូវទៅលើតម្លៃយោងនៃបំណុល និងត្រូវបានរំលស់ផ្អែកលើរយៈពេលដែលនៅសល់នៃបំណុលហិរញ្ញវត្ថុដែលបានកែប្រែនោះ ដោយធ្វើការគណនាអត្រាការប្រាក់ប្រសិទ្ធភាពឡើងវិញលើឧបករណ៍ហិរញ្ញវត្ថុ។

ធនាគារ អេស៊ីលីដា អ៊ីអិលស៊ី និង ក្រុមហ៊ុនបុត្រសម្ព័ន្ធ

កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ និងសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់

២. សេចក្តីសង្ខេបអំពីគោលនយោបាយគណនេយ្យសំខាន់ៗ (ត)

(ង) ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (ត)

(v) ការកាត់កង

ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ អាចកាត់កងគ្នាបាន និងត្រូវបង្ហាញជាចំនួនសុទ្ធនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ លុះត្រាតែសម្ព័ន្ធធនាគារ និងធនាគារ មានសិទ្ធិតាមច្បាប់ដើម្បីធ្វើការកាត់កងគ្នាបាន និងមានបំណងធ្វើការទូទាត់ដោយផ្អែកលើមូលដ្ឋានចំនួននៅសល់សុទ្ធ ឬក៏លក់ទ្រព្យសកម្ម និងទូទាត់បំណុលក្នុងពេលដំណាលគ្នា។

ចំណូល និងចំណាយ ត្រូវបានបង្ហាញជាមូលដ្ឋានសុទ្ធនៅពេលដែលត្រូវបានអនុញ្ញាតដោយ ស.រ.ហ.អ.ក ឬសម្រាប់ចំណេញ ឬខាត ដែលកើតឡើងពីក្រុមនៃប្រតិបត្តិការស្រដៀងគ្នា ដូចជានៅក្នុងសកម្មភាពជួញដូររបស់សម្ព័ន្ធធនាគារ និងធនាគារ។

(vi) ការវាស់វែងតម្លៃសមស្រប

តម្លៃសមស្រប គឺជាថ្លៃដែលនឹងទទួលបានដោយការលក់ទ្រព្យសកម្ម ឬថ្លៃដែលបានសងចំពោះការផ្ទេរបំណុលនៅក្នុងប្រតិបត្តិការធម្មតា រវាងអ្នកចូលរួមក្នុងទីផ្សារនានានៅកាលបរិច្ឆេទនៃការវាស់វែងនៅក្នុងទីផ្សារគោល ឬក្នុងករណីមិនមានទីផ្សារគោល គឺយកទីផ្សារជាអាទិភាពបំផុត ដែលសម្ព័ន្ធធនាគារ និងធនាគារ អាចកំណត់រកបាននៅកាលបរិច្ឆេទនៃការវាស់វែងនោះ។ តម្លៃសមស្របរបស់បំណុល ឆ្លុះបញ្ចាំងពីហានិភ័យមិនមែនប្រតិបត្តិការ។

តម្លៃសមស្របនៃបំណុលហិរញ្ញវត្ថុមានលក្ខណៈពិសេសនៃតម្រូវការ (ឧទាហរណ៍ ប្រាក់បញ្ញើតាមតម្រូវការ) គឺមិនត្រូវតិចជាងចំនួនទឹកប្រាក់ដែលត្រូវសងតាមតម្រូវការទេ ដោយត្រូវធ្វើអប្បហារចាប់ពីថ្ងៃដំបូងដែលចំនួនទឹកប្រាក់អាចតម្រូវឱ្យសង។

សម្ព័ន្ធធនាគារ និងធនាគារទទួលស្គាល់ការផ្ទេររវាងកម្រិតនៃឋានានុក្រមនៃតម្លៃសមស្រប នៅចុងការិយបរិច្ឆេទ នៃរបាយការណ៍អំឡុងពេលដែលការផ្លាស់ប្តូរបានកើតឡើង។

(vii) ឱនភាពនៃតម្លៃ

សម្ព័ន្ធធនាគារ និងធនាគារទទួលស្គាល់សំវិធានធនលើការខាតបង់ សម្រាប់ការខាតបង់ឥណទានដែលរំពឹងទុក (ECL) ចំពោះឧបករណ៍ហិរញ្ញវត្ថុ ដែលមិនបានវាស់វែងតាម FVTPL ដូចខាងក្រោម៖

- ទ្រព្យសកម្មហិរញ្ញវត្ថុ ដែលជាឧបករណ៍បំណុល
- ឥណទាន និងបុរេប្រទាន
- កិច្ចសន្យាធានាហិរញ្ញវត្ថុដែលបានបោះផ្សាយ និង
- កិច្ចសន្យាផ្តល់ឥណទានដែលបានបោះផ្សាយ

ធនាគារ អេស៊ីលីដា អ៊ីអិលស៊ី និង ក្រុមហ៊ុនបុត្រសម្ព័ន្ធ

កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ និងសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់

២. សេចក្តីសង្ខេបអំពីគោលនយោបាយគណនេយ្យសំខាន់ៗ (ត)

(ង) ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (ត)

(vii) ឱនភាពនៃតម្លៃ (ត)

ពុំមានការខាតបង់លើឱនភាពនៃតម្លៃត្រូវបានទទួលស្គាល់លើការវិនិយោគមូលធនឡើយ។

សម្ព័ន្ធធនាគារ និងធនាគារវាស់វែងសំវិធានធនលើការខាតបង់ តាមចំនួនដែលស្មើនឹង ECL ពេញមួយអាយុកាល លើកលែងឧបករណ៍ហិរញ្ញវត្ថុដែលត្រូវបានវាស់វែងតាម ECL ១២ ខែ ដូចខាងក្រោមនេះ៖

- មូលបត្រវិនិយោគបំណុលដែលត្រូវបានកំណត់ថាមានហានិភ័យឥណទានទាបនាកាលបរិច្ឆេទរាយការណ៍ និង
- ឧបករណ៍ហិរញ្ញវត្ថុផ្សេងទៀត (ក្រៅពីគណនីឥណទាន និងបុរេប្រទាន) ដែលហានិភ័យឥណទានមិនបានកើនឡើងជាសារវន្ត ចាប់តាំងពីការទទួលស្គាល់លើកដំបូង។

សំវិធានធនលើការខាតបង់សម្រាប់គណនីឥណទាន និងបុរេប្រទាន តែងតែត្រូវបានវាស់វែងតាមចំនួនស្មើនឹង ECL ពេញមួយអាយុកាល។

សម្ព័ន្ធធនាគារ និងធនាគារពិចារណាលើមូលបត្រវិនិយោគបំណុលមួយថាមានហានិភ័យឥណទានទាប នៅពេលដែលចំណាត់ថ្នាក់ហានិភ័យឥណទានរបស់វា ស្មើទៅនឹង និយមន័យដែលត្រូវបានគេស្គាល់ជាសកលនៃ "ថ្នាក់វិនិយោគ"។ សម្ព័ន្ធធនាគារ និងធនាគារមិនអនុវត្តការលើកលែងហានិភ័យឥណទានទាបចំពោះឧបករណ៍ហិរញ្ញវត្ថុដទៃទៀតឡើយ។

ECL ១២ ខែ គឺជាផ្នែកនៃ ECL ដែលបណ្តាលមកពីព្រឹត្តិការណ៍ខកខានសងប្រាក់ក្នុងរយៈពេល ១២ ខែ របស់ឧបករណ៍ហិរញ្ញវត្ថុមួយដែលអាចកើតឡើងក្នុងរយៈពេល ១២ខែ បន្ទាប់ពីកាលបរិច្ឆេទរាយការណ៍។ ឧបករណ៍ហិរញ្ញវត្ថុដែលបានទទួលស្គាល់តាម ECL ១២ខែ ត្រូវបានចាត់ទុកជា "ឧបករណ៍ហិរញ្ញវត្ថុស្ថិតក្នុងដំណាក់កាលទី ១"។

ECL ពេញមួយអាយុកាល (Life-time ECL) គឺជា ECL ដែលអាចបណ្តាលមកពីព្រឹត្តិការណ៍ខកខានសងប្រាក់ក្នុងអាយុកាលដែលរំពឹងទុក (expected life) ទាំងអស់របស់ឧបករណ៍ហិរញ្ញវត្ថុ។ ឧបករណ៍ហិរញ្ញវត្ថុដែលបានទទួលស្គាល់តាម ECL ពេញមួយអាយុកាល ប៉ុន្តែមិនមែនមានឱនភាពនៃតម្លៃឥណទាន (credit-impaired) ត្រូវបានចាត់ទុកជា "ឧបករណ៍ហិរញ្ញវត្ថុស្ថិតក្នុងដំណាក់កាលទី ២"។

ការវាស់វែង ECL

ECL គឺជាការប៉ាន់ស្មានដែលបានថ្លឹងតាមប្រូបាប៊ីលីតេនៃការខាតបង់ឥណទាន។ ECL ត្រូវបានវាស់វែងដូចខាងក្រោម៖

២. សេចក្តីសង្ខេបអំពីគោលនយោបាយគណនេយ្យសំខាន់ៗ (ត)

(ង) ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (ត)

(vii) ឱនភាពនៃតម្លៃ (ត)

***ការវាស់វែង** ECL (ត)*

- ទ្រព្យសកម្មហិរញ្ញវត្ថុដែលមិនមានឱនភាពនៃតម្លៃនាកាលបរិច្ឆេទរាយការណ៍៖ ជាតម្លៃបច្ចុប្បន្ននៃកង្វះខាតសាច់ប្រាក់ទាំងអស់ (ពោលគឺភាពខុសគ្នារវាងលំហូរសាច់ប្រាក់ដែលជំពាក់ ដោយយោងតាមកិច្ចសន្យា និងលំហូរសាច់ប្រាក់ដែលសម្ព័ន្ធធនាគារ និងធនាគាររំពឹងទុកថានឹងទទួលបាន) ។
- ទ្រព្យសកម្មហិរញ្ញវត្ថុដែលមានឱនភាពនៃតម្លៃនាកាលបរិច្ឆេទរាយការណ៍៖ ជាភាពខុសគ្នារវាងតម្លៃយោងដុល និងតម្លៃបច្ចុប្បន្ននៃលំហូរសាច់ប្រាក់នាពេលអនាគតដែលរំពឹងទុក។
- កិច្ចសន្យាផ្តល់ឥណទានដែលមិនទាន់បានប្រើប្រាស់៖ ជាតម្លៃបច្ចុប្បន្ននៃភាពខុសគ្នារវាងលំហូរសាច់ប្រាក់តាមកិច្ចសន្យាដែលជំពាក់សម្ព័ន្ធធនាគារ និងធនាគារ ប្រសិនបើកិច្ចសន្យាឥណទានត្រូវបានប្រើប្រាស់ និងលំហូរសាច់ប្រាក់ដែលសម្ព័ន្ធធនាគារ និងធនាគារ រំពឹងទុកថានឹងទទួលបាន និង

  កិច្ចសន្យាធានាហិរញ្ញវត្ថុ៖ ការទូទាត់ដែលរំពឹងទុក ចំពោះចំនួនទឹកប្រាក់ដែលនឹងផ្តល់ទៅអ្នកទទួលផល ដោយដកចេញនូវចំនួនទឹកប្រាក់ដែលសម្ព័ន្ធធនាគារ និងធនាគាររំពឹងថានឹងទទួលបានមកវិញ។

ធាតុចូលសំខាន់ៗ ក្នុងការវាស់វែង ECL គឺបានមកពីអថេរដូចខាងក្រោម៖

- ប្រូបាប៊ីលីតេនៃការខកខានសង (PD);
- ការខាតបង់ដែលបណ្តាលមកពីការខកខានសង (LGD) និង
- ទំហំនៃការខកខានសង (EAD)

ECL សម្រាប់ទំហំក្នុងដំណាក់កាលទី ១ ត្រូវបានគណនាដោយផលគុណនៃប្រូបាប៊ីលីតេនៃការខកខានសងក្នុង ១២ ខែ នឹងការខាតបង់ដែលបណ្តាលមកពីការខកខានសង នឹងទំហំនៃការខកខានសង។ ECL ពេញមួយអាយុកាល ត្រូវបានគណនាដោយផលគុណនៃប្រូបាប៊ីលីតេនៃការខកខានសងពេញមួយអាយុកាល និងការខាតបង់ដែលបណ្តាលមកពីការខកខានសង និង ទំហំនៃការខកខានសង។

ការសន្មត់ដែលផ្អែកលើការគណនា ECL ត្រូវបានត្រួតពិនិត្យតាមមូលដ្ឋានប្រចាំខែ និងត្រួតពិនិត្យឡើងវិញតាមមូលដ្ឋានប្រចាំត្រីមាស។ មិនមានការផ្លាស់ប្តូរសំខាន់ៗទៅលើបច្ចេកទេសប៉ាន់ស្មាន ឬមានការសន្មត់សំខាន់ៗណាមួយបានកើតឡើងក្នុងអំឡុងកាលបរិច្ឆេទនៃរបាយការណ៍នេះឡើយ។

ប្រូបាប៊ីលីតេនៃការខកខានសង (PD) ផ្តល់នូវការប៉ាន់ប្រមាណនៃលទ្ធភាពដែលអតិថិជនម្នាក់នឹងមិនអាចបំពេញកាតព្វកិច្ចបំណុល ឬភាពខកខានក្នុងរយៈពេលជាក់លាក់មួយ។ ទ្រព្យសកម្មហិរញ្ញវត្ថុក្រោម វិធីសាស្ត្រទូទៅដែលតម្រូវមានដំណាក់កាល និងតម្រូវទាំងការប៉ាន់ស្មានប្រូបាប៊ីលីតេនៃការខកខានសងក្នុង១២ខែ និង ប្រូបាប៊ីលីតេ

២. សេចក្តីសង្ខេបអំពីគោលនយោបាយគណនេយ្យសំខាន់ៗ (ត)

(ង) ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (ត)

(vii) ឱនភាពនៃតម្លៃ (ត)

ការវាស់វែង ECL (ត)

នៃការខកខានសងក្នុងពេញមួយអាយុកាល ដោយយោងទៅតាមទិន្នន័យប្រវត្តិសាស្ត្រដោយប្រើវិធីសាស្ត្រ Migration (migration approach) ឬវិធីសាស្ត្រការផ្តល់ចំណាត់ថ្នាក់លទ្ធភាពសងពីភាគីឯករាជ្យ។

ការខាតបង់ដែលបណ្តាលមកពីការខកខានសង គឺជាកម្រិតដែលអាចបាត់បង់ប្រសិនបើមានការខកខានសង។ ការខាតបង់ដែលបណ្តាលមកពីការខកខានសង ត្រូវបានកំណត់ជាភាគរយនៃទំហំប្រឈមដែលធនាគារអាចនឹងបាត់បង់ក្នុងករណីដែលអតិថិជនខកខានសង។ ការខាតបង់ទាំងនេះជាធម្មតាត្រូវបានបង្ហាញជាភាគរយនៃទំហំនៃការខកខានសង (EAD) ហើយពឹងផ្អែកលើប្រភេទនិងចំនួនទ្រព្យដាក់បញ្ចាំព្រមទាំងប្រភេទនៃអតិថិជន និងការប្រមូលបំណុលដែលរំពឹងទុកពីអតិថិជន ។

ជាមួយនឹងតម្លៃទ្រព្យដាក់បញ្ចាំដែលត្រឹមត្រូវ ដែលត្រូវបានធ្វើបច្ចុប្បន្នកម្មពីមួយពេលទៅមួយពេល ធនាគារអាចពិចារណាយកទ្រព្យដាក់បញ្ចាំចូលទៅក្នុងការគណនា ការខាតបង់ដែលបណ្តាលមកពីការខកខានសង សម្រាប់ការគណនា ECL។ ក្នុងករណីមានទ្រព្យដាក់បញ្ចាំលើសលុប កម្រិតទាបបំផុតរបស់ ការខាតបង់ដែលបណ្តាលមកពីការខកខានសង មួយ នឹងត្រូវយកទៅអនុវត្តសម្រាប់ការគណនា ECL។

ទំហំនៃការខកខានសង គឺជាចំនួនទឹកប្រាក់នៅជំពាក់ នៅពេលមានការខកខានសង។ ទោះយ៉ាងណា ទំហំនៃការខកខានសង ខុសគ្នាទៅតាមលក្ខណៈនៃផលិតផល៖

- ហ្វាស៊ីលីធីរំលស់៖ ចំនួនទឹកប្រាក់បច្ចុប្បន្នដែលត្រូវបានអនុញ្ញាតក្រោមកិច្ចសន្យា និងកើតឡើងពីការធ្វើរំលស់
- ហ្វាស៊ីលីធីអាចប្រើប្រាស់ឡើងវិញ៖ អត្រាប្រើប្រាស់
- ក្រៅតារាងតុល្យការ៖ កត្តាបំប្លែងឥណទាន ("CCF")

ដូចការរៀបរាប់ខាងលើ និងដោយផ្អែកលើការប្រើប្រាស់ជាអតិបរមានៃប្រូបាប៊ីលីតេនៃការខកខានសងក្នុង ១២ខែ សម្រាប់ទ្រព្យសកម្មហិរញ្ញវត្ថុនៅដំណាក់កាលទី១ សម្ព័ន្ធធនាគារ និងធនាគារវាស់វែង ECL ដោយពិចារណាលើហានិភ័យនៃការខកខានសង ក្នុងរយៈពេលតាមកិច្ចសន្យាជាអតិបរមា (រួមបញ្ចូលទាំងជម្រើសការពន្យារពេលសងរបស់អតិថិជនប្រសិនបើមាន) ដែលប្រឈមនឹងហានិភ័យឥណទាន ទោះបីជាក្នុងគោលបំណងគ្រប់គ្រងហានិភ័យឥណទានក៏ដោយ សម្ព័ន្ធធនាគារ ឬ ធនាគារពិចារណាលើរយៈពេលដែលវែងជាងមួយ។ រយៈពេលដែលវែងបំផុត គឺគិតត្រឹមថ្ងៃដែលសម្ព័ន្ធធនាគារ និងធនាគារមានសិទ្ធិទាមទារការសងត្រឡប់នៃឥណទាន ឬបុរេប្រទាន ឬបញ្ចប់កិច្ចសន្យាធានា ឬកិច្ចសន្យាផ្តល់ឥណទាន។

ធនាគារ អេស៊ីលីដា ភីអិលស៊ី និង ក្រុមហ៊ុនបុត្រសម្ព័ន្ធ

កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ និងសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់

២. សេចក្តីសង្ខេបអំពីគោលនយោបាយគណនេយ្យសំខាន់ៗ (ត)

(ង) ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (ត)

(vii) ឱនភាពនៃតម្លៃ (ត)

ការវាស់វែង ECL (ត)

ទោះយ៉ាងណាក៏ដោយ សម្រាប់ហ្វាស៊ីលីធីប័ណ្ណឥណទានដែលរួមមានទាំងឥណទាន និងធាតុការសន្យាផ្តល់ឥណទានដែលមិនទាន់បានប្រើប្រាស់ ដែលសម្ព័ន្ធធនាគារ និងធនាគារវាស់វែង ECL ក្នុងរយៈពេលមួយវែងជាងរយៈពេលតាមកិច្ចសន្យាអតិបរមា ប្រសិនបើ សមត្ថភាពតាមកិច្ចសន្យារបស់សម្ព័ន្ធធនាគារ និងធនាគារក្នុងការទាមទារសំណង និងលុបចោលការសន្យាផ្តល់ឥណទានដែលមិនទាន់បានប្រើប្រាស់ មិនកំណត់ការប្រឈមរបស់សម្ព័ន្ធធនាគារ និងធនាគារចំពោះការខាតបង់ឥណទានចំពោះរយៈពេលជូនដំណឹងតាមកិច្ចសន្យា។ ហ្វាស៊ីលីធីទាំងនេះមិនមានរយៈពេលថេរ ឬរចនាសម្ព័ន្ធសងត្រឡប់ទេ ហើយត្រូវបានគ្រប់គ្រងលើមូលដ្ឋានហ្វាស៊ីលីធីក្រុម។ សម្ព័ន្ធធនាគារ និងធនាគារអាចលុបចោលពួកគេដោយប្រសិទ្ធភាពភ្លាមៗ ប៉ុន្តែសិទ្ធិតាមកិច្ចសន្យានេះមិនត្រូវបានអនុវត្តនៅក្នុងការគ្រប់គ្រងប្រចាំថ្ងៃជាធម្មតាទេ ប៉ុន្តែនៅពេលដែលសម្ព័ន្ធធនាគារ ឬ ធនាគារ ដឹងអំពីការកើនឡើងហានិភ័យឥណទាននៅកម្រិតហ្វាស៊ីលីធី។ រយៈពេលវែងជាងនេះ ត្រូវបានប៉ាន់ប្រមាណដោយគិតគូរពីសកម្មភាពគ្រប់គ្រងហានិភ័យឥណទាន ដែលសម្ព័ន្ធធនាគារ និងធនាគាររំពឹងថានឹងអនុវត្ត ហើយដែលអាចជួយកាត់បន្ថយ ECL បាន។ ទាំងនេះរួមបញ្ចូលទាំងការកាត់បន្ថយកម្រិតកំណត់ការលុបចោលនៃហ្វាស៊ីលីធី និង/ឬ បង្វែរសមតុល្យដែលនៅជំពាក់ទៅជាឥណទានដែលមានលក្ខខណ្ឌសងត្រឡប់វិញថេរ។

ទ្រព្យសកម្មហិរញ្ញវត្ថុដែលបានរៀបចំឡើងវិញ

ប្រសិនបើលក្ខខណ្ឌនៃទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានចរចា ឬកែប្រែ ឬទ្រព្យសកម្មហិរញ្ញវត្ថុដែលមានស្រាប់ ត្រូវបានជំនួសដោយទ្រព្យសកម្មហិរញ្ញវត្ថុថ្មី ដោយសារស្ថានភាពលំបាកផ្នែកហិរញ្ញវត្ថុរបស់អតិថិជន នោះការវាយតម្លៃត្រូវបានធ្វើឡើង ដើម្បីវាយតម្លៃថាតើទ្រព្យសកម្មហិរញ្ញវត្ថុគួរតែត្រូវឈប់ទទួលស្គាល់ ឬទេ ហើយ ECL ត្រូវបានវាស់វែងដូចខាងក្រោម៖

- ប្រសិនបើការរៀបចំឡើងវិញ មិននាំឱ្យការឈប់ទទួលស្គាល់ទ្រព្យសកម្មដែលមានស្រាប់ទេ នោះលំហូរសាច់ប្រាក់ដែលរំពឹងទុកថាកើតមានពីទ្រព្យសកម្មហិរញ្ញវត្ថុដែលបានកែប្រែ ត្រូវបានបញ្ចូលនៅក្នុងការគណនាកង្វះខាតនៃសាច់ប្រាក់ពីទ្រព្យសកម្មដែលមានស្រាប់។
- ប្រសិនបើការរៀបចំឡើងវិញ នាំឱ្យមានការឈប់ទទួលស្គាល់ទ្រព្យសកម្មដែលមានស្រាប់ នោះតម្លៃសមស្របរំពឹងទុកនៃទ្រព្យសកម្មថ្មីនោះ ត្រូវបានចាត់ទុកជាលំហូរសាច់ប្រាក់ចុងក្រោយទទួលបានពីទ្រព្យសកម្មហិរញ្ញវត្ថុបច្ចុប្បន្ន នៅពេលដែលឈប់ទទួលស្គាល់។ ចំនួនទឹកប្រាក់នេះត្រូវបានបញ្ចូលទៅក្នុងការគណនាកង្វះខាតសាច់ប្រាក់ពីទ្រព្យសកម្មហិរញ្ញវត្ថុបច្ចុប្បន្ន ដែលត្រូវបានធ្វើអប្បហារពីកាលបរិច្ឆេទរំពឹងទុកនៃការឈប់ទទួលស្គាល់ ទៅកាលបរិច្ឆេទរាយការណ៍ ដោយប្រើអត្រាការប្រាក់ប្រសិទ្ធភាពដើមនៃទ្រព្យសកម្មហិរញ្ញវត្ថុបច្ចុប្បន្ន។

ធនាគារ អេស៊ីលីដា អ៊ីអិលស៊ី និង ក្រុមហ៊ុនបុត្រសម្ព័ន្ធ

កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ និងសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់

២. សេចក្តីសង្ខេបអំពីគោលនយោបាយគណនេយ្យសំខាន់ៗ (ត)

(ង) ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (ត)

(vii) ឱនភាពនៃតម្លៃ (ត)

ទ្រព្យសកម្មហិរញ្ញវត្ថុដែលមានឱនភាពនៃតម្លៃឥណទាន

នៅថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២១ ធនាគារជាតិ នៃ កម្ពុជា បានចេញសារាចរលេខ ធ៧-០២១-២៣១៤ ស្តីពីការធ្វើចំណាត់ថ្នាក់ និងសំវិធានធន ចំពោះឥណទានរៀបចំឡើងវិញ។ នៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០២២ សិក្ខាសាលារវាងធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុទាំងអស់ (“BFIs”) នៅក្រោមសមាគមធនាគារនៅក្នុងប្រទេសកម្ពុជា និងធនាគារជាតិ នៃ កម្ពុជា ដែលរៀបចំឡើងដើម្បីជាជំនួយដល់ BFIs នៅក្នុងការអនុវត្តលើសារាចរ និងដើម្បីពិភាក្សាទៅលើបញ្ហាសំខាន់ៗមួយចំនួនទៀត។ តាមរយៈការធ្វើសិក្ខាសាលានេះ ធនាគារជាតិ នៃ កម្ពុជា បានធ្វើការជូនដំណឹងដល់ BFIs តាមរយៈលិខិតលេខ ធ៧-០២២-១៦៧ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០២២ ស្តីពីការពន្យាពេលក្នុងការបញ្ជូនរបាយការណ៍ហ្វូតដល់ថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២២ និងការផ្លាស់ប្តូរទិន្នន័យហិរញ្ញវត្ថុដែលនឹងត្រូវប្រើរហ្វូតដល់ខែមករា ឆ្នាំ២០២២ ក្នុងចំណោមទិន្នន័យផ្សេងទៀត។

នៅកាលបរិច្ឆេទរាយការណ៍នីមួយៗ សម្ព័ន្ធធនាគារ និងធនាគារវាយតម្លៃថាតើទ្រព្យសកម្មហិរញ្ញវត្ថុដែលបានកត់ត្រាតាមតម្លៃដករំលស់ និងទ្រព្យសកម្មហិរញ្ញវត្ថុបំណុលដែលបានកត់ត្រាតាម FVOCI និងគណនីត្រូវទទួលភតិសន្យាហិរញ្ញវត្ថុមានឱនភាពនៃតម្លៃឥណទានដែរ ឬទេ (សំដៅលើ “ទ្រព្យសកម្មហិរញ្ញវត្ថុនៅដំណាក់កាលទី៣”។ ទ្រព្យសកម្មហិរញ្ញវត្ថុមួយមានឱនភាពនៃតម្លៃឥណទាន នៅពេលដែលព្រឹត្តិការណ៍មួយ ឬច្រើន ដែលនាំឱ្យមានផលប៉ះពាល់ជាអវិជ្ជមានទៅលើលំហូរសាច់ប្រាក់នាពេលអនាគតដែលរំពឹងទុកនៃទ្រព្យសកម្មហិរញ្ញវត្ថុ បានកើតឡើង។

ភស្តុតាងដែលបញ្ជាក់ថាទ្រព្យសកម្មហិរញ្ញវត្ថុមានឱនភាពនៃតម្លៃឥណទាន រួមមានទិន្នន័យដែលអាចអង្កេតបានដូចខាងក្រោម៖

- ការលំបាកផ្នែកហិរញ្ញវត្ថុជាសារវន្តរបស់អតិថិជន ឬអ្នកបោះផ្សាយ
- ការបំពានកិច្ចសន្យា ដូចជាការខកខានសង ឬហួសកាលកំណត់
- ការរៀបចំឡើងវិញលើលក្ខខណ្ឌនៃឥណទាន ឬបុរេប្រទាន ដោយសម្ព័ន្ធធនាគារ និងធនាគារ លើលក្ខខណ្ឌដែលសម្ព័ន្ធធនាគារ និងធនាគារមិនគួរយល់ព្រម
- អតិថិជនទំនងជានឹងក្ស័យធន ឬត្រូវរៀបចំហិរញ្ញវត្ថុផ្សេងទៀតឡើងវិញ
- ការបាត់បង់ទីផ្សារសកម្មចំពោះទ្រព្យដាក់បញ្ចាំមួយដោយសារតែការលំបាកផ្នែកហិរញ្ញវត្ថុ។

២. សេចក្តីសង្ខេបអំពីគោលនយោបាយគណនេយ្យសំខាន់ៗ (ត)

(ង) ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (ត)

(vii) ឱនភាពនៃតម្លៃ (ត)

ទ្រព្យសកម្មហិរញ្ញវត្ថុដែលមានឱនភាពនៃតម្លៃឥណទាន (ត)

ឥណទានដែលត្រូវបានចរចាឡើងវិញ ដោយសារតែការធ្លាក់ចុះនៃស្ថានភាពរបស់អតិថិជន ត្រូវបានចាត់ទុកថាមានឱនភាពនៃតម្លៃឥណទាន លុះត្រាតែមានភស្តុតាងបញ្ជាក់ថាហានិភ័យនៃការមិនទទួលបានលំហូរសាច់ប្រាក់តាមកិច្ចសន្យាបានថយចុះជាសារវន្ត និងមិនមានសូចនាករផ្សេងទៀតដែលនាំឱ្យមានឱនភាពនៃតម្លៃ។ បន្ថែមលើនេះ ឥណទានសម្រាប់ការជួញដូររាយដែលហួសកាលកំណត់សង ៩០ថ្ងៃ ឬលើសពីនេះ ត្រូវបានចាត់ទុកថាមានឱនភាពនៃតម្លៃឥណទាន ទោះបីជានិយមន័យនៃការខកខានសងតាមបទប្បញ្ញត្តិបានកំណត់ផ្សេងគ្នាក៏ដោយ។

ការបង្ហាញសំវិធានធនសម្រាប់ ECL នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ

សំវិធានធនខាតបង់សម្រាប់ ECL ត្រូវបានបង្ហាញនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុដូចខាងក្រោម៖

- ទ្រព្យសកម្មហិរញ្ញវត្ថុដែលវាស់វែងដោយតម្លៃដករំលស់៖ ជាការកាត់បន្ថយពីតម្លៃយោងដុលរបស់ទ្រព្យសកម្ម
- ការសន្យាផ្តល់ឥណទាន និងកិច្ចសន្យាធានាហិរញ្ញវត្ថុ៖ ជាទូទៅ ជាការធ្វើសំវិធានធន
- នៅពេលដែលឧបករណ៍ហិរញ្ញវត្ថុមួយរួមបញ្ចូលទាំងសមាសធាតុមិនទាន់បានប្រើប្រាស់ និងបានប្រើប្រាស់ ហើយសម្ព័ន្ធធនាគារ និងធនាគារមិនអាចកំណត់ ECL លើសមាសធាតុការសន្យាផ្តល់ឥណទានដោយឡែកពីសមាសធាតុនៃការសន្យាផ្តល់ឥណទានដែលបានប្រើប្រាស់ សម្ព័ន្ធធនាគារ និងធនាគារធ្វើការបង្ហាញ សំវិធានធនខាតបង់រួមបញ្ចូលគ្នាសម្រាប់សមាសធាតុទាំងពីរ។ ចំនួនរួមបញ្ចូលគ្នាត្រូវបានបង្ហាញជា ការកាត់ចេញពីតម្លៃយោងដុលនៃសមាសធាតុដែលបានបានប្រើប្រាស់។ ចំនួនលើសរបស់សំវិធានធន ខាតបង់លើតម្លៃយោងដុលនៃសមាសធាតុដែលបានប្រើប្រាស់ត្រូវបានបង្ហាញជាការធ្វើសំវិធានធន និង
- ឧបករណ៍បំណុលដែលវាស់វែងតាម FVOCI៖ មិនមានសំវិធានធនខាតបង់ដែលត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុទេ ពីព្រោះតម្លៃយោងនៃទ្រព្យសកម្មទាំងនេះគឺជាតម្លៃសមស្រប។ ទោះយ៉ាងណាក៏ដោយសំវិធានធនខាតបង់ត្រូវបានលាតត្រដាង និងទទួលស្គាល់នៅក្នុងទុនបម្រុងតម្លៃសមស្រប។

ធនាគារ អេស៊ីលីដា អ៊ីអិលស៊ី និង ក្រុមហ៊ុនបុត្រសម្ព័ន្ធ

កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ និងសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់

២. សេចក្តីសង្ខេបអំពីគោលនយោបាយគណនេយ្យសំខាន់ៗ (ត)

(ង) ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (ត)

(vii) ឱនភាពនៃតម្លៃ (ត)

ការជម្រះចេញពីបញ្ជី

ឥណទាន និងមូលបត្របំណុលត្រូវបានជម្រះចេញពីបញ្ជី (ជាផ្នែក ឬទាំងស្រុង) នៅពេលមិនមានការរំពឹងទុកសមហេតុផលថា អាចប្រមូលបានមកវិញនូវទ្រព្យសកម្មហិរញ្ញវត្ថុនោះទាំងស្រុង ឬចំណែកណាមួយ។ ករណីនេះមានជាទូទៅ នៅពេលសម្ព័ន្ធធនាគារ និងធនាគារកំណត់ថាអ្នកខ្ចីពុំមានទ្រព្យសកម្ម ឬប្រភពចំណូលណាដែលអាចបង្កើតបាននូវលំហូរសាច់ប្រាក់គ្រប់គ្រាន់ ដើម្បីទូទាត់សងនូវចំនួនដែលត្រូវលុបចេញពីបញ្ជី។ ការវាយតម្លៃនេះត្រូវបានធ្វើឡើងតាមកម្រិតទ្រព្យសកម្មទោល។

ទឹកប្រាក់ដែលប្រមូលបានមកវិញពីចំនួនដែលបានលុបចេញពីបញ្ជី ត្រូវបញ្ចូលនៅក្នុងរបាយការណ៍ចំណេញ ឬខាត និងលទ្ធផលម្ជិតផ្សេងៗ។

ទ្រព្យសកម្មហិរញ្ញវត្ថុដែលបានជម្រះចេញពីបញ្ជី នៅតែអាចជាកម្មវត្ថុចំពោះសកម្មភាពទាមទារសងមកវិញតាមផ្លូវច្បាប់ ដើម្បីអនុលោមតាមនីតិវិធីរបស់សម្ព័ន្ធធនាគារ និងធនាគារក្នុងការប្រមូលមកវិញនូវទឹកប្រាក់ដែលនៅជំពាក់។

ការធានាហិរញ្ញវត្ថុមិនមែនជាផ្នែកសំខាន់នៃកិច្ចសន្យា

សម្ព័ន្ធធនាគារ និងធនាគារ វាយតម្លៃថាតើកិច្ចសន្យាធានាហិរញ្ញវត្ថុ គឺជាធាតុផ្សំមួយដ៏សំខាន់នៃទ្រព្យសកម្មហិរញ្ញវត្ថុ ដែលត្រូវបានរាប់បញ្ចូលជាសមាសធាតុនៃឧបករណ៍នោះ ឬជាកិច្ចសន្យាដែលត្រូវបានកត់ត្រាដោយឡែកពីគ្នា។ កត្តាដែលសម្ព័ន្ធធនាគារ និងធនាគារពិចារណានៅពេលធ្វើការវាយតម្លៃនេះ រួមមាន៖

- ការធានា គឺជាផ្នែកមួយនៃលក្ខខណ្ឌតាមកិច្ចសន្យារបស់ឧបករណ៍បំណុល
- ការធានាត្រូវបានទាមទារដោយច្បាប់ និងបទប្បញ្ញត្តិដែលគ្រប់គ្រងកិច្ចសន្យារបស់ឧបករណ៍បំណុល
- ការធានាត្រូវបានបញ្ចូលក្នុងពេលដំណាលគ្នានិងឧបករណ៍បំណុល និង
- ការធានាត្រូវបានផ្តល់ដោយក្រុមហ៊ុនមេរបស់អ្នកខ្ចី ឬក្រុមហ៊ុនផ្សេងទៀតនៅក្នុងសម្ព័ន្ធរបស់អ្នកខ្ចី។

ធនាគារ អេស៊ីលីដា ភីអិលស៊ី និង ក្រុមហ៊ុនបុត្រសម្ព័ន្ធ

កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ និងសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់

២. សេចក្តីសង្ខេបអំពីគោលនយោបាយគណនេយ្យសំខាន់ៗ (ត)

(ង) ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (ត)

(vii) ឱនភាពនៃតម្លៃ (ត)

ការធានាហិរញ្ញវត្ថុមិនមែនជាផ្នែកសំខាន់នៃកិច្ចសន្យា (ត)

ប្រសិនបើសម្ព័ន្ធធនាគារ និងធនាគារកំណត់ថាការធានាគឺជាធាតុផ្សំសំខាន់មួយនៃទ្រព្យសកម្មហិរញ្ញវត្ថុ នោះបុព្វលាភត្រូវសងណាមួយទាក់ទងនឹងការទទួលស្គាល់លើកដំបូងនៃទ្រព្យសកម្មហិរញ្ញវត្ថុ ត្រូវបានចាត់ទុកថាជាចំណាយ ប្រតិបត្តិការក្នុងការធ្វើលទ្ធកម្មទ្រព្យសកម្មហិរញ្ញវត្ថុ។ សម្ព័ន្ធធនាគារ និងធនាគារពិចារណាលើផលប៉ះពាល់នៃការការពារនៅពេលវាស់វែងតម្លៃសមស្របនៃឧបករណ៍បំណុល និងនៅពេលវាស់វែង ECL។

ប្រសិនបើសម្ព័ន្ធធនាគារ និងធនាគារកំណត់ថាការធានាមិនមែនជាធាតុផ្សំសំខាន់នៃឧបករណ៍បំណុលទេ នោះវាទទួលស្គាល់ជាទ្រព្យសកម្មមួយ ដែលបង្ហាញពីការបង់ប្រាក់ជាមុននៃបុព្វលាភនៃការធានា និងសិទ្ធិទូទាត់សងសម្រាប់ការខាតបង់ឥណទាន។ ទ្រព្យសកម្មបុព្វលាភបង់មុន ត្រូវបានទទួលស្គាល់លុះត្រាតែការធានាមិនមានឱនភាពនៃតម្លៃឥណទាន ឬមិនមានការកើនឡើងជាសារវន្តនូវ ហានិភ័យឥណទាននៅពេលការធានាត្រូវបានទទួលស្គាល់។ ទ្រព្យសកម្មទាំងនេះត្រូវបានទទួលស្គាល់នៅក្នុង "ទ្រព្យសកម្មផ្សេងៗ"។ សម្ព័ន្ធធនាគារ និងធនាគារបង្ហាញពីចំណេញ ឬខាត លើសិទ្ធិទទួលបានសំណងនៅក្នុងចំណេញ ឬខាត ក្នុងធាតុជួរ "ការខាតបង់លើឱនភាពនៃតម្លៃរបស់ឧបករណ៍ហិរញ្ញវត្ថុ"។

(viii) ឧបករណ៍ហិរញ្ញវត្ថុនិស្សន្ទស៍

សម្ព័ន្ធធនាគារ និងធនាគារមានឧបករណ៍ហិរញ្ញវត្ថុនិស្សន្ទស៍ច្រើនប្រភេទ ដើម្បីគ្រប់គ្រងការប្រឈមទៅនឹងហានិភ័យអត្រាការប្រាក់តាមរយៈការផ្លាស់ប្តូរអត្រាការប្រាក់។ ការប្រើប្រាស់ឧបករណ៍ហិរញ្ញវត្ថុនិស្សន្ទស៍ត្រូវបានគ្រប់គ្រងដោយគោលនយោបាយរបស់សម្ព័ន្ធធនាគារ និងធនាគារ ដែលបានអនុម័តដោយក្រុមប្រឹក្សាភិបាល ដែលផ្តល់នូវគោលការណ៍ជាលាយលក្ខណ៍អក្សរលើការប្រើប្រាស់និស្សន្ទស៍ហិរញ្ញវត្ថុ។

ឧបករណ៍និស្សន្ទស៍ ត្រូវបានទទួលស្គាល់ដំបូងតាមតម្លៃសមស្របនាកាលបរិច្ឆេទនៃកិច្ចសន្យានៃឧបករណ៍និស្សន្ទស៍ដែលបានធ្វើឡើង និងត្រូវបានវាស់វែងជាបន្តបន្ទាប់តាមតម្លៃសមស្របរបស់វានាកាលបរិច្ឆេទនៃរបាយការណ៍នីមួយៗ។ លទ្ធផលចំណេញ/ខាត ត្រូវបានទទួលស្គាល់ក្នុងគណនីចំណេញ ឬខាតភ្លាមៗ លើកលែងតែឧបករណ៍និស្សន្ទស៍ត្រូវបានកំណត់ និងមានប្រសិទ្ធិភាពជាឧបករណ៍ការពារហានិភ័យ ក្នុងរយៈពេលនៃព្រឹត្តិការណ៍ក្នុងការទទួលស្គាល់ក្នុងគណនីចំណេញ ឬខាត គឺអាស្រ័យលើលក្ខណៈនៃទំនាក់ទំនងនៃការការពារហានិភ័យ។

ឧបករណ៍និស្សន្ទស៍ដែលមានតម្លៃសមស្របវិជ្ជមានត្រូវបានទទួលស្គាល់ជាទ្រព្យសកម្មហិរញ្ញវត្ថុ ខណៈពេលដែលឧបករណ៍និស្សន្ទស៍ដែលមានតម្លៃសមស្របអវិជ្ជមានត្រូវបានទទួលស្គាល់ជាបំណុលហិរញ្ញវត្ថុ។ ឧបករណ៍និស្សន្ទស៍ មិនត្រូវបានកាត់កងនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុលើកលែងតែសម្ព័ន្ធធនាគារមានទាំងសិទ្ធិស្របច្បាប់និងគោលបំណងក្នុងការកាត់កង។

ធនាគារ អេស៊ីលីដា ភីអិលស៊ី និង ក្រុមហ៊ុនបុត្រសម្ព័ន្ធ

កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ និងសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់

២. សេចក្តីសង្ខេបអំពីគោលនយោបាយគណនេយ្យសំខាន់ៗ (ត)

(ង) ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (ត)

(ix) គណនេយ្យការពារលើហានិភ័យ

សម្ព័ន្ធធនាគារ និងធនាគារកំណត់នូវឧបករណ៍និស្សន្ទស៍ជាក់លាក់ជាឧបករណ៍ការពារហានិភ័យដែលទាក់ទងនឹងហានិភ័យរូបិយប័ណ្ណបរទេស និងហានិភ័យអត្រាការប្រាក់ក្នុងការការពារហានិភ័យតម្លៃសមស្រប ការការពារហានិភ័យលើលំហូរសាច់ប្រាក់ ឬការការពារហានិភ័យដែលសមស្របក្នុងការវិនិយោគក្នុងក្រុមហ៊ុនបរទេស។ ការការពារហានិភ័យនៃអត្រាការប្រាក់តាមកិច្ចព្រមព្រៀងរបស់ក្រុមហ៊ុន ត្រូវបានកំណត់ជាការការពារហានិភ័យលំហូរសាច់ប្រាក់។ សម្ព័ន្ធធនាគារ និងធនាគារមិនត្រូវបានអនុវត្តទៅលើគណនេយ្យការពារហានិភ័យតម្លៃសមស្របនៃផលប័ត្រនៃការការពារហានិភ័យអត្រាការប្រាក់។

នាកាលបរិច្ឆេទនៃការចាប់ផ្តើមអនុវត្តលើការការពារហានិភ័យ សម្ព័ន្ធធនាគារ និងធនាគារធ្វើការកត់ត្រាពីទំនាក់ទំនងរវាងឧបករណ៍ការពារហានិភ័យ និងសមាសធាតុការពារហានិភ័យ រួមជាមួយគោលបំណងចម្បងក្នុងការគ្រប់គ្រងហានិភ័យ និងយុទ្ធសាស្ត្ររបស់ក្រុមហ៊ុនក្នុងការធ្វើប្រតិបត្តិការក្នុងការការពារហានិភ័យ។

បន្ថែមពីនេះទៀត នាកាលបរិច្ឆេទនៃការចាប់ផ្តើមការការពារហានិភ័យ និងបន្តនិរន្តរភាព សម្ព័ន្ធធនាគារ និងធនាគារកត់ត្រាថាតើឧបករណ៍ការពារហានិភ័យមានប្រសិទ្ធិភាពក្នុងការកាត់កងក្នុងការផ្លាស់ប្តូរតម្លៃសមស្រប ឬលំហូរសាច់ប្រាក់នៃឧបករណ៍ការពារហានិភ័យដែលចូលរួមក្នុងការការពារហានិភ័យ នៅពេលដែលការការពារហានិភ័យទាក់ទងនឹងការបំពេញតាមតម្រូវការក្នុងការការពារហានិភ័យប្រកបដោយប្រសិទ្ធិភាពដូចខាងក្រោម៖

- មិនមានទំនាក់ទំនងផ្នែកសេដ្ឋកិច្ចរវាងសមាសធាតុគណនីការពារហានិភ័យ និងឧបករណ៍ការពារហានិភ័យ
- ផលប៉ះពាល់ពីហានិភ័យឥណទានមិនទទួលឥទ្ធិពលពីការផ្លាស់ប្តូរតម្លៃដែលជាលទ្ធផលពីទំនាក់ទំនងផ្នែកសេដ្ឋកិច្ច និង
- អនុបាតនៃការការពារហានិភ័យដែលទាក់ទង គឺដូចគ្នាទៅនឹងលទ្ធផលពីបរិមាណការពារហានិភ័យដែលសម្ព័ន្ធធនាគារ និងធនាគារធ្វើការការពារហានិភ័យជាក់ស្តែង និងបរិមាណនៃឧបករណ៍ការពារហានិភ័យដែលសម្ព័ន្ធធនាគារ និងធនាគារបានប្រើប្រាស់ជាក់ស្តែងក្នុងការពារហានិភ័យ។

សម្ព័ន្ធធនាគារ និងធនាគារ ធ្វើតុល្យភាពឡើងវិញទាក់ទងនឹងការពារហានិភ័យ ដើម្បីបំពេញនូវតម្រូវការនៃអនុបាតការពារហានិភ័យនៅពេលដែលចាំបាច់។

ប្រសិនបើទំនាក់ទំនងនៃការពារហានិភ័យ មិនបានបំពេញតាមតម្រូវការនៃការការពារហានិភ័យប្រកបដោយប្រសិទ្ធិភាពទាក់ទងអនុបាតការពារហានិភ័យ ប៉ុន្តែគោលបំណងនៃការគ្រប់គ្រងហានិភ័យសម្រាប់ទំនាក់ទំនងនៃការ

ធនាគារ អេស៊ីលីដា ភីអិលស៊ី និង ក្រុមហ៊ុនបុត្រសម្ព័ន្ធ

កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ និងសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់

២. សេចក្តីសង្ខេបអំពីគោលនយោបាយគណនេយ្យសំខាន់ៗ (ត)

(ង) ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ (ត)

(ix) គណនេយ្យការពារលើហានិភ័យ (ត)

ការពារហានិភ័យនៅរក្សាដដែល សម្ព័ន្ធធនាគារ និងធនាគារធ្វើការកែតម្រូវលើអនុបាតការពារហានិភ័យនៃទំនាក់ទំនងនៃការការពារហានិភ័យ (ឧទាហរណ៍ ធ្វើតុល្យភាពការពារហានិភ័យឡើងវិញ) ដូច្នេះវាបំពេញតាមតម្រូវការលក្ខណៈនៃវិនិច្ឆ័យ ម្តងទៀត។

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ សម្ព័ន្ធធនាគារ និងធនាគារ មានតែការការពារហានិភ័យលំហូរសាច់ប្រាក់តែប៉ុណ្ណោះនៅក្នុងកិច្ចសន្យាផ្លាស់ប្តូរអត្រាការប្រាក់។

ផ្នែកដែលមានប្រសិទ្ធិភាពក្នុងការផ្លាស់ប្តូររលើតម្លៃសមស្របនៃឧបករណ៍ហិរញ្ញវត្ថុនិស្សន្ទស៍ និងឧបករណ៍ការពារហានិភ័យដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ដែលត្រូវបានកំណត់ និងការការពារហានិភ័យលំហូរសាច់ប្រាក់ត្រូវបានទទួលស្គាល់ក្នុងគណនីប្រាក់ចំណេញរក្សាទុករបស់សម្ព័ន្ធធនាគារ និងធនាគារ បានកំណត់ទៅលើការផ្លាស់ប្តូរតម្លៃសមស្របលើសមាសធាតុការពារហានិភ័យ ចាប់ពីកាលបរិច្ឆេទចាប់ផ្តើមការការពារហានិភ័យដកចេញ នូវសមតុល្យដែលបានកែតម្រូវឡើងវិញទៅលើគណនីចំណេញ ឬខាត។

សមតុល្យសាច់ប្រាក់ដែលបានទទួលស្គាល់កន្លងមកក្នុង លទ្ធផលលម្អិតផ្សេងៗ និងត្រូវបានបង្ករក្នុងគណនីមូលធនត្រូវបានធ្វើ ចំណាត់ថ្នាក់ឡើងវិញទៅជាគណនីចំណេញ ឬខាត ក្នុងកាលបរិច្ឆេទនៅពេលដែលសមាសធាតុការពារហានិភ័យប៉ះពាល់ដល់គណនីចំណេញ ឬខាត ក្នុងករណីដូចគ្នាក្នុងការទទួលស្គាល់សមាសធាតុការពារហានិភ័យ។ ប្រសិនបើសម្ព័ន្ធធនាគារ និងធនាគារមិនរំពឹងទុកថាប្រតិបត្តិការនេះនឹងកើតឡើង នោះសមតុល្យនេះត្រូវបានចាត់ថ្នាក់ឡើងវិញភ្លាមៗទៅក្នុងគណនីចំណេញ ឬខាត។

សម្ព័ន្ធធនាគារ និងធនាគារបញ្ចប់គណនីការពារហានិភ័យលុះត្រាតែទំនាក់ទំនងការពារហានិភ័យ (ឬផ្នែកមួយរបស់វា) មិនបានបំពេញតាមលក្ខណៈវិនិច្ឆ័យគ្រប់គ្រាន់ (បន្ទាប់ពីការធ្វើសមតុល្យឡើងវិញ ប្រសិនបើអាចអនុវត្តបាន)។ ទាំងនេះរួមបញ្ចូលទាំងករណីដែលឧបករណ៍ការពារហានិភ័យបានហួសកាលកំណត់ ឬបានលក់ចេញ បានលុបចោល ឬបានប្រើប្រាស់ ឬនៅពេលដែលប្រតិបត្តិការក្នុងការព្យាករណ៍លើការការពារហានិភ័យដែលបានកំណត់មិនត្រូវបានកំណត់ថាអាចកើតមានឡើង។ ការបញ្ឈប់ ត្រូវបានកំណត់សម្រាប់ពេលអនាគត។ រាល់ការចំណេញ/ខាត ត្រូវបានទទួលស្គាល់ក្នុង លទ្ធផលលម្អិតផ្សេងៗ និង បង្ករទុកក្នុងគណនីមូលធននាកាលបរិច្ឆេទដែលគណនីមូលធនដែលនៅសល់ ហើយត្រូវបានទទួលស្គាល់នៅពេលដែលការព្យាករណ៍ប្រតិបត្តិការត្រូវបានទទួលស្គាលចុងក្រោយក្នុងគណនីចំណេញ ឬខាត។ នៅពេលដែលការព្យាករណ៍ប្រតិបត្តិការមិនត្រូវបានរំពឹងទុកថានឹងកើតមានឡើងទៀត ចំណេញ/ខាត ត្រូវបានបង្ករក្នុងគណនីមូលធន គឺត្រូវបានចាត់ថ្នាក់ឡើងវិញ និងបានទទួលស្គាល់ភ្លាមៗ ក្នុងគណនីចំណេញ ឬខាត។

២. សេចក្តីសង្ខេបអំពីគោលនយោបាយគណនេយ្យសំខាន់ៗ (ត)

(ច) សាច់ប្រាក់ និងសាច់ប្រាក់សមមូល

សាច់ប្រាក់ និងសាច់ប្រាក់សមមូល រួមមានសាច់ប្រាក់ក្នុងដៃ និង ប្រាក់បញ្ញើនៅធនាគារផ្សេងៗ ដែលឥណប្រតិទានដំបូងមានរយៈពេល ៣ខែ ឬតិចជាង និងដែលអាចប្តូរជាសាច់ប្រាក់ពេលណាក៏បាន ដោយមានហានិភ័យតិចតួចចំពោះការផ្លាស់ប្តូរតម្លៃ។

សាច់ប្រាក់ និងសមមូលសាច់ប្រាក់ ត្រូវបានគិតតាមតម្លៃដករំលស់ក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។

(ឆ) ឥណទាន និងបុរេប្រទាន

"ឥណទាន និងបុរេប្រទាន" ដែលបង្ហាញនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ រួមមានឥណទាន និងបុរេប្រទាន ដែលបានវាស់វែងតាមតម្លៃដករំលស់។ ឥណទាន និងបុរេប្រទានត្រូវបានវាស់វែងលើកដំបូងតាមតម្លៃសមស្រប បូកនឹងចំណាយប្រតិបត្តិការដែលកើតឡើងដោយផ្ទាល់បន្ថែម ហើយនាពេលបន្ទាប់ត្រូវកត់ត្រាតាមតម្លៃដករំលស់ដោយប្រើវិធីសាស្ត្រការប្រាក់ប្រសិទ្ធភាព។

(ជ) ការវិនិយោគហិរញ្ញវត្ថុ

"ការវិនិយោគហិរញ្ញវត្ថុ" ដែលបង្ហាញនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ រួមមាន៖

- មូលបត្រវិនិយោគបំណុល ដែលបានវាស់វែងតាមតម្លៃដករំលស់ថ្លៃដើម។ មូលបត្រវិនិយោគបំណុលទាំងនេះត្រូវបានវាស់លើកដំបូង តាមតម្លៃសមស្របបូកនឹងចំណាយប្រតិបត្តិការដែលកើតឡើងដោយផ្ទាល់បន្ថែម ហើយនាពេលបន្ទាប់ត្រូវកត់ត្រាតាមតម្លៃដករំលស់ដោយប្រើវិធីសាស្ត្រការប្រាក់ប្រសិទ្ធភាព។
- មូលបត្របំណុលដែលវាស់វែងតាម FVOCI និង
- មូលបត្រវិនិយោគលើមូលធនដែលបានកំណត់តាម FVOCI។

ចំពោះមូលបត្របំណុលដែលបានវាស់វែងតាម FVOCI ចំណេញ និងខាត ត្រូវបានទទួលស្គាល់នៅក្នុងលទ្ធផលលម្អិតផ្សេងៗលើកលែងតែចំណុចដូចខាងក្រោម ដែលត្រូវបានទទួលស្គាល់នៅក្នុងចំណេញ ឬខាត តាមរបៀបដូចគ្នានឹងទ្រព្យសកម្មហិរញ្ញវត្ថុដែលត្រូវបានវាស់តាមតម្លៃដករំលស់៖

- ចំណូលការប្រាក់ដោយប្រើវិធីសាស្ត្រការប្រាក់ប្រសិទ្ធភាព
- ECL និងការកត់ត្រាបញ្ច្រាស និង
- ចំណេញ និងខាតលើការប្តូររូបិយប័ណ្ណបរទេស។

ធនាគារ អេស៊ីលីដា ភីអិលស៊ី និង ក្រុមហ៊ុនបុត្រសម្ព័ន្ធ

កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ និងសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់

២. សេចក្តីសង្ខេបអំពីគោលនយោបាយគណនេយ្យសំខាន់ៗ (ត)

(ជ) ការវិនិយោគហិរញ្ញវត្ថុ (ត)

នៅពេលដែលមូលបត្របំណុលវាស់វែងតាម FVOCI ត្រូវបានឈប់ទទួលស្គាល់ ចំណេញ ឬខាតបង្គរដែលបានទទួលស្គាល់ពីមុននៅក្នុងលទ្ធផលលម្អិតផ្សេងៗ ត្រូវបានចាត់ថ្នាក់ឡើងវិញពីមូលធន ទៅរបាយការណ៍ចំណេញ ឬខាត។

សម្ព័ន្ធធនាគារ និងធនាគារជ្រើសរើសបង្ហាញនៅក្នុងលទ្ធផលលម្អិតផ្សេងៗ អំពីការផ្លាស់ប្តូរនៅក្នុងតម្លៃសមស្របនៃការវិនិយោគជាក់លាក់នៅក្នុងឧបករណ៍មូលធន ដែលមិនត្រូវបានទុកសម្រាប់ជួញដូរ។ ការជ្រើសរើសនេះធ្វើឡើងដោយផ្អែកលើមូលដ្ឋាននៃឧបករណ៍នីមួយៗនៅពេលទទួលស្គាល់លើកដំបូង និងជាស្ថាពរ។

ចំណេញ និងខាតលើឧបករណ៍មូលធនទាំងនេះនឹងមិនត្រូវបានចាត់ថ្នាក់ឡើងវិញទៅរបាយការណ៍ចំណេញ ឬខាតទេ ហើយក៏ពុំមានឱនភាពនៃតម្លៃត្រូវបានទទួលស្គាល់ក្នុងរបាយការណ៍ចំណេញ ឬខាតដែរ។ ភាគលាភត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ចំណេញ ឬខាត លើកលែងតែវាបង្ហាញយ៉ាងច្បាស់ពីការប្រមូលបានមកវិញលើផ្នែកខ្លះរបស់ថ្លៃដើមនៃការវិនិយោគ ក្នុងករណីដែលពួកគេត្រូវបានទទួលស្គាល់ នៅក្នុងលទ្ធផលលម្អិតផ្សេងៗ។ ចំណេញ និងខាតបង្គរដែលត្រូវបានទទួលស្គាល់នៅក្នុងលទ្ធផលលម្អិតផ្សេងៗត្រូវបានផ្ទេរទៅប្រាក់ចំណេញរក្សាទុកលើការលក់ចេញរបស់ការវិនិយោគ។

(ឈ) ដើមទុន

ភាគហ៊ុនធម្មតា ត្រូវបានចាត់ថ្នាក់ជាមូលធន។ ភាគហ៊ុនដទៃទៀតត្រូវបានចាត់ថ្នាក់ជាមូលធន និង/ឬបំណុលផ្អែកលើសមាសធាតុសេដ្ឋកិច្ចនៃឧបករណ៍ទាំងនោះ។ ការបែងចែកទៅអ្នកកាន់កាប់ឧបករណ៍ហិរញ្ញវត្ថុមួយ ដែលបានចាត់ថ្នាក់ជាឧបករណ៍មូលធន ត្រូវបានទូទាត់ដោយផ្ទាល់ពីមូលធន។

(ញ) ចំណេញក្នុងមួយភាគហ៊ុន

ចំណេញក្នុងមួយភាគហ៊ុនមូលដ្ឋាន (EPS) គឺកំណត់ដោយយកប្រាក់ចំណេញសុទ្ធដែលបានធ្វើនិយ័តកម្មរួចបែងចែកទៅម្ចាស់ភាហ៊ុនដោយចែកនឹងចំនួនជាមធ្យមនៃចំនួនភាគហ៊ុនដែលមាននៅក្នុងអំឡុងការិយបរិច្ឆេទ បន្ទាប់ពីការបែងចែកភាគលាភនៅក្នុងការិយបរិច្ឆេទ។

ចំណេញក្នុងមួយភាគហ៊ុនថយចុះ ក៏គណនាដូចគ្នាដោយយកប្រាក់ចំណេញសុទ្ធចែកនឹងចំនួនជាមធ្យមនៃចំនួនភាគហ៊ុនដែលមាន និងចេញផ្សាយនៅក្នុងអំឡុងការិយបរិច្ឆេទ។ ទោះជាយ៉ាងណាក៏ដោយប្រាក់ចំណេញសុទ្ធសម្រាប់បែងចែកភាគហ៊ុន និងចំនួនជាមធ្យមនៃចំនួនភាគហ៊ុនដែលមាន គឺត្រូវធ្វើនិយ័តកម្មដើម្បីឆ្លុះបញ្ចាំងពីផលប៉ះពាល់លើភាគហ៊ុនដែលអាចបម្លែង។ ភាគហ៊ុនដែលអាចបម្លែងបាន ត្រូវបានបម្លែងទៅជាភាគហ៊ុនបោះផ្សាយសម្រាប់ភាគហ៊ុនធម្មតា។

ធនាគារ អេស៊ីលីដា ភីអិលស៊ី និង ក្រុមហ៊ុនបុត្រសម្ព័ន្ធ

កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ និងសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់

២. សេចក្តីសង្ខេបអំពីគោលនយោបាយគណនេយ្យសំខាន់ៗ (ត)

(ញ) ចំណេញក្នុងមួយភាគហ៊ុន (ត)

ក្នុងករណីបង់ផ្តាច់នៃភាគហ៊ុនធម្មតា ប្រាក់ចំណេញសុទ្ធដែលយកទៅគណនាចំណេញក្នុងមួយភាគហ៊ុនមូលដ្ឋាន និងចំណេញក្នុងមួយភាគហ៊ុនថយចុះ គឺថយចុះដោយភាពលើសនៃតម្លៃសមស្របដែលបានបង់ទៅអ្នកកាន់កាប់ឧបករណ៍ លើតម្លៃយោងនៃការទទួលទិញឧបករណ៍នោះ។

(ដ) ទ្រព្យ និងបរិក្ខារ

ទ្រព្យ និងបរិក្ខារត្រូវបានកត់ត្រាតាមថ្លៃដើម ដករំលស់បង្គរ និងការខាតបង់ឱនភាពនៃតម្លៃបង្គរ។ ថ្លៃដើមរួមមានការចំណាយផ្ទាល់នានា ក្នុងការធ្វើលទ្ធកម្មទ្រព្យសកម្មទាំងនោះ។

ថ្លៃដើមរបស់ទ្រព្យសម្បត្តិ និងបរិក្ខារមាន៖

- តម្លៃទិញចូលនៃទ្រព្យសម្បត្តិ និងបរិក្ខារ រួមទាំងចំណាយនាំចូល និងពន្ធលើការទិញដែលមិនអាចដកមកវិញបាន បន្ទាប់ពីការដកតម្លៃអប្បហារពាណិជ្ជកម្ម និងការបង្វិលប្រាក់មកវិញ និង
- ថ្លៃដើមណាមួយដែលពាក់ព័ន្ធដោយផ្ទាល់ទៅនឹងការនាំយកទ្រព្យសម្បត្តិទៅកាន់ទីតាំង និងលក្ខខណ្ឌដែលសមស្របក្នុងការធ្វើប្រតិបត្តិការអាជីវកម្មតាមការកំណត់របស់អ្នកគ្រប់គ្រង។

ចំណាយបន្តបន្ទាប់ផ្សេងៗត្រូវបានកត់ត្រាបញ្ចូលទៅក្នុងតម្លៃយោងនៃទ្រព្យនោះ ឬត្រូវបានកត់ត្រាជាទ្រព្យដាច់ដោយឡែក តាមការសមស្រប តែនៅពេលដែលមានភាពប្រាកដប្រជាថា ផលប្រយោជន៍សេដ្ឋកិច្ចនាពេលអនាគត នៃទ្រព្យនោះនឹងហូរចូលមកក្នុងសម្ព័ន្ធធនាគារ និងធនាគារ ហើយថ្លៃដើមនៃទ្រព្យនោះអាចត្រូវបានវាស់វែងគួរឱ្យជឿជាក់បានតែប៉ុណ្ណោះ។ តម្លៃយោងផ្នែកនៃទ្រព្យដែលបានជំនួសត្រូវបានឈប់ទទួលស្គាល់។ រាល់ចំណាយលើការជួសជុល និងការថែទាំផ្សេងៗទៀតទាំងអស់ ត្រូវបានកត់ត្រាជាបន្ទុកនៅក្នុងរបាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗ ក្នុងឆ្នាំដែលប្រតិបត្តិការនោះកើតឡើង។

ថ្លៃដើមក្នុងការសាងសង់ទ្រព្យសម្បត្តិដោយខ្លួនឯង រួមបញ្ចូលទាំងចំណាយលើវត្ថុធាតុដើម និងកម្លាំងពលកម្មផ្ទាល់ រួមទាំងចំណាយណាមួយដែលចូលរួមដោយផ្ទាល់ក្នុងការនាំយកទ្រព្យសម្បត្តិទៅកាន់លក្ខខណ្ឌការងារសម្រាប់គោលបំណងនៃការប្រើប្រាស់ដែលបានគ្រោងទុក រួមទាំងថ្លៃដើមនៃការរុះរើ និងការដកហូតធាតុនៃទ្រព្យសម្បត្តិ និងការរៀបចំទីតាំងដែលទ្រព្យសម្បត្តិនោះស្ថិតនៅ ហើយនិងចំណាយការប្រាក់ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់។ ដីធ្លីមិនត្រូវបានធ្វើរំលស់ទេ។ ទ្រព្យ និងបរិក្ខារផ្សេងទៀតត្រូវបានធ្វើរំលស់តាមមូលដ្ឋានរំលស់ថេរ ដើម្បីលុបចេញពីបញ្ជីនូវថ្លៃដើមនៃទ្រព្យសកម្មត្រឹមតម្លៃកាកសំណល់លើអាយុកាលប្រើប្រាស់ប៉ាន់ស្មាននៃ ទ្រព្យសកម្មនីមួយៗ សង្ខេបដូចខាងក្រោម៖

២. សេចក្តីសង្ខេបអំពីគោលនយោបាយគណនេយ្យសំខាន់ៗ (ត)

(ដ) ទ្រព្យ និងបរិក្ខារ (ត)

	ឆ្នាំ
ការកែលម្អលើដី	៣ ដល់ ២០
អគារ និង ការកែលម្អ	៣ ដល់ ២០
ការកែលម្អលើទ្រព្យជួល*	៣ ដល់ ៥
បរិក្ខារការិយាល័យ	៣ ដល់ ៧
បរិក្ខារកុំព្យូទ័រ	៣ ដល់ ៧
យានយន្ត	៣ ដល់ ៨

** ការកែលម្អលើទ្រព្យជួល គឺត្រូវបានរំលស់ដោយផ្អែកលើអាយុកាលប្រើប្រាស់នៃការកែលម្អចាប់ពី៣ឆ្នាំ ដល់៥ឆ្នាំ ឬ រយៈពេលខ្លីជាងនេះនៃកតិសន្យាដែលពាក់ព័ន្ធ។*

តម្លៃកាកសំណល់របស់ទ្រព្យសកម្ម និងអាយុកាលប្រើប្រាស់ត្រូវបានត្រួតពិនិត្យ និងកែតម្រូវប្រសិនជាមានភាពសមស្រប នៅរៀងរាល់ចុងការិយបរិច្ឆេទនៃរបាយការណ៍នីមួយៗ។

រំលស់លើទ្រព្យសកម្មដែលកំពុងសាងសង់ចាប់ផ្តើមនៅពេលដែលទ្រព្យសកម្មត្រូវបានត្រៀមរួចរាល់ សម្រាប់ការប្រើប្រាស់ដែលបានគ្រោងទុក។

ទ្រព្យ និងបរិក្ខារ ត្រូវបានពិនិត្យឡើងវិញ សម្រាប់ការបង្ហាញពីឱនភាពនៃតម្លៃនៅរៀងរាល់កាលបរិច្ឆេទនៃរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុនីមួយៗ និងរាល់ពេលដែលព្រឹត្តិការណ៍ ឬការផ្លាស់ប្តូរកាលៈទេសៈបង្ហាញថាតម្លៃយោងអាចនឹងមិនអាចប្រមូលបានមកវិញ។ នៅពេលដែលតម្លៃយោងនៃទ្រព្យសកម្មណាមួយលើសពីតម្លៃដែលអាចប្រមូលបានមកវិញដែលប៉ាន់ស្មាន ត្រូវបានកត់ត្រាបន្ថយឱ្យនៅត្រឹមតម្លៃដែលអាចប្រមូលបានមកវិញ។

ចំណេញ និងខាតពីការលក់ទ្រព្យ និងបរិក្ខារ ត្រូវបានកំណត់ដោយធ្វើការប្រៀបធៀបចំណូលបានមកពីការលក់ និងតម្លៃយោង ហើយត្រូវបានកត់ត្រានៅក្នុងចំណូលផ្សេងៗ។

(ឋ) ទ្រព្យសកម្មអរូបី

ទ្រព្យអរូបីរួមមានអាជ្ញាប័ណ្ណសូហ្វវែរកុំព្យូទ័រដែលបានធ្វើលទ្ធកម្ម និងចំណាយដែលទាក់ទង។ ទ្រព្យសកម្មអរូបីត្រូវបានទទួលស្គាល់តែនៅពេលដែលការចំណាយរបស់វាអាចវាស់វែងដោយជឿទុកចិត្តបាន ហើយទំនងជាផលប្រយោជន៍សេដ្ឋកិច្ចនាពេលអនាគតដែលរំពឹងទុក នឹងហូរចូលក្នុងសម្ព័ន្ធធនាគារ និងធនាគារ។

ធនាគារ អេស៊ីលីដា ភីអិលស៊ី និង ក្រុមហ៊ុនបុត្រសម្ព័ន្ធ

កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ និងសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់

២. សេចក្តីសង្ខេបអំពីគោលនយោបាយគណនេយ្យសំខាន់ៗ (ត)

(ហ) ទ្រព្យសកម្មអរូបី (ត)

ទ្រព្យសកម្មអរូបីត្រូវបានរាយការណ៍តាមថ្លៃដើមប្រវត្តិសាស្ត្រដកវិលស់បង្គរ និងការខាតបង់ឱនភាពនៃតម្លៃបង្គរ ប្រសិនជាមាន។ ទ្រព្យសកម្មអរូបីត្រូវបានធ្វើវិលស់ដោយប្រើប្រាស់វិធីសាស្ត្រថេរលើអាយុកាលប្រើប្រាស់ប៉ាន់ស្មានរបស់ទ្រព្យសកម្ម។ អាយុកាលប្រើប្រាស់របស់សូហ្វវែរកុំព្យូទ័រមានរយៈពេលប្រាំឆ្នាំ លើកលែងតែអាជ្ញាប័ណ្ណកម្មរបស់ប្រព័ន្ធធនាគារស្នូល ដែលមានអាយុកាលប្រើប្រាស់ដប់ឆ្នាំ។

ទ្រព្យសកម្មអរូបីមិនត្រូវបានគេទទួលស្គាល់នៅពេលលុបចោល ឬនៅពេលគ្មានការរំពឹងទុកពីផលប្រយោជន៍សេដ្ឋកិច្ចនាពេលអនាគតពីការប្រើប្រាស់ ឬការលុបចោល។ ចំណេញ ឬខាតដែលកើតចេញពីការមិនទទួលស្គាល់ទ្រព្យសកម្មអរូបីដែលវាស់វែងដោយភាពខុសគ្នារវាងផលចំណេញនៃការលុបចោលសុទ្ធ និងទឹកប្រាក់យោងរបស់ទ្រព្យសកម្មត្រូវបានទទួលស្គាល់ជាប្រាក់ចំណេញ ឬខាត នៅពេលដែលទ្រព្យសកម្មនោះត្រូវបានលុបចោល។ ចំណាយផ្សេងៗពាក់ព័ន្ធនឹងការថែរក្សាសូហ្វវែរកុំព្យូទ័រ ត្រូវបានកត់ត្រាជាចំណាយនៅពេលដែលប្រតិបត្តិការនោះបានកើតឡើង។

(ឌ) ឱនភាពនៃតម្លៃរបស់ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ

ការខាតបង់ឱនភាពត្រូវបានទទួលស្គាល់នៅក្នុងកាលបរិច្ឆេទឆ្នាំចាស់ គឺត្រូវបានវាយតម្លៃនារាល់ចុងការិយបរិច្ឆេទនៃរបាយការណ៍នីមួយៗ សម្រាប់ការចង្អុលបង្ហាញណាមួយដែលបង្ហាញថាការខាតបង់បានថយចុះ ឬមិនបានកើតមានទៀត។ ការខាតបង់ឱនភាពគឺត្រូវបានកត់ត្រាបញ្ច្រាស់ ប្រសិនបើមានការកែប្រែក្នុងការប៉ាន់ស្មានដែលបានប្រើប្រាស់ក្នុងការកំណត់ចំនួនទឹកប្រាក់ដែលអាចប្រមូលមកវិញបាន។ ឱនភាពនៃការខាតបង់ គឺត្រូវបានកត់ត្រាបញ្ច្រាស់ ចំពោះតែទំហំទឹកប្រាក់យោងរបស់ទ្រព្យសកម្មដែលមិនលើសពីចំនួនទឹកប្រាក់ដែលត្រូវបានកំណត់រួចរាល់ ចំនួនវិលស់លើទ្រព្យរូបី និងវិលស់លើទ្រព្យអរូបីសុទ្ធ ប្រសិនបើមិនមានឱនភាពនៃការខាតបង់ត្រូវបានទទួលស្គាល់។ ការកត់ត្រាបញ្ច្រាស់នៃឱនភាពនៃការខាតបង់ត្រូវបានទទួលស្គាល់ជាចំណូល។

ទ្រព្យសកម្មដែលមានអាយុកាលមិនអាចកំណត់បានមិនមែនជាកម្មវត្ថុក្នុងការធ្វើវិលស់ទេ និងត្រូវបានធ្វើតេស្តឡើងវិញជាប្រចាំឆ្នាំដើម្បីកំណត់ឱនភាពនៃតម្លៃ។ ទ្រព្យសកម្មជាកម្មវត្ថុក្នុងការធ្វើវិលស់ត្រូវបានត្រួតពិនិត្យឡើងវិញនៅពេលមានព្រឹត្តិការណ៍ ឬការផ្លាស់ប្តូរក្នុងកាលៈទេសៈ ដែលបង្ហាញថាតម្លៃយោងអាចនឹងមិនប្រមូលបានមកវិញ។ ការខាតបង់ឱនភាពនៃតម្លៃ ត្រូវបានទទួលស្គាល់ស្មើនឹងចំនួនដែលតម្លៃយោងរបស់ ទ្រព្យសកម្ម លើសពីតម្លៃដែលអាចប្រមូលបានមកវិញ។

សម្រាប់គោលបំណងនៃការធ្វើតេស្តឱនភាពនៃតម្លៃ ទ្រព្យសកម្មត្រូវបានដាក់បញ្ចូលគ្នាជាក្រុមតូចៗបំផុតដែលមានលំហូរសាច់ប្រាក់អាចកំណត់បានដោយផ្នែក (អង្គភាពរកសាច់ប្រាក់)។ ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុក្រៅពីមូលនិធិពាណិជ្ជកម្មដែលទទួលរងនូវឱនភាពនៃតម្លៃ ត្រូវបានពិនិត្យឡើងវិញចំពោះការកត់ត្រាបញ្ច្រាស់មកវិញរបស់ឱនភាពនៃតម្លៃដែលអាចកើតមាន។ ការខាតបង់ឱនភាពនៃតម្លៃត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ចំណេញ ឬខាត និងលទ្ធផល លម្អិតផ្សេងៗ។

ធនាគារ អេស៊ីលីដា អ៊ីអិលស៊ី និង ក្រុមហ៊ុនបុត្រសម្ព័ន្ធ

កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ និងសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់

២. សេចក្តីសង្ខេបអំពីគោលនយោបាយគណនេយ្យសំខាន់ៗ (ត)

(ឈ) ទុនបម្រុង

ទុនបម្រុងរួមមាន ទុនបម្រុងទូទៅ ទុនបម្រុងតាមបទប្បញ្ញត្តិ និងទុនបម្រុងផ្សេងៗ។

ទុនបម្រុងទូទៅ ត្រូវបានបង្កើតឡើងសម្រាប់ហានិភ័យហិរញ្ញវត្ថុទូទៅ។ ក្រុមប្រឹក្សាភិបាលអនុវត្តការសម្រេចចិត្តរបស់ខ្លួន សម្រាប់ការប្រើប្រាស់ និងថែរក្សាទុនបម្រុងទូទៅ។ ការផ្ទេរពីប្រាក់ចំណេញរក្សាទុក ទៅទុនបម្រុងទូទៅត្រូវមានការយល់ព្រមពីក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុននីមួយៗនៅក្នុងសម្ព័ន្ធ។

ទុនបម្រុងតាមបទប្បញ្ញត្តិ ត្រូវបានបង្កើតឡើងសម្រាប់ភាពខុសគ្នានៃសំវិធានធនរវាងឱនភាពនៃតម្លៃឥណទានអនុលោមតាម ស.រ.ហ.អ.ក និងសំវិធានធនតាមបទប្បញ្ញត្តិ។ វាត្រូវបានផ្ទេររវាងប្រាក់ចំណេញរក្សាទុក និងទុនបម្រុងតាមបទប្បញ្ញត្តិ។

ទុនបម្រុងផ្សេងៗ គឺសម្រាប់លម្អៀងពីការប្តូររូបិយប័ណ្ណនៃការវិនិយោគសុទ្ធក្នុងកិច្ចប្រតិបត្តិការបរទេស។

(ណ) ពន្ធលើប្រាក់ចំណូលបច្ចុប្បន្ន និងពន្ធពន្យារ

ការចំណាយពន្ធក្នុងឆ្នាំរួមមាន ពន្ធលើប្រាក់ចំណូលបច្ចុប្បន្ន និងពន្ធពន្យារ។ ពន្ធត្រូវបានទទួលស្គាល់នៅក្នុង ចំណេញ ឬខាត លើកលែងតែវិសាលភាពដែលវាទាក់ទងទៅនឹងខ្នង់ដែលត្រូវបានទទួលស្គាល់នៅក្នុងលទ្ធផលលម្អិតផ្សេងៗ ឬដោយផ្ទាល់ក្នុងមូលធន។ ក្នុងករណីនេះ ពន្ធត្រូវបានទទួលស្គាល់នៅក្នុងលទ្ធផលលម្អិតផ្សេងៗ ឬដោយផ្ទាល់ក្នុងមូលធនរៀងៗគ្នា។

ចំណាយពន្ធបច្ចុប្បន្ន ត្រូវបានកំណត់យោងទៅតាមច្បាប់ពន្ធនៃយុត្តាធិការនីមួយៗ ដែលសម្ព័ន្ធធនាគារប្រតិបត្តិការ និងបង្កើតប្រាក់ចំណេញដែលជាប់ពន្ធ និងរាប់បញ្ចូលពន្ធទាំងអស់ដែលផ្អែកលើប្រាក់ចំណេញជាប់ពន្ធ។

ពន្ធលើប្រាក់ចំណូលពន្យារ ត្រូវបានទទួលស្គាល់ទាំងអស់ដោយប្រើវិធីសាស្ត្របំណុលលើភាពខុសគ្នាបណ្តោះអាសន្នដែលកើតឡើងរវាងមូលដ្ឋានពន្ធនៃទ្រព្យសកម្ម និងបំណុល និងចំនួនតម្លៃយោងរបស់ពួកគេនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។ ទោះយ៉ាងណាក៏ដោយពន្ធលើប្រាក់ចំណូលពន្យារ មិនត្រូវបានរាប់បញ្ចូលប្រសិនបើវាកើតឡើងពីការទទួលស្គាល់លើកដំបូងនៃទ្រព្យសកម្ម ឬបំណុល នៅក្នុងប្រតិបត្តិការណាមួយក្រៅពីការរួមបញ្ចូលអាជីវកម្មដែលនៅពេលប្រតិបត្តិការមិនប៉ះពាល់ដល់គណនេយ្យ ឬចំណេញ ឬខាត ដែលជាប់ពន្ធ។

ទ្រព្យសកម្មពន្ធពន្យារ ត្រូវបានទទួលស្គាល់ក្នុងវិសាលភាពដែលវាទំនងថាប្រាក់ចំណេញជាប់ពន្ធនាពេលអនាគតនឹងកើតមានសម្រាប់ភាពខុសគ្នាបណ្តោះអាសន្ន និងការខាតបង់ពន្ធដែលមិនបានប្រើ ឬឥណទានពន្ធដែលមិនបានប្រើ ។

២. សេចក្តីសង្ខេបអំពីគោលនយោបាយគណនេយ្យសំខាន់ៗ (ត)

(ត) អត្ថប្រយោជន៍និយោជិត

(i). អត្ថប្រយោជន៍និយោជិតរយៈពេលខ្លី

សម្ព័ន្ធធនាគារ និងធនាគារទទួលស្គាល់នូវការទទួលស្គាល់បំណុល និងចំណាយសម្រាប់ប្រាក់បន្ថែម។ សម្ព័ន្ធធនាគារ និងធនាគារទទួលស្គាល់សំវិធានធនមួយនៅពេលមានកាតព្វកិច្ចមានកិច្ចសន្យា ឬមានការអនុវត្តកន្លងមកដែលបានបង្កើតកាតព្វកិច្ចស្ថាបនា។

ប្រាក់ឈ្នួល ប្រាក់បៀវត្ស ប្រាក់បន្ថែម និងអត្ថប្រយោជន៍រយៈពេលខ្លីផ្សេងៗ ត្រូវបានទទួលស្គាល់ជាចំណាយក្នុងឆ្នាំ ដែលសេវាកម្មពាក់ព័ន្ធ ត្រូវបានផ្តល់ជូនដោយនិយោជិតរបស់សម្ព័ន្ធធនាគារ និងធនាគារ។

(ii) អត្ថប្រយោជន៍ក្រោយពីបំពេញការងារ

សម្ព័ន្ធធនាគារ និងធនាគារមានផែនការអត្ថប្រយោជន៍ក្រោយពីបំពេញការងារផ្សេងៗច្រើន។ ផែនការអត្ថប្រយោជន៍ទាំងនេះមានដូចខាងក្រោម៖

អត្ថប្រយោជន៍អតីតភាពការងារ

យោងទៅតាមប្រកាសលេខ ៥៤៣ កប/ប្រ.ក.ខ.ល ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៨ និងសេចក្តីណែនាំលេខ ០៤២/១៩ កប/ស.ណ.ន.ខ.ល ចុះថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៩ ចេញដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈធនាគារ និងក្រុមហ៊ុនបុត្រសម្ព័ន្ធលើកលែងតែធនាគារអេស៊ីលីដាឡាវ និងស្ថាប័នមីក្រូហិរញ្ញវត្ថុអេស៊ីលីដាមីយ៉ាន់ម៉ា នឹងផ្តល់ជូននិយោជិតនូវប្រាក់បំណាច់អតីតភាពការងារ ដូចខាងក្រោម៖

- ប្រាក់បំណាច់អតីតភាពការងារបច្ចុប្បន្ន៖ និយោជិតដែលបម្រើការចាប់ពី ១ខែ ដល់ ៦ខែ (មិនរាប់បញ្ចូលរយៈពេលសាកល្បងការងារ) គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឬថ្ងៃទី៣១ ខែធ្នូ នឹងទទួលបានប្រាក់បំណាច់អតីតភាពការងារចំនួន ៧.៥ថ្ងៃ។
- ប្រាក់បំណាច់រំលឹកអតីតភាពការងារ៖ និយោជិតដែលបម្រើការក្រោមកិច្ចសន្យាការងារមានថេរវេលាមិនកំណត់ ហើយបម្រើការចាប់ពី ១ខែ ដល់ ៦ខែ ក្នុងការិយបរិច្ឆេទហិរញ្ញវត្ថុ នឹងទទួលបានប្រាក់រំលឹកអតីតភាពការងារស្មើនឹង ៣ថ្ងៃ ហើយក្នុងករណីបម្រើការងារលើសពី ៣ខែ នឹងទទួលបាន ១៥ថ្ងៃ។ ប្រាក់បំណាច់អតិបរមាដែលត្រូវទូទាត់ មិនត្រូវលើសពី ៦ថ្ងៃ នៃប្រាក់ឈ្នួលមូលដ្ឋានគិតជាមធ្យមតាមឆ្នាំនីមួយៗដែលបានទូទាត់ ចាប់ពីឆ្នាំ២០០៨ ដល់ឆ្នាំ២០១៨ ប៉ុន្តែមិនត្រូវលើសពី ១៥៦ថ្ងៃ ឡើយ។ ប្រាក់បំណាច់នឹងត្រូវទូទាត់ចាប់ពីខែធ្នូ ឆ្នាំ២០២១។

ធនាគារ អេស៊ីលីដា អ៊ីអិលស៊ី និង ក្រុមហ៊ុនបុត្រសម្ព័ន្ធ

កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ និងសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់

២. សេចក្តីសង្ខេបអំពីគោលនយោបាយគណនេយ្យសំខាន់ៗ (ត)

(ត) អត្ថប្រយោជន៍និយោជិត (ត)

(ii) អត្ថប្រយោជន៍ក្រោយពីបំពេញការងារ (ត)

អត្ថប្រយោជន៍អតីតភាពការងារ (ត)

បំណុលនេះត្រូវបានទទួលស្គាល់តាមតម្លៃបច្ចុប្បន្ន នៃកាតព្វកិច្ចដែលបានកំណត់នាកាលបរិច្ឆេទរាយការណ៍ ដោយប្រើវិធីសាស្ត្រឥណទានតាមងកតាព្យាករណ៍ ដើម្បីប៉ាន់ស្មានតម្លៃអត្ថប្រយោជន៍ចុងក្រោយរបស់សម្ព័ន្ធធនាគារ និងធនាគារ ដែលនិយោជិតត្រូវទទួលបានចំពោះសេវាកម្មរបស់ពួកគេនៅក្នុងពេលបម្រើការងារចាប់ពីឆ្នាំ២០០៨ ដល់ ២០១៨។ សម្ព័ន្ធធនាគារ និងធនាគារបែងចែកអត្ថប្រយោជន៍ទៅតាមថេរវេលា ដែលត្រូវទូទាត់ប្រាក់បំណាច់រំលឹកអតីតភាពនេះ។ កាតព្វកិច្ចនេះកើតឡើងនៅពេលនិយោជិតបម្រើការងារដើម្បីទទួលបានប្រាក់បំណាច់រំលឹកអតីតភាពការងារ ដែលសម្ព័ន្ធធនាគារ និងធនាគាររំពឹងថានឹងត្រូវទូទាត់នៅកាលបរិច្ឆេទរាយការណ៍នាពេលអនាគត។

តម្លៃបច្ចុប្បន្នប្រាក់បំណាច់រំលឹកអតីតភាពការងារ ត្រូវបានកំណត់ដោយធ្វើអប្បហារប្រាក់ដែលត្រូវទូទាត់នាពេលអនាគត ដោយប្រើអត្រាការប្រាក់បញ្ញើមានកាលកំណត់សម្រាប់រយៈពេល ៦០ខែ។

អត្ថប្រយោជន៍ពេលចូលនិវត្ត

ធនាគារ និងក្រុមហ៊ុនបុត្រសម្ព័ន្ធ លើកលែងតែស្ថាប័នមីក្រូហិរញ្ញវត្ថុ អេស៊ីលីដា មីយ៉ាន់ម៉ា ផ្តល់ជូនផែនការអត្ថប្រយោជន៍ពេលចូលនិវត្តដែលមិនត្រូវបានផ្តល់ជាមូលនិធិ ដែលជាផែនការអត្ថប្រយោជន៍ដែលបានកំណត់សម្រាប់បុគ្គលិកដែលមានសិទ្ធិទទួលនៅពេលដែលពួកគាត់ដល់អាយុចូលនិវត្ត ដូចខាងក្រោម៖

- បុគ្គលិកដែលមានអតីតភាពការងារជាមួយសម្ព័ន្ធធនាគារ និងធនាគារ ចំនួន ១៥ឆ្នាំ ឬលើស ហើយត្រូវចូលនិវត្តនៅអាយុ ៥៨ឆ្នាំ ចំពោះអ្នកគ្មានជំនាញ និង ៦០ឆ្នាំ ចំពោះអ្នកមានជំនាញ នឹងទទួលបានអត្ថប្រយោជន៍ពេលចូលនិវត្តស្មើនឹងប្រាក់បៀវត្សរ៍ចំនួន ១២ខែ នៃប្រាក់បៀវត្សរ៍ចុងក្រោយ ឬ
- បុគ្គលិកដែលមានអតីតភាពការងារជាមួយសម្ព័ន្ធធនាគារ និងធនាគារចំនួន ១៥ឆ្នាំ ឬលើស ហើយត្រូវចូលនិវត្តមុន នៅអាយុ ៥៥ឆ្នាំ ចំពោះអ្នកគ្មានជំនាញ និង ៥៧ឆ្នាំ ចំពោះអ្នកមានជំនាញ នឹងទទួលបានអត្ថប្រយោជន៍ពេលចូលនិវត្តស្មើនឹងប្រាក់បៀវត្សរ៍ចំនួន ៦ខែ នៃប្រាក់បៀវត្សរ៍ចុងក្រោយ។

ចំពោះអត្ថប្រយោជន៍ពេលចូលនិវត្តនេះ មិនមានរក្សាទុកក្នុងមូលនិធិដាច់ដោយឡែកទេ ហើយការប្រាក់ត្រូវបានផ្តល់សម្រាប់អត្ថប្រយោជន៍ពេលចូលនិវត្ត។

ធនាគារ អេស៊ីលីដា ភីអិលស៊ី និង ក្រុមហ៊ុនបុត្រសម្ព័ន្ធ

កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ និងសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់

២. សេចក្តីសង្ខេបអំពីគោលនយោបាយគណនេយ្យសំខាន់ៗ (ត)

(ត) អត្ថប្រយោជន៍និយោជិត (ត)

(ii) អត្ថប្រយោជន៍ក្រោយពីបំពេញការងារ (ត)

អត្ថប្រយោជន៍ពេលចូលនិវត្ត (ត)

បំណុល ត្រូវបានកត់ត្រានៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុតាមតម្លៃបច្ចុប្បន្ននៃកាតព្វកិច្ចដែលបានកំណត់ នាការិយបរិច្ឆេទរាយការណ៍ ដោយប្រើវិធីសាស្ត្រឥណទានតាមឯកតាព្យាករណ៍ ដើម្បីប៉ាន់ស្មានតម្លៃចុងក្រោយបំផុតដែលសម្ព័ន្ធធនាគារ និងធនាគារត្រូវចំណាយចំពោះអត្ថប្រយោជន៍ដែលនិយោជិតត្រូវទទួលបានជាផ្ទួរនឹងការបម្រើការងាររបស់ពួកគេក្នុងពេលបច្ចុប្បន្ន និងពេលកន្លងមក។

សម្ព័ន្ធធនាគារ និងធនាគារបែងចែក អត្ថប្រយោជន៍តាមគ្រានីមួយៗ ដែលកាតព្វកិច្ចផ្តល់អត្ថប្រយោជន៍ ពេលចូលនិវត្តបានកើតឡើង។ កាតព្វកិច្ចនោះកើតឡើងនៅពេលដែលបុគ្គលិកបម្រើការងារ ដើម្បីទទួលបានអត្ថប្រយោជន៍ពេលចូលនិវត្ត ដែលសម្ព័ន្ធធនាគារ និងធនាគារ រំពឹងថានឹងទូទាត់ក្នុងការិយបរិច្ឆេទរាយការណ៍នាពេលអនាគត ។

តម្លៃបច្ចុប្បន្ននៃកាតព្វកិច្ចអត្ថប្រយោជន៍ពេលចូលនិវត្ត ត្រូវបានកំណត់ដោយធ្វើការអប្បហារការទូទាត់ដែលរំពឹងទុកនាពេលអនាគត ដោយប្រើប្រាស់អត្រាការប្រាក់នៃប្រាក់បញ្ញើមានកាលកំណត់សម្រាប់រយៈពេលវែងរបស់ធនាគារជាអត្រាយោងរបស់វា ដោយសារនៅពេលបច្ចុប្បន្នមិនមានទីផ្សារមូលបត្រក្រុមហ៊ុនដែលមានគុណភាពខ្ពស់ ហើយក៏មិនមានមូលបត្របំណុលរាជរដ្ឋាភិបាលនៅក្នុងទីផ្សារដែរ ។

ចំណេញ និងខាតដែលគណនាដោយផ្អែកលើមូលដ្ឋានច្បាស់លាស់ កើតឡើងពីការកែតម្រូវគណនីសម្រង់ និងពីបម្រែបម្រួលការសន្មត ដែលគណនាដោយផ្អែកលើមូលដ្ឋានច្បាស់លាស់ ត្រូវបានកត់ត្រានៅក្នុងរបាយការណ៍លទ្ធផលលម្អិតផ្សេងៗ និងទទួលស្គាល់ដោយផ្ទាល់ នៅក្នុងប្រាក់ចំណេញរក្សាទុក ក្នុងការិយបរិច្ឆេទដែលប្រតិបត្តិការនោះកើតឡើង។ ចំណាយទាក់ទិននឹងការផ្តល់អត្ថប្រយោជន៍ទាំងនេះ ត្រូវបានកត់ត្រានៅក្នុងរបាយការណ៍លទ្ធផលលម្អិតផ្សេងៗ ដើម្បីធ្វើការបែងចែកចំណាយទាំងនោះទៅតាមរយៈពេលបម្រើការងារ ដែលមានសិទ្ធិទទួលបានអត្ថប្រយោជន៍នេះ។ តម្លៃសេវាកម្មពីអតីតកាល ត្រូវបានទទួលស្គាល់ភ្លាមៗនៅក្នុងចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗ។

ធនាគារ អេស៊ីលីដា ភីអិលស៊ី និង ក្រុមហ៊ុនបុត្រសម្ព័ន្ធ

កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ និងសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់

២. សេចក្តីសង្ខេបអំពីគោលនយោបាយគណនេយ្យសំខាន់ៗ (ត)

(ត) អត្ថប្រយោជន៍និយោជិត (ត)

(ii) អត្ថប្រយោជន៍និយោជិតក្រោយពីបំពេញការងារ (ត)

អត្ថប្រយោជន៍អភិវឌ្ឍន៍វិជ្ជាជីវៈគ្រប់គ្រង

ធនាគារផ្តល់អត្ថប្រយោជន៍ភិវឌ្ឍន៍វិជ្ជាជីវៈគ្រប់គ្រងដល់និយោជិត បម្រើការងារនៅក្នុងតួនាទីគ្រប់គ្រង ដូចខាងក្រោម៖

លំដាប់ថ្នាក់មុខតំណែងគ្រប់គ្រង	អត្ថប្រយោជន៍
លំដាប់ថ្នាក់ទី ៦	១.២៥០ ដុល្លារអាមេរិក
លំដាប់ថ្នាក់ទី ៧	២.៥០០ ដុល្លារអាមេរិក
លំដាប់ថ្នាក់ទី ៨	៣.៣៧៥ ដុល្លារអាមេរិក ទៅ ៣.៧៥០ ដុល្លារអាមេរិក
លំដាប់ថ្នាក់ទី ៩	៥.០០០ ដុល្លារអាមេរិក
លំដាប់ថ្នាក់ទី ១០	៦.២៥០ ដុល្លារអាមេរិក

ពួកគេមានសិទ្ធិទទួលបានអត្ថប្រយោជន៍ដែលបានផ្តល់ឱ្យ ពេលដែលពួកគេបានធ្វើការចាប់តាំងពីកាលបរិច្ឆេទនៃការតែងតាំង នៅក្នុងមុខតំណែងគ្រប់គ្រងបានរយៈពេលពីរឆ្នាំជាប់ៗគ្នា ហើយការវាយតម្លៃលទ្ធផលការងាររបស់ពួកគេមានកម្រិតខ្ពស់ (ឧទាហរណ៍: ពិន្ទុនៃការវាយតម្លៃស្មើនឹង ឬខ្ពស់ជាង ៧០០ និងគ្មានលិខិតព្រមាន)។ ពួកគេនឹងមានសិទ្ធិទទួលបានអត្ថប្រយោជន៍ដោយស្វ័យប្រវត្តិនៅថ្ងៃដំបូងនៃឆ្នាំទីបីរបស់ពួកគេ។

បំណុលត្រូវបានទទួលស្គាល់ នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ នៅតម្លៃបច្ចុប្បន្ននៃកាតព្វកិច្ចអត្ថប្រយោជន៍នៅចុងការិយបរិច្ឆេទនៃរបាយការណ៍នីមួយៗ ដោយប្រើវិធីសាស្ត្រឥណទានតាមងកតាព្យាករណ៍។ តម្លៃបច្ចុប្បន្ន ត្រូវបានកំណត់ដោយការធ្វើអប្បហារការទូទាត់នាពេលអនាគតដែលបានប៉ាន់ស្មាន ដោយយោងទៅលើអត្រាការប្រាក់បញ្ញើមានកាលកំណត់សម្រាប់រយៈពេលបីឆ្នាំ ដោយសារសិទ្ធិក្នុងការទទួលបានអត្ថប្រយោជន៍មានរយៈពេលបីឆ្នាំ។

(ថ) សំវិធានធន

សំវិធានធន ត្រូវបានទទួលស្គាល់នៅពេលដែលសម្ព័ន្ធធនាគារ និងធនាគារមានកាតព្វកិច្ចផ្លូវច្បាប់ ឬកាតព្វកិច្ចស្ថាបនា នាពេលបច្ចុប្បន្ន ដែលជាលទ្ធផល នៃព្រឹត្តិការណ៍ពីអតីតកាល ហើយវាទំនងជាអាចមានការហូរចេញនៃធនធានដើម្បីទូទាត់កាតព្វកិច្ចនោះ ហើយទឹកប្រាក់នៃកាតព្វកិច្ចអាចត្រូវបានប៉ាន់ស្មានដោយភាពជឿជាក់។

២. សេចក្តីសង្ខេបអំពីគោលនយោបាយគណនេយ្យសំខាន់ៗ (ត)

(ថ) សំវិធានធន (ត)

នៅពេលដែលមានកាតព្វកិច្ចស្រដៀងគ្នាច្រើន ភាពដែលកើតមានឡើងនៃលំហូរចេញដើម្បីទូទាត់កាតព្វកិច្ចនោះ ត្រូវបានកំណត់ដោយធ្វើការពិចារណាទៅលើថ្នាក់នៃកាតព្វកិច្ចទាំងមូល។ សំវិធានធនត្រូវបានទទួលស្គាល់ទោះបីជាលទ្ធភាពនៃលំហូរចេញទាក់ទងនឹងធាតុណាមួយដែលបានរួមបញ្ចូលនៅក្នុងថ្នាក់ដូចគ្នានៃកាតព្វកិច្ច អាចមានតិចតួចក៏ដោយ។

សំវិធានធន ត្រូវបានវាស់វែងតាមតម្លៃបច្ចុប្បន្ននៃចំណាយដែលរំពឹងថានឹងត្រូវធ្វើការទូទាត់កាតព្វកិច្ចនោះ ដោយប្រើប្រាស់អត្រាមុនគិតពន្ធ ដើម្បីឆ្លុះបញ្ចាំងពីការវាយតម្លៃតាមទីផ្សារបច្ចុប្បន្ននៃពេលវេលានៃការប្រើប្រាស់សាច់ប្រាក់ និងហានិភ័យជាក់លាក់ចំពោះកាតព្វកិច្ចនោះ។ ការកើនឡើងនៃសំវិធានធនដោយសារ ការកន្លងផុតទៅនៃពេលវេលា ត្រូវបានទទួលស្គាល់ជាចំណាយការប្រាក់។

(ទ) ការប្រាក់

អត្រាការប្រាក់ប្រសិទ្ធភាព

ចំណូល និងចំណាយការប្រាក់ត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ចំណេញ ឬខាត ដោយប្រើវិធីសាស្ត្រការប្រាក់ប្រសិទ្ធភាព។ "អត្រាការប្រាក់ប្រសិទ្ធភាព" គឺជាអត្រាដែលអប្បហារការទទួល ឬទូទាត់សាច់ប្រាក់នាពេលអនាគតដែលរំពឹងទុក ក្នុងអាយុកាលដែលរំពឹងទុករបស់ឧបករណ៍ហិរញ្ញវត្ថុ មកស្មើនឹង៖

- តម្លៃយោងដុលរបស់ទ្រព្យសកម្មហិរញ្ញវត្ថុ ឬ
- តម្លៃដករំលស់របស់បំណុលហិរញ្ញវត្ថុ។

នៅពេលគណនាអត្រាការប្រាក់ប្រសិទ្ធភាពសម្រាប់ឧបករណ៍ហិរញ្ញវត្ថុ ក្រៅពីទ្រព្យសកម្មដែលមានឱនភាពនៃតម្លៃឥណទាននៅពេលធ្វើលទ្ធកម្ម ឬបង្កើត សម្ព័ន្ធធនាគារ និងធនាគារធ្វើការប៉ាន់ស្មានលំហូរសាច់ប្រាក់នាពេលអនាគតដោយពិចារណារាល់លក្ខខណ្ឌតាមកិច្ចសន្យាទាំងអស់របស់ឧបករណ៍ហិរញ្ញវត្ថុ ប៉ុន្តែមិនរាប់បញ្ចូលនូវការខាតបង់ដែលរំពឹងទុក (ECL) នោះទេ។ សម្រាប់ទ្រព្យសកម្មហិរញ្ញវត្ថុដែលមានឱនភាពនៃតម្លៃឥណទាននៅពេលធ្វើលទ្ធកម្ម ឬបង្កើត អត្រាការប្រាក់ប្រសិទ្ធភាពដែលបានកែតម្រូវហានិភ័យឥណទាន ត្រូវបានគណនាដោយប្រើលំហូរសាច់ប្រាក់នាពេលអនាគតដែលប៉ាន់ស្មានរួមបញ្ចូលទាំងការខាតបង់ឥណទានដែលរំពឹងទុក (ECL)។

ធនាគារ អេស៊ីលីដា អ៊ីអិលស៊ី និង ក្រុមហ៊ុនបុត្រសម្ព័ន្ធ

កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ និងសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់

២. សេចក្តីសង្ខេបអំពីគោលនយោបាយគណនេយ្យសំខាន់ៗ (ត)

(ទ) ការប្រាក់ (ត)

អត្រាការប្រាក់ប្រសិទ្ធភាព (ត)

ការគណនាអត្រាការប្រាក់ប្រសិទ្ធភាពរួមបញ្ចូលនូវចំណាយប្រតិបត្តិការ និងកម្រៃដែលបានបង់ ឬទទួល ដែលជាផ្នែកនៃអត្រាការប្រាក់ប្រសិទ្ធភាព។ ចំណាយប្រតិបត្តិការរួមមាន ការចំណាយបន្ថែមដែលចូលរួមដោយផ្ទាល់ទៅនឹងការធ្វើលទ្ធកម្ម ឬការបោះផ្សាយទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ។

តម្លៃដករំលស់ និងតម្លៃយោងដុល

តម្លៃដករំលស់របស់ទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ គឺជាចំនួនដែលទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ ត្រូវបានវាស់វែងនៅពេលទទួលស្គាល់លើកដំបូង ដកការសងមកវិញនូវប្រាក់ដើម បូក ឬដករំលស់បង្គរ ដោយប្រើវិធីសាស្ត្រការប្រាក់ប្រសិទ្ធភាព នៃភាពខុសគ្នារវាងចំនួនដែលទទួលស្គាល់លើកដំបូង និងចំនួននៅឥណប្រតិទាន និងត្រូវធ្វើនិយ័តកម្មចំពោះការខាតបង់ឥណទានដែលរំពឹងទុក (ចំពោះទ្រព្យសកម្មហិរញ្ញវត្ថុ)។

តម្លៃយោងដុលរបស់ទ្រព្យសកម្មហិរញ្ញវត្ថុ គឺជាតម្លៃដករំលស់របស់ទ្រព្យសកម្មហិរញ្ញវត្ថុ មុនពេលធ្វើនិយ័តកម្មសំវិធានធនលើការខាតបង់ឥណទានដែលរំពឹងទុក។

ការគណនាចំណូលការប្រាក់ និងចំណាយការប្រាក់

អត្រាការប្រាក់ប្រសិទ្ធភាពរបស់ទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ ត្រូវបានគណនាលើការទទួលស្គាល់ដំបូងនៃទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ។ ក្នុងការគណនាចំណូលការប្រាក់ និងចំណាយការប្រាក់ អត្រាការប្រាក់ប្រសិទ្ធភាពត្រូវបានអនុវត្តលើតម្លៃយោងដុលរបស់ទ្រព្យសកម្ម (នៅពេលដែលទ្រព្យសកម្មមិនត្រូវបានចាត់ទុកថាមានឱនភាពនៃតម្លៃឥណទាន) ឬតម្លៃដករំលស់នៃបំណុល។ អត្រាការប្រាក់ប្រសិទ្ធភាពត្រូវបានធ្វើការកែប្រែឡើងវិញ ដែលជាលទ្ធផលនៃការប៉ាន់ស្មានឡើងវិញតាមពេលកំណត់ របស់លំហូរសាច់ប្រាក់នៃឧបករណ៍ដែលមានអត្រាការប្រាក់អថេរ ដើម្បីឆ្លុះបញ្ចាំងពីការផ្លាស់ប្តូរអត្រាការប្រាក់ទីផ្សារ។ អត្រាការប្រាក់ប្រសិទ្ធភាពក៏ត្រូវធ្វើការកែប្រែឡើងវិញ សម្រាប់ការធ្វើនិយ័តកម្មតម្លៃសមស្របនៃការទប់ស្កាត់ហានិភ័យ នៅកាលបរិច្ឆេទធ្វើរំលស់នៃការធ្វើនិយ័តកម្មការទប់ស្កាត់ហានិភ័យ ត្រូវចាប់ផ្តើម។

ចំពោះទ្រព្យសកម្មហិរញ្ញវត្ថុដែលមានឱនភាពនៃតម្លៃឥណទានបន្ទាប់ពីបានទទួលស្គាល់លើកដំបូង ចំណូលការប្រាក់ ត្រូវបានគណនាដោយប្រើអត្រាការប្រាក់ប្រសិទ្ធភាព លើតម្លៃដករំលស់របស់ទ្រព្យសកម្មហិរញ្ញវត្ថុ។ ប្រសិនបើទ្រព្យសកម្មហិរញ្ញវត្ថុលែងមានឱនភាពនៃតម្លៃឥណទាន នោះការគណនាចំណូលការប្រាក់ត្រូវប្តូរមកលើមូលដ្ឋានតម្លៃដុលវិញ។

២. សេចក្តីសង្ខេបអំពីគោលនយោបាយគណនេយ្យសំខាន់ៗ (ត)

(ទ) ការប្រាក់ (ត)

ការគណនាចំណូលការប្រាក់ និងចំណាយការប្រាក់

ចំពោះទ្រព្យសកម្មហិរញ្ញវត្ថុដែលមានឱនភាពនៃតម្លៃឥណទាននៅពេលទទួលស្គាល់លើកដំបូង ចំណូលការប្រាក់ត្រូវបានគណនាដោយប្រើអត្រាការប្រាក់ប្រសិទ្ធភាពដែលបានកែតម្រូវឥណទាន លើតម្លៃដករំលស់នៃទ្រព្យសកម្មហិរញ្ញវត្ថុ។ ការគណនាចំណូលការប្រាក់នេះ មិនត្រូវប្តូរទៅមូលដ្ឋានតម្លៃដុលវិញទេ ទោះបីជាហានិភ័យឥណទានរបស់ទ្រព្យសកម្មនោះ មានភាពប្រសើរក៏ដោយ។

ការបង្ហាញ

ចំណូលការប្រាក់ ត្រូវបានគណនាដោយប្រើវិធីសាស្ត្រការប្រាក់ប្រសិទ្ធិភាព ដែលបានបង្ហាញនៅក្នុងរបាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗ រួមមាន៖

- ការប្រាក់លើទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុវាស់តាមតម្លៃដករំលស់
- ការប្រាក់លើឧបករណ៍បំណុលវាស់វែងតាម FVOCI
- ចំណែកដែលមានប្រសិទ្ធភាពនៃការផ្លាស់ប្តូរតម្លៃសមស្របក្នុងដេរីវេធីវការទប់ស្កាត់ហានិភ័យ ដែលមានគុណវុធ្ឍិ ដែលបានកំណត់ជាការទប់ស្កាត់ហានិភ័យលំហូរសាច់ប្រាក់នៃភាពប្រែប្រួលរបស់លំហូរសាច់ប្រាក់ការប្រាក់ ក្នុងអំឡុងពេលដូចគ្នា ខណៈដែលលំហូរសាច់ប្រាក់បានទប់ស្កាត់ហានិភ័យមានឥទ្ធិពលដល់ចំណូល ឬចំណាយការប្រាក់ និង
- ចំណែកដែលមានប្រសិទ្ធភាពនៃការផ្លាស់ប្តូរតម្លៃសមស្របក្នុងដេរីវេធីវការទប់ស្កាត់ហានិភ័យ ដែលបានកំណត់ជាតម្លៃសមស្របនៃការទប់ស្កាត់ហានិភ័យនៃតម្លៃហានិភ័យអត្រាការប្រាក់។

ចំណាយការប្រាក់ដែលបានបង្ហាញនៅក្នុងរបាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗ រួមមាន៖

- បំណុលហិរញ្ញវត្ថុដែលវាស់វែងតាមតម្លៃដករំលស់ និង
- ចំណែកដែលមានប្រសិទ្ធភាពនៃការផ្លាស់ប្តូរតម្លៃសមស្របក្នុងដេរីវេធីវការទប់ស្កាត់ហានិភ័យ ដែលមានគុណវុធ្ឍិ ដែលបានកំណត់ជាការទប់ស្កាត់ហានិភ័យលំហូរសាច់ប្រាក់ នៃភាពប្រែប្រួលរបស់លំហូរសាច់ប្រាក់ការប្រាក់ក្នុងអំឡុងពេលដូចគ្នា ខណៈដែលលំហូរសាច់ប្រាក់បានទប់ស្កាត់ហានិភ័យមានឥទ្ធិពលដល់ចំណូលឬចំណាយការប្រាក់។

ចំណូល និងចំណាយការប្រាក់លើទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុផ្សេងៗ តាម FVTPL ត្រូវបានបង្ហាញជាប្រាក់ចំណូលសុទ្ធពីឧបករណ៍ហិរញ្ញវត្ថុផ្សេងទៀតតាម FVTPL។

២. សេចក្តីសង្ខេបអំពីគោលនយោបាយគណនេយ្យសំខាន់ៗ (ត)

(ធ) កម្រៃ និងជើងសា

ចំណូល និងចំណាយកម្រៃ និងជើងសា ដែលជាផ្នែកនៃអត្រាការប្រាក់ប្រសិទ្ធភាព នៃទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ ត្រូវបានរួមបញ្ចូលទៅក្នុងអត្រាការប្រាក់ប្រសិទ្ធភាព។

ចំណូលកម្រៃ និងជើងសាផ្សេងៗ រួមមានកម្រៃសេវាកម្មគណនី កម្រៃគ្រប់គ្រងការវិនិយោគ ជើងសាលើការលក់ កម្រៃបញ្ញើ និងកម្រៃការប្រមូលផ្តុំ ត្រូវបានទទួលស្គាល់ជាសេវាកម្មពាក់ព័ន្ធត្រូវបានបម្រើ។

ប្រសិនបើ កិច្ចសន្យាផ្តល់ឥណទានមិនត្រូវបានរំពឹងថានឹងមានការដកប្រើប្រាស់ជាឥណទាន នោះកម្រៃកិច្ចសន្យាផ្តល់ឥណទានដែលទាក់ទង ត្រូវបានទទួលស្គាល់ដោយឈរលើមូលដ្ឋានថេរ ក្នុងរយៈពេលនៃកិច្ចសន្យា។

កិច្ចសន្យាជាមួយអតិថិជនដែលបង្កើតឱ្យមានការទទួលស្គាល់ជាឧបករណ៍ហិរញ្ញវត្ថុ នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់សម្ព័ន្ធធនាគារ និងធនាគារ អាចជាផ្នែកនៅក្នុងវិសាលភាពនៃ ស.រ.ហ.អ.ក ៩ និងជាផ្នែកនៅក្នុងវិសាលភាពនៃ ស.រ.ហ.អ.ក ១៥។ ក្នុងករណីនេះ សម្ព័ន្ធធនាគារ និងធនាគារត្រូវអនុវត្តជាដំបូង ស.រ.ហ.អ.ក ៩ ដើម្បីបែងចែក និងវាស់វែងផ្នែកនៃកិច្ចសន្យា ដែលស្ថិតក្នុងវិសាលភាពនៃ ស.រ.ហ.អ.ក ៩ ហើយបន្ទាប់មកអនុវត្ត ស.រ.ហ.អ.ក ១៥ ចំពោះផ្នែកដែលនៅសេសសល់។

(ន) ការទទួលស្គាល់កម្រៃសេវា និងចំណូលផ្សេងៗ

(i) ភាគលាភ

ភាគលាភ ត្រូវបានទទួលស្គាល់នៅពេលសិទ្ធិទទួលបានការទូទាត់ត្រូវបានបង្កើតឡើង។ ជាធម្មតានេះ គឺជាកាលបរិច្ឆេទនៃការបែងចែកភាគលាភ (អ៊ិចឌីវីដិន) សម្រាប់មូលបត្រមូលធនសម្រង់។

ភាគលាភលើឧបករណ៍មូលធនកំណត់តាម FVOCI ដែលបង្ហាញយ៉ាងច្បាស់ពីការប្រមូលបានមកវិញ របស់ផ្នែកនៃថ្លៃដើមរបស់ការវិនិយោគត្រូវបង្ហាញនៅក្នុងលទ្ធផលលម្អិតផ្សេងៗ។

(ii) សេវាកម្មបណ្តុះបណ្តាល និងប្រឹក្សាយោបល់

សម្ព័ន្ធធនាគារ និងធនាគារទទួលស្គាល់ចំណូលពីសេវាកម្ម នៅពេលដែលវាទំនងថាអត្ថប្រយោជន៍សេដ្ឋកិច្ចនឹងហូរចូលសម្ព័ន្ធធនាគារ និងធនាគារ ហើយចំនួនទឹកប្រាក់នៃចំណូលអាចវាស់វែងដោយជឿជាក់។ ចំណូលពីសេវាកម្មបណ្តុះបណ្តាល និងសេវាកម្មប្រឹក្សាយោបល់ ត្រូវបានទទួលស្គាល់នៅពេលដែលសេវាកម្មត្រូវបានផ្តល់។

ធនាគារ អេស៊ីលីដា ភីអិលស៊ី និង ក្រុមហ៊ុនបុត្រសម្ព័ន្ធ

កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ និងសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់

២. សេចក្តីសង្ខេបអំពីគោលនយោបាយគណនេយ្យសំខាន់ៗ (ត)

(ប) ភតិសន្យា

នៅដំណាក់កាលដំបូងនៃកិច្ចសន្យា សម្ព័ន្ធធនាគារ និងធនាគារធ្វើការវាយតម្លៃថាតើកិច្ចសន្យាមួយមាន ឬជាភតិសន្យាដែរ ឬទេ។ កិច្ចសន្យាជា ឬមានភតិសន្យា ប្រសិនបើកិច្ចសន្យាផ្តល់សិទ្ធិអភិបាលការប្រើប្រាស់ទ្រព្យសកម្ម ជាក់លាក់មួយក្នុងរយៈពេលកំណត់មួយ ជាផ្ទូរនឹងតម្លៃតបស្នង។

ក្នុងនាមជាភតិករ:

នៅពេលចាប់ផ្តើម ឬការកែប្រែនៃកិច្ចសន្យាដែលមានសមាសធាតុភតិសន្យា សម្ព័ន្ធធនាគារ និងធនាគារបែងចែកតម្លៃតបស្នងនៅក្នុងកិច្ចសន្យាទៅតាមសមាសធាតុភតិសន្យានីមួយៗ ដោយផ្អែកលើមូលដ្ឋានថ្លៃតែម្នាក់ឯង។

សម្ព័ន្ធធនាគារ និងធនាគារទទួលស្គាល់សិទ្ធិប្រើប្រាស់ទ្រព្យសកម្ម និងបំណុលភតិសន្យានៅកាលបរិច្ឆេទចាប់ផ្តើមភតិសន្យា។ សិទ្ធិប្រើប្រាស់ទ្រព្យសកម្មត្រូវបានវាស់តាមថ្លៃដើមដំបូង ដែលរួមមានតម្លៃដំបូងនៃបំណុលភតិសន្យាដែលត្រូវបានកែតម្រូវសម្រាប់ការទូទាត់ភតិសន្យាដែលបានធ្វើឡើងនៅ ឬមុនកាលបរិច្ឆេទចាប់ផ្តើម បូកនឹងចំណាយដោយផ្ទាល់ដំបូងដែលបានកើតឡើង និងការប៉ាន់ស្មាននៃចំណាយដើម្បីរុះរើ និងផ្លាស់ចេញទ្រព្យសកម្មជាមូលដ្ឋាន ឬដើម្បីស្តារឡើងវិញនូវទ្រព្យសកម្មជាមូលដ្ឋាន ឬទីតាំងដែលវាស្ថិតនៅ ឬស្តារឡើងវិញនូវទ្រព្យសកម្មជាមូលដ្ឋានទៅតាមលក្ខខណ្ឌតម្រូវ ក្នុងលក្ខខណ្ឌនៃភតិសន្យា (លើកលែងតែចំណាយដែលកើតឡើងក្នុងការផលិតសន្និធិ) ដកចេញការលើកទឹកចិត្តភតិសន្យាដែលបានទទួល។

សិទ្ធិប្រើប្រាស់ទ្រព្យសកម្មត្រូវបានរំលស់ជាបន្តបន្ទាប់តាមវិធីសាស្ត្រថេរ ចាប់ពីកាលបរិច្ឆេទចាប់ផ្តើម រហូតដល់ចុងបញ្ចប់នៃអាយុកាលភតិសន្យា លើកលែងតែភតិសន្យាផ្ទេរការកាន់កាប់ទ្រព្យសកម្មជាមូលដ្ឋានទៅឱ្យសម្ព័ន្ធធនាគារ និងធនាគារនៅចុងការិយបរិច្ឆេទនៃរយៈពេលភតិសន្យា ឬថ្លៃដើមនៃសិទ្ធិប្រើប្រាស់ទ្រព្យសម្ម ឆ្លុះបញ្ចាំងថាសម្ព័ន្ធធនាគារ និងធនាគារនឹងអនុវត្តជម្រើសធ្វើលទ្ធកម្ម។ ក្នុងករណីដែលសិទ្ធិប្រើប្រាស់ទ្រព្យសកម្មនឹងត្រូវបានធ្វើរំលស់ក្នុងអាយុប្រើប្រាស់នៃទ្រព្យសកម្មជាមូលដ្ឋាន ដែលត្រូវបានកំណត់ដោយផ្អែកលើមូលដ្ឋានដូចគ្នានៅនឹងទ្រព្យនិង បរិក្ខារ។ បន្ថែមលើនេះ សិទ្ធិប្រើប្រាស់ទ្រព្យសកម្ម ត្រូវបានកាត់បន្ថយជាប្រចាំទៅតាមការខាតបង់ឱនភាពនៃតម្លៃ និងកែតម្រូវសម្រាប់ការវាស់វែងឡើងវិញនៃបំណុលភតិសន្យា។

បំណុលភតិសន្យា ត្រូវបានវាស់វែងលើកដំបូងតាមតម្លៃបច្ចុប្បន្ននៃការទូទាត់ភតិសន្យាដែលមិនទាន់ បានបង់នៅកាលបរិច្ឆេទចាប់ផ្តើម ធ្វើអប្បហារដោយប្រើអត្រាការប្រាក់ដែលបង្កប់នៅក្នុងភតិសន្យា ឬករណីដែលអត្រានោះមិនអាចកំណត់ សម្ព័ន្ធធនាគារ និងធនាគារប្រើប្រាស់អត្រាការប្រាក់កម្ចីបន្ថែមរបស់ខ្លួន។ ជាទូទៅសម្ព័ន្ធធនាគារ និងធនាគារប្រើប្រាស់អត្រាការប្រាក់កម្ចីបន្ថែមរបស់ខ្លួនជាអត្រាអប្បហារ។

ធនាគារ អេស៊ីលីដា ភីអិលស៊ី និង ក្រុមហ៊ុនបុត្រសម្ព័ន្ធ

កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ និងសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់

២. សេចក្តីសង្ខេបអំពីគោលនយោបាយគណនេយ្យសំខាន់ៗ (ត)

(ប) ភតិសន្យា (ត)

ក្នុងនាមជាភតិក: (ត)

នៅថ្ងៃដែលចាប់ផ្តើមប្រើប្រាស់ សម្ព័ន្ធធនាគារ និងធនាគារប្រើប្រាស់អត្រាការប្រាក់របស់ប្រាក់បញ្ញើមានកាលកំណត់រយៈពេលវែង ធ្វើអប្បហារនឹងការទូទាត់ភតិសន្យានាថ្ងៃអនាគត ដោយមិនគិតពីប័ណ្ណបំណុលសហការ ឬប័ណ្ណបំណុលរដ្ឋាភិបាល។

ការទូទាត់ភតិសន្យាដែលបានរួមបញ្ចូលក្នុងការវាស់វែងនៃបំណុលភតិសន្យា មានដូចខាងក្រោម៖

- ការទូទាត់ថេររួមទាំងសមាសធាតុនៃការទូទាត់ថេរ ដកចេញនូវរាល់អត្ថប្រយោជន៍នៃភតិសន្យា។
- ការទូទាត់ភតិសន្យាអថេរដែលអាស្រ័យលើសន្ទស្សន៍ ឬអត្រាមួយ ដែលវាស់វែងលើកដំបូងដោយប្រើសន្ទស្សន៍ ឬអត្រានៅកាលបរិច្ឆេទចាប់ផ្តើម
- តម្លៃដែលរំពឹងថានឹងត្រូវបង់នៅក្រោមតម្លៃកាកសំណល់មានការធានា និង
- ថ្លៃអនុវត្តដែលស្ថិតក្រោមជម្រើសនៃការធ្វើលទ្ធកម្មដែលសម្ព័ន្ធធនាគារ និងធនាគារមានភាពប្រាកដប្រជាក្នុងការអនុវត្ត ការទូទាត់ភតិសន្យានៅក្នុងរយៈពេលមានជម្រើសនៃការបន្តជាថ្មីប្រសិនបើសម្ព័ន្ធធនាគារ និងធនាគារ មានភាពប្រាកដប្រជាក្នុងការអនុវត្តជម្រើសពន្យារ និងការពិន័យ សម្រាប់ការបញ្ចប់ភតិសន្យា មុនពេលកំណត់លើកលែងតែសម្ព័ន្ធធនាគារ និងធនាគារមានភាពប្រាកដប្រជា មិនបញ្ចប់មុនពេលកំណត់។

បំណុលភតិសន្យា ត្រូវបានវាស់វែងតាមតម្លៃដករំលស់ដោយប្រើវិធីសាស្ត្រការប្រាក់ប្រសិទ្ធភាព។ បំណុលភតិសន្យាត្រូវបានវាស់វែងឡើងវិញនៅពេលមានការកែប្រការទូទាត់ភតិសន្យានាពេលអនាគត ដែលកើតឡើងពីការផ្លាស់ប្តូរនៃសន្ទស្សន៍ ឬអត្រាណាមួយ ឬប្រសិនបើមានការកែប្រែតម្លៃប៉ាន់ស្មានដែលសម្ព័ន្ធធនាគារ និងធនាគាររំពឹងថានឹងត្រូវទូទាត់ ក្រោមតម្លៃកាកសំណល់មានការធានា។ ប្រសិនបើសម្ព័ន្ធធនាគារ និងធនាគារផ្លាស់ប្តូរ ការវាយតម្លៃថាតើត្រូវអនុវត្តជម្រើសការធ្វើលទ្ធកម្ម ពន្យារ ឬបញ្ចប់ដែរ ឬទេ ឬប្រសិនបើមានការទូទាត់ថេរ ជាស្ថានភាពជាក់ពិតដែលកែ ប្រែ ឬ ភតិសន្យាត្រូវបានកែប្រែ ហើយការកែប្រែលើភតិសន្យាមិនត្រូវបានកត់ត្រាជាភតិសន្យាដាច់ដោយឡែក ឡើយ។

នៅពេលដែលបំណុលភតិសន្យា ត្រូវបានវាស់វែងតាមវិធីសាស្ត្រនេះ ការកែតម្រូវត្រូវបានធ្វើឡើងលើតម្លៃយោង នៃសិទ្ធិប្រើប្រាស់ទ្រព្យសកម្ម ឬក៏ទទួលស្គាល់ក្នុងចំណេញ ឬខាត បើសិនជាសិទ្ធិប្រើប្រាស់ទ្រព្យសកម្ម ត្រូវបានបញ្ចុះរហូតដល់មានតម្លៃសូន្យ។

សម្ព័ន្ធធនាគារ និងធនាគារបង្ហាញនូវសិទ្ធិប្រើប្រាស់ទ្រព្យសកម្មនិងបំណុលភតិសន្យាដោយឡែកពីគ្នា នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។

ធនាគារ អេស៊ីលីដា អ៊ីអិលស៊ី និង ក្រុមហ៊ុនបុត្រសម្ព័ន្ធ

កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ និងសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់

២. សេចក្តីសង្ខេបអំពីគោលនយោបាយគណនេយ្យសំខាន់ៗ (ត)

(ប) ភតិសន្យា (ត)

ភតិសន្យាមានរយៈពេលខ្លី និងភតិសន្យានៃទ្រព្យសកម្មដែលមានតម្លៃទាប

ភតិសន្យាដែល នាកាលបរិច្ឆេទចាប់ផ្តើម ដែលមានរយៈពេល ១២ខែ ឬតិចជាងនេះ។ ភតិសន្យាដែលរួមមានជម្រើសក្នុងការទិញគឺមិនមែនជាភតិសន្យាជួលរយៈពេលខ្លីនោះទេ។

មូលដ្ឋាននៃការជួលទ្រព្យសម្បត្តិ ដែលមិនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ជាភតិសន្យានៃទ្រព្យសកម្មដែលមានតម្លៃទាប ប្រសិនបើលក្ខណៈនៃទ្រព្យសម្បត្តិដែលមានសភាពថ្មី ហើយជាទូទៅមិនមានតម្លៃទាប ។ ឧទាហរណ៍ការជួលឡានដែលមិនសមស្របជាភតិសន្យាជួលនៃទ្រព្យសកម្មដែលមានតម្លៃទាបឡើយ ព្រោះឡានថ្មីមិនមានតម្លៃទាបឡើយ។

សម្ព័ន្ធធនាគារ និងធនាគារបានជ្រើសរើសមិនទទួលស្គាល់សិទ្ធិប្រើប្រាស់ទ្រព្យសកម្ម និងបំណុលភតិសន្យាត្រឹមត្រូវ សម្រាប់ភតិសន្យានៃទ្រព្យសកម្មដែលមានតម្លៃទាប និងភតិសន្យារយៈពេលខ្លី។ សម្ព័ន្ធធនាគារ និងធនាគារទទួលស្គាល់ការទូទាត់ភតិសន្យាដែលទាក់ទងនឹងភតិសន្យាទាំងនេះ ជាការចំណាយតាមមូលដ្ឋានថេរក្នុងរយៈពេលនៃភតិសន្យា។

(ជ) ទ្រព្យសកម្មយថាភាព និងបំណុលយថាភាព

ទ្រព្យសកម្មយថាភាព គឺជាការកើតឡើងដោយមិនបានគ្រោងទុក ឬរំពឹងទុកដែលបណ្តាលមកពីភាពដែលអាចទៅរួចនៃលំហូរចូលនូវអត្ថប្រយោជន៍សេដ្ឋកិច្ចទៅលើសម្ព័ន្ធធនាគារ និងធនាគារ។ ជាលទ្ធផល វាត្រូវបានគេចាត់ទុកថាជាចំណូលដែលមិនអាចទទួលស្គាល់ ទ្រព្យសកម្មយថាភាព មិនត្រូវបានកត់ត្រាក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់សម្ព័ន្ធធនាគារ និងធនាគារ។

បំណុលយថាភាព ត្រូវបានរាប់បញ្ចូលទាំងការធានា និងលិខិតឥណទានដែលត្រូវបានដាក់តំកល់ជាទ្រព្យបញ្ចាំ គឺកាតព្វកិច្ចដែលអាចកើតមានបណ្តាលពីព្រឹត្តិការណ៍អតីតកាលទាំងឡាយ ដែលអត្ថិភាពរបស់វានឹងត្រូវបានបញ្ជាក់ដោយការកើតឡើង ឬមិនកើតឡើងនៃព្រឹត្តិការណ៍នាពេលអនាគតមិនប្រាកដប្រជាមួយ ឬច្រើន ដែលមិនស្ថិតនៅក្រោមការគ្រប់គ្រងរបស់សម្ព័ន្ធធនាគារ និងធនាគារ ឬជាកាតព្វកិច្ចបច្ចុប្បន្ន ដែលកើតឡើងពីព្រឹត្តិការណ៍អតីតកាលដែលមិនបានទទួលស្គាល់ ពីព្រោះវាអាចជាលំហូរចេញនៃអត្ថប្រយោជន៍សេដ្ឋកិច្ច ឬព្រោះតែមិនអាចវាស់វែងទៅលើចំនួននៃកាតព្វកិច្ចអោយបានច្បាស់លាស់។

បំណុលយថាភាព មិនត្រូវបានកត់ត្រាក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់សម្ព័ន្ធធនាគារ និងធនាគារ ប៉ុន្តែត្រូវបានដាក់បង្ហាញ លើកលែងតែប្រូបាប៊ីលីតេនៃការកាត់កង គឺស្ទើរតែគ្មាន។

ធនាគារ អេស៊ីលីដា ភីអិលស៊ី និង ក្រុមហ៊ុនបុត្រសម្ព័ន្ធ

កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ និងសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់

២. សេចក្តីសង្ខេបអំពីគោលនយោបាយគណនេយ្យសំខាន់ៗ (ត)

(ព) ព្រឹត្តិការណ៍បន្ទាប់ពីកាលបរិច្ឆេទនៃរបាយការណ៍

សម្ព័ន្ធធនាគារ និងធនាគារកំណត់យកព្រឹត្តិការណ៍បន្ទាប់ពីចុងការិយបរិច្ឆេទដែលបានបញ្ចប់នៃរបាយការណ៍នីមួយៗ ថាព្រឹត្តិការណ៍ទាំងនោះជាព្រឹត្តិការណ៍អំណោយផល និងមិនអំណោយផល ដែលកើតឡើងក្នុងរវាងចុងការិយបរិច្ឆេទនៃ របាយការណ៍ និងនាកាលបរិច្ឆេទដែលរបាយការណ៍ហិរញ្ញវត្ថុបណ្តោះអាសន្នបានអនុម័តឱ្យចេញផ្សាយ។ របាយការណ៍ហិរញ្ញវត្ថុបណ្តោះអាសន្នរបស់សម្ព័ន្ធធនាគារ និងធនាគារ គឺត្រូវធ្វើនិយ័តកម្មដើម្បីឆ្លុះបញ្ចាំងពីព្រឹត្តិការណ៍ទាំងនោះ ដែលផ្តល់នូវភស្តុតាងនៃស្ថានភាពដែលបានកើតឡើងនាចុងការិយបរិច្ឆេទនៃរបាយការណ៍។ ព្រឹត្តិការណ៍ ដែលមិនបានធ្វើនិយ័តកម្មបន្ទាប់ចុងការិយបរិច្ឆេទ នៃរបាយការណ៍ត្រូវបានបង្ហាញនៅក្នុងកំណត់សម្គាល់នៃរបាយការណ៍ហិរញ្ញវត្ថុបណ្តោះអាសន្នជាសារវន្ត។

(ក) របាយការណ៍តាមផ្នែក

ប្រតិបត្តិការតាមផ្នែក គឺជាធាតុផ្សំរបស់សម្ព័ន្ធធនាគារដែលទាក់ទងនឹងសកម្មភាពអាជីវកម្ម ដែលវាអាចនឹងកើតមានចំណូល និងចំណាយ ដែលរួមបញ្ចូលចំណូល និងចំណាយ ដែលទាក់ទងនឹងប្រតិបត្តិការដែលមាននៅក្នុងធាតុផ្សំរបស់សម្ព័ន្ធធនាគារ។

ព័ត៌មានអំពីប្រតិបត្តិការតាមផ្នែក ដែលត្រូវនឹងកម្រិតកំណត់ខាងក្រោម សម្ព័ន្ធធនាគារនឹងរាយការណ៍ដាច់ដោយឡែករួមមាន៖

- ចំនួនទឹកប្រាក់នៃរបាយការណ៍ចំណេញ ឬខាតដែលស្មើនឹង ១០% ឬច្រើនជាងនៃចំនួនទឹកប្រាក់ចំណេញរួមនៃប្រតិបត្តិការតាមផ្នែកទាំងអស់ ដែលមិនរាយការណ៍ខាត និងទឹកប្រាក់ខាតរួមនៃប្រតិបត្តិការតាមផ្នែកទាំងអស់ដែលរាយការណ៍ខាត និង
- ទ្រព្យសកម្មដែលមានចំនួន ១០% ឬច្រើនជាងនៃទ្រព្យសកម្មរួមនៃប្រតិបត្តិការតាមផ្នែក។

ប្រតិបត្តិការតាមផ្នែក ដែលមិនត្រូវនឹងកម្រិតកំណត់នេះ អាចត្រូវបានរាយការណ៍ និងលាតត្រដាងដាច់ដោយឡែក ប្រសិនបើអ្នកគ្រប់គ្រងជឿថាព័ត៌មានអំពីផ្នែកនោះ គឺផ្តល់ផលប្រយោជន៍សម្រាប់អ្នកប្រើប្រាស់នៃរបាយការណ៍ហិរញ្ញវត្ថុរួម។

សម្រាប់គោលបំណងរបស់អ្នកគ្រប់គ្រង សម្ព័ន្ធធនាគារគឺកំពុងតែរៀបចំឱ្យទៅជាអាជីវកម្មធំៗចំនួន២ គឺឱ្យកម្ចី និង សេវាហិរញ្ញវត្ថុផ្សេងៗ។ ផ្នែកទាំងនេះជាមូលដ្ឋាន ដែលសម្ព័ន្ធធនាគាររាយការណ៍ ក្នុងរបាយការណ៍តាមផ្នែកដំបូង។

ព័ត៌មានហិរញ្ញវត្ថុតាមផ្នែកត្រូវបានលាតត្រដាងនៅក្នុងកំណត់សម្គាល់៦។

៣. សមាសភាពនៃសម្ព័ន្ធ

លម្អិតនៃបុត្រសម្ព័ន្ធរបស់ធនាគារនៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ និងថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ គឺត្រូវបានលាតត្រដាងនៅក្នុងកំណត់សម្គាល់១៣។

៣. សមាសភាពនៃសម្ព័ន្ធ (ត)

ព័ត៌មានហិរញ្ញវត្ថុសំខាន់ៗនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ នៃបុត្រសម្ព័ន្ធមិនមែនកាន់កាប់ដោយធនាគារ ដែលមានភាគកម្មមិនមានអភិបាលភាពជាសារវន្ត នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ និងសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ត្រូវបានបង្ហាញនៅក្នុងទំព័រ។ សង្ខេបនៃព័ត៌មានហិរញ្ញវត្ថុខាងក្រោម គឺតំណាងឱ្យចំនួនទឹកប្រាក់មុនពេលលុបបំបាត់ចោល

វិទ្យាស្ថានពាណិជ្ជសាស្ត្រ អេស៊ីលីដា	**២០២១** **ដុល្លារអាមេរិក**
ស្ថានភាពហិរញ្ញវត្ថុ	
ទ្រព្យសកម្មរយៈពេលខ្លី	២.០១៦.៥១៨
ទ្រព្យសកម្មរយៈពេលវែង	៣២.៧១២.៨៩៤
ទ្រព្យសកម្មសរុប	៣៤.៧២៩.៤១២
បំណុលរយៈពេលខ្លី	៤៥៩.៧៥៩
បំណុលរយៈពេលវែង	៨.៦៤៧.៤១៤
បំណុលសរុប	៩.១០៧.១៧៣
មូលធន	២៥.៦២២.២៣៩
ម្ចាស់កម្មសិទ្ធិ និងសិទ្ធិបោះឆ្នោតកាន់កាប់ដោយភាគកម្មមិនមានអភិបាលភាព	២៣,៣៩១%
មូលធនបែងចែកទៅ៖	
មូលធនកាន់កាប់ដោយសម្ព័ន្ធធនាគារ	១៩.៦២៨.៩៤១
ភាគកម្មមិនមានអភិបាលភាព	៥.៩៩៣.២៩៨
លទ្ធផលនៃប្រតិបត្តិការ៖	
ចំណូល	៣.៨៩០.៤៩៧
ផ្លែដើម និងចំណាយ	៤.៩១៨.៧០៩
ចំណេញសម្រាប់ការិយបរិច្ឆេទ	(១.០២៨.២១២)
សរុបលទ្ធផលចំណេញលម្អិតផ្សេងៗសម្រាប់ការិយបរិច្ឆេទ	(១.១០១.៣០០)
ប្រាក់ចំណេញបែងចែកទៅ៖	
មូលធនកាន់កាប់ដោយសម្ព័ន្ធធនាគារ	(៧៨៧.៧០៣)
ភាគកម្មមិនមានអភិបាលភាព	(២៥០.៥០៩)
សរុបលទ្ធផលចំណេញលម្អិតផ្សេងៗសម្រាប់ការិយបរិច្ឆេទបែងចែកទៅ៖	
មូលធនកាន់កាប់ដោយសម្ព័ន្ធធនាគារ	(៨៤៣.៦៩៥)
ភាគកម្មមិនមានអភិបាលភាព	(២៥៧.៦០៥)
ភាគលាភបានបង់ទៅភាគកម្មមិនមានអភិបាលភាព	-
លំហូរសាច់ប្រាក់៖	
សាច់ប្រាក់ប្រើក្នុងសកម្មភាពប្រតិបត្តិការ	(១.៧០៩.១៧៦)
សាច់ប្រាក់ប្រើក្នុងសកម្មភាពវិនិយោគ	(៧៩.៩៤១)
សាច់ប្រាក់ប្រើក្នុងសកម្មភាពហិរញ្ញប្បទាន	១.៩៨៨.០៩៤
លំហូរសាច់ប្រាក់សុទ្ធ	២០៣.៩៧៧

៤. ការប៉ាន់ស្មាន និង វិនិច្ឆ័យគណនេយ្យសំខាន់ៗក្នុងការអនុវត្តគោលនយោបាយគណនេយ្យ

សម្ព័ន្ធធនាគារ និងធនាគារធ្វើការប៉ាន់ស្មាន និងការសន្មតដែលពាក់ព័ន្ធនឹងអនាគត។ តាមនិយមន័យការប៉ាន់ស្មានគណនេយ្យនឹងកម្រស្មើនឹងលទ្ធផលជាក់ស្តែងដែលពាក់ព័ន្ធ។ ដើម្បីលើកកម្ពស់ខ្លឹមសារព័ត៌មាននៃការប៉ាន់ស្មានអថេរសំខាន់ៗមួយចំនួន ដែលត្រូវបានគេរំពឹងថានឹងមានផលប៉ះពាល់ ជាសារវន្តដល់លទ្ធផល និងក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុរបស់សម្ព័ន្ធធនាគារ និងធនាគារ ត្រូវបានសាកល្បងសម្រាប់ភាពប្រែប្រួលទៅនឹងការផ្លាស់ប្តូរនៅក្នុងប៉ារ៉ាម៉ែត្រជាមូលដ្ឋាន។ ការប៉ាន់ស្មាន និងការសន្មតដែលមានហានិភ័យជាសារវន្តក្នុងការបង្ក ឱ្យមានការកែតម្រូវជាសារវន្តទៅនឹងតម្លៃយោងនៃទ្រព្យសម្ម និងបំណុលក្នុងឆ្នាំហិរញ្ញវត្ថុបន្ទាប់មានដូចខាងក្រោម៖

(ក) ការវិនិច្ឆ័យ

ព័ត៌មានអំពីការវិនិច្ឆ័យ ដែលបានធ្វើឡើងក្នុងការអនុវត្តគោលនយោបាយគណនេយ្យដែលមានឥទ្ធិពលជាសារវន្ត លើចំនួនទឹកប្រាក់ដែលត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ត្រូវបានបញ្ចូលក្នុងកំណត់សម្គាល់ដូចខាងក្រោម។

- កំណត់សម្គាល់ ២(ច) (ii)៖ ការធ្វើចំណាត់ថ្នាក់ទ្រព្យសកម្មហិរញ្ញវត្ថុ៖ ការវាយតម្លៃម៉ូដែលអាជីវកម្ម ដែលទ្រព្យទាំងនោះត្រូវបានកាន់កាប់ និងការវាយតម្លៃថាតើលក្ខខណ្ឌកិច្ចសន្យានៃទ្រព្យសកម្មហិរញ្ញវត្ថុ គឺជាការទូទាត់តែប្រាក់ដើម និងការប្រាក់ ("SPPI") តាមបរិមាណប្រាក់ដើមដែលនៅជាប់ជំពាក់។
- កំណត់សម្គាល់ ៣៨.១(ច)៖ ការបង្កើតលក្ខណៈវិនិច្ឆ័យសម្រាប់កំណត់ ថាតើហានិភ័យឥណទានលើទ្រព្យសកម្មហិរញ្ញវត្ថុបានកើនឡើងជាសារវន្ត ចាប់តាំងពីការទទួលស្គាល់ដំបូង ដោយកំណត់វិធីសាស្ត្រសម្រាប់បញ្ចូលព័ត៌មាននាពេលអនាគតទៅក្នុងការវាស់វែងនៃ ឥណទានដែលរំពឹងថានឹងបាត់បង់ (ECL) និងការជ្រើសរើស និងការអនុម័តលើម៉ូដែល ដែលប្រើដើម្បីវាស់វែង ECL។
- អត្រាប្រាក់បញ្ញើមានកាលកំណត់រយៈពេលវែងរបស់អតិថិជនត្រូវបានប្រើជាអត្រាអប្បហារ សម្រាប់គណនាបំណុលភតិសន្យា និងកាតព្វកិច្ចអត្ថប្រយោជន៍ពេលចូលនិវត្តន៍។

រូបិយប័ណ្ណគោល

ផ្អែកលើខ្លឹមសារសេដ្ឋកិច្ចនៃមូលដ្ឋានកាលៈទេសៈដែលពាក់ព័ន្ធនឹងសម្ព័ន្ធធនាគារ និងធនាគារ អ្នកគ្រប់គ្រងកំណត់យករូបិយប័ណ្ណគោលរបស់សម្ព័ន្ធធនាគារ និងធនាគារ ជាប្រាក់ដុល្លារអាមេរិក ("USD")។ ដុល្លារអាមេរិក គឺជារូបិយប័ណ្ណនៃបរិយាកាសសេដ្ឋកិច្ចចម្បងដែលសម្ព័ន្ធធនាគារ និងធនាគារ ធ្វើប្រិតបត្តិការ ហើយវាក៏ជារូបិយប័ណ្ណដែលមានឥទ្ធិពលខ្លាំងទៅលើឥណទាន និងបញ្ញើសន្សំផ្តល់ដល់អតិថិជន ដែលបង្កើតជាចំណូលការប្រាក់ និងចំណាយការប្រាក់។

៤. ការប៉ាន់ស្មាន និង វិនិច្ឆ័យគណនេយ្យសំខាន់ៗក្នុងការអនុវត្តគោលនយោបាយគណនេយ្យ (ត)

ភតិសន្យា

ការវាយតម្លៃថាតើការរៀបចំមានរួមបញ្ចូលនូវភតិសន្យា គឺផ្អែកលើខ្លឹមសាររបស់ភតិសន្យានោះ។ ការរៀបចំមាន ឬរួមមានភតិសន្យា ជួលនៅពេលដែលការបំពេញនូវ ការរៀបចំដោយផ្អែកលើទ្រព្យសកម្មជាក់លាក់ ឬ ទ្រព្យសកម្ម និងការរៀបចំដែលទាក់ទងសិទ្ធិក្នុងការប្រើប្រាស់លើទ្រព្យសកម្ម។

ក្នុងការសិក្សាដើម្បីកំណត់ថាភតិសន្យាមានតម្លៃទាប អ្នកគ្រប់គ្រងពិចារណាលើតម្លៃសេដ្ឋកិច្ចនៃទ្រព្យសកម្ម ទាំងមូល។

អត្ថប្រយោជន៍ពេលចូលនិវត្តន៍

អវត្តមាននៃទីផ្សារសញ្ញាប័ណ្ណ និងមូលបត្របំណុលរដ្ឋាភិបាល ការគ្រប់គ្រងបានប្រើអត្រាការប្រាក់បញ្ញើមានកាលកំណត់រយៈពេល ៦ ឆ្នាំ របស់ពួកគេ ជាអត្រាអប្បហារដើម្បីកំណត់តម្លៃបច្ចុប្បន្ននៃលំហូរសាច់ប្រាក់ដែលត្រូវបានប៉ាន់ស្មាននាពេលអនាគត ដែលគេរំពឹងថានឹងត្រូវបានតម្រូវដើម្បីទូទាត់កាតព្វកិច្ចអត្ថប្រយោជន៍ពេលចូលនិវត្តន៍។

(ខ) ភាពមិនច្បាស់លាស់នៃការសន្មត និងការប៉ាន់ស្មាន

ខាងក្រោមនេះគឺជាការសន្មត់សំខាន់ៗទាក់ទងនឹងអនាគត និងប្រភពសំខាន់ៗផ្សេងទៀតនៃភាពមិនប្រាកដប្រជានៃការប៉ាន់ប្រមាណនៅចុងបញ្ចប់នៃការិយបរិច្ឆេទរបាយការណ៍នីមួយៗ។

ឱនភាពនៃទ្រព្យសម្បត្តិហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិមិនមែនហិរញ្ញវត្ថុ

ឱនភាពកើតឡើងនៅពេលតម្លៃយោងរបស់ទ្រព្យសកម្ម ឬឯកតាបង្កើតសាច់ប្រាក់លើសតម្លៃអាចប្រមូលមកវិញបាន គឺជាតម្លៃដែលខ្ពស់ជាងរវាងតម្លៃសមស្របដកថ្លៃដើមដើម្បីលក់ និងតម្លៃប្រើប្រាស់។ តម្លៃសមស្របដកថ្លៃដើមដើម្បីលក់ ត្រូវបានគណនាដោយប្រើប្រាស់ទិន្នន័យដែលមានស្រាប់ពីប្រតិបត្តិការលក់នៅក្នុងប្រតិបត្តិការបុគ្គលជាប់ទាក់ទិនរបស់ទ្រព្យសកម្មដែលមានភាពស្រដៀងគ្នា ឬតម្លៃទីផ្សារដែលអាចសង្កេតបានដកការចំណាយកើនឡើងសម្រាប់ការលក់ទ្រព្យសកម្ម ។ តម្លៃប្រើប្រាស់ ត្រូវបានគណនាដោយប្រើមូលដ្ឋានអប្បហារ។ លំហូរសាច់ប្រាក់បានពីគម្រោងថវិការ និងមិនរួមបញ្ចូលការកែប្រែរចនាសម្ព័ន្ធ របស់ធនាគារ និងសម្ព័ន្ធធនាគារ ដែលមិនទាន់បានប្តេជ្ញា ឬធ្វើការវិនិយោគនាពេលអនាគតដែលនឹងធ្វើឱ្យប្រសើរឡើងវិញនៃសមត្ថភាពទ្រព្យសកម្មរបស់ឯកតាបង្កើតសាច់ប្រាក់ដែលកំពុងធ្វើតេស្ត។

តម្លៃអាចប្រមូលមកវិញបាន គឺល្អបំផុតសម្រាប់អត្រាអប្បហារ ដែលប្រើប្រាស់សម្រាប់ម៉ូដែលអប្បហារលំហូរសាច់ប្រាក់ ក៏ដូចជាលំហូរសាច់ប្រាក់ដែលរំពឹងទុកថានឹងហូរចូលនៅពេលអនាគត និងអត្រាកំណើនដែលត្រូវបានប្រើប្រាស់សម្រាប់គោលបំណងបន្ថែម។

ធនាគារ អេស៊ីលីដា ភីអិលស៊ី និង ក្រុមហ៊ុនបុត្រសម្ព័ន្ធ

កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ និងសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់

៤. ការប៉ាន់ស្មាន និង វិនិច្ឆ័យគណនេយ្យសំខាន់ៗក្នុងការអនុវត្តគោលនយោបាយគណនេយ្យ (ត)

(ខ) ភាពមិនច្បាស់លាស់នៃការសន្មត និងការប៉ាន់ស្មាន (ត)

- កំណត់សម្គាល់ ៣៨.១(ច)៖ ឱនភាពនៃតម្លៃរបស់ឧបករណ៍ហិរញ្ញវត្ថុ៖ កំណត់ការបញ្ចូលសមាសធាតុទៅក្នុងម៉ូដែលនៃការវាស់វែង ការខាតបង់ឥណទានដែលរំពឹងទុក (ECL) រួមទាំងការបញ្ចូលព័ត៌មាននាពេលអនាគត ។
- កំណត់សម្គាល់ ៣៩៖ ការកំណត់លើតម្លៃសមស្របនៃឧបករណ៍ហិរញ្ញវត្ថុជាមួយទិន្នន័យដែលមិនអាចអង្កេតបានជាសារវន្ត។
- កំណត់សម្គាល់ ៣៥៖ ការទទួលស្គាល់ និងការវាស់វែងយថាភាព៖ ការសន្មតសំខាន់ៗអំពីលទ្ធភាព និងទំហំនៃលំហូរធនធាន។
- កំណត់សម្គាល់ ២(ច)(vii)៖ ឱនភាពនៃតម្លៃរបស់ឧបករណ៍ហិរញ្ញវត្ថុ៖ ការសន្មតសំខាន់ៗ ដែលប្រើក្នុងការប៉ាន់ស្មាន លំហូរសាច់ប្រាក់ដែលអាចប្រមូលមកវិញបាន។

អនុវត្តតាម ស.គ.ក ៣៦៖ ឱនភាពនៃទ្រព្យសកម្ម៖ នៅបញ្ចប់នៃការិយបរិច្ឆេទរបាយការណ៍នីមួយៗ ធនាគារធ្វើការសិក្សាថាតើមានសូចនាករណាមួយដែលបង្ហាញថាការវិនិយោគនៅក្នុងបុត្រសម្ព័ន្ធអាចនឹងមានឱនភាពដែរឬទេ? ប្រសិនបើមានការចង្អុលបង្ហាញបែបនេះ ធនាគារត្រូវប៉ាន់ប្រមាណនូវចំនួនទឹកប្រាក់ដែលអាចទទួលបានមកវិញនៃទ្រព្យកម្ម និងធ្វើការប្រៀបធៀប សមតុល្យយោង ជាមួយនឹងទឹកប្រាក់ដែលបានធ្វើការសិក្សា។

ក្នុងការសិក្សាថាតើមានសូចនាករណាមួយដែលបង្ហាញថាទ្រព្យសកម្មអាចនឹងមានឱនភាព ធនាគារត្រូវពិចារណាជាអប្បបរមាលើសូចនាករដូចខាងក្រោម៖

- ប្រភពព័ត៌មានខាងក្រៅ
  - ក) តម្លៃទីផ្សារនៃទ្រព្យសកម្មបានថយចុះគួរឲ្យកត់សម្គាល់ក្នុងអំឡុងពេលណាមួយ លើសពីការរំពឹងទុកដោយសារ កន្លងហួសពេលវេលា ឬការប្រើប្រាស់ធម្មតា។
  - ខ) ការផ្លាស់ប្តូរគួរឱ្យកត់សម្គាល់ដែលមានផលប៉ះពាល់អវិជ្ជមានដល់ធនាគារដែលបានកើតឡើងក្នុងអំឡុងពេល ឬនឹងកើតឡើងនាពេលអនាគតដ៏ខ្លី នៅក្នុងបរិដ្ឋាននៃបច្ចេកវិទ្យាទីផ្សារ សេដ្ឋកិច្ច ឬច្បាប់ដែលធនាគារធ្វើអាជីវកម្ម ឬនៅក្នុងទីផ្សារដែលទ្រព្យសកម្មមានគោលបំណងពិសេស។
  - គ) អត្រាការប្រាក់ទីផ្សារ ឬអត្រាទីផ្សារផ្សេងទៀតនៃផលចំណេញពីការវិនិយោគដែលបានកើនឡើងក្នុងអំឡុងពេលនោះ ហើយការកើនឡើងទាំងនោះទំនងជាប៉ះពាល់ដល់អត្រាអប្បហារដែលបានប្រើប្រាស់ក្នុងការគណនាតម្លៃកំពុងប្រើប្រាស់របស់ទ្រព្យសកម្ម ហើយធ្លាក់ចុះជាសារវន្តនូវតម្លៃទទួលបានមកវិញរបស់ទ្រព្យ។
  - ឃ) តម្លៃក្នុងបញ្ជីរបស់ទ្រព្យសកម្មសុទ្ធ របស់អង្គភាពលើសពីមូលធននីយកម្ម។

៤. ការប៉ាន់ស្មាន និង វិនិច្ឆ័យគណនេយ្យសំខាន់ៗក្នុងការអនុវត្តគោលនយោបាយគណនេយ្យ (ត)

(ខ) ភាពមិនច្បាស់លាស់នៃការសន្មត និងការប៉ាន់ស្មាន (ត)

- ប្រភពព័ត៌មានខាងក្នុង
  - ក) ភស្តុតាងដែលអាចរកបានពីភាពហួសសម័យ ឬការខូចខាតនៃទ្រព្យសកម្ម។
  - ខ) ការផ្លាស់ប្តូរដែលមានផលប៉ះពាល់អវិជ្ជមានលើធនាគារ ដែលបានកើតឡើងក្នុងអំឡុងពេលនោះ ឬត្រូវបានរំពឹងថានឹងកើតឡើងនាពេលអនាគតដ៏ខ្លី ក្នុងទំហំ និងឥរិយាបទដែលទ្រព្យសកម្មត្រូវបានកំពុងប្រើប្រាស់ ឬរំពឹងថានឹងប្រើប្រាស់ ។ ការផ្លាស់ប្តូរទាំងនេះរួមមាន ទ្រព្យសកម្មដែលនៅទំនេរ ផែនការមិនបន្ត ឬរុះរើប្រតិបត្តិការដែលទ្រព្យសកម្មកំពុងស្ថិតនៅ ផែនការលុបចោលទ្រព្យសកម្មមុនកាលបរិច្ឆេទដែលរំពឹងទុកពីមុន។
  - គ) ភស្តុតាងដែលអាចរកបានពីរបាយការណ៍ផ្ទៃកក្នុង ដែលបង្ហាញថាដំណើរការសេដ្ឋកិច្ចរបស់ទ្រព្យសកម្ម មានភាពអាក្រក់ ឬនឹងអាក្រក់ជាងការរំពឹងទុក។

ក្នុងការកំណត់តម្លៃដែលអាចប្រមូលមកវិញបាន ធនាគារបានធ្វើការព្យាករណ៍លើលំហូរសាច់ប្រាក់សុទ្ធក្នុងកាលបរិច្ឆេទប្រាំឆ្នាំខាងមុខរបស់ខ្លួន ដោយប្រើប្រាស់គំរូ Gordon Growth។ ក្រោមគំរូនេះ អ្នកគ្រប់គ្រងកំណត់ថ្លៃដើមជាមធ្យមនៃដើមទុនជាអត្រាអប្បហារ ដោយផ្អែកលើរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួចចុងក្រោយបង្អស់របស់ធនាគារ ហើយអាចផ្លាស់ប្តូរបានប្រសិនបើមានការធានា។ បន្ថែមពីនេះទៀត អ្នកគ្រប់គ្រងសន្មតថាអត្រាកំណើន GPD ជាមធ្យមក្នុងរយៈពេល ១០ឆ្នាំរបស់ប្រទេសនីមួយៗដែលក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ធនាគារកំពុងធ្វើប្រតិបត្តិការអាជីវកម្ម គឺស្មើនឹងអត្រាកំណើន និងត្រូវធ្វើបច្ចុប្បន្នភាពតាមកាលបរិច្ឆេទនីមួយៗ។

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ អ្នកគ្រប់គ្រងជឿជាក់ថាតម្លៃដែលអាចប្រមូលមកវិញបាននៃមូលធនវិនិយោគរបស់ធនាគារ លើសពីតម្លៃយោងរបស់ខ្លួន។ ដូច្នេះហើយមិនមានការខាតបង់លើឱនភាពនៃតម្លៃណាមួយត្រូវបានកត់ត្រាឡើយ។

វីរុសកូរ៉ូណា និងផលប៉ះពាល់លើការខាតបង់ឥណទានរំពឹងទុក

ការខាតបង់ឥណទានរំពឹងទុកត្រូវបានប៉ាន់ប្រមាណដោយផ្អែកទៅលើលក្ខខណ្ឌសេដ្ឋកិច្ចដែលបានព្យាករណ៍មួយចំនួននៅក្នុងការិយបរិច្ឆេទរាយការណ៍។ ការផ្ទុះឡើងនៃណូវែលវីរុសកូរ៉ូណា (“កូវីដ-១៩”) បានរាលដាលលើប្រទេសចិនដីគោក កម្ពុជា និងបណ្តាប្រទេសផ្សេងៗទៀត ធ្វើឱ្យមានការរាំងស្ទះសកម្មភាពអាជីវកម្ម និងសេដ្ឋកិច្ច។

ផលប៉ះពាល់លើផលិតផលក្នុងស្រុកសរុប (ផ.ស.ស) និងសូចនាករសំខាន់ផ្សេងៗត្រូវបានពិចារណាក្នុងការកំណត់ភាពធ្ងន់ធ្ងរ និងលទ្ធភាពនៃការធ្លាក់ចុះនៃសេដ្ឋកិច្ចដែលប្រើប្រាស់ក្នុងការព្យាករណ៍ការខាតបង់ឥណទានរំពឹងទុក។

៤. ការប៉ាន់ស្មាន និង វិនិច្ឆ័យគណនេយ្យសំខាន់ៗក្នុងការអនុវត្តគោលនយោបាយគណនេយ្យ (ត)

(ខ) ភាពមិនច្បាស់លាស់នៃការសន្មត និងការប៉ាន់ស្មាន (ត)

រុសក្ហ្ស៊ីណា និងផលប៉ះពាល់លើការខាតបង់ឥណទានរំពឹងទុក (ត)

ការគណនាការខាតបង់ឥណទានរំពឹងទុកនៅស្ថានភាពបច្ចុប្បន្នអាចមានភាពមិនជាក់លាក់ជាសារវន្ត។ អ្នកគ្រប់គ្រងបានព្យាករណ៍ទៅលើផលប៉ះពាល់របស់រីរុសក្ហ្ស៊ីណាទៅលើសម្ព័ន្ធធនាគារ និងធនាគារ ប៉ុន្តែការព្យាករណ៍នេះអាចនឹងប្រែប្រួលជាសារវន្តពេលមានព្រឹត្តិការណ៍កើតឡើង។ នៅពេលដែលផលប៉ះពាល់នោះកាន់តែមានសភាពធ្ងន់ធ្ងរ និងយូរជាងការរំពឹងទុក នោះនឹងបណ្តាលឱ្យមានផលប៉ះពាល់ទៅលើខាតបង់ឥណទានរំពឹងទុក ស្ថានភាពហិរញ្ញវត្ថុ និងលទ្ធផលហិរញ្ញវត្ថុរបស់សម្ព័ន្ធធនាគារ និងធនាគារ។

អត្ថប្រយោជន៍ពេលចូលនិវត្តន៍

តម្លៃបច្ចុប្បន្ននៃកាតព្វកិច្ចអត្ថប្រយោជន៍ចូលនិវត្តន៍អាស្រ័យលើកត្តាមួយចំនួន ដែលត្រូវបានកំណត់ដោយការគ្រប់គ្រង ដោយប្រើការសន្មតមួយចំនួនដូចជាអត្រាកំណើនប្រាក់ខែ អត្រាឈប់ពីការងារ និងអត្រាមរណភាព។ ការសន្មតដែលត្រូវបានប្រើក្នុងការកំណត់ចំណាយសុទ្ធសម្រាប់អត្ថប្រយោជន៍ពេលចូលនិវត្តន៍ រួមមានអត្រាអប្បហារ។ ការផ្លាស់ប្តូរណាមួយនៅក្នុងការសន្មតទាំងនេះ នឹងប៉ះពាល់ដល់តម្លៃនៃកាតព្វកិច្ចអត្ថប្រយោជន៍ពេលចូលនិវត្តន៍។

ពន្ធ

ពន្ធត្រូវបានគណនាលើមូលដ្ឋាននៃការបកស្រាយលើបទប្បញ្ញត្តិពន្ធបច្ចុប្បន្ន ដែលបានអនុម័តនាកាលបរិច្ឆេទនៃរបាយការណ៍។ អ្នកគ្រប់គ្រងវាយតម្លៃជាប្រចាំលើស្ថានភាពនៃប្រកាសពន្ធដែលស្របជាមួយបទប្បញ្ញត្តិ ស្តីពីពន្ធដារ ដែលត្រូវបានបកស្រាយ។ ច្បាប់នេះបង្កើតនូវបទប្បញ្ញាត្តិដែលសមស្រប លើមូលដ្ឋាននៃចំនួនទឹកប្រាក់ដែលបានរំពឹងទុកថានឹងត្រូវបង់ជូនអាជ្ញាធរពន្ធដារ។

ទោះជាយ៉ាងណាក៏ដោយ បទប្បញ្ញាត្តិទាំងនេះអាចមានការប្រែប្រួលតាមកាលកំណត់ ហើយការកំណត់នៃបំណុលពន្ធនឹងត្រូវបានធ្វើឡើងបន្ទាប់ពីការត្រួតពិនិត្យពីអាជ្ញាធរពន្ធដារ។ នៅពេលដែលលទ្ធផលពន្ធចុងក្រោយ នៃបញ្ហាទាំងនេះខុសគ្នាពីចំនួនទឹកប្រាក់ដែលបានកត់ត្រាដំបូង ភាពខុសគ្នាទាំងនេះនឹងប៉ះពាល់ដល់បំណុលពន្ធ និងសមតុល្យក្នុងកាលបរិច្ឆេទដែលការកំណត់ត្រូវបានធ្វើឡើង។

៤. ការប៉ាន់ស្មាន និង វិនិច្ឆ័យគណនេយ្យសំខាន់ៗក្នុងការអនុវត្តគោលនយោបាយគណនេយ្យ (ត)

(ខ) ភាពមិនច្បាស់លាស់នៃការសន្មត និងការប៉ាន់ស្មាន (ត)

ការប៉ាន់ស្មានថ្លៃដើមនៃសិទ្ធិប្រើប្រាស់ទ្រព្យសកម្ម

ការកំណត់ថ្លៃដើមនៃសិទ្ធិប្រើប្រាស់ទ្រព្យសកម្មរួមបញ្ចូលចំនួននៃបំណុលភតិសន្យាដែលទទួលស្គាល់ និងការប៉ាន់ស្មានថ្លៃដើម ដែលនឹងកើតឡើងនៅពេលរុះរើ និងដកចេញនូវទ្រព្យសកម្មនោះ ឬធ្វើឱ្យដូចដើមតាមលក្ខខណ្ឌដែលមានចែងក្នុងកិច្ចសន្យា។

បំណុលភតិសន្យា គឺវាស់វែងតាមតម្លៃបច្ចុប្បន្ន នៃភតិសន្យាដែលត្រូវទូទាត់ទៅតាមរយៈពេលនៃភតិសន្យា។

នៅក្នុងការគណនា បំណុលភតិសន្យា សម្ព័ន្ធធនាគារ និងធនាគារប្រើប្រាស់អត្រាមធ្យមនៃប្រាក់ថ្លៃដើមកម្ចី និងអត្រាការប្រាក់នៃប្រាក់បញ្ញើមានកាលកំណត់សម្រាប់រយៈពេលវែង នៅពេលចាប់ផ្តើមអនុវត្ត ទៅតាមរយៈពេលនៃភតិសន្យា។

ការប៉ាន់ស្មានអាយុកាលនៃទ្រព្យសកម្ម

អាយុកាលនៃការប្រើប្រាស់ទ្រព្យសកម្មរបស់សម្ព័ន្ធធនាគារ និងធនាគារត្រូវបានប៉ាន់ស្មានផ្អែកលើការរំពឹងទុកទ្រព្យសកម្មអាចប្រើប្រាស់បាន។ ការប៉ាន់ស្មានអាយុកាលទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារបស់សម្ព័ន្ធធនាគារ និងធនាគារត្រូវបានត្រួតពិនិត្យជាប្រចាំតាមកាលកំណត់ និងកែប្រែប្រសិនបើការរំពឹងទុកខុសពីការប៉ាន់ស្មានដោយសាររូបរាង បច្ចេកទេស ឬសម័យកាល និងតាមច្បាប់ ឬការកំណត់ការប្រើប្រាស់ទ្រព្យសកម្មនៃសម្ព័ន្ធធនាគារ និងធនាគារ។ បន្ថែមលើសពីនេះការប៉ាន់ស្មានអាយុកាល គឺផ្អែកទៅលើការវាយតម្លៃតាមការអនុវត្តនៅក្នុងវិស័យ ការវាយតម្លៃតាមអ្នកបច្ចេកទេសខាងក្នុង និងបទពិសោធន៍លើទ្រព្យសកម្មដែលស្រដៀងគ្នា។ ទោះបីជាយ៉ាងណាក៏ដោយ លទ្ធផលប្រតិបត្តិការនៅពេលអនាគតអាចប៉ះពាល់ជាសារវន្ត ដោយការកែប្រែការប៉ាន់ស្មានតាមកត្តាដែលរៀបរាប់ខាងលើ។ ចំនួនទឹកប្រាក់ និងពេលវេលានៃកត់ត្រាចំណាយនៃរយៈពេលណាមួយ អាចមានផលប៉ះពាល់ដោយសារការកែប្រែនៃកត្តាទាំងនោះ។ ការថយចុះនៃការប៉ាន់ស្មានអាយុកាលប្រើប្រាស់ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារនឹងកើនឡើងការទទួលស្គាល់ចំណាយប្រតិបត្តិការ និងថយចុះទ្រព្យសកម្មរយៈពេលវែង។

៥. ការប្តូរពីដុល្លារអាមេរិកទៅជាប្រាក់រៀល

របាយការណ៍ហិរញ្ញវត្ថុ ត្រូវបានបង្ហាញជាប្រាក់ដុល្លារអាមេរិក។ ការប្តូររូបិយប័ណ្ណពីប្រាក់ដុល្លារអាមេរិក ទៅជាប្រាក់រៀល ត្រូវបានធ្វើឡើងដើម្បីសម្រាប់តែអនុវត្តទៅតាមច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម។

ទ្រព្យសកម្ម និងបំណុលត្រូវបានប្តូរតាមអត្រា នាកាលបរិច្ឆេទរាយការណ៍។ របាយការណ៍ចំណេញ ឬខាត និងលទ្ធផលលម្អិតផ្សេងៗ និងរបាយការណ៍លំហូរទឹកប្រាក់ ត្រូវបានប្តូរទៅជាប្រាក់រៀល ដោយប្រើប្រាស់អត្រាមធ្យម

ធនាគារ អេស៊ីលីដា ភីអិលស៊ី និង ក្រុមហ៊ុនបុត្រសម្ព័ន្ធ

កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ និងសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់

៥. ការប្តូរពីដុល្លារអាមេរិកទៅជាប្រាក់រៀល (ត)

នៅក្នុងការិយបរិច្ឆេទ។ ភាពខុសគ្នាដែលកើតឡើងពីការប្តូររូបិយប័ណ្ណ ត្រូវបានទទួលស្គាល់ជា "លម្អៀងពីការប្តូររូបិយប័ណ្ណ" នៅក្នុងរបាយការណ៍លទ្ធផលលម្អិតផ្សេងៗ។

សម្ព័ន្ធធនាគារ និង ធនាគារ ប្រើប្រាស់អត្រារូបិយប័ណ្ណដូចខាងក្រោម៖

			អត្រានាកាលបរិច្ឆេទរាយការណ៍	**អត្រាមធ្យម**
ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១	១ ដុល្លារអាមេរិក =		៤.០៧៤រៀល	៤.០៦៨រៀល
ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០	១ ដុល្លារអាមេរិក =		៤.០៤៥រៀល	៤.០៧៧រៀល

តួលេខដែលត្រូវបានប្តូរនេះ មិនគួរបកស្រាយថាតួលេខនេះជាតួលេខសម្រាប់បង្ហាញ ដូចតួលេខជាប្រាក់ដុល្លារអាមេរិក ឬយល់ថាជាតួលេខត្រូវបានប្តូរ ឬអាចប្តូរទៅជាប្រាក់រៀលតាមអត្រាប្តូរប្រាក់ខាងលើ ឬអត្រាប្តូរប្រាក់ផ្សេងទៀតទេ។

៦. ព័ត៌មានតាមផ្នែក

ប្រតិបត្តិការចម្បងរបស់សម្ព័ន្ធធនាគារ គឺក្នុងវិស័យហិរញ្ញវត្ថុ ដែលបានកំណត់ដោយរបាយការណ៍តាមផ្នែករបស់សម្ព័ន្ធធនាគារ។

(ក) អាជីវកម្មតាមផ្នែក

ប្រតិបត្តិការអាជីវកម្មរបស់សម្ព័ន្ធធនាគារ គឺគ្រប់គ្រងដាច់ដោយឡែក តាមលក្ខណៈនៃសេវា (ផ្នែកដំបូង) និងតាមទីផ្សារតំបន់ផ្សេងគ្នា (ផ្នែកទី២) ដែលផ្នែកនីមួយៗ គឺតំណាងឱ្យយុទ្ធសាស្ត្រអាជីវកម្ម។ ផ្នែកអាជីវកម្មរបស់សម្ព័ន្ធធនាគារមានដូចខាងក្រោម៖

កម្ចី៖ ផ្តល់ប្រាក់កម្ចីទៅឯកត្តជន ក្រុម និងនីតិបុគ្គល ក៏ដូចជា ស្ថាប័នហិរញ្ញវត្ថុ។ ផលិតផលត្រូវផ្តល់ជូនទៅតាមគោលបំណង លក្ខណៈ និងទំហំដូចជា កម្ចីជាក្រុម កម្ចីធនតូច កម្ចីមធ្យម កម្ចីទិញផ្ទះ កម្ចីទិញឡាន កម្ចីទិញម៉ូតូ ឥណទានវិបារូបរ៍ កម្ចីសម្រាប់ទុនបង្វិលភតិសន្យាហិរញ្ញវត្ថុ និងកម្ចីហិរញ្ញប្បទានពាណិជ្ជកម្ម ។ល។

សេវាហិរញ្ញវត្ថុផ្សេងៗ៖ ផ្តល់សេវាផ្សេងៗដូចជា ប្តូរប្រាក់ ការផ្តល់កាតឥណទាន និងឥណពន្ធ និងការទទួលសេវាកម្ម ការផ្ទេរប្រាក់ នៅក្នុងប្រទេស និងក្រៅប្រទេស សេវាចាត់ចែងសាច់ប្រាក់ ដូចជា ប្រាក់បៀវត្ស៍ និងប្រមូលសាច់ប្រាក់ ទូទាត់វិក្កយបត្រ បញ្ជូលទឹកប្រាក់ទូរស័ព្ទ និងបញ្ជាអចិន្ត្រៃយ៍។ សេវាទាំងនេះ គឺកំពុងធ្វើទំនើបកម្មប្រើប្រាស់តាមប្រព័ន្ធធនាគារឌីជីថល តាមរយៈកម្មវិធីទូរស័ព្ទ អេបក្នុងទូរស័ព្ទដៃ អេស៊ីលីដា អ៊ីនធើណែត និង អ៊ីខុមមើស ក៏ដូចជាកម្មវិធីឌីជីថលផ្សេងៗទៀត។

៦. ព័ត៌មានតាមផ្នែក (ត)

(ក) អាជីវកម្មតាមផ្នែក (ត)

ផ្នែកទាំងនេះ គឺជាមូលដ្ឋានដែលសម្ព័ន្ធធនាគាររាយការណ៍ជាព័ត៌មាននៃផ្នែកដំបូង។ ប្រតិបត្តិការផ្សេងៗរបស់សម្ព័ន្ធធនាគារ រួមមានប្រតិបត្តិការ និងហិរញ្ញវត្ថុគ្រប់គ្រងដោយសម្ព័ន្ធធនាគារ។ ប្រតិបត្តិការរវាងផ្នែកនីមួយៗកើតឡើងតាមការប៉ាន់ស្មានអត្រាទីផ្សារលើមូលដ្ឋានជំហ៊ាងដៃ។

ចំណូល និងចំណាយតាមផ្នែក គឺបែងចែកដោយផ្ទាល់ទៅផ្នែកដំបូងនៃអាជីវកម្ម និងទាក់ទងនឹងផ្នែកខ្លះនៃចំណូល និងចំណាយរបស់សម្ព័ន្ធធនាគារ ដែលអាចចែកទៅតាមផ្នែកនៃអាជីវកម្ម ដែលឆ្លុះបញ្ចាំងពីចំណូល និងចំណាយនៃផ្នែកអាជីវកម្មនោះ។

សម្រាប់ផ្នែកទី២ ចំណូល និងចំណាយ នឹងបែងចែកទៅតាមតំបន់ភូមិសាស្ត្រ ដោយផ្អែកលើធនធានដែលបង្កើតប្រាក់ចំណូល និងតំបន់ភូមិសាស្ត្រដែលចំណាយកើតឡើង។

(ខ) ការវិភាគព័ត៌មានផ្នែកដំបូង

ព័ត៌មានផ្នែកដំបូង តាមផ្នែកអាជីកម្មលើមូលដ្ឋានរួមសម្រាប់ដំណាច់ការិយបរិច្ឆេទ ២០២១ និង ឆ្នាំ២០២០ មានដូចខាងក្រោម៖

	២០២១		
	កម្ចី ដុល្លារអាមេរិក	**សេវាហិរញ្ញវត្ថុផ្សេងៗ ដុល្លារអាមេរិក**	**សរុប ដុល្លារអាមេរិក**
ចំណូល			
ពីអតិថិជន			
ចំណូលការប្រាក់	៥៧៣.៧៩៩.៧៥៣	-	៥៧៣.៧៩៩.៧៥៣
ចំណាយការប្រាក់	១៧២.៣៧០.៨១២	-	១៧២.៣៧០.៨១២
ចំណូលការប្រាក់សុទ្ធ	៤០១.៤២៨.៩៤១	-	៤០១.៤២៨.៩៤១
ចំណូលមិនមែនការប្រាក់	-	៦២.៨៩៧.៩៧៨	៦២.៨៩៧.៩៧៨
សរុបចំណូលសុទ្ធ	៤០១.៤២៨.៩៤១	៦២.៨៩៧.៩៧៨	៤៦៤.៣២៦.៩១៩

៦. ព័ត៌មានតាមផ្នែក (ត)

(ខ) ការវិភាគព័ត៌មានផ្នែកដំបូង (ត)

	២០២០		
	កម្ចី ដុល្លារអាមេរិក	**សេវាហិរញ្ញវត្ថុផ្សេងៗ ដុល្លារអាមេរិក**	**សរុប ដុល្លារអាមេរិក**
ចំណូល			
ពីអតិថិជន			
ចំណូលការប្រាក់	៥១៥.០៩៤.៤៧៦	-	៥១៥.០៩៤.៤៧៦
ចំណាយការប្រាក់	១៥០.៧៧៧.៣១៧	-	១៥០.៧៧៧.៣១៧
ចំណូលការប្រាក់សុទ្ធ	៣៦៤.៣១៧.១៥៩	-	៣៦៤.៣១៧.១៥៩
ចំណូលមិនមែនការប្រាក់	-	៦៤.១២៦.៥២៣	៦៤.១២៦.៥២៣
សរុបចំណូលសុទ្ធ	៣៦៤.៣១៧.១៥៩	៦៤.១២៦.៥២៣	៤២៨.៤៤៣.៦៨២

(គ) ការវិភាគព័ត៌មានផ្នែកទី២

ព័ត៌មានផ្នែកទី២ (តាមភូមិសាស្ត្រ) សម្រាប់ដំណាច់ការិយបរិច្ឆេទ ២០២១ និង២០២០ មានដូចខាងក្រោម៖

	២០២១			
	ព្រះរាជាណាចក្រកម្ពុជា ដុល្លារអាមេរិក	**សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ដុល្លារអាមេរិក**	**សាធារណរដ្ឋសហភាព មីយ៉ាន់ម៉ា ដុល្លារអាមេរិក**	**សរុប ដុល្លារអាមេរិក**
របាយការណ៍ចំណេញ ឬខាត និងលទ្ធផល លម្អិតផ្សេងៗ				
ចំណូលសរុប	៥៩៨.៩៩៧.៧៣៦	៣១.៥៩១.៨០៥	៩.០៨២.១៧១	៦៣៩.៦៧១.៧១២
ចំណាយសរុប	៤៣៧.៨៣៨.៣៣២	២៣.៨១៤.៨៥៩	១០.៨២៤.៥៥៨	៤៧២.៤៧៧.៧៤៩
ចំណេញសុទ្ធ	១៦១.១៥៩.៤០៤	៧.៧៧៦.៩៤៦	(១.៧៤២.៣៨៧)	១៦៧.១៩៣.៩៦៣
របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ				
ទ្រព្យសកម្មសរុប	៧.៧៣២.២០៧.៩៥៨	១៩៩.២១៨.៤៤១	២២.៣១៣.៧៣១	៧.៩៥៣.៧៤០.១៣០
បំណុលសរុប	៦.៤៩៥.៣៧៩.៩៧៤	១៥៦.៤០៧.១៣៩	៥.៩៦៨.៤៧៣	៦.៦៥៧.៧៥៥.៥៨៦
ព័ត៌មានតាមផ្នែកផ្សេងៗ				
រំលស់ទ្រព្យរូបី និងអរូបី	២២.៨៤១.៤៨៣	១.៣១៩.៨៨៩	១៤២.១៧៩	២៤.៣០៣.៥៥១

៦. ព័ត៌មានតាមផ្នែក (ត)

(គ) ការវិភាគព័ត៌មានផ្នែកទី២ (ក)

	២០២០			
	ព្រះរាជាណាចក្រកម្ពុជា ដុល្លារអាមេរិក	សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ដុល្លារអាមេរិក	សាធារណរដ្ឋសហភាព មីយ៉ាន់ម៉ា ដុល្លារអាមេរិក	សរុប ដុល្លារអាមេរិក
របាយការណ៍ចំណេញ ឬខាត និងលទ្ធផល លម្អិតផ្សេងៗ				
ចំណូលសរុប	៥៤១.៤៥៧.៥២៧	២៧.៩០១.១៧០	១២.៥៣៩.៣៣០	៥៨១.៨៩៨.០២៧
ចំណាយសរុប	៤០៥.៣៨៦.៧៨២	២៣.០១៣.៦១៩	១២.០៣៨.៧០៦	៤៤០.៤៣៩.១០៧
ចំណេញសុទ្ធ	១៣៦.០៧០.៧៤៥	៤.៨៨៧.៥៥១	៥០០.៦២៤	១៤១.៤៥៨.៩២០
របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ				
ទ្រព្យសកម្មសរុប	៦.៤១៥.៧៧២.៣១៧	១៨៨.២២២.២៥៨	៤៨.៩៣២.៧១៣	៦.៦៥២.៩២៧.២៨៨
បំណុលសរុប	៥.៣០៣.០០៤.៩២១	១៤៥.២១០.៤៧០	២៤.៦៥៦.៥០៣	៥.៤៧២.៨៧១.៨៩៤
ព័ត៌មានតាមផ្នែកផ្សេងៗ				
រំលស់ទ្រព្យធ្ងន់ និងអរូបី	២៣.៧៤៥.៤៣៥	៩៨៧.២៤២	១៨៤.១២៤	២៤.៩១៦.៨០១

(ឃ) ការផ្ទៀងផ្ទាត់

ការបង្ហាញខាងក្រោមជាការផ្ទៀងផ្ទាត់ព័ត៌មានតាមផ្នែករបស់សម្ព័ន្ធធនាគារ ទៅនឹងព័ត៌មានហិរញ្ញវត្ថុសំខាន់ដែលបានលាតត្រដាងនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរួម។

៦. ព័ត៌មានតាមផ្នែក (ត)

(ឃ) ការផ្ទៀងផ្ទាត់ (ត)

	២០២១ ដុល្លារអាមេរិក	២០២០ ដុល្លារអាមេរិក	២០២១ ពាន់រៀល (កំណត់សម្គាល់ ៥)	២០២០ ពាន់រៀល (កំណត់សម្គាល់ ៥)
ចំណូល				
ចំណូលសរុបតាមផ្នែក	៦៣៩.៦៧១.៧១២	៥៨១.៨៩៨.០២៧	២.៦០២.១៨៤.៥២៤	២.៣៧២.៣៩៨.២៥៦
លុបចោលនៅចំណូលផ្នែកខាងក្នុង	(២.៩៧៣.៩៨១)	(២.៦៧៧.០២៨)	(១២.០៩៨.១៥៤)	(១០.៩១៤.២៤២)
ចំណូលសុទ្ធនៅក្នុងចំណេញ ឬខាត	៦៣៦.៦៩៧.៧៣១	៥៧៩.២២០.៩៩៩	២.៥៩០.០៨៦.៣៧០	២.៣៦១.៤៨៤.០១៤
ចំណេញ ឬខាត				
ចំណូលសរុបតាមផ្នែកប្រតិបត្តិការ	១៦៧.១៩៣.៩៦៣	១៤១.៤៥៨.៩២០	៦៨០.១៤៥.០៤១	៥៧៦.៧២៨.០១៧
លុបចោលនៅចំណូលផ្នែកខាងក្នុង	(៥១៩.៦១៥)	៣៣.៦៧០	(២.១១៣.៧៩២)	១៣៧.២៧២
ចំណូលសុទ្ធរបស់សម្ព័ន្ធធនាគារ នៅក្នុងចំណេញ ឬខាត	១៦៦.៦៧៤.៣៤៨	១៤១.៤៩២.៥៩០	៦៧៨.០៣១.២៤៩	៥៧៦.៨៦៥.២៨៩

	២០២១ ដុល្លារអាមេរិក	២០២០ ដុល្លារអាមេរិក	២០២១ ពាន់រៀល (កំណត់សម្គាល់ ៥)	២០២០ ពាន់រៀល (កំណត់សម្គាល់ ៥)
ទ្រព្យសកម្ម				
ទ្រព្យសកម្មសរុបតាមផ្នែក	៧.៩៥៣.៧៤០.១៣០	៦.៦៥២.៩២៧.២៨៨	៣២.៤០៣.៥៣៧.២៩០	២៦.៩១១.០៩០.៨៨០
ទ្រព្យសកម្មមិនបានបែងចែក	(៩៨.៤៨៧.៨០៦)	(១០១.៤៣៣.៣០០)	(៤០១.២៣៩.៣២៣)	(៤១០.២៩៧.៦៩៨)
ទ្រព្យសកម្មសរុប	៧.៨៥៥.២៥២.៣២៤	៦.៥៥១.៤៩៣.៩៨៨	៣២.០០២.២៩៧.៩៦៧	២៦.៥០០.៧៩៣.១៨២
បំណុល				
បំណុលសរុបតាមផ្នែក	៦.៦៥៧.៧៥៥.៥៨៦	៥.៤៧២.៨៧១.៨៩៤	២៧.១២៣.៦៩៦.២៥៧	២២.១៣៧.៧៦៦.៨១១
បំណុលមិនបានបែងចែក(លុបចោលនៅបំណុលផ្នែកខាងក្នុង)	(៧.៥៣៨.៣០៤)	(១១.០០៣.៤១៣)	(៣០.៧១១.០៥០)	(៤៤.៥០៨.៨០៥)
បំណុលសរុប	៦.៦៥០.២១៧.២៨២	៥.៤៦១.៨៦៨.៤៨១	២៧.០៩២.៩៨៥.២០៧	២២.០៩៣.២៥៨.០០៦

ធនាគារ អេស៊ីលីដា អ៊ីអិលស៊ី និង ក្រុមហ៊ុនបុត្រសម្ព័ន្ធ

កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ និងសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់

៧. សាច់ប្រាក់ក្នុងដៃ

	សម្ព័ន្ធធនាគារ				ធនាគារ			
	២០២១ ដុល្លារអាមេរិក	២០២០ ដុល្លារអាមេរិក	២០២១ ពាន់រៀល (កំណត់សម្គាល់ ៥)	២០២០ ពាន់រៀល (កំណត់សម្គាល់ ៥)	២០២១ ដុល្លារអាមេរិក	២០២០ ដុល្លារអាមេរិក	២០២១ ពាន់រៀល (កំណត់សម្គាល់ ៥)	២០២០ ពាន់រៀល (កំណត់សម្គាល់ ៥)
តាមរូបិយប័ណ្ណ៖								
ជាប្រាក់ដុល្លារអាមេរិក	៣១៣.៨៥៧.៥៦៤	២៨៤.៨៩២.០៩៨	១.២៧៨.៦១៤.៥៦៨	១.១៥២.៣៨៨.៥៣៦	៣១២.៣០៦.៥២៤	២៨៣.០២៨.៨២៨	១.២៧២.៣៣៦.៧៧៩	១.១៤៤.៨៥១.៦០៩
ជាប្រាក់រៀលខ្មែរ	១០៤.៩៩៦.៣៥៩	១០៣.៤៨៨.២៤៧	៤២៧.៧៥៥.១៦៧	៤១៨.៦០៩.៩៥៩	១០៤.៩៩៤.៤៣០	១០៣.៤៨០.៣២៥	៤២៧.៧៤៧.៣០៨	៤១៨.៥៧៧.៩១៥
ជាប្រាក់បាតថៃ	១៩.០១៩.០៩១	១២.២៤៧.១៦០	៧៧.៤៨៣.៧៧៧	៤៩.៥៣៩.៧៦២	១៧.១៥២.៥០៨	៩.៩២៧.០៤៤	៦៩.៨៧៩.៣១៨	៤០.១៥៤.៨៩៣
ជាប្រាក់អឺរ៉ូ	២.៥២១.៤៨០	២.៩៦៧.៥០២	១០.២៧២.៥១០	១២.០០៣.៥៤៦	២.៥១៨.៧៦៥	២.៩៦៥.១០៦	១០.២៦១.៤៤៩	១១.៩៩៣.៨៥៤
ជារូបិយប័ណ្ណផ្សេងៗ	៩.៩៩០.៧៥៥	៩.១៦៤.០៤៤	៤០.៧០២.៣៣៥	៣៧.០៦៨.៥៥៨	២.៤៩៣.៧៥៣	១.៤១៤.៨២៣	១០.១៥៩.៥៤៩	៥.៧២២.៩៥៩
	៤៥០.៣៧៥.១៤៩	៤១២.៧៥៩.០៥១	១.៨៣៤.៨២៨.៣៥៧	១.៦៦៩.៦១០.៣៦១	៤៣៩.៤៦៥.៩៨០	៤០០.៨១៦.១២៦	១.៧៩០.៣៨៤.៤០៣	១.៦២១.៣០១.២៣០

៨. ប្រាក់បញ្ញើនៅធនាគារផ្សេងៗ - សុទ្ធ

	សម្ព័ន្ធធនាគារ				ធនាគារ			
	២០២១ ដុល្លារអាមេរិក	២០២០ ដុល្លារអាមេរិក	២០២១ ពាន់រៀល (កំណត់សម្គាល់ ៥)	២០២០ ពាន់រៀល (កំណត់សម្គាល់ ៥)	២០២១ ដុល្លារអាមេរិក	២០២០ ដុល្លារអាមេរិក	២០២១ ពាន់រៀល (កំណត់សម្គាល់ ៥)	២០២០ ពាន់រៀល (កំណត់សម្គាល់ ៥)
សមតុល្យជាមួយធនាគារក្នុងស្រុក៖								
ធនាគារជាតិនៃកម្ពុជា	២៩០.៤៧៧.៤៤១	២៦៤.១៩៧.៥៦៣	១.១៨៣.៤០៥.០៩៥	១.០៦៨.៦៧៩.១៤២	២៩០.៤៧៧.៤៤០	២៦៤.១៩៧.៥៦៣	១.១៨៣.៤០៥.០៩១	១.០៦៨.៦៧៩.១៤២
ធនាគារផ្សេងៗ	៤១.៩៤០.៧៧៧	៣.៣១៨.៧៥១	១៧០.៨៦៦.៧២៥	១៣.៤២៤.៣៤៨	៤១.៩៤០.៧៧៧	៣.៣១៨.៧៥១	១៧០.៨៦៦.៧២៥	១៣.៤២៤.៣៤៨
	៣៣២.៤១៨.២១៨	២៦៧.៥១៦.៣១៤	១.៣៥៤.២៧១.៨២០	១.០៨២.១០៣.៤៩០	៣៣២.៤១៨.២១៧	២៦៧.៥១៦.៣១៤	១.៣៥៤.២៧១.៨១៦	១.០៨២.១០៣.៤៩០
សមតុល្យជាមួយធនាគារនៅក្រៅប្រទេស៖								
ធនាគារឡារ	៣០.៦៣១.៤២៦	១៩.៧៧១.៤៤៤	១២៤.៧៩២.៤៣០	៧៩.៩៧៥.៤៩១	-	-	-	-
ធនាគារផ្សេងៗ	២១៤.៥៤៦.៨១៧	២៤៧.៩៤៧.៨៣២	៨៧៤.០៦៣.៧៣២	១.០០២.៩៤៨.៩៨០	២១១.២២៨.៩៨៥	២៤០.២៥៤.៦៣៦	៨៦០.៥៤៦.៨៨៥	៩៧១.៨៣០.០០៣
	២៤៥.១៧៨.២៤៣	២៦៧.៧១៩.២៧៦	៩៩៨.៨៥៦.១៦២	១.០៨២.៩២៤.៤៧១	២១១.២២៨.៩៨៥	២៤០.២៥៤.៦៣៦	៨៦០.៥៤៦.៨៨៥	៩៧១.៨៣០.០០៣
សរុបសមតុល្យជាមួយធនាគារក្នុងស្រុកនិងក្រៅស្រុក	៥៧៧.៥៩៦.៤៦១	៥៣៥.២៣៥.៥៩០	២.៣៥៣.១២៧.៩៨២	២.១៦៥.០២៧.៩៦១	៥៤៣.៦៤៧.២០២	៥០៧.៧៧០.៩៥០	២.២១៤.៨១៨.៧០១	២.០៥៣.៩៣៣.៤៩៣
សំវិធានធនលើឱនភាពនៃតម្លៃខាតបង់	(៤៧៩.១៦៣)	(៥៨២.៤៤៤)	(១.៩៥២.១១០)	(២.៣៥៥.៩៨៥)	(២២០.២៨២)	(១៩១.៥៤៣)	(៨៩៧.៤២៩)	(៥៧២.៥៤២)
	៥៧៧.១១៧.២៩៨	៥៣៤.៦៥៣.១៤៦	២.៣៥១.១៧៥.៨៧២	២.១៦២.៦៧១.៩៧៦	៥៤៣.៤២៦.៩២០	៥០៧.៦២៩.៤០៧	២.២១៣.៩២១.២៧២	២.០៥៣.៣៦០.៩៥១
ប្រាក់បញ្ញើរយៈពេលខ្លី	៥៧៧.១១៧.២៩៨	៥៣៤.៦៥៣.១៤៦	២.៣៥១.១៧៥.៨៧២	២.១៦២.៦៧១.៩៧៦	៥៤៣.៤២៦.៩២០	៥០៧.៦២៩.៤០៧	២.២១៣.៩២១.២៧២	២.០៥៣.៣៦០.៩៥១
ប្រាក់បញ្ញើរយៈពេលវែង	-	-	-	-	-	-	-	-
	៥៧៧.១១៧.២៩៨	៥៣៤.៦៥៣.១៤៦	២.៣៥១.១៧៥.៨៧២	២.១៦២.៦៧១.៩៧៦	៥៤៣.៤២៦.៩២០	៥០៧.៦២៩.៤០៧	២.២១៣.៩២១.២៧២	២.០៥៣.៣៦០.៩៥១

ធនាគារ អេស៊ីលីដា អ៊ីអិលស៊ី និង ក្រុមហ៊ុនបុត្រសម្ព័ន្ធ

កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ និងសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់

៨. ប្រាក់បញ្ញើនៅធនាគារផ្សេងៗ - សុទ្ធ(ត)

ក) តាមប្រភេទគណនី

	សម្ព័ន្ធធនាគារ				ធនាគារ			
	២០២១ ដុល្លារអាមេរិក	២០២០ ដុល្លារអាមេរិក	២០២១ ពាន់រៀល (កំណត់សម្គាល់ ៥)	២០២០ ពាន់រៀល (កំណត់សម្គាល់ ៥)	២០២១ ដុល្លារអាមេរិក	២០២០ ដុល្លារអាមេរិក	២០២១ ពាន់រៀល (កំណត់សម្គាល់ ៥)	២០២០ ពាន់រៀល (កំណត់សម្គាល់ ៥)
សមតុល្យជាមួយធនាគារក្នុងស្រុក៖								
គណនីចរន្ត	២៩១.១៧៣.៩៤២	២៦៤.៤៨១.០៥៤	១.១៨៦.២៤២.៦៤០	១.០៦៩.៨២៥.៨៦៣	២៩១.១៧៣.៩៤១	២៦៤.៤៨១.០៥៤	១.១៨៦.២៤២.៦៣៦	១.០៦៩.៨២៥.៨៦៣
ប្រាក់បញ្ញើមានកាលកំណត់	៤១.២៤៤.២៧៦	៣.០៣៥.២៦០	១៦៨.០២៩.១៨០	១២.២៧៧.៦២៧	៤១.២៤៤.២៧៦	៣.០៣៥.២៦០	១៦៨.០២៩.១៨០	១២.២៧៧.៦២៧
	៣៣២.៤១៨.២១៨	២៦៧.៥១៦.៣១៤	១.៣៥៤.២៧១.៨២០	១.០៨២.១០៣.៤៩០	៣៣២.៤១៨.២១៧	២៦៧.៥១៦.៣១៤	១.៣៥៤.២៧១.៨១៦	១.០៨២.១០៣.៤៩០
សមតុល្យជាមួយធនាគារនៅប្រទេស៖								
គណនីចរន្ត	២៤៥.១៧៨.២៤៣	២៦៦.១០១.៤៥៣	៩៩៨.៨៥៦.១៦២	១.០៧៦.៣៨០.៣៧៧	២១០.២២៣.៦២៩	២៣៩.៧៥១.៩៥៨	៨៥៦.៤៥១.០៦៥	៩៦៩.៧៩៦.៦៧០
ប្រាក់បញ្ញើមានកាលកំណត់	-	១.៦១៧.៨២៣	-	៦.៥៤៤.០៩៤	១.០០៥.៣៥៦	៥០២.៦៧៨	៤.០៩៥.៨២០	២.០៣៣.៣៣៣
	២៤៥.១៧៨.២៤៣	២៦៧.៧១៩.២៧៦	៩៩៨.៨៥៦.១៦២	១.០៨២.៩២៤.៤៧១	២១១.២២៨.៩៨៥	២៤០.២៥៤.៦៣៦	៨៦០.៥៤៦.៨៨៥	៩៧១.៨៣០.០០៣
	៥៧៧.៥៩៦.៤៦១	៥៣៥.២៣៥.៥៩០	២.៣៥៣.១២៧.៩៨២	២.១៦៥.០២៧.៩៦១	៥៤៣.៦៤៧.២០២	៥០៧.៧៧០.៩៥០	២.២១៤.៨១៨.៧០១	២.០៥៣.៩៣៣.៤៩៣
សំវិធានធនលើឱនភាពនៃតម្លៃខាតបង់	(៤៧៩.១៦៣)	(៥៨២.៤៤៤)	(១.៩៥២.១១០)	(២.៣៥៥.៩៨៥)	(២២០.២៨២)	(១៤១.៥៤៣)	(៨៩៧.៤២៩)	(៥៧២.៥៤២)
	៥៧៧.១១៧.២៩៨	៥៣៤.៦៥៣.១៤៦	២.៣៥១.១៧៥.៨៧២	២.១៦២.៦៧១.៩៧៦	៥៤៣.៤២៦.៩២០	៥០៧.៦២៩.៤០៧	២.២១៣.៩២១.២៧២	២.០៥៣.៣៦០.៩៥១

៨. ប្រាក់បញ្ញើនៅធនាគារផ្សេងៗ - សុទ្ធ (ត)

ខ) តាមអត្រាការប្រាក់ (ក្នុងមួយឆ្នាំ)

	សម្ព័ន្ធធនាគារ		ធនាគារ	
	២០២១	២០២០	២០២១	២០២០
គណនីចរន្ត	គ្មាន	គ្មាន	គ្មាន	គ្មាន
គណនីសន្សំ	០,០០% - ០,៥០%	០,២០% - ០,៥០%	គ្មាន	គ្មាន
ប្រាក់បញ្ញើមានកាលកំណត់	០,១២% - ៧,៥០%	០,១២% - ៧,៥០%	០,១២% - ៥,៥០%	០,១២% - ៣,៣០%

គ) តាមឥណប្រតិទាន

	សម្ព័ន្ធធនាគារ				ធនាគារ			
	២០២១ ដុល្លារអាមេរិក	២០២០ ដុល្លារអាមេរិក	២០២១ ពាន់រៀល (កំណត់សម្គាល់ ៥)	២០២០ ពាន់រៀល (កំណត់សម្គាល់ ៥)	២០២១ ដុល្លារអាមេរិក	២០២០ ដុល្លារអាមេរិក	២០២១ ពាន់រៀល (កំណត់សម្គាល់ ៥)	២០២០ ពាន់រៀល (កំណត់សម្គាល់ ៥)
តាមតម្រូវការ	៥៣៦.៣៥២.១៨៥	៥៣០.៥៨២.៥០៧	២.១៨៥.០៩៨.៨០២	២.១៤៦.២០៦.២៤០	៥០១.៣៩៧.៥៧០	៥០៤.២៣៣.០១២	២.០៤២.៦៩៣.៧០១	២.០៣៩.៦២២.៥៣៣
មិនលើសពីមួយខែ	១០.០០៣.៤៣០	-	៤០.៧៥៣.៩៧៤	-	១១.០០៨.៧៨៧	-	៤៤.៨៤៩.៧៩៧	-
រវាងពីពីរខែទៅបីខែ	២១.៤០៧.៦៩៣	១.៦១៧.៨២៣	៨៧.២១៤.៩៤១	៦.៥៤៤.០៩៤	២១.៤០៧.៦៩១	៥០២.៦៧៨	៨៧.២១៤.៩៣៣	២.០៣៣.៣៣៣
រវាងពីបួនខែទៅប្រាំមួយខែ	៩.៨៣៣.១៥៣	៣.០៣៥.២៦០	៤០.០៦០.២៦៥	១២.២៧៧.៦២៧	៩.៨៣៣.១៥៤	៣.០៣៥.២៦០	៤០.០៦០.២៧០	១២.២៧៧.៦២៧
	៥៧៧.៥៩៦.៤៦១	៥៣៥.២៣៥.៥៩០	២.៣៥៣.១២៧.៩៨២	២.១៦៥.០២៧.៩៦១	៥៤៣.៦៤៧.២០២	៥០៧.៧៧០.៩៥០	២.២១៤.៨១៨.៧០១	២.០៥៣.៩៣៣.៤៩៣

៩. ការវិនិយោគហិរញ្ញវត្ថុ

		សម្ព័ន្ធធនាគារ				ធនាគារ			
		២០២១	២០២០	២០២១	២០២០	២០២១	២០២០	២០២១	២០២០
	កំណត់សម្គាល់	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ពាន់រៀល	ពាន់រៀល	ដុល្លារអាមេរិក	ដុល្លារអាមេរិក	ពាន់រៀល	ពាន់រៀល
				(កំណត់សម្គាល់ ៥)	(កំណត់សម្គាល់ ៥)			(កំណត់សម្គាល់ ៥)	(កំណត់សម្គាល់ ៥)
មូលបត្រភាគហ៊ុនដែលមិនបានចុះបញ្ជី - ដោយតម្លៃសមស្របតាមរយៈលទ្ធផលលម្អិតផ្សេងៗ៖									
ក្រុមហ៊ុន Credit Bureau Holding (Cambodia) Ltd	(ក)	១៥៣.៥២៩	១៥៣.៥២៩	៦២៥.៤៧៧	៦២១.០២៥	១៥៣.៥២៩	១៥៣.៥២៩	៦២៥.៤៧៧	៦២១.០២៥
Swift		៣៦.១៤១	-	១៤៧.២៣៨	-	៣៦.១៤១	-	១៤៧.២៣៨	-
សរុបវិនិយោគហិរញ្ញវត្ថុនៅ FVOCI		១៨៩.៦៧០	១៥៣.៥២៩	៧៧២.៧១៥	៦២១.០២៥	១៨៩.៦៧០	១៥៣.៥២៩	៧៧២.៧១៥	៦២១.០២៥
ការវិនិយោគហិរញ្ញវត្ថុសរុបនៅក្នុងតម្លៃដកវិលស់									
វិញ្ញាបនបត្រប្រាក់បញ្ញើដែលអាចចរចារបាន ជាមួយ ធនាគារជាតិនៃកម្ពុជា	(ខ)	៨០០.៨៩៤.៧២២	៥៦៦.៥២០.៩៩៤	៣.២៦២.៨៤៥.០៩៨	២.២៩១.៥៧៧.៤២១	៨០០.៨៩៤.៧២២	៥៦៦.៥២០.៩៩៤	៣.២៦២.៨៤៥.០៩៨	២.២៩១.៥៧៧.៤២១
សរុបវិនិយោគហិរញ្ញវត្ថុ		៨០១.០៨៤.៣៩២	៥៦៦.៦៧៤.៥២៣	៣.២៦៣.៦១៧.៨១៣	២.២៩២.១៩៨.៤៤៦	៨០១.០៨៤.៣៩២	៥៦៦.៦៧៤.៥២៣	៣.២៦៣.៦១៧.៨១៣	២.២៩២.១៩៨.៤៤៦

(ក) តំណាងអោយការវិនិយោគតាមមូលធនរបស់ធនាគារនៅក្នុងក្រុមហ៊ុន Credit Bureau Holding (Cambodia) Ltd. (“CBC”). កាន់កាប់ដោយផ្ទាល់ចំនួន ៥% និងកាន់កាប់ដោយប្រយោល ១% តាមរយៈសមាគមធនាគារក្នុងប្រទេសកម្ពុជា (“ABC”)។ ទឹកប្រាក់វិនិយោគរបស់ធនាគារនៅក្នុងក្រុមហ៊ុន Credit Bureau Holding (Cambodia) Ltd. (“CBC”). មានចំនួន ១៥៣.៥២៩ ដុល្លារអាមេរិក នៅថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០២១ (ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០២០ ៖ ១៥៣.៥២៩ ដុល្លារអាមេរិក) និងនៅក្នុងក្រុមហ៊ុន Swift មានចំនួន ៣៦.១៤១ ដុល្លារអាមេរិក ដោយអ្នកគ្រប់គ្រងជឿថាថ្លៃដើមនៃការវិនិយោគ គឺមានតម្លៃប្រហាក់ប្រហែលនឹងតម្លៃសមស្រប។ ភាគលាភទទួលបានពី CBC ក្នុងអំឡុងឆ្នាំ ២០២១ មានចំនួន ១១៦.៦១៤ ដុល្លារអាមេរិក (ឆ្នាំ ២០២០៖១៧៤.៤៧៩ ដុល្លារអាមេរិក)។

(ខ) ធនាគារបានដាក់មូលបត្រអាចជួញដូរបានដែលមានទឹកប្រាក់ចំនួន ១៥.៧៩៣.៨៨២ ដុល្លារអាមេរិក (ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០២០៖ ១៤.៣៧៤.៨៧១ ដុល្លារអាមេរិក) ជាមួយធនាគារជាតិ នៃ កម្ពុជា ជាទ្រព្យបញ្ចាំ សម្រាប់ទូទាត់ ។ មូលបត្រអាចជួញដូរបានផ្សេងទៀត មានទឹកប្រាក់ចំនួន ៧៨៥.១០០.៨៤០ ដុល្លារអាមេរិក (ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០២០៖ ៥៥២.១៤៦.១២៣ ដុល្លារអាមេរិក) ជាមួយធនាគារជាតិ នៃ កម្ពុជា ក្នុងគោលបំណងរកចំណូលការប្រាក់ ។ មូលបត្រអាចជួញដូរបានមានរយៈពេលមិនលើសប្រាំមួយខែ។ គិតត្រឹមថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០២១ និង ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០២០ ធនាគារមិនទាន់បានប្រើឥណទានវិបាកប៉ះនេះនៅឡើយទេ។

៩. ការវិនិយោគហិរញ្ញវត្ថុ (ត)

វិភាគតាមឥណប្រតិទាន នៃមូលបត្រអាចជួញដូរបានដែលមាននៅ ធនាគារជាតិ នៃ កម្ពុជា

	សម្ព័ន្ធធនាគារ				ធនាគារ			
	២០២១ ដុល្លារអាមេរិក	២០២០ ដុល្លារអាមេរិក	២០២១ ពាន់រៀល (កំណត់សម្គាល់ ៥)	២០២០ ពាន់រៀល (កំណត់សម្គាល់ ៥)	២០២១ ដុល្លារអាមេរិក	២០២០ ដុល្លារអាមេរិក	២០២១ ពាន់រៀល (កំណត់សម្គាល់ ៥)	២០២០ ពាន់រៀល (កំណត់សម្គាល់ ៥)
មិនលើសពីមួយខែ	៧៨៥.១០០.៨៤០	៥៥២.១៤៦.១២១	៣.១៩៨.៥០០.៨២៣	២.២៣៣.៤៣១.០៥៩	៧៨៥.១០០.៨៤០	៥៥២.១៤៦.១២១	៣.១៩៨.៥០០.៨២៣	២.២៣៣.៤៣១.០៥៩
រវាងពីពីរខែទៅបីខែ	១៥.៤៩៣.៨៥៦	១៣.៨៥១.៨៨១	៦៣.១២១.៩៦៩	៥៦.០៣០.៨៥៩	១៥.៤៩៣.៨៥៦	១៣.៨៥១.៨៨១	៦៣.១២១.៩៦៩	៥៦.០៣០.៨៥៩
រវាងពីបួនខែទៅប្រាំមួយខែ	៣០០.០២៦	-	១.២២២.៣០៦	-	៣០០.០២៦	-	១.២២២.៣០៦	-
រវាងពីប្រាំពីរខែទៅដប់ពីរខែ	-	៥២២.៩៩២	-	២.១១៥.៥០៣	-	៥២២.៩៩២	-	២.១១៥.៥០៣
	៨០០.៨៩៤.៧២២	៥៦៦.៥២០.៩៩៤	៣.២៦២.៨៤៥.០៩៨	២.២៩១.៥៧៧.៤២១	៨០០.៨៩៤.៧២២	៥៦៦.៥២០.៩៩៤	៣.២៦២.៨៤៥.០៩៨	២.២៩១.៥៧៧.៤២១

ធនាគារ អេស៊ីលីដា អ៊ីអិលស៊ី និង ក្រុមហ៊ុនបុត្រសម្ព័ន្ធ

កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ និងសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់

១០. ឥណទាន និងបុរេប្រទាន - សុទ្ធ

	សម្ព័ន្ធធនាគារ											
	២០២១			២០២០			២០២១			២០២០		
	តម្លៃយោងដុល ដុល្លារអាមេរិក	សំវិធានធន ECL ដុល្លារអាមេរិក	តម្លៃយោង ដុល្លារអាមេរិក	តម្លៃយោងដុល ដុល្លារអាមេរិក	សំវិធានធន ECL ដុល្លារអាមេរិក	តម្លៃយោង ដុល្លារអាមេរិក	តម្លៃយោងដុល ពាន់រៀល (កំណត់សម្គាល់ ៥)	សំវិធានធន ECL ពាន់រៀល (កំណត់សម្គាល់ ៥)	តម្លៃយោង ពាន់រៀល (កំណត់សម្គាល់ ៥)	តម្លៃយោងដុល ពាន់រៀល (កំណត់សម្គាល់ ៥)	សំវិធានធន ECL ពាន់រៀល (កំណត់សម្គាល់ ៥)	តម្លៃយោង ពាន់រៀល (កំណត់សម្គាល់ ៥)
ឥណទានខ្នាតតូច	២.៤៥៤.៣០៦.១៥៥	១៩.៩៧០.៥៨៧	២.៤៣៤.៣៣៥.៥៦៨	២.២១១.១៩៧.២៧២	១៧.៣៥៣.៧៧៣	២.១៩៣.៨៤៣.៤៩៩	៩.៩៩៨.៨៤៣.២៧៥	៨១.៣៦០.១៧០	៩.៩១៧.៩៨៣.១០៥	៨.៩៤៤.២៩២.៩៦៥	៧០.១៩៦.០១២	៨.៨៧៤.០៩៦.៩៥៣
ឥណទានគេហដ្ឋានបុគ្គលិក	២៤.៥៦២.០៨៩	១០.២០៦	២៤.៥៥១.៨៨៣	២៥.២៣៩.៧៦៣	១៧.០០៩	២៥.២២២.៧៥៤	១០០.០៦៥.៩៥១	៤១.៥៧៩	១០០.០២៤.៣៧២	១០២.០៩៤.៨៤១	៦៨.៨០១	១០២.០២៦.០៤០
ឥណទានគេហដ្ឋាន សាធារណៈ	១៣៥.៩៧១.៨០៨	៨៩២.៥២៦	១៣៥.០៧៩.២៨២	១៣៥.៥៥៥.៣៦១	១.០៣២.៦០៥	១៣៤.៥២២.៧៥៦	៥៥៣.៩៩៩.១៨៦	៣.៦៣៦.១៥១	៥៥០.៣១២.៩៩៥	៥៩៨.៣២១.៩៣៥	៤.១៧៦.៨៨៧	៥៩៤.១៩៤.៥៩៨
ឥណទានបុគ្គលិក	២៥៥.៦៥៨.៣៩៩	១៥៤.៧៨១	២៥៥.៥០៣.៦១៨	២២១.៩២៣.៧៦១	២២៥.៨៩១	២២១.៦៩៧.៩២០	១.០៩១.៥៥២.៣១៨	៦៣០.៥៧៨	១.០៩០.៩២១.៧៩០	៨៩៧.៦៨១.៦១៣	៩១៣.៥២៧	៨៩៦.៧៦៨.០៨៦
ឥណទានវិចារណ៍	៩៥.៩៧៤.១១៦	២៩៨.២៥៣	៩៥.៦៧៥.៨៦៣	៥៨.០៣៦.៣០២	៣៥២.៩៥០	៥៧.៦៨៣.៣៥២	៣៩០.៩៩៨.៥៩៩	១.២១៥.០៨៣	៣៨៩.៧៨៣.៥៦៦	២៣៤.៧៥៦.៨៨២	១.៤២៧.៦៨៣	២៣៣.៣២៩.១៥៩
ឥណទានកែលម្អគេហដ្ឋាន	៣១.៥៥១.០២៨	៥៧៥.០០៥	៣០.៨៧៦.០២៣	៤៧.៧៨០.២៩៥	៣៣៤.៦៤៤	៤៧.៤៩៥.៦៥១	១២៨.១៣១.៤៨៨	២.៣៤២.៥៧០	១២៥.៧៨៨.៩១៨	១៩៣.២៧១.២៩៣	១.៣៥៣.៦៣៥	១៩១.៩១៧.៦៥៨
ឥណទានផ្ទាល់ខ្លួននិងអ្នកប្រើប្រាស់ផ្សេងៗ	២០២.៥៤២.០៤១	១.៦៧៤.៥៦៦	២០០.៨៦៧.៤៧៥	១៥៨.៣០០.២៨៤	១.០៦១.៩៧២	១៥៧.២៣៨.៣១២	៨២៥.១៥៦.២៧៤	៦.៨២២.១៨២	៨១៨.៣៣៤.០៩២	៦៤០.៣២៤.៦៤៩	៤.២៩៥.៦៧៦	៦៣៦.០២៨.៩៧៣
ប័ណ្ណឥណទាន	៤០.២៨១.០៧៨	៧៣៤.៩៥៦	៣៩.៥៤៦.១២២	២៥.៦៤១.៩៦២	៦៦៧.៣៤៥	២៤.៩៧៤.៦១៧	១៦៤.១០៥.១១២	២.៩៩៤.២១១	១៦១.១១០.៩០១	១០៣.៧២១.៧៣៦	២.៦៩៩.៤១១	១០១.០២២.៣២៥
ឥណទានពាណិជ្ជកម្ម	១១.២០៨.២៣៧	១៣.៥៩១	១១.១៩៤.៦៤៦	៩.៦៣២.៦៥៦	២១.៥៧៨	៩.៦១១.០៧៨	៤៥.៦៦២.៣៥៨	៥៥.៣៧០	៤៥.៦០៦.៩៨៨	៣៨.៩៦៤.០៩៤	៨៧.២៨៣	៣៨.៨៧៦.៨១១
ឥណទានឃ្វីល	៤៩.៦៥០.៣៩៣	៨៣.១៧៤	៤៩.៥៦៧.២១៩	៣៣.២៩៦.២៧២	២៣.៥១២	៣៣.២៧២.៧៦០	២០២.២៧៥.៧០១	៣៣៨.៨៥១	២០១.៩៣៦.៨៥០	១៣៤.៦៨៣.៤២០	៩៥.១០៦	១៣៤.៥៨៨.៣១៤
ឥណទានខ្នាតមធ្យម	២.១២៦.៩៦៩.២៣៣	១០.២១៣.៤២៩	២.១១៦.៧៥៥.៨០៤	១.៥៨០.០៣៩.២៣៧	១៤.២៥១.៣១៨	១.៥៦៥.៧៨៧.៩១៩	៨.៦៦៥.២៧២.៦៥៥	៤១.៦០៩.៥១១	៨.៦២៣.៦៦៣.១៤៤	៦.៣៩១.២៥៨.៧១៤	៥៧.៦៤៦.៥៨១	៦.៣៣៣.៦១២.១៣៣
	៥.៤២៨.៥៧៤.៥៧៧	៣៤.៦២១.០៧៤	៥.៣៩៣.៩៥៣.៥០៣	៤.៥០៦.៦៨៣.១៦៥	៣៥.៣៤២.៥៤៧	៤.៨៧១.៣០០.៦១៨	២២.១១៦.០១២.៨២៧	១៤១.០៤៦.២៥៦	២១.៩៧៤.៩៦៦.៥៧១	១៨.២២៩.៣៧១.៦០២	១៤២.៩៦០.៦០២	១៨.០៨៦.៤១១.០០០

ធនាគារ អេស៊ីលីដា អ៊ីអិលស៊ី និង ក្រុមហ៊ុនបុត្រសម្ព័ន្ធ

កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ និងសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់

១០. ឥណទាន និងបុរេប្រទាន - សុទ្ធ (ត)

	ធនាគារ											
	២០២១			២០២០			២០២១			២០២០		
	តម្លៃយោងដុល ដុល្លារអាមេរិក	សំវិធានធន ECL ដុល្លារអាមេរិក	តម្លៃយោង ដុល្លារអាមេរិក	តម្លៃយោងដុល ដុល្លារអាមេរិក	សំវិធានធន ECL ដុល្លារអាមេរិក	តម្លៃយោង ដុល្លារអាមេរិក	តម្លៃយោងដុល ពាន់រៀល (កំណត់សម្គាល់ ៥)	សំវិធានធន ECL ពាន់រៀល (កំណត់សម្គាល់ ៥)	តម្លៃយោង ពាន់រៀល (កំណត់សម្គាល់ ៥)	តម្លៃយោងដុល ពាន់រៀល (កំណត់សម្គាល់ ៥)	សំវិធានធនECL ពាន់រៀល (កំណត់សម្គាល់ ៥)	តម្លៃយោង ពាន់រៀល (កំណត់សម្គាល់ ៥)
ឥណទានខ្នាតតូច	២.៣១០.៧៧៨.៣២៣	៨.៦៣០.៣២៥	២.៣០២.១៨៧.៩៩៨	២.០៨៨.៩៣៦.៨១២	១៣.៣៩៣.៥៥២	២.០៣៥.៥៩២.៨៦០	៩.៨១៤.១១០.៨៨៨	៣៥.១៩៩.៩៤៤	៩.៣៧៨.៩៥០.៩៤៤	៨.២៨៧.៩៤៧.៧៨៧	៥៣.៩៧៤.៦៦៨	៨.២៣៣.៩៧៣.១១៩
ឥណទានគេហដ្ឋានបុគ្គលិក	២៤.៤៩០.៥២៧	១០.១៨៨	២៤.៤៨០.៣៣៩	២៥.១០៨.៨៧៩	១៦.៩០៧	២៥.០៩១.៩៧២	៩៩.៧៧៤.៤០៧	៤១.៥០៦	៩៩.៧៣២.៩០១	១០១.៥៦៥.៤១៦	៦៨.៣៨៩	១០១.៤៩៧.០២៧
ឥណទានគេហដ្ឋានសាធារណៈ	១៣៤.៣៥៩.៣៤១	៨៩១.២៣០	១៣៣.៤៦៨.១១១	១៣៥.០៨៤.០៥៦	១.០១៦.៧៨៩	១៣៤.០៦៧.២៦៧	៥៤៧.៣៧៩.៩៥៥	៣.៦៣០.៨៧១	៥៤៣.៧៤៩.០៨៤	៥៤៦.៤១៥.០០៧	៤.១១២.៩១២	៥៤២.៣០២.០៩៥
ឥណទានបុគ្គលិក	២៤៨.៧៧២.២៩៤	១១៧.៥៩៤	២៤៨.៦៥៤.៧០០	២១៤.៣៨៩.១២១	២០៩.៩០៦	២១៤.១៧៩.២១៥	១.០១៣.៤៩៨.៣២៦	៤៧៩.០៧៨	១.០១៣.០១៩.២៤៨	៨៦៧.២០៣.៩៩៤	៨៤៩.០៧០	៨៦៦.៣៥៤.៩២៤
ឥណទានវិចារ៉ូ	៩៤.៥៥០.៨៥៣	២៩៥.៥៦៤	៩៤.២៥៥.២៨៩	៥៧.៩៨៨.២៣៦	៣៥១.៤៣២	៥៧.៥៩៦.៨០៤	៣៨៥.២០០.១៧៥	១.២០៤.១២៨	៣៨៣.៩៩៦.០៤៧	២៣៤.៤០០.៦១៥	១.៤២១.៥៤២	២៣២.៩៧៩.០៧៣
ឥណទានកែលម្អគេហដ្ឋាន	២៥.៣០៣.០៣៥	១៦០.៤៨៨	២៥.១៤២.៥៤៧	៤៤.២៦១.៤២១	២៩៤.៤០១	៤៣.៩៦៧.០២០	១០៣.០៨៤.៥៦៥	៦៥៣.៨២៨	១០២.៤៣០.៧៣៧	១៧៩.០៣៧.៤៤៨	១.១៩០.៨៥២	១៧៧.៨៤៦.៥៩៦
ឥណទានផ្ទាល់ខ្លួននិងអ្នកប្រើប្រាស់ផ្សេងៗ	១៩៦.៣៨៧.៧០២	១.៤៧៩.៩១៤	១៩៤.៩០៧.៧៨៨	១៥៧.២២៨.៥៤១	១.០៨៣.៧៩៣	១៥៦.១៤៤.៧៤៨	៨០០.០៨៣.៤៩៨	៦.០២៩.១៧០	៧៩៤.០៥៤.៣២៨	៦៣៥.៩៨៩.៤៤៨	៤.៣៨៣.៩៤១	៦៣១.៦០៥.៥០៧
ប័ណ្ណឥណទាន	៤០.២៨១.០៧៨	៧៣៤.៩៥៦	៣៩.៥៤៦.១២២	២៥.៦៤១.៩៦២	៦៦៧.៣៤៥	២៤.៩៧៤.៦១៧	១៦៤.១០៥.១១២	២.៩៩៤.២១១	១៦១.១១០.៩០១	១០៣.៧២១.៧៣៦	២.៦៩៩.៤១១	១០១.០២២.៣២៥
ឥណទានពាណិជ្ជកម្ម	១១.២០៨.២៣៧	១៣.៥៩១	១១.១៩៤.៦៤៦	៩.៦៣២.៦៥៦	២១.៥៧៨	៩.៦១១.០៧៨	៤៥.៦៦២.៣៥៨	៥៥.៣៧០	៤៥.៦០៦.៩៨៨	៣៨.៩៦៤.០៩៤	៨៧.២៨៣	៣៨.៨៧៦.៨១១
ឥណទានបង្វិល	៤៩.៦៥០.៣៩៣	៨៣.១៧៤	៤៩.៥៦៧.២១៩	៣៣.២៩៦.២៧២	២៣.៥១២	៣៣.២៧២.៧៦០	២០២.២៧៥.៧០១	៣៣៨.៨៥១	២០១.៩៣៦.៨៥០	១៣៤.៦៨៣.៤២០	៩៥.១០៦	១៣៤.៥៨៨.៣១៤
ឥណទានខ្នាតមធ្យម	២.១១៨.៨៦៥.៦៤២	១០.១៧១.៤៨១	២.១០៨.៦៩៤.១៦១	១.៥៧២.៣៣០.៩៩២	១៤.១៨០.១៧៤	១.៥៥៨.១៥០.៨១៨	៨.៦៣២.២៥៨.៦២៦	៤១.៤៣៨.៦១៤	៨.៥៩០.៨២០.០១២	៦.៣៦០.០៧៨.៨៦១	៥៧.៣៥៨.៨០៤	៦.៣០២.៧២០.០៥៧
	៥.២៥៤.៦៤៧.៤២៥	២២.៥៨៨.៥០៥	៥.២៣២.០៥៨.៩២០	៤.៣២៣.៨៥៨.៥៤៨	៣១.២០៩.៣៨៩	៤.២៩២.៦៤៩.១៥៩	២១.៤០៧.៤៣៣.៦១១	៩២.០២៥.៥៧១	២១.៣១៥.៤០៨.០៤០	១៧.៤៩០.០០៧.៨២៦	១២៦.២៤១.៩៧៨	១៧.៣៦៣.៧៦៥.៨៤៨

១០. ឥណទាន និងបុរេប្រទាន - សុទ្ធ

(ក) ឥណទាន និងបុរេប្រទានជាចំនួនដុលតាមឥណប្រតិទាន

	សម្ព័ន្ធធនាគារ				ធនាគារ			
	២០២១ ដុល្លារអាមេរិក	២០២០ ដុល្លារអាមេរិក	២០២១ ពាន់រៀល (កំណត់សម្គាល់ ៥)	២០២០ ពាន់រៀល (កំណត់សម្គាល់ ៥)	២០២១ ដុល្លារអាមេរិក	២០២០ ដុល្លារអាមេរិក	២០២១ ពាន់រៀល (កំណត់សម្គាល់ ៥)	២០២០ ពាន់រៀល (កំណត់សម្គាល់ ៥)
មិនលើសពីមួយឆ្នាំ	១.៣៥០.០៦០.០៤៦	១.១៩៩.៥៨៣.០០២	៥.៥០០.១៩៤.៦២៧	៤.៨៥២.៣១៣.២៤៣	១.២៨២.៨៨៦.៩២៤	១.១១៤.៨១០.៨០១	៥.២២៦.៤៨១.៣២៨	៤.៥០៩.៤០៩.៦៩០
លើសមួយឆ្នាំ ប៉ុន្តែមិនលើសពីបីឆ្នាំ	១.៨៩៨.៣០៣.៩៤២	១.៦៦៩.៩៩២.១០៩	៧.៧៣៣.៦៩០.២៦០	៦.៧៥៥.១១៨.០៨១	១.៨៣៦.៥៨៤.១៧០	១.៦០៧.៤៨៧.០៣៥	៧.៤៨២.២៤៣.៩០៩	៦.៥០២.២៨៥.០៥៧
លើសបីឆ្នាំ ប៉ុន្តែមិនលើសពីប្រាំឆ្នាំ	១.៣២៦.២០៣.០៣៦	១.០៧៤.៥៩៧.៧៥៣	៥.៤០២.៩៥១.១៦៩	៤.៣៤៦.៧៤៧.៩១១	១.២៩៤.០០០.២៥៤	១.០៤៩.០៧៥.៧០៤	៥.២៧១.៧៥៧.០៣៥	៤.២៤៣.៥១១.២២៣
លើសពីប្រាំឆ្នាំ	៨៥៤.០០៧.៥៥៣	៥៦២.៤៧០.៣០១	៣.៤៧៩.២២៦.៧៧១	២.២៧៥.១៩២.៣៦៧	៨៤១.១៧៦.០៧៧	៥៥២.៤៨៥.០០៨	៣.៤២៦.៩៥១.៣៣៩	២.២៣៤.៨០១.៨៥៦
	៥.៤២៨.៥៧៤.៥៧៧	៤.៥០៦.៦៤៣.១៦៥	២២.១១៦.០១២.៨២៧	១៨.២២៩.៣៧១.៦០២	៥.២៥៤.៦៤៧.៤២៥	៤.៣២៣.៨៥៨.៥៤៨	២១.៤០៧.៤៣៣.៦១១	១៧.៤៩០.០០៧.៨២៦

១០. ឥណទាន និងបុរេប្រទាន - សុទ្ធ (ត)

សម្រាប់ការិយបរិច្ឆេទ ធនាគារ និងសម្ព័ន្ធ ធនាគារបានទទួលស្គាល់ សំវិធានធនសម្រាប់ ការខាតបង់ ឱនភាពនៃតម្លៃ ដូចខាងក្រោម៖

	សម្ព័ន្ធធនាគារ				**ធនាគារ**			
	២០២១	**២០២០**	**២០២១**	**២០២០**	**២០២១**	**២០២០**	**២០២១**	**២០២០**
	ដុល្លារអាមេរិក	**ដុល្លារអាមេរិក**	**ពាន់រៀល** (កំណត់សម្គាល់ ៥)	**ពាន់រៀល** (កំណត់សម្គាល់ ៥)	**ដុល្លារអាមេរិក**	**ដុល្លារអាមេរិក**	**ពាន់រៀល** (កំណត់សម្គាល់ ៥)	**ពាន់រៀល** (កំណត់សម្គាល់ ៥)
សំវិធានធនសម្រាប់ ការខាតបង់ ឱនភាពនៃតម្លៃ លើ៖								
ឥណទាន និងបុរេប្រទាន	១៣.៧៩៧.៩៩៧	២០.៨៥២.៣៥៧	៥៦.១៣០.០៩៨	៨៥.០១៥.០៥៩	៥២៩.៥៣៨	១៦.២០៤.៤៦២	១.៧៤៧.៣៦០	៦៦.០៦៥.៥៩២
ប្រាក់បញ្ញើ នៅធនាគារផ្សេងៗ	(៨១.៣៨៥)	(៧.៧៨៦)	(៣៣១.០៧៤)	(៣១.៧៤៤)	៧៨.៨២០	៩៦.០៨៣	៣២០.៦៤០	៣៩១.៧៣០
គណនីត្រូវទទួលផ្សេងៗ	(១៧៤.៥៨៨)	(៥០.៥៤០)	(៧១០.២២៤)	(២០៦.០៥១)	(១៩១.៦០៤)	(៥២.៨៦៩)	(៧៧៩.៤៤៥)	(២១៥.៥៤៧)
	១៣.៥៤១.៩៧៤	២០.៧៩៤.០៣១	៥៥.០៨៨.៧៥០	៨៤.៧៧៧.២៦៤	៣១៦.៧៥៤	១៦.២៤៧.៦៧៦	១.២៨៨.៥៥៥	៦៦.២៤១.៧៧៥
កិច្ចសន្យាក្រៅតារាងតុល្យការ	(១៣៩.៤៤៩)	(៥៤.១៥៦)	(៥៦៧.២៧៩)	(២២០.៧៩៤)	(៣៨០.៥៦៩)	(១៣២.០៨២)	(១.៥៤៨.១៥៥)	(៥៣៨.៤៩៨)
	១៣.៤០២.៥២៥	២០.៧៣៩.៨៧៥	៥៤.៥២១.៤៧១	៨៤.៥៥៦.៤៧០	(៦៣.៨១៥)	១៦.១១៥.៥៩៤	(២៥៩.៦០០)	៦៥.៧០៣.២៧៧

១០. ឥណទាន និងបុរេប្រទាន - សុទ្ធ (ត)

បម្រែបម្រួលការខាតបង់ឱនភាពនៃតម្លៃសម្រាប់ការិយបរិច្ឆេទ មានដូចខាងក្រោម៖

	សម្ព័ន្ធធនាគារ				ធនាគារ			
	២០២១ ដុល្លារអាមេរិក	២០២០ ដុល្លារអាមេរិក	២០២១ ពាន់រៀល (កំណត់សម្គាល់ ៥)	២០២០ ពាន់រៀល (កំណត់សម្គាល់ ៥)	២០២១ ដុល្លារអាមេរិក	២០២០ ដុល្លារអាមេរិក	២០២១ ពាន់រៀល (កំណត់សម្គាល់ ៥)	២០២០ ពាន់រៀល (កំណត់សម្គាល់ ៥)
នាដើមការិយបរិច្ឆេទ	៣៥.៣៤២.៥៤៧	៣៣.៤៤៣.០៥៥	១៤២.៩៦០.៦០២	១៣៦.២៨០.៤៤៩	៣១.២០៩.៣៨៩	៣២.៨៤៥.៤០២	១២៦.២៤១.៩៧៨	១៣៣.៨៤៥.០១២
សំវិធានធនកិច្ចសន្យាក្រៅតារាងតុល្យការ	-	(២០៧.៤៧៩)	-	(៨៣៩.២៥៣)	-	(៦៥៥.៨២២)	-	(២.៦៥២.៨០០)
សំវិធានធន/(កត់ត្រាត្រលប់)សម្រាប់ការខាតបង់ឱនភាពនៃតម្លៃសម្រាប់ការិយបរិច្ឆេទ	១៣.៧៩៧.៩៤៧	២០.៨៥២.៣៥៧	៥៦.១៣០.០៤៨	៨៥.០១៥.០៥៩	៤២៩.៥៣៨	១៦.២០៤.៤៦២	១.៧៤៧.៣៦០	៦៦.០៦៥.៥៩២
លុបចេញពីបញ្ជីសម្រាប់ការិយបរិច្ឆេទ	(១១.៣៩៣.៧១៦)	(១៨.៦៧៦.៤៥៩)	(៤៦.៣៤៩.៦៣៧)	(៧៦.១៤៣.៩២៣)	(៨.២៨១.៧៤៦)	(១៧.១៥៨.០៥៤)	(៣៣.៦៩០.១៤៣)	(៦៩.៩៥៣.៣៨៦)
លម្អៀងពីការប្តូររូបិយប័ណ្ណ	(៣.១២៥.៧០៤)	(៦៨.៩២៧)	(១២.៧១៥.៣៦៤)	(២៨១.០១៥)	(៧៦៨.៦៧៦)	(២៦.៥៩៩)	(៣.១២៦.៩៧៤)	(១០៨.៤៤៤)
លម្អៀងពីអត្រាប្តូរប្រាក់	-	-	១.០២០.៦០៧	(១.០៧០.៧១៥)	-	-	៨៥៣.៣៥០	(៩៥៣.៩៩៦)
នាចុងការិយបរិច្ឆេទ	៣៤.៦២១.០៧៤	៣៥.៣៤២.៥៤៧	១៤១.០៤៦.២៥៦	១៤២.៩៦០.៦០២	២២.៥៨៨.៥០៥	៣១.២០៩.៣៨៩	៩២.០២៥.៥៧១	១២៦.២៤១.៩៧៨

១១. ទ្រព្យសកម្មផ្សេងៗ

	សម្ព័ន្ធធនាគារ				ធនាគារ			
	២០២១ ដុល្លារអាមេរិក	២០២០ ដុល្លារអាមេរិក	២០២១ ពាន់រៀល (កំណត់សម្គាល់ ៥)	២០២០ ពាន់រៀល (កំណត់សម្គាល់ ៥)	២០២១ ដុល្លារអាមេរិក	២០២០ ដុល្លារអាមេរិក	២០២១ ពាន់រៀល (កំណត់សម្គាល់ ៥)	២០២០ ពាន់រៀល (កំណត់សម្គាល់ ៥)
ការទូទាត់ជាមុន និងបុរេប្រទាន	១៧.៨៥៤.៤៨៤	១២.៨៦៦.៤៥៩	៧២.៧៣៩.១៦៨	៥២.០៤៤.៨២៧	១៦.១៣៨.៣៥១	១០.៧៨២.៤៦០	៦៥.៧៤៧.៦៤២	៤៣.៦១៥.០៥១
ការផ្គត់ផ្គង់សម្ភារការិយាល័យ	២.៨២០.៣៨១	២.៤២៣.៧៨០	១១.៤៩០.២៣២	៩.៨០៤.១៩០	២.៦៧៣.៨២៨	២.២៤៨.៣៩២	១០.៨៩៣.១៧៥	៩.០៩៤.៧៤៦
ប្រាក់ទទួលបានពី Western Union	២.១៧២.៣២៧	៣.៧៥៥.០៦៤	៨.៨៥០.០៦០	១៥.១៨៩.២៣៤	២.០៧៩.២៨៦	៣.៦៦៦.០២១	៨.៤៧១.០១១	១៤.៨២៩.០៥៥
ពន្ធប្រាក់ចំណេញត្រូវទទួល	២.៧៧៨.៣៦៩	១.៩៦០.៩១៨	១១.៣១៩.០៧៥	៧.៩៣១.៩១៣	២.៧០៧.៥៩៧	១.៩០១.៩៦៤	១១.០៣០.៧៥០	៧.៦៩៣.៤៤៤
ផ្សេងៗ	២.៥១៥.៦២៩	១.៧៦០.៦៩២	១០.២៤៨.៦៧៣	៧.១២១.៩៩៩	២.៤៥០.៤៥១	១.៦៥៧.២៧៣	៩.៩៨៣.១៣៩	៦.៧០៣.៦៦៩
	២៨.១៤១.១៩០	២២.៧៦៦.៩១៣	១១៤.៦៤៧.២០៨	៩២.០៩២.១៦៣	២៦.០៤៩.៥១៣	២០.២៥៦.១១០	១០៦.១២៥.៧១៧	៨១.៩៣៥.៩៦៥

	សម្ព័ន្ធធនាគារ				ធនាគារ			
	២០២១ ដុល្លារអាមេរិក	២០២០ ដុល្លារអាមេរិក	២០២១ ពាន់រៀល (កំណត់សម្គាល់ ៥)	២០២០ ពាន់រៀល (កំណត់សម្គាល់ ៥)	២០២១ ដុល្លារអាមេរិក	២០២០ ដុល្លារអាមេរិក	២០២១ ពាន់រៀល (កំណត់សម្គាល់ ៥)	២០២០ ពាន់រៀល (កំណត់សម្គាល់ ៥)
ទ្រព្យសកម្មរយៈពេលខ្លី	១៧.៩៩៥.៤០២	១៧.១៧០.៥៨៤	៧៣.៣១៣.២៦៨	៦៩.៤៥៥.០១២	១៦.២៦៩.៤៤១	១៥.៣៥៣.៨០៧	៦៦.២៨១.៧០៥	៦២.១០៦.១៤៩
ទ្រព្យសកម្មរយៈពេលវែង	១០.១៤៥.៧៨៨	៥.៥៩៦.៣២៩	៤១.៣៣៣.៩៤០	២២.៦៣៧.១៥១	៩.៧៨០.០៧២	៤.៩០២.៣០៣	៣៩.៨៤៤.០១២	១៩.៨២៩.៨១៦
	២៨.១៤១.១៩០	២២.៧៦៦.៩១៣	១១៤.៦៤៧.២០៨	៩២.០៩២.១៦៣	២៦.០៤៩.៥១៣	២០.២៥៦.១១០	១០៦.១២៥.៧១៧	៨១.៩៣៥.៩៦៥

១២. ប្រាក់បញ្ញើតាមច្បាប់

	សម្ព័ន្ធធនាគារ				ធនាគារ			
	២០២១ ដុល្លារអាមេរិក	២០២០ ដុល្លារអាមេរិក	២០២១ ពាន់រៀល (កំណត់សម្គាល់ ៥)	២០២០ ពាន់រៀល (កំណត់សម្គាល់ ៥)	២០២១ ដុល្លារអាមេរិក	២០២០ ដុល្លារអាមេរិក	២០២១ ពាន់រៀល (កំណត់សម្គាល់ ៥)	២០២០ ពាន់រៀល (កំណត់សម្គាល់ ៥)
ជាមួយធនាគារកណ្តាល(ក)	៤១២.៩៨៦.៤៥៤	៣៥៦.៧៥៣.៧៥៦	១.៦៨២.៥០៦.៨១៤	១.៤៤៣.០៦៨.៩៤៣	៤១២.៩៨៦.៤៥៤	៣៥៦.៧៥៣.៧៥៦	១.៦៨២.៥០៦.៨១៤	១.៤៤៣.០៦៨.៩៤៣
ជាមួយធនាគារកណ្តាលផ្សេងៗ(ខ)	២.២២៥.០៤៧	៣.៣៧៦.០៣៣	៩.០៦៤.៨៤១	១៣.៦៥៦.០៥៤	-	-	-	-
ផ្សេងៗ(គ)	២៤៥.៤៥៩	២៤៧.២១៩	១.០០០.០០០	១.០០០.០០០	-	-	-	-
	៤១៥.៤៥៦.៩៦០	៣៦០.៣៧៧.០០៨	១.៦៩២.៥៧១.៦៥៥	១.៤៥៧.៧២៤.៩៩៧	៤១២.៩៨៦.៤៥៤	៣៥៦.៧៥៣.៧៥៦	១.៦៨២.៥០៦.៨១៤	១.៤៤៣.០៦៨.៩៤៣

(ក) ជាមួយធនាគារកណ្តាល

(i) ទុនបម្រុងកាតព្វកិច្ច

ទុនបម្រុងកាតព្វកិច្ច គឺជាទុនបម្រុងអប្បបរមាដែលត្រូវបានគណនាតាមអត្រា ៨% ចំពោះប្រាក់រៀល និង ១២,៥០% ចំពោះរូបិយប័ណ្ណផ្សេងៗ នៃប្រាក់បញ្ញើរបស់អតិថិជន ប្រាក់បញ្ញើរបស់ធនាគារ អនិវាសនជន និង ប្រាក់បញ្ញើគ្រឹះស្ថានហិរញ្ញវត្ថុ និង ប្រាក់កម្ចីអនិវាសនជន ។ យោងតាមប្រកាសរបស់ធនាគារជាតិ នៃ កម្ពុជា លេខ ធ៧-០១៨-២៨២ប្រ.ក. ស្តីពីរការរក្សាទុនបម្រុងកាតព្វកិច្ចចំពោះប្រាក់បញ្ញើ និងប្រាក់កម្ចីរបស់ធនាគារពាណិជ្ជ ទុនបម្រុងកាតព្វកិច្ចសម្រាប់រូបិយប័ណ្ណប្រាក់រៀលនិងរូបិប័ណ្ណផ្សេងទៀតមិនមានការប្រាក់ទេចាប់តាំងពីថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៨ ។

ដើម្បីចូលរួមកាត់បន្ថយផលប៉ះពាល់ពីការឆ្លងរាលដាលជម្ងឺកូវីដ១៩មកលើសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា ធនាគារជាតិនៃកម្ពុជាបានចេញសេចក្តីថ្លែងការណ៍ ដោយប្រកាសកាត់បន្ថយអត្រាទុនបម្រុងកាតព្វកិច្ច (“RRR”) ចំពោះប្រាក់រៀលពី៨% មកត្រឹម ៧% និងរូបិយប័ណ្ណបរទេសពី១២,៥០% មកត្រឹម ៧%។

ទុនបម្រុងកាតព្វកិច្ចមានចំនួន ៣៦៩.៦៧០.១៥២ ដុល្លារអាមេរិក និង ៣១៣.៤៣៧.៤៥៤ ដុល្លារអាមេរិក នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ និងថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០។

១២. ប្រាក់បញ្ញើតាមច្បាប់ (ត)

(ក) ជាមួយធនាគារកណ្តាល (ត)

(ii) ការធានាដើមទុន

យោងតាមប្រកាសរបស់ធនាគារជាតិ នៃ កម្ពុជា លេខ ធ៧-០១-១៣៦ប្រ.ក. ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ២០០១ ស្តីពីប្រាក់តម្កល់ធានាលើដើមទុន តម្រូវឱ្យធនាគារតម្កល់ប្រាក់ចំនួន ១០% នៃដើមទុនចុះបញ្ជីនៅធនាគារកណ្តាល។ ប្រាក់តម្កល់នេះនឹងត្រូវបង្វិលជូនធនាគារវិញ នៅពេលធនាគារស្ម័គ្រចិត្តបញ្ចប់ប្រតិបត្តិការអាជីវកម្មរបស់ខ្លួន នៅក្នុងប្រទេសកម្ពុជា ហើយប្រាក់តម្កល់នេះមិនសម្រាប់ប្រើក្នុងប្រតិបត្តិការប្រចាំថ្ងៃរបស់ធនាគារទេ ។ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ និងថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ ប្រាក់តម្កល់ធានាលើដើមទុនមានចំនួន ៤៣.៣១៦.៣០២ ដុល្លារអាមេរិក ទាំងពីរឆ្នាំ។ ប្រាក់តម្កល់ធានាលើដើមទុន គឺទទួលបានការប្រាក់នូវអត្រា ១/៤ នៃ SIBOR ក្នុងមូលដ្ឋាន៦ខែ។

(ខ) ជាមួយធនាគារកណ្តាលផ្សេងៗ

ទាំងនេះគឺជាប្រាក់បញ្ញើតាមច្បាប់របស់ធនាគារ អេស៊ីលីដា ឡាវ លីមីធីត ដែលត្រូវបានរក្សាទុកជាមួយ ធនាគារជាតិឡាវ ដោយអនុលោមតាមបទប្បញ្ញត្តិរបស់ធនាគារជាតិឡាវ។ ប្រាក់បញ្ញើតាមច្បាប់ទាំងនេះរួមមាន ទុនបម្រុងកាតព្វកិច្ច ដែលត្រូវបានគណនាចំនួន ៥% នៃប្រាក់បញ្ញើរបស់អតិថិជនជារូបិយប័ណ្ណក្នុងស្រុក និង ៨% នៃប្រាក់បញ្ញើជារូបិយប័ណ្ណបរទេស និងការធានាដើមទុននៃភាគហ៊ុននោះ ។ ប្រាក់បញ្ញើតាមច្បាប់មិនមានការប្រាក់ទេ ។

(គ) ផ្សេងៗ

អនុលោមតាមប្រកាសរបស់គណៈកម្មការមូលបត្រកម្ពុជា (ហៅកាត់ថា "គ.ម.ក") លេខ ០០៩ ស្តីពីការផ្តល់អាជ្ញាប័ណ្ណដល់ក្រុមហ៊ុនមូលបត្រ និង ក្រុមហ៊ុនតំណាងមូលបត្រ ក្រុមហ៊ុន អេស៊ីលីដា ស៊ីយ្យូរីធី ភីអិលស៊ី ត្រូវបានតម្រូវឱ្យដាក់ប្រាក់តម្កល់ទៅក្នុងគណនីរបស់គណៈកម្មការមូលបត្រកម្ពុជា ដែលរក្សាទុកនៅធនាគារជាតិ នៃ កម្ពុជាចំនួន ១.០០០.០០០.០០០ រៀល (សមមូលនឹង ២៤៥.៤៥៩ ដុល្លារអាមេរិក) ដើម្បីធ្វើប្រតិបត្តិការជាឈ្មួញមូលបត្រនៅក្នុង ព្រះរាជាណាចក្រកម្ពុជា ។ ប្រាក់បញ្ញើតាមច្បាប់មិនមានការប្រាក់ទេ ។

ធនាគារ អេស៊ីលីដា ភីអិលស៊ី និង ក្រុមហ៊ុនបុត្រសម្ព័ន្ធ

កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ និងសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់

១៣. ការវិនិយោគលើក្រុមហ៊ុនបុត្រសម្ព័ន្ធ

		ធនាគារ			
		២០២១ ដុល្លារអាមេរិក	២០២០ ដុល្លារអាមេរិក	២០២១ ពាន់រៀល (កំណត់សម្គាល់ ៥)	២០២០ ពាន់រៀល (កំណត់សម្គាល់ ៥)
ភាគហ៊ុនធម្មតាដែលមិនត្រូវបានចុះបញ្ជីលើផ្សារភាគហ៊ុនតាមថ្លៃដើម					
ធនាគារអេស៊ីលីដា ឡាវ លីមីធីត	(ក)	៤៩.៣៨៩.៥៦៦	៤៩.៣៨៩.៥៦៦	២០១.២១៣.០៩២	១៩៩.៧៨០.៧៩៤
ក្រុមហ៊ុនអេស៊ីលីដា ស៊ីយ្យូរីធី ភីអិលស៊ី	(ខ)	២.០១០.០០០	២.០១០.០០០	៨.១៨៨.៧៤០	៨.១៣០.៤៥០
វិទ្យាស្ថានពាណិជ្ជសាស្ត្រ អេស៊ីលីដា	(គ)	១៩.៨០៥.០០០	១៩.៨០៥.០០០	៨០.៦៨៥.៥៧០	៨០.១១១.២២៥
ស្ថាប័នមីក្រូហិរញ្ញវត្ថុ អេស៊ីលីដា មីយ៉ាន់ម៉ា	(ឃ)	១៩.៩១៣.១៥០	១៩.៩១១.០០៥	៨១.១២៦.១៧៣	៨០.៥៤០.០១៦
ការវិនិយោគក្នុងក្រុមហ៊ុនបុត្រសម្ព័ន្ធសរុប		៩១.១១៧.៧១៦	៩១.១១៥.៥៧១	៣៧១.២១៣.៥៧៥	៣៦៨.៥៦២.៤៨៥

លម្អិតពីក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ធនាគារមានដូចខាងក្រោម៖

		ជាម្ចាស់ភាគហ៊ុន និងមានសិទ្ធបោះឆ្នោត	
		២០២១	២០២០
ឈ្មោះក្រុមហ៊ុនបុត្រសម្ព័ន្ធ			
ធនាគារអេស៊ីលីដា ឡាវ លីមីធីត	(ក)	៩៩,៩០%	៩៩,៩០%
ក្រុមហ៊ុនអេស៊ីលីដា ស៊ីយ្យូរីធី ភីអិលស៊ី	(ខ)	១០០%	១០០%
វិទ្យាស្ថានពាណិជ្ជសាស្ត្រ អេស៊ីលីដា	(គ)	៧៦,៦០៩%	១០០%
ស្ថាប័នមីក្រូហិរញ្ញវត្ថុ អេស៊ីលីដា មីយ៉ាន់ម៉ា	(ឃ)	១០០%	៩៩,៩៩%

(ក) ធនាគារ អេស៊ីលីដា ឡាវ លីមីធីត

ធនាគារ អេស៊ីលីដា ឡាវ លីមីធីត (ហៅកាត់ថា "អេស៊ីលីដា ឡាវ") ត្រូវបានបង្កើតឡើងនៅសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ នៅថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០០៧ ដោយបានទទួលអាជ្ញាប័ណ្ណជាលើកដំបូងពីធនាគារជាតិឡាវ។ សកម្មភាពអាជីវកម្មចម្បង គឺការផ្តល់សេវាធនាគារ និងសេវាហិរញ្ញវត្ថុផ្សេងៗទៀតនៅ សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ។

ធនាគារ អេស៊ីលីដា ភីអិលស៊ី កាន់កាប់ភាគហ៊ុនរបស់អេស៊ីលីដា ឡាវ ចំនួន ៩៩,៩០% ។ ធនាគារធ្វើការវិនិយោគដំបូងនៅឆ្នាំ២០០៨ ជាមួយ អេស៊ីលីដា ឡាវ នូវទឹកប្រាក់ចំនួន ៥.៤៧៧.៣៩៩ ដុល្លារអាមេរិក។ នៅឆ្នាំ២០០៩ ធនាគារធ្វើការលក់ភាគហ៊ុនទៅក្រុមហ៊ុន International Finance Corporation ("IFC") នូវទឹកប្រាក់ចំនួន ៨៧៦.៣៨៤ ដុល្លារអាមេរិក ដែលធ្វើឱ្យថយចុះការវិនិយោគនៅត្រឹមចំនួន ៤.៦០១.០១៥ ដុល្លារអាមេរិក។ នៅឆ្នាំ២០១០ ធនាគារធ្វើការបន្ថែមដើមទុនទៅ អេស៊ីលីដា ឡាវ ចំនួន ៥.៩៦៦.៩៦៩ដុល្លារអាមេរិក ដោយធ្វើឱ្យកើនឡើងការវិនិយោគដល់១០.៥៦៧.៩៨៤ ដុល្លារអាមេរិក។

ធនាគារ អេស៊ីលីដា ភីអិលស៊ី និង ក្រុមហ៊ុនបុត្រសម្ព័ន្ធ

កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ (ត)
នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ និងសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់

១៣. ការវិនិយោគលើក្រុមហ៊ុនបុត្រសម្ព័ន្ធ (ត)

(ក) ធនាគារ អេស៊ីលីដា ឡាវ លីមីធីត (ត)

នៅឆ្នាំ២០១៤ ធនាគារធ្វើការទិញភាគហ៊ុនពី FMO. StichtingTriodosDoen "TRI-Doen". Tridos Fair Share Fund "TRI-Fair" និង IFC ចំនួន ២៨.៨៧៥.០៩៨ ដុល្លារអាមេរិក និងធ្វើការបន្ថែមដើមទុនទៅ អេស៊ីលីដា ឡាវ ចំនួន ៩.៩៤៦.៤៨៤ ដុល្លារអាមេរិក ដោយធ្វើឱ្យកើនឡើងការវិនិយោគដល់ ៤៩.៣៨៩.៥៦៦ ដុល្លារអាមេរិក។ នៅថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០២១ ការ វិនិយោគនៅក្នុង អេស៊ីលីដា ឡាវ គឺនៅដដែល។

(ខ) ក្រុមហ៊ុន អេស៊ីលីដា ស៊ីយ្យូរីធី ភីអិលស៊ី

